ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប

# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ប្រចាំឆ្នាំ២០១៩-២០២០ និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១



**សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ថ្ងៃ១៩-២០ និង២៣ ខែមីនា ឆ្នាំ២០២០**

# មាតិកា

I- សេចក្តីផ្តើម ........ 1
II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ........ 3
III- លទ្ធផលជារួម ........ 16
IV- លទ្ធផលតាមអនុវិស័យ ........ 18
១.បង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្ម ........ 18
២.ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 41
៣.លទ្ធផលនៃការគ្រប់គ្រងធនធានជលផលនិងការអភិវឌ្ឍន៍វារីវប្បកម្ម ........ 57
៤.លទ្ធផលនៃការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ ........ 59
៥.លទ្ធផលនៃការពង្រឹងសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស ........ 64
V- បញ្ហាប្រឈម ........ 92
VI- ទិសដៅអនុវត្ត ........ 93
១. ផែនការផលិតកម្មដំណាំស្រូវដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........ 93
២. ផែនការផលិតកម្មដំណាំកៅស៊ូ ........ 95
៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 96
៤. ផែនការផ្នែកជលផល ........ 97
៥. ផែនការផ្នែកព្រៃឈើ ........ 98
VII- សេចក្តីសន្និដ្ឋាន ........ 99
ឧបសម្ព័ន្ធ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៩-២០២០
# និងទិសដៅអនុវត្តឆ្នាំ២០២០-២០២១

## I- សេចក្តីផ្តើម

វិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាគន្លឹះ របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** វិស័យនេះបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ ការគ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ រួមទាំងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម ដោយបានអនុវត្តវិធានការគោលនយោបាយនានា សំដៅបង្កើនផលិតភាពលើមុខដំណាំដែលមានតម្លៃទីផ្សារខ្ពស់ ធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងកសិ-ពាណិជ្ជកម្ម។ ជាមួយគ្នានេះ ក្រសួងបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនទៀតរួមមាន៖ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនគុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័នដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិ-ពាណិជ្ជកម្ម និងការបង្កើនចំណូលជាតិ។

គួរកត់សម្គាល់ថា ផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនានា អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម និងការនាំចេញ។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវ បណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេសការពង្រីកកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដី ដើម្បីបង្កើនជីជាតិ និងទិន្នផល ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍន៍ពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗស្របតាមតម្រូវការទីផ្សារ។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តនូវយន្តការអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធឡសម្ងួត និងឃ្លាំងស្តុកស្រូវ ក៏ដូចជាទុនបង្វិល ដើម្បីការពារផលប្រយោជន៍កសិករ តាមរយៈការការពារ

ស្ថិរភាពនៃថ្លៃស្រូវ គឺទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះខ្លាំងពេកហួសពីថ្លៃទីផ្សារដោយមិនសមហេតុផល។ ទន្ទឹមនឹងការប្រឈមស្ថានភាពនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញនូវសេចក្តីណែនាំស្តីពីវិធានការលើកកម្ពស់ផលិតកម្ម និងធុរកិច្ចស្រូវអង្ករ ដោយផ្តោតលើការផលិតនិងនាំចេញអង្ករក្រអូប ការកាត់បន្ថយថ្លៃដើមផលិតកម្ម ការជំរុញឱ្យអ្នកប្រមូលទិញស្រូវត្រូវបន្តធ្វើការទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីទទួលបានឥណទានប្រមូលទិញស្រូវពីកសិករ សហគមន៍កសិកម្ម និងជំរុញឱ្យសហព័ន្ធស្រូវអង្ករកម្ពុជាយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពកែច្នៃអង្ករឱ្យមានគុណភាពបន្ថែមទៀតសម្រាប់បម្រើឱ្យទីផ្សារអន្តរជាតិ។

បច្ចុប្បន្ននេះ ក្រសួងបានកត់សម្គាល់ឃើញថា ប្រជាកសិករយើងកំពុងផ្លាស់ប្តូរទម្លាប់ពីការផលិតសម្រាប់បម្រើសេចក្តីត្រូវការផ្ទាល់ខ្លួន មកជាការផលិតដើម្បីលក់ ព្រោះមានតម្រូវការទីផ្សារនិងផលចំណេញខ្ពស់។ ផ្អែកលើការផ្លាស់ប្តូរនេះ ក្រសួងអាចវាយតម្លៃបានថា សហគមន៍កសិកម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលនាំឱ្យមានលទ្ធផលជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា។ កត្តានេះបង្ហាញឱ្យឃើញថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី **“កសិករទៅជាកសិ-ពាណិជ្ជករ”** ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។

ជាមួយគ្នានេះ ស្ថាប័នជាច្រើន ទាំងរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលបាន និងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹងនិងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាម និងច្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។ វិស័យឯកជនបានតម្រង់ទិសការផលិតឆ្ពោះទៅរកទីផ្សារនាំចេញ តាមរយៈការបង្កើនសមត្ថភាពកែច្នៃ ធានាបានទាំងគុណភាពនិងបរិមាណ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ ពិសេសការនាំចេញចេកអំបូងលឿង ស្វាយកែវរមៀត ម្រេច ដំឡូងមី និងផលិតផលកសិកម្មសំខាន់ៗដ៏ទៃទៀត មានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់។

ការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ ការចូលរួមពីផ្នែកឯកជនក្នុងការធ្វើវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងកៅស៊ូគ្រួសារ បានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើង ទោះជាស្ថានភាពទីផ្សារនិងតម្លៃកៅស៊ូ ព្រមទាំងកម្លាំងពលកម្មមានការប្រឈមក៏ដោយ។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឲ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើសនិងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ការអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រូវបាននិងកំពុងអនុវត្តយ៉ាងមានប្រសិទ្ធភាព។ ការអភិវឌ្ឍផ្នែកផលិតកម្មសត្វ ពិសេសផលិតកម្មគោពូជកូនកាត់ដែលផ្តល់តម្លៃខ្ពស់ និងលើកកម្ពស់សុខភាពសត្វនៅកម្ពុជាបាន និងកំពុងជំរុញយ៉ាងផុលផុស។ ជាងនេះទៅទៀត ការទប់ស្កាត់ចលនាសត្វខុសច្បាប់ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយការទប់ស្កាត់ជំងឺឆ្លងសត្វ ក៏ត្រូវបានពង្រឹងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការកែទម្រង់ស៊ីជម្រៅអនុវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព តាមរយៈការអនុវត្តទិសស្លោក **“សហគមន៍នេសាទ គ្មានបទល្មើស”** ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង និងថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស។ ការ

ធ្វើវារីវប្បកម្ម ពិសេសការចិញ្ចឹមបង្កង ត្រីរ៉ស់ ត្រីឆ្តោ និងពពួកត្រីដែលមានតម្លៃទីផ្សារខ្ពស់ ទាំងជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មត្រូវបានអនុវត្តយ៉ាងសកម្ម ហើយបានរួមចំណែកដល់ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។ ជាលទ្ធផល ជាក់ស្តែងផលិតកម្មវារីវប្បកម្ម បានកើនឡើងរហូតដល់ជាង២២% បើប្រៀបធៀបនឹងឆ្នាំមុន។

ចំពោះការកែទម្រង់វិស័យព្រៃឈើ ក្រសួងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបង្កើនសមត្ថភាព បច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសពង្រឹងការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ជាការកត់សម្គាល់ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ឃើញថាទទួលបានប្រសិទ្ធភាពជាងមុន។ បន្ថែមលើសពីនេះ ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅទូទាំងប្រទេស។

ជាមួយគ្នានេះ ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល បាននិងកំពុងធ្វើវិសោធនកម្ម ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង។ ក្នុងការអនុវត្តកន្លងមក ក្រសួងបានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីយកចិត្តទុកដាក់មិនខ្លាចនឿយហត់ និងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើ ដែលបានខិតខំតស៊ូបំពេញភារកិច្ចរបស់ខ្លួនបានល្អប្រសើរ ជាពិសេសការខិតខំប្រឹងប្រែងក្នុងឱកាសដែលរាជរដ្ឋាភិបាលកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យទាំងពីរនេះ ដែលនេះជាសក្ខីភាពបង្ហាញឱ្យឃើញនូវការចូលរួមចំណែកក្នុងបុព្វហេតុនៃការលើកកម្ពស់ផ្នែកជលផល និងព្រៃឈើនៅកម្ពុជាឲ្យមានការរីកចម្រើនជាលំដាប់ប្រកបដោយមោទនភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ជាពិសេសការបង្ក្រាបបទល្មើសតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ ទោះបីនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម

### ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣នេះ គឺជាឯកសារផែនការគោលនយោបាយ និងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវដែលបានកំណត់ច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ និងបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ សំដៅរួមចំណែកដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានអនុម័ត និងបានប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៩ នាពេលកន្លងទៅនេះ ដើម្បីអនុវត្តបន្ត និងចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្មប្រកបដោយភាពប្រកួតប្រជែង បរិយាបន្ន និងនិរន្តរភាព បង្កើនការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មគឺ៖ “*កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា*”។

ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ គោលបំណងគោលនយោបាយរួមមួយនឹងត្រូវដាក់ចេញដើម្បីអនុវត្តគឺ៖ *ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព*។

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម (Gross Value Added-GVA) សម្រេចបានក្នុងរង្វង់ពី៣ទៅ៥%ក្នុងមួយឆ្នាំ ហើយនៅ៥ឆ្នាំខាងមុខនេះ ការព្យាករណ៍នៃកំណើននេះ នឹងត្រូវសម្រេចឱ្យបានក្នុងរង្វង់៤%ក្នុងមួយឆ្នាំៗ ពោលគឺនឹងត្រូវកើនពី២១ ៩១៣ប៊ីលានរៀលនាឆ្នាំ២០១៨ ដល់២៥ ៧០០ប៊ីលានរៀលនៅឆ្នាំ២០២៣។

គោលដៅគោលនយោបាយអាទិភាពចំនួន០២ត្រូវបានកំណត់គឺ៖

*(ទី១) បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម*

*(ទី២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព*

គោលដៅគោលនយោបាយទី១គឺ តម្រង់ឆ្ពោះទៅលើការជំរុញផលិតកម្មកសិកម្មតាមលក្ខណៈទំនើប និងយន្តូបនីយកម្មជំនួសឲ្យការថយចុះនៃកម្លាំងពលកម្មកសិកម្ម មានលក្ខណៈសន្សំសំចៃ ធ្វើឲ្យថ្លៃដើមផលិតទាប ធ្វើពិពិធកម្មទៅរកមុខដំណាំដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ផ្តល់ប្រាក់ចំណេញច្រើនសម្រាប់កសិករ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍នេសាទ ដែលនឹងនាំដល់ការប្រកួតប្រជែងទីផ្សារខ្ពស់ ព្រមទាំងដំណើរការកសិ-ធុរកិច្ចមានលក្ខណៈបរិយាប័ន្ន ប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាព។

គោលដៅគោលនយោបាយទី២គឺ តម្រង់ឆ្ពោះទៅលើការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ សមត្ថភាពបច្ចេកទេសក្នុងការគ្រប់គ្រងនឹងត្រូវបានបង្កើនឡើងជាចាំបាច់ ដើម្បីធានាតុល្យភាពរវាងការអភិវឌ្ឍនិងការអភិរក្ស ស្របតាមគោលការណ៍ច្បាប់កំណត់ជាធរមាន។

ដើម្បីសម្រេចបាននូវគោលដៅគោលនយោបាយអាទិភាពខាងលើ យុទ្ធសាស្ត្រចំនួន៥នឹងត្រូវបានដាក់ចេញឱ្យអនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខនេះគឺ៖

*(១) បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច*

*(២) លើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម*

*(៣) ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព*

*(៤) ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព*

*(៥) បង្កើនប្រសិទ្ធភាពនៃការពង្រឹងការគ្រប់គ្រងស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស*

យុទ្ធសាស្ត្រទាំង៥ខាងលើនេះ នឹងត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ដោយមានកម្មវិធីទាំង៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាតួអង្គសំខាន់សម្រាប់ប្រតិបត្តិ និងគ្រប់គ្រងដោយអង្គភាពថវិការបស់ក្រសួង។

កម្មវិធីទាំង៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន៖

**កម្មវិធីទី១៖ បង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម**

គោលបំណងកម្មវិធី៖ “ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម៧%ក្នុងមួយឆ្នាំ ដោយពង្រីកទំនើបកម្មកសិកម្ម បង្កើនផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងការប្រកួតប្រជែងទីផ្សារខ្ពស់”។

ក្នុងរយៈពេល៥ឆ្នាំ (២០១៩-២០២៣) ខាងមុខនេះ សូចនាករចំនួន៣នឹងត្រូវសម្រេចឱ្យបានគឺៈ (១) ផលិតផលកសិកម្មសរុបនឹងត្រូវជំរុញឱ្យកើនពី២៩លានតោននាឆ្នាំ២០១៩ ដល់៣៦លានតោននៅឆ្នាំ២០២៣ (២) បង្កើនអនុបាត (%) នៃពិពិធកម្មដំណាំឱ្យកើនពី៦៣% នាឆ្នាំ២០១៩ ដល់៦៧% នៅឆ្នាំ២០២៣ និង(៣) ផលិតផលដំណាំកសិកម្មនាំចេញនឹងកើនពី៥,៨លានតោននាឆ្នាំ២០១៩ ដល់៧,៧លានតោននៅឆ្នាំ២០២៣។

**កម្មវិធីទី២ៈ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**

គោលបំណងនៃកម្មវិធីនេះគឺជំរុញផលិតកម្មសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រង និងការអភិវឌ្ឍការចិញ្ចឹមសត្វ កាត់បន្ថយហានីភ័យជំងឺឆ្លងសត្វ និងពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវសម្រួចការអនុវត្តតាមគោលដៅជាយុទ្ធសាស្រ្តចំនួន៣ជាសំខាន់ (១) បង្កើនផលិតផលសាច់ឱ្យកើនពី ២៤០ពាន់តោន នាឆ្នាំ២០១៩ ដល់២៧០ពាន់តោន នៅឆ្នាំ២០២៣ និង (២) បង្កើនអត្រា (%) នៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនពី ២៣% នាឆ្នាំ២០១៩ ដល់៣០% នៅឆ្នាំ២០២៣ និង (៣) កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

**កម្មវិធីទី៣ៈ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម**

គោលបំណងនៃកម្មវិធីនេះគឺ បង្កើនការគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល រក្សាការចាប់ផលនេសាទពីធម្មជាតិក្នុងរង្វង់៦០០ពាន់តោនក្នុងមួយឆ្នាំ បង្កើនផលវារីវប្បកម្មយ៉ាងតិច២០%ក្នុងមួយឆ្នាំ និងធ្វើឱ្យសហគមន៍នេសាទមានកម្រិតជីវភាពកាន់តែប្រសើរឡើង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានជលផលប្រកបដោយចីរភាព ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពសម្រាប់ការប្រើប្រាស់ បង្កើនផលវារីវប្បកម្មពី២៩៨ពាន់តោននាឆ្នាំ២០១៩ ឱ្យកើនដល់ប្រមាណជាង៦១៩ពាន់តោននៅឆ្នាំ២០២៣ ដោយបង្កើនការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី បង្កង ក្រពើ ជាដើម។

**កម្មវិធីទី៤ៈ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ**

គោលបំណងនៃកម្មវិធីនេះគឺ បង្កើនការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃឱ្យមាននិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំដុះព្រៃឈើឡើងវិញ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ ព្រមទាំងពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើឱ្យមានជីវភាពកាន់តែប្រសើរឡើង។ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវសម្រួចការអនុវត្តនូវសូចនាករចំនួន២ជាសំខាន់គឺ (១) បរិមាណផលឈើដាំកើនពី២០០ពាន់ម៉ែត្រគូបនាឆ្នាំ២០១៩ ដល់២៧៥ពាន់ម៉ែត្រគូបនៅឆ្នាំ២០២៣ និង (២) អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបង្កើនឱ្យបានពី ១០% នៅឆ្នាំ២០១៩ ដល់ ១៨%នៅឆ្នាំ២០២៣។

**កម្មវិធីទី៥ៈ បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងការពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងៈ (១) ពង្រឹងស្ថាប័នតាមរយៈការជំរុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទក្រសួងឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគោលនយោបាយ សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយចីរភាព (២) បង្កើនប្រសិទ្ធភាពសេវាគាំទ្រ តាមរយៈការបង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្រ្ត ពង្រឹងប្រព័ន្ធព័ត៌មាននិងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនិងឯកជន ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការអនុវត្តថវិកាកម្មវិធី ការធ្វើអធិការកិច្ច សវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព និង(៣)ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម ដោយបង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបក

តំហើញថ្មីៗ សំដៅពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

## ២. យុទ្ធសាស្ត្រចម្បងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្ម

ទី១- បន្តលើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើបក្នុងទិសដៅបង្កើន បរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តរភាព ក្នុងបរិបទបម្រែបម្រួល អាកាសធាតុ និងតម្រូវការទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ។ យកចិត្តទុកដាក់បន្តពង្រឹងការអប់រំ បណ្តុះបណ្តាល បច្ចេកទេសកសិកម្ម និងអភិវឌ្ឍន៍ធនធានមនុស្សគ្រប់កម្រិតសញ្ញាបត្រ និងជំនាញវិជ្ជាជីវៈ និងជាពិសេស បង្កើនចំនួនអ្នកស្រាវជ្រាវនិងអ្នកវិទ្យាសាស្ត្រកសិកម្មឱ្យបានច្រើន ដោយផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជាចាំបាច់។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗប្រកបដោយនវានុវត្តន៍ និងមានលក្ខណៈបច្ចេកវិទ្យាឌីជីថល ការអនុវត្តកសិកម្មល្អ ការរៀបចំកំណត់តំបន់ដាំដុះ ការរៀបចំផែនការដាំដុះទៅតាមតម្រូវការទីផ្សារ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកតាមរយៈប្រព័ន្ធសន្សំសំចៃទឹក ការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយប្រមូលផល ការបង្កើនភាពធន់នឹងអាកាសធាតុ និងគ្រោះធម្មជាតិ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្មឱ្យបានទៅដល់កសិករ និងសហគមន៍កសិកម្ម ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម និងធាតុចូលកសិកម្ម ពង្រីកសមត្ថភាពមន្ទីរពិសោធន៍ជាតិ កសិដ្ឋានផលិតពូជ និងស្ថានីយមជ្ឈមណ្ឌលស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្មឱ្យបានល្អប្រសើរ។ ត្រូវជំរុញការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តលើដំណាំកសិកម្ម ការគ្រប់គ្រងកសិដ្ឋាន ការពារដំណាំ និងភូតគាមអនាម័យ។

ទី២- ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលបានចុះបញ្ជីរួចហើយឲ្យមានលក្ខណៈជាពាណិជ្ជកម្ម ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់សន្សំសំចៃទឹកនៅតាមសហគមន៍កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម តាមអភិក្រម “ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម/ផលិតករ” ឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការរកទីផ្សារបន្ថែមសម្រាប់ផលិតផលកសិកម្មជាអាទិភាព។ លើសពីនេះទៀត ត្រូវពិនិត្យមើលលទ្ធភាពធ្វើយ៉ាងណាឱ្យសហគមន៍អាចទទួលបានផលប្រយោជន៍ និងមានចំណូលសម្រាប់ដំណើរការអភិវឌ្ឍរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ។ ទន្ទឹមនឹងនេះ ក៏ត្រូវបន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីជំនាញ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍ ព្រមទាំងជំរុញ និងរួមគ្នាធ្វើការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឲ្យយល់ដឹងជាសាធារណៈអំពីការអភិវឌ្ឍវិស័យកសិកម្ម។

ទី៣- ពង្រឹងនិងពង្រីកសហគមន៍កៅស៊ូគ្រួសារ ដើម្បីបង្កើនកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករ ទាំងការដាំដុះ ការប្រមូលផល ការកែច្នៃ ព្រមទាំងពង្រឹងអំណាចនៃការចរចាថ្លៃនៅពេលលក់ផលិតផលទាំងនោះ។ ជំរុញការវិនិយោគលើការកែច្នៃផលិតផលកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែម បង្កើតការងារ ចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទ។ ជាមួយគ្នានេះ ត្រូវពិនិត្យនិងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។

ទី៤- ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ បសុសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ ស្តង់ដារគុណភាពតាមរយៈគោលការណ៍ការអនុវត្តកសិកម្មល្អ (GAP) ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ការអនុវត្តវារីវប្បកម្មល្អ

(GAqP) ក៏ដូចជាពង្រឹងវិធានការពារដំណាំ សុខភាពសត្វ និង គុណភាពផលិតផលសត្វ និងផល ផលិតផលជលផល អនាម័យនិងភូតគាមអនាម័យ (SPS) តាមរយៈការចរចាជាមួយបណ្តាប្រទេសដែលទិញ ផលិតផលកសិកម្មពីកម្ពុជា ការរៀបចំពិធីសារស្តីពីការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

ទី៥- ជំរុញការចិញ្ចឹមសត្វរបស់កសិករឲ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹមគោពូជកូនកាត់ដែលមានផលិតភាពខ្ពស់ ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែលមានផលិតភាពខ្ពស់ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ គ្រប់គ្រងការធ្វើអាជីវកម្មសត្វរស់ ផលិតផលសត្វ ចំណីសត្វ បសុឱសថ និងធាតុចូលផ្សេងៗ ដោយមិនឲ្យមានការធ្វើអាជីវកម្មផ្តាច់មុខដែលប៉ះពាល់ដល់តម្លៃ និងបញ្ហាទីផ្សារ។ ត្រូវជំរុញការកែច្នៃផលិតផលសាច់ ដោយត្រូវគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងកន្លែងកែច្នៃ ឲ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល និងមានការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ធានាបាននូវគុណភាព អនាម័យ និងសុវត្ថិភាពសាច់សម្រាប់ធានាតម្រូវការក្នុងស្រុក និងឆ្ពោះទៅរកការនាំចេញទៅបរទេស។ ជាមួយគ្នានេះ ត្រូវពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ដើម្បីបង្ការការពារជំងឺឆ្លងសត្វ ជំងឺស៊ូណូស ផលិតផលសត្វប្រកបដោយសុវត្ថិភាព និងគ្រប់គ្រងហានិភ័យជំងឺរាតត្បាតនានាជាយថាហេតុ។ ជាមួយនោះ ត្រូវពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វឲ្យមានប្រសិទ្ធភាពខ្ពស់ និងត្រូវរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ទី៦- បង្កើតស្ថានីយចត្តាឡីស័កសម្រាប់ដំណាំ សត្វ និងជលផល នៅតាមតំបន់សំខាន់ៗ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលសមាសធាតុចង្រៃ ជំងឺសត្វ និងជំងឺស៊ូណូស ជំងឺត្រី ព្រមទាំងទប់ស្កាត់ការនាំចូល នាំចេញ ឆ្លងកាត់នូវផលិតផលកសិកម្មខូចគុណភាព ដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងខូចទីផ្សារក្នុងស្រុក និងនាំចេញ។ ជំរុញឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលខេត្តនៅជាប់ព្រំដែន ត្រូវសហការឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព ព្រមទាំងក្តាប់ឲ្យបាននូវព័ត៌មាននិងទិន្នន័យនៃការនាំចូល និងនាំចេញផលិតផលកសិកម្មពីបណ្តាប្រទេសជិតខាង ដើម្បីធានានូវការគ្រប់គ្រងផលស្តុកក្នុងស្រុក និងផលប៉ះពាល់ទីផ្សារក្នុងតំបន់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ទី៧- ពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទឱ្យក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផល ទាំងទឹកសាបនិងសមុទ្រ។ ជាមួយគ្នានេះ ត្រូវជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងត្រូវបន្តពង្រឹងការគ្រប់គ្រង និងការពារកន្លែងអភិរក្សជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសត្រូវថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងឱ្យបានគង់វង្ស ដែលជាជម្រកដ៏សំខាន់របស់មច្ឆជាតិ។ លើសពីនេះទៀត បន្តចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល និងត្រូវខិតខំរៀបចំលិខិតបទដ្ឋានគតិយុត្ត ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការនេសាទល្មើសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ (IUU Fishing) ដោយត្រូវបង្កើតយន្តការថ្នាក់ជាតិឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាមួយអន្តរស្ថាប័នស្របតាមនីតិវិធីជាធរមាន។

ទី៨- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រៃផ្តល់ផល ដើម្បីឆ្លើយតបទៅនឹងបរិបទកំណែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍអនុវិស័យព្រៃឈើជាតិយូរអង្វែង។ បន្ថែមលើនេះ ត្រូវបន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម។ ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរឹល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីដីសម្បទានសេដ្ឋកិច្ច ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយសម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំដុះ។ ជាមួយគ្នានេះ ត្រូវរៀបចំបង្កើតសួនភូតគាមសាស្ត្រ (Botanical Garden)

នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិកម្ពុជា ក្នុងគោលបំណងអប់រំ បណ្ដុះបណ្ដាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទគ្រួសារ និងអំបូរដទៃទៀត ដោយប្រើប្រាស់ប្រភពថវិកាមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងពីប្រភពផ្សេងៗទៀត។ សហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ដើម្បីចូលរួមឱ្យបានល្អក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងការកាប់រានដីព្រៃឈើឱ្យមានប្រសិទ្ធភាព។ តំបន់សម្បទានដីសេដ្ឋកិច្ចដែលនៅសេសសល់ពីមុនមកនឹងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹង ដើម្បីធានាថា ដំណើរការសម្បទានដីសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។ ព្រមជាមួយនោះ ត្រូវចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់។

ទី៩- បន្តចុះស្រាវជ្រាវរុករក និងបង្ក្រាបបទល្មើសព្រៃឈើ ជលផល ការកាប់រាន ដុត ឈូសឆាយដីព្រៃឈើ និងព្រៃលិចទឹកយកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយប្រើប្រាស់កម្លាំងចម្រុះ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងតុលាការ ព្រមទាំងបន្តយកចិត្តទុកដាក់ជំរុញការបោះបង្គោលព្រំព្រៃឈើ និងព្រៃលិចទឹកឱ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវការរំលោភបំពានលើដីព្រៃឈើ និងព្រៃលិចទឹកជាដើម។

ទី១០- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្ដាប្រទេសដៃគូអភិវឌ្ឍន៍នានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ព្រមទាំងខិតខំបង្កើនកិច្ចសហប្រតិបត្តិការ និងធ្វើការចរចាដើម្បីស្វែងរកទីផ្សារសម្រាប់ការនាំចេញផលិតផលកសិកម្មឱ្យបានទូលំទូលាយជាមួយប្រទេសនានាក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ លើកទឹកចិត្តដល់អ្នកវិនិយោគទុនពីខាងក្នុងនិងក្រៅប្រទេស បង្កើនទុនវិនិយោគក្នុងវិស័យកសិកម្មលើគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម ពិសេសការកែច្នៃផលិតផលកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករ ឬសហគមន៍កសិកម្ម ទៅនឹងទីផ្សារតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម/ផលិតករ។ ទន្ទឹមនឹងនេះ ត្រូវជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិអន្តរជាតិទាំងអស់ ឱ្យបន្តគាំទ្រការលើកកម្ពស់ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មតាមគ្រប់រូបភាព ជាពិសេសត្រូវរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអនុវិស័យនៃវិស័យកសិកម្ម ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ៣. វេទិកាសាធារណៈស្ដីពីការអភិវឌ្ឍវិស័យកសិកម្ម

### ៣.១ វេទិកាសាធារណៈស្ដីពីកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងសម្បទានដីសេដ្ឋកិច្ច

កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ ដំណើរការវេទិកាស្ដីពីកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងសម្បទានដីសេដ្ឋកិច្ច ដោយបានប្រព្រឹត្តទៅក្នុងរយៈពេលពេញ១ព្រឹក ក្នុងគោលបំណងដើម្បីពិភាក្សា និងស្វែងយល់អំពីការអភិវឌ្ឍវិស័យកសិកម្ម និងបញ្ហាប្រឈមដែលជួបប្រទះក្នុងផ្នែកផលិតកម្មដំណាំ កៅស៊ូ នីតិកម្ម ផ្នែកព្រៃឈើ ផ្នែកជលផល ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ និងផ្នែកសម្បទានដីសេដ្ឋកិច្ច ពិសេសបង្កើតឱកាសប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកជំនាញបច្ចេកទេស ក៏ដូចជាស្ថាប័នពាក់ព័ន្ធទាំងអស់ សំដៅរកឱ្យឃើញអំពីបញ្ហាប្រឈមជាក់ស្ដែងដែលបានជួបប្រទះ និងរិះរកវិធានការដោះស្រាយបញ្ហាទាំងអស់នោះឱ្យបានល្អប្រសើរ ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យទទួលបានជោគជ័យ ដើម្បីគាំទ្រដល់គោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា។

អង្គវេទិកានេះបានដំណើរការ និងប្រព្រឹត្តទៅដោយមានការអញ្ជើញចូលរួមពីបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល គ្រប់អង្គភាពជំនាញថ្នាក់កណ្ដាល និងថ្នាក់រាជធានី ខេត្ត តំណាងរដ្ឋបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន និងវិស័យឯកជន ដែលមានចំនួនសរុបជាង៥៣០នាក់។

អង្គវេទិកាបានស្តាប់អំពីទិសដៅគោលនយោបាយ និងវឌ្ឍនភាពនៃវិស័យកសិកម្ម ពិសេសចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ដោយត្រូវឈានទៅរកដំណាក់កាលអនុវត្តតាមបែបប្រពលវប្បកម្ម ផ្អែកលើបច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវនិងការអភិវឌ្ឍ ការធ្វើយន្តូបនីយកម្ម និងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មដំណាំ រួមទាំងជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព ព្រមទាំងការធានាចីរភាពបរិស្ថាន និងធនធានធម្មជាតិ ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានកំណត់យ៉ាងច្បាស់ថា វិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងមានតួនាទីគន្លឹះក្នុងការជំរុញសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សង្គម។

ជាមួយគ្នានេះ អង្គវេទិកាក៏បានស្វែងយល់បន្ថែមអំពីដំណើរការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដែលមានលក្ខណៈល្អប្រសើរ ដោយសារគោលនយោបាយ “ឈ្នះ-ឈ្នះ” របស់រាជរដ្ឋាភិបាល បានធ្វើឱ្យប្រទេសជាតិមានស្ថិរភាពនយោបាយ និងផ្លែផ្កានៃសន្តិភាពដ៏ត្រចះត្រចង់ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើឱ្យកម្ពុជាអាចឈានពីប្រទេសមានចំណាត់ថ្នាក់ជាប្រទេសចំណូលទាប ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ អង្គវេទិកាបានស្តាប់អំពីការកែទម្រង់ថ្មីៗរបស់ក្រសួង ក្នុងការបង្កើនផលិតភាពលើមុខដំណាំដែលមានចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ ព្រមទាំងការជំរុញឱ្យមានការធ្វើយន្តូបនីយកម្មកសិកម្ម ជំនួសឱ្យការប្រើប្រាស់ពលកម្មកសិកម្មដែលកំពុងតែមាននិន្នាការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ។

បន្ទាប់ពីបានថ្លែងបញ្ជាក់ជូនអង្គវេទិកាអំពីស្ថានភាពសេដ្ឋកិច្ចជាតិ ទិសដៅគោលនយោបាយ និងវឌ្ឍនភាពនៃវិស័យកសិកម្មរួចមក សមាជិក សមាជិកានៃអង្គវេទិកាបានលើកឡើងអំពីក្តីកង្វល់ បញ្ហាដែលបានជួបប្រទះ និងសំណូមពរដោះស្រាយដែលពាក់ព័ន្ធទៅនឹងចំណុចគន្លឹះមួយចំនួនដូចតទៅ៖

១. ការស្នើសុំព្យួរលិខិតលេខ៨១១ សជណ.ហធ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំគោលការណ៍លើការផ្ទេរធនធានចំណូលមិនមែនសារពើពន្ធ ពីចំណូលថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធនឹងការគណនាថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចឡើងវិញ ដោយកំណត់ថ្លៃឈ្នួលតាមទំហំផ្ទៃដីដែលរដ្ឋបានផ្តល់ជូន ហើយវិស័យឯកជន (តំណាងសភាពាណិជ្ជកម្ម) បានលើកឡើងថា រដ្ឋបានដាក់បន្ទុកធ្ងន់ថែមទៀតដល់វិស័យឯកជន ដែលវិធីនៃការបង់ថ្លៃឈ្នួលនេះ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ និងបានស្នើឱ្យថា គួរតែមានការពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចមុននឹងចេញនូវលិខិតនេះ។ វិស័យឯកជនក៏បានស្នើឱ្យបង្កើតអាងស្តុកទឹកនៅតាមតំបន់ជុំវិញបឹងទន្លេសាប ដែលជាការផ្តល់នូវអត្ថប្រយោជន៍ដល់ផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងធ្វើវារីវប្បកម្ម។

២. ការស្នើសុំពិនិត្យឡើងវិញអំពីការធ្វើសុខដុមនីយកម្មនៃក្រុមការងារកសិកម្មនិងទឹក ដែលនាពេលកន្លងមកនេះ ដៃគូអភិវឌ្ឍន៍តែងតែបានលើកឡើងអំពីការលំបាកពាក់ព័ន្ធនឹងការងារទឹកនិងកសិកម្ម ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ឱ្យស៊ីសង្វាក់គ្នាស្របតាមសក្តានុពលទឹកនិងកសិកម្ម។

៣. អ្នកនាំចូលសត្វបានលើកឡើងពីបញ្ហានៃការរឹតត្បិតនូវការកំណត់កូតានាំចូលសត្វ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ថ្លៃលក់សាច់ក្នុងស្រុក ហើយបានសំណូមពរស្នើសុំឱ្យមានការពិនិត្យឡើងវិញនូវវិធានការនេះ។ ក៏ប៉ុន្តែសមាគមអ្នកចិញ្ចឹមសត្វក្នុងស្រុកបានសម្តែងនូវការត្រេកអរ និងការគាំទ្រលើវិធានការក្នុងការកំណត់កូតានាំចូលសត្វពីប្រទេសជិតខាង ជាពិសេស ជ្រូក និងមាន់ ដែលវិធានការនេះបានផ្តល់ផលប្រយោជន៍ និងលើកទឹកចិត្តយ៉ាងច្រើនដល់អ្នកចិញ្ចឹមសត្វក្នុងស្រុក និងទទួលបានតម្លៃមួយសមស្របសម្រាប់ទីផ្សារ។

៤. ការស្នើសុំជួយដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធគម្រោងដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តសៀមរាប និងខេត្តព្រះវិហាររបស់ក្រុមហ៊ុនហ្វ្រីនវ៉ាប់ប័រ ដែលបញ្ហានេះបានលើកឡើងនាពេលកន្លងមក ហើយរហូតមកដល់ពេល

បច្ចុប្បន្ននេះ មិនទាន់មានដំណោះស្រាយសមស្របណាមួយសម្រាប់ក្រុមហ៊ុននៅឡើយ ដែលជាហេតុធ្វើឱ្យក្រុមហ៊ុនមានការបាត់បង់នូវពេលវេលា និងទុនវិនិយោគអស់ជាច្រើនលើបញ្ហាពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លីនេះ។

៥. តំណាងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា បានស្នើសុំបង្កើតក្រុមការងារមួយជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីពិនិត្យ និងដោះស្រាយបញ្ហារួមគ្នាជាកញ្ចប់លើបញ្ហាផលិតកម្មតាមកិច្ចសន្យា ការប្រមូលទិញការកែច្នៃ និងការនាំចេញផលិតផលកសិកម្ម ក្នុងគោលដៅជួយលើកកម្ពស់ជីវភាពរស់នៅ និងប្រាក់ចំណូលដល់ប្រជាកសិករជាសមាជិកសហគមន៍។

៦. តំណាងសហគមន៍កសិកម្មបានស្នើសុំផ្តល់ទុនឱ្យបានកាន់តែច្រើនបន្ថែមទៀតដល់សហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ដើម្បីឱ្យសហគមន៍មានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រីកអាជីវកម្មរបស់សហគមន៍បន្តទៅទៀត។ ជាមួយគ្នានេះ តំណាងសហគមន៍កសិកម្មក៏បានស្នើសុំជួយផ្សព្វផ្សាយអំពីការអនុវត្តកសិកម្មល្អ (GAP) ដល់ប្រជាកសិករដែលបាន និងកំពុងប្រកបរបរដាំដុះដំណាំ ជាពិសេសស្វាយកែវរមៀត និងមៀនប៉ៃលិន ដោយសារប្រទេសនាំចូលបានទាមទារឱ្យមានការបញ្ជាក់ពីការអនុវត្តកសិកម្មល្អ និងសុំសម្រួលបែបបទក៏ដូចជានីតិវិធីក្នុងការចុះបញ្ជីផលិតផលកសិកម្ម "GAP" របស់សហគមន៍នៅខេត្តបាត់ដំបង។

៧. ការស្នើសុំរបស់តំណាងសហគមន៍នេសាទនៅខេត្តស្ទឹងត្រែង ស្តីពីការចាត់វិធានការទៅលើបទល្មើសនេសាទដែលមានភាពសកម្មជាមុន និងប្រើប្រាស់ឧបករណ៍ និងមធ្យោបាយទំនើបជាងមន្ត្រីជលផល។

ជាការឆ្លើយតបទៅនឹងបញ្ហាប្រឈម និងសំណូមពរខាងលើ អង្គវេទិកាបានធ្វើការពន្យល់បកស្រាយ និងរកដំណោះស្រាយ ដូចខាងក្រោម៖

១. ចំពោះការស្នើសុំព្យួរលិខិតលេខ៨១១ សជណ.ហធ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី អង្គវេទិកាបានសម្រេចថាត្រូវអនុវត្តតាមការសម្រេចនេះ និងប្រគល់ភារកិច្ចជូន ឯកឧត្តម **គុយ ម៉ារិនឌី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ ធ្វើការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការជួបប្រជុំគ្នា ដើម្បីពិនិត្យអំពីនីតិវិធីអនុវត្តជាក់លាក់ ស្របតាមក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ រួចធ្វើការកោះប្រជុំដោយអញ្ជើញក្រុមហ៊ុន សម្បទានដីសេដ្ឋកិច្ចទាំងអស់ចូលរួម ដើម្បីពន្យល់បកស្រាយ និងណែនាំឱ្យបានច្បាស់លាស់ក្នុងការអនុវត្ត។

២. ការស្នើសុំពិនិត្យឡើងវិញអំពីការធ្វើសុខដុមនីយកម្មនៃក្រុមការងារកសិកម្មនិងទឹក៖ អង្គវេទិកាបានប្រគល់ភារកិច្ចនេះជូនឯកឧត្តមរដ្ឋលេខាធិការជាសហប្រធានក្រុមការងារកសិកម្មនិងទឹក បន្តពិនិត្យសម្របសម្រួលកិច្ចការងារនេះ តាមរយៈយន្តការនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកសិកម្មនិងទឹក។ អង្គវេទិកា ក៏បានស្នើឱ្យមានការចែករំលែកព័ត៌មានអំពីការបញ្ចប់ការស្តារ និងការសាងសង់ប្រព័ន្ធប្រឡាយស្រោចស្រពមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីក្រសួងមានជាវិធានការក្នុងការជំរុញការងារផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្មជាដើមនៅកន្លែងដែលមានប្រភពទឹកទាំងនោះ។

៣. ពាក់ព័ន្ធនឹងការកំណត់កូតានាំចូលសត្វ ជាពិសេស ជ្រូក និងមាន់ ដែលបានលើកឡើងក្នុងអង្គវេទិកានេះ ស្នើឱ្យអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បន្តធ្វើការសម្របសម្រួល ពិនិត្យ និងដោះស្រាយរាល់កង្វល់ដែលលើកឡើងនេះ ដោយត្រូវមានមូលដ្ឋានច្បាស់លាស់ក្នុងការកំណត់បរិមាណសាច់ត្រូវនាំចូល ពិនិត្យក្រុមហ៊ុន ឬអ្នកដែលនាំចូលត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងបទដ្ឋានបច្ចេកទេស និងក្របខ័ណ្ឌគតិយុត្តត្រឹមត្រូវ។

៤. ចំពោះករណីក្រុមហ៊ុនហ្គ្រីនរ៉ាប់ប័រ អង្គវេទិកាបានសម្រេចប្រគល់ភារកិច្ចជូន ឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច និង ឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកការងារព្រៃឈើ បន្តដោះស្រាយ

បញ្ហាទំនាស់ដីធ្លីពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុននេះ ឱ្យបានចប់សព្វគ្រប់ក្នុងឆ្នាំ២០២០។ ជាមួយគ្នានេះ ត្រូវកោះប្រជុំជាមួយអន្តរក្រសួង រដ្ឋបាលខេត្តពាក់ព័ន្ធ និងសម្បទានិកនៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដោយធ្វើការជ្រើសរើសក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចណាដែលបានអនុវត្តដោយជោគជ័យ មកធ្វើបទបង្ហាញជូន ដើម្បីជាការចែករំលែកបទពិសោធន៍ភាពជោគជ័យក្នុងការដោះស្រាយទំនាស់ និងត្រូវពិនិត្យរាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទំនាស់ដីធ្លី ព្រមទាំងធ្វើបច្ចុប្បន្នភាពក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ ជាពិសេសក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចណាដែលមិនបានអនុវត្តទៅតាមលិខិតជូនដំណឹងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានដល់ការស្នើលុបចោលកិច្ចសន្យាវិនិយោគ។

៥. ពាក់ព័ន្ធនឹងការស្នើសុំផ្តល់ទុនឱ្យបានកាន់តែច្រើនបន្ថែមទៀតដល់សហគមន៍កសិកម្ម អង្គវេទិកាបានសម្រេចប្រគល់ភារកិច្ចជូនធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម បន្តជួយដោះស្រាយបញ្ហាប្រាក់កម្ចីដល់សហគមន៍កសិកម្មនៅខេត្តព្រះវិហារ និងជូនឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកការងារកសិ-ឧស្សាហកម្មជំរុញការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។

៦. ចំពោះករណីស្នើសុំជួយផ្សព្វផ្សាយអំពីការអនុវត្តកសិកម្មល្អ (GAP) និងសម្រួលបែបបទក៏ដូចជានីតិវិធីក្នុងការចុះបញ្ជីផលិតផលកសិកម្ម "GAP" អង្គវេទិកាបានសម្រេចប្រគល់ភារកិច្ចជូនអគ្គនាយកដ្ឋានកសិកម្ម ពិនិត្យលើកិច្ចការនេះ និងកំណត់នូវវិធាននៃការចុះបញ្ជីក្នុងកម្រិតណាដែលត្រូវចុះបញ្ជីនៅអគ្គនាយកដ្ឋានកសិកម្ម និងកម្រិតណាដែលចុះបញ្ជីនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ដើម្បីជួយសម្រួលការងារនេះដល់កសិករ សហគមន៍កសិកម្ម និងអ្នកផលិតក្នុងស្រុក។

៧. ប្រគល់ភារកិច្ចជូនឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកការងារជលផលសហការជាមួយឯកឧត្តមអភិបាលខេត្ត ពិនិត្យការងារនេសាទនេះជាបន្ទាន់ ដើម្បីឆ្លើយតបសំណើរបស់តំណាងសហគមន៍នេសាទនៅខេត្តស្ទឹងត្រែង និងត្រូវផ្តល់មធ្យោបាយដល់មន្ត្រីជលផលឱ្យបានគ្រប់គ្រាន់ ព្រមទាំងបន្តខិតខំពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យបានរឹងមាំ។

## ៣.២ កិច្ចប្រជុំក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម (ក្រុម"ក") នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំកិច្ចប្រជុំក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងសំខាន់ចំនួន០២ គឺ៖

១. ពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម។

២.ពិភាក្សា ផ្លាស់ប្តូរយោបល់ ស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងរិះរកគំនិតផ្តួចផ្តើម យន្តការដោះស្រាយថ្មីៗ ក្នុងស្មារតីស្ថាបនាដើម្បីបង្កើនផលិតភាព ជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិប្រកបដោយសុខដុមនីយកម្ម លើកស្ទួយវិស័យកសិកម្ម វិស័យកសិ-ឧស្សាហកម្ម និងអភិវឌ្ឍន៍ជនបទប្រកបដោយនិរន្តរភាព។

កិច្ចប្រជុំនេះបានដំណើរការ និងប្រព្រឹត្តទៅដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ អនុប្រធាន សមាជិក សមាជិកានៃក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម របស់រាជរដ្ឋាភិបាល និងផ្នែកឯកជន តំណាងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមហ៊ុនឯកជន និងអ្នកពាក់ព័ន្ធសរុបប្រមាណ៨០នាក់។

បន្ទាប់ពីបានបញ្ជាក់អំពីវឌ្ឍនភាពនៃការអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្មរួចមក អង្គប្រជុំបានលើកឡើងអំពីក្ដីកង្វល់ បញ្ហាប្រឈមដែលបានជួបប្រទះ និងសំណូមពរជួយដោះស្រាយដែលពាក់ព័ន្ធទៅនឹងចំណុចគន្លឹះមួយចំនួនដូចមានខាងក្រោម៖

១) វិស័យឯកជនស្នើសុំព្យួរការយកថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចជូនរដ្ឋជាបណ្ដោះអាសន្ន ដោយរង់ចាំការចុះបញ្ជីដីរដ្ឋចប់សព្វគ្រប់ជាមុនសិន ទើបធ្វើការបង់ពន្ធជូនរដ្ឋទៅតាមទំហំផ្ទៃដីជាក់ស្ដែងជាក្រោយ។

២) វិស័យឯកជនស្នើឱ្យមានការជួយអន្តរាគមន៍ដោះស្រាយវិវាទដីធ្លី របស់អាជ្ញាធរមូលដ្ឋានជូនក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច និងសហគមន៍ឲ្យបានទាន់ពេលវេលា ដើម្បីក្រុមហ៊ុនមានលទ្ធភាពក្នុងការអនុវត្តគម្រោងវិនិយោគ។

៣) វិស័យឯកជនស្នើឱ្យមានការអន្តរាគមន៍ ដើម្បីពន្លឿនការងារចុះបញ្ជីដីសម្បទានសេដ្ឋកិច្ច ដែលមានភាពស្មុគស្មាញដោយត្រូវអូសបន្លាយរយៈពេលយូរ។

៤) វិស័យឯកជនស្នើសុំការសម្របសម្រួលពីក្រសួងបរិស្ថាន ដើម្បីបង្កើនចំនួនក្រុមហ៊ុន និងទីប្រឹក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (EIA) ដោយបច្ចុប្បន្នមានចំនួនតិច ហើយត្រូវចំណាយពេលវេលាយូរ និងថវិកាច្រើនក្នុងការទទួលបានការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនេះ។

៥) វិស័យឯកជនស្នើសុំព្យួរការបង់ពន្ធនាំចេញកៅស៊ូ (៥០$/តោន) ជាបណ្ដោះអាសន្នរហូតតម្លៃកៅស៊ូកើនដល់ ១ ៦០០ដុល្លារអាមេរិក/មួយតោន ទើបក្រុមហ៊ុនមានលទ្ធភាពបង់ពន្ធជូនរដ្ឋ ព្រោះតម្លៃកៅស៊ូមានការធ្លាក់ចុះខ្លាំង គិតត្រឹមឆ្នាំ២០១៩មានតម្លៃត្រឹមតែ ១ ៣៣១ដុល្លារអាមេរិក/មួយតោនប៉ុណ្ណោះ រួមជាមួយការរត់ពន្ធកៅស៊ូខុសច្បាប់ដោយគ្មានការបង់ពន្ធ ដែលជាហេតុធ្វើឱ្យក្រុមហ៊ុនវិនិយោគក្នុងស្រុកពុំមានលទ្ធភាពប្រកួតប្រជែងថ្លៃ និងខ្វះជ័រកៅស៊ូដើម្បីធ្វើការកែច្នៃ។

៦) វិស័យឯកជនស្នើឲ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត មានសិទ្ធិចេញវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (SPS) ដើម្បីបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនក្នុងការនាំចេញ។

៧) វិស័យឯកជនស្នើសុំលើកលែងការបង់អាករលើតម្លៃបន្ថែមសម្រាប់ការចិញ្ចឹមសត្វចំនួន១០% ដោយបានលើកឡើងថា នៅបណ្ដាប្រទេសជិតខាងគឺមិនមានការយកពន្ធអាករលើតម្លៃបន្ថែមសម្រាប់ការចិញ្ចឹមសត្វនោះទេ។

៨) ស្នើសុំបញ្ចុះតម្លៃអគ្គិសនីមកត្រឹមតែ៤៥០-៤៨០រៀល/គីឡូវ៉ាត់ម៉ោង ដើម្បីបង្កើនការកែច្នៃផលិតផលសាច់ និងកាត់បន្ថយការនាំចូលផលិតផលកែច្នៃពីបណ្ដាប្រទេសជិតខាង។

ជាលទ្ធផល អង្គប្រជុំបានសម្រេចឱ្យស្ថាប័នជំនាញពាក់ព័ន្ធ រួមគ្នាដោះស្រាយបញ្ហាប្រឈម និងសំណូមពររបស់វិស័យឯកជន។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានជួយអន្តរាគមន៍លើសំណូមពរមួយចំនួនរួចហើយនាពេលកន្លងមក រួមមាន៖ (១) ការកែប្រែតម្លៃអាករនាំចេញលើមុខទំនិញកៅស៊ូ តាមរយៈលិខិតលេខ ៦៩៩ កសក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ (២) ការលើកសំណើសុំអន្តរាគមន៍ និងជួយសម្របសម្រួលដោះស្រាយបញ្ហាប្រឈម ដែលជាសំណូមពររបស់ផ្នែកឯកជនក្នុងផលិតកម្មកសិកម្ម កសិ-ឧស្សាហកម្ម និងការកែច្នៃផលិតផលកសិកម្ម តាមរយៈលិខិតលេខ១៩០/០១១ កសក.នផ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ (៣) បញ្ហាព្យួរការបង់ថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការងារនេះជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការជួបប្រជុំគ្នាដើម្បីពិនិត្យអំពីនីតិវិធីអនុវត្តជាក់លាក់ ស្របតាមក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ រួចធ្វើការកោះប្រជុំដោយអញ្ជើញក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ចូលរួម ដើម្បីពន្យល់បកស្រាយ និងណែនាំឱ្យបានច្បាស់លាស់ និងសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជាក្នុងករណីពុំអាចដោះស្រាយបាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តជួយអន្តរាគមន៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដើម្បីបន្តជួយដោះស្រាយបញ្ហាចុះបញ្ជីដី និងវិវាទដីធ្លីជូនក្រុមហ៊ុនវិនិយោគ

សម្បទានដីសេដ្ឋកិច្ច។ ជាមួយគ្នានេះ ក្រសួងនឹងលើកសំណើរបស់វិស័យឯកជនជូនក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងមានវិធានការបន្តក្នុងការជំរុញលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (EIA)។ ចំពោះការស្នើសុំកាត់បន្ថយថ្លៃអគ្គិសនី រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការបញ្ចុះតម្លៃនាពេលកន្លងមក ហើយថ្មីៗនេះរាជរដ្ឋាភិបាលបានសម្រេចបញ្ចុះតម្លៃថាមពលអគ្គិសនីចំនួនមួយសេនដុល្លារ ឬស្មើនឹង៤០រៀល/គីឡូវ៉ាត់ម៉ោង រួចហើយដែរ។ លើសពីនេះទៀត ការចេញវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (SPS) គឺអគ្គនាយកដ្ឋានកសិកម្មនឹងបន្តជួយសម្រួលដល់ផ្នែកឯកជន ដើម្បីពន្លឿនការនាំចេញផលិតផលកសិកម្ម។

ដោយឡែកក៏នៅមានបញ្ហាមួយចំនួន ដែលអង្គប្រជុំសូមគោរពស្នើសុំការដោះស្រាយពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា។ ឆ្លើយតបទៅនឹងសំណូមពរទាំងអស់នេះ ក្រសួងបានគោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** នូវសំណើសុំលើកលែងការបង់អាករលើតម្លៃបន្ថែមសម្រាប់ការចិញ្ចឹមសត្វ (VAT ១០ភាគរយ) ដើម្បីជួយដល់ការចិញ្ចឹមសត្វនៅកម្ពុជា។

## ៣.៣ ការកំណត់តំបន់ដាំដុះដំណាំកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់ទុកការកំណត់តំបន់ដាំដុះកសិកម្មជាការងារអាទិភាពមួយ ដោយបានដាក់បញ្ចូលក្នុងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីឆ្នាំ២០១៨-២០២៧ ដែលប្រមុខរាជរដ្ឋាភិបាលបានអនុម័តនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨។ ឆ្លើយតបទៅនឹងកម្មវិធីសកម្មភាពជាតិនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្មសម្រាប់អនុវត្តការងារនេះឱ្យបានជោគជ័យ។ ក្នុងជំហានដំបូងនៃការអនុវត្ត គណៈកម្មាធិការបានរៀបចំឯកសារទស្សនទានដោយបានកំណត់យកវិធីសាស្ត្រសិក្សា ការកំណត់ប្រភេទដំណាំ ការប្រមូល និងការវិភាគទិន្នន័យ (ប្រើកម្មវិធី ArcMap) និងរបៀបចងក្រងឯកសារ។

### វឌ្ឍនភាពនៃការរៀបចំកំណត់តំបន់ដាំដុះកសិកម្ម៖

ការកំណត់តំបន់ដាំដុះសមស្របសម្រាប់ដំណាំ ត្រូវបានចែកចេញជា៥ចំណាត់ថ្នាក់គឺ ១-សមស្របខ្លាំង (ល្អ) ២-សមស្រប (ល្អបង្គួរ) ៣-សមស្របល្មម (មធ្យម) ៤-សមស្របទាប (តិច) និង៥-មិនសមស្រប។ ប៉ារ៉ាម៉ែត្រសំខាន់ដែលបានប្រើសម្រាប់ចំណាត់ថ្នាក់នីមួយៗរួមមាន ប្រភេទដី កម្រិតជម្រាល បរិមាណទឹកភ្លៀងប្រចាំឆ្នាំ រយៈកម្ពស់ និងតំបន់គម្របដី ហើយប៉ារ៉ាម៉ែត្រនីមួយៗ ត្រូវបានផ្តល់ពិន្ទុសម្រាប់ប្រភេទដំណាំដោយមន្ត្រីជំនាញ។ ជាលទ្ធផល ក្រសួងបានផលិតផែនទីដាំដុះតំបន់សមស្របសម្រាប់ដំណាំកសិកម្ម៩ប្រភេទ សរុបចំនួន ១២សន្លឹក រួមមានដំណាំស្រូវ ដំឡូងមី ពោត ស្វាយ ស្វាយចន្ទី ទុរេន អំពៅ ម្រេច និងកាហ្វេ។ ផែនទីទាំងនេះ ជាសេចក្តីព្រាងលើកទី១ ដែលក្រុមការងារជំនាញកំពុងបន្តពិនិត្យលក្ខណៈបច្ចេកទេសបន្ថែមដោយបញ្ចូលនូវប៉ារ៉ាម៉ែត្រថ្មី ដើម្បីធ្វើឱ្យកាន់តែមានភាពល្អប្រសើរ មុននឹងសម្រេចបោះពុម្ពផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ។

### ផែនការអនុវត្តបន្ត ៖

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារទស្សនទានស្តីពីការកំណត់តំបន់ដាំដុះកសិកម្មនៅកម្ពុជា ដើម្បីស្វែងរកការគាំទ្រផ្នែកថវិកា និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ ជាមួយគ្នានេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវផែនការបន្តរួមមាន៖ (១) ពិនិត្យលក្ខណៈបច្ចេកទេសដោយបញ្ចូលនូវប៉ារ៉ាម៉ែត្រថ្មីៗ ការបញ្ចូលប្រភេទដំណាំថ្មីៗដែលកំពុងមានសក្តានុពលផលិតនាំចេញ (ចេក សណ្តែកសៀងជាដើម) ការផលិតផែនទីបង្ហាញពីតំបន់ដំណាំ ការចុះផ្ទៀងផ្ទាត់លទ្ធផលនៅទីវាលជាក់ស្តែង ការសរសេរចងក្រងឯកសារស្តីពីការកំណត់តំបន់ដាំដុះកសិកម្មនៅកម្ពុជា និងការរៀបចំផែនទីសម្រាប់ប្រើជាមួយទូរស័ព្ទដៃ

ទំនើប (២) រៀបចំកិច្ចប្រជុំគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្មនៅកម្ពុជា ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនទីដែលផលិតបានសំដៅធ្វើឱ្យកាន់តែប្រសើរឡើង និង(៣) រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងអ្នកពាក់ព័ន្ធលើសេចក្តីព្រាងចុងក្រោយនៃផែនទីកំណត់តំបន់ដាំដុះកសិកម្មនៅកម្ពុជា។

## ៣.៤ វិធានការចាំបាច់នានាសម្រាប់ទ្រទ្រង់វិស័យស្រូវ-អង្ករកម្ពុជា

### ៣.៤.១ ពាក់ព័ន្ធនឹងការធ្វើធូបទកម្ម (Fumigation)

បច្ចុប្បន្នការផ្តល់សេវាធូបទកម្ម (Fumigation) នៅប្រទេសកម្ពុជាមានចំនួន០៣ក្រុមហ៊ុន ហើយតម្លៃសេវាក៏ទាបជាងប្រទេសជិតខាងនៅក្នុងតំបន់។ ជាក់ស្តែង ការចំណាយលើសេវាធូបទកម្មក្នុងមួយកុងតេន័រដែលមានទំហំ២០Feet នៅប្រទេសកម្ពុជាមានតម្លៃ២៣ដុល្លារអាមេរិក ប្រទេសថៃមានតម្លៃ២៥ដុល្លារអាមេរិក ប្រទេសវៀតណាមមានតម្លៃ៤០ដុល្លារអាមេរិក និងប្រទេសម៉ាឡេស៊ីមានតម្លៃ៤៥ដុល្លារអាមេរិក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកចំហរឱ្យក្រុមហ៊ុនដទៃទៀតធ្វើអាជីវកម្មលើសេវាកម្មនេះ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានធ្វើការផ្សព្វផ្សាយឡើងវិញជាសាធារណៈតាមរយៈសិក្ខាសាលានាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩នេះផងដែរ។ ដើម្បីឱ្យសាធារណជន និងបណ្តាក្រុមហ៊ុននាំចេញអង្ករទាំងអស់បានជ្រាបកាន់តែច្បាស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីជូនដំណឹងឡើងវិញអំពីការបើកចំហរក្នុងការផ្តល់សេវាធូបទកម្ម ជៀសវាងមានការយល់ច្រឡំអំពីការធ្វើអាជីវកម្មផ្តាច់មុខលើសេវានេះ ហើយក៏អាចផ្តល់ឱកាសឱ្យក្រុមហ៊ុនដែលមានបំណងចង់ធ្វើអាជីកម្មលើសេវានេះផងដែរ។

### ៣.៤.២ ពាក់ព័ន្ធនឹងកម្រៃសេវាត្រួតពិនិត្យភូតគាមអនាម័យ

អនុលោមតាមគោលការណ៍អន្តរជាតិ អនុសញ្ញាការពាររុក្ខជាតិអន្តរជាតិ និងអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចទទួលខុសត្រូវលើការអនុវត្តការងារត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយទៀតក្នុងព្រះរាជាណាចក្រកម្ពុជា។ កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមិនទាន់បានកំណត់ឱ្យយកកម្រៃសេវាត្រួតពិនិត្យភូតគាមអនាម័យនៅឡើយ ដោយសារពុំទាន់មានប្រកាសរួមស្តីការកំណត់សេវាសាធារណៈសម្រាប់ការងារនេះ។ ដូច្នេះ ការចុះត្រួតពិនិត្យទំនិញដោយមន្ត្រីភូតគាមអនាម័យ ធ្វើឡើងដោយពុំបានតម្រូវឱ្យផ្នែកឯកជនបង់កម្រៃសេវាឡើយ ក៏ប៉ុន្តែផ្នែកឯកជនត្រូវទទួលរ៉ាប់រងការចំណាយលើការធ្វើដំណើរ ហូបចុក និងស្នាក់នៅរបស់មន្ត្រីដែលត្រូវចុះធ្វើការត្រួតពិនិត្យភូតគាមអនាម័យ។ ប្រតិបត្តិការនេះកន្លងមកបានដំណើរការឡើង ដោយមានភ្នាក់ងាររត់ការឯកជនដែលក្រុមហ៊ុនម្ចាស់ទំនិញមួយចំនួនបានជួលឱ្យធ្វើការជំនួស ដែលការណ៍នេះធ្វើឱ្យម្ចាស់ទំនិញត្រូវចំណាយខ្ពស់លើកម្រៃជើងសារជាយថាហេតុ។

ពាក់ព័ន្ធនឹងចំណុចនេះ ក្រសួងបានដាក់ចេញនូវវិធានការបន្ទាន់ វិធានការរយៈពេលមធ្យមនិងវែង ដើម្បីឆ្លើយតបទៅនឹងសំណូមពរនេះដូចខាងក្រោម៖

- ក្រសួងនឹងចេញសេចក្តីជូនដំណឹងដល់បណ្តាក្រុមហ៊ុនដែលមានគោលបំណងស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យឱ្យមកធ្វើការទំនាក់ទំនងដោយផ្ទាល់ ជៀសវាងត្រូវចំណាយលើការប្រើប្រាស់ភ្នាក់ងារឯកជន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងជំរុញការអនុវត្តប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈលើការត្រួតពិនិត្យភូតគាមអនាម័យ ការវិភាគពូជដំណាំ និងមន្ទីរពិសោធន៍។ល។

- អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបង្កើតច្រកចេញចូលតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួលដល់បណ្ដាក្រុមហ៊ុនឱ្យធ្វើការទំនាក់ទំនងដោយផ្ទាល់ និងជៀសវាងការចំណាយក្រៅផ្លូវការ
- ដើម្បីរំកិលសេវាឱ្យទៅជិតអតិថិជន កាត់បន្ថយការចំណាយ និងចំណេញពេលវេលា អគ្គនាយកដ្ឋានកសិកម្មនឹងបញ្ជូនមន្ត្រីត្រួតពិនិត្យភូតគាមអនាម័យ ហើយរៀបចំបំពាក់ឧបករណ៍សម្ភារៈដាក់ឱ្យដំណើរការសាខាការិយាល័យភូតគាមអនាម័យប្រចាំតំបន់ទាំង០៥កន្លែងនៅទូទាំងប្រទេស។
- អគ្គនាយកដ្ឋានកសិកម្មនឹងធ្វើការបណ្ដុះបណ្ដាលដល់មន្ត្រីនៅតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមួយចំនួន ដើម្បីចូលរួមធ្វើការងារជាមួយមន្ត្រីភូតគាមអនាម័យថ្នាក់ជាតិនៅតាមសាខាការិយាល័យភូតគាមអនាម័យប្រចាំតំបន់
- ត្រូវបង្កើតប្រព័ន្ធវិញ្ញាបនកម្មភូតគាមអនាម័យស្វ័យប្រវត្តិកម្ម (e-Phyto certification system) ដោយតភ្ជាប់ជាមួយប្រព័ន្ធបញ្ជរតែមួយជាតិ ដែលពេលនេះបានរៀបចំមួយជំហានហើយ ក្រោមក្របខ័ណ្ឌគម្រោងបញ្ជរតែមួយជាតិដំណាក់កាលទី២ ការងារចំពោះមុខត្រូវបន្តអភិវឌ្ឍជាប្រព័ន្ធវិញ្ញាបនកម្មភូតគាមអនាម័យស្វ័យប្រវត្តិកម្មពេញលេញ ដើម្បីឈានទៅចេញផ្ដល់វិញ្ញាបនបត្រភូតគាមអនាម័យជាលក្ខណៈអេឡិកត្រូនិក ការងារនេះទាមទារឱ្យមានការវិនិយោគថវិកាដើម្បីរៀបចំកសាងកម្មវិធី បំពាក់សម្ភារៈ មធ្យោបាយធ្វើដំណើរ និងអភិវឌ្ឍន៍ធនធានមនុស្ស
- ជំរុញការរៀបចំ និងអនុម័តច្បាប់ស្ដីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យឱ្យបានឆាប់។

**៣.៤.៣ ពាក់ព័ន្ធនឹងការប្រើប្រាស់គ្រាប់ពូជស្រូវ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតែងតែធ្វើការស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជស្រូវដែលផ្ដល់ទិន្នផលខ្ពស់ ធន់នឹងសមាសភាពចង្រៃ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងសមស្របតាមតម្រូវការទីផ្សារដើម្បីផ្សព្វផ្សាយដល់អ្នកផលិត និងកសិករសម្រាប់ធ្វើការដាំដុះ។ ជាមួយគ្នានេះដែរ ក្រសួងក៏បានរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រពូជដំណាំ ក្រុមប្រឹក្សានិងគណៈកម្មការបញ្ចេញពូជដំណាំ និងបង្កើតភ្នាក់ងារអធិការកិច្ចត្រួតពិនិត្យគុណភាពពូជដំណាំផងដែរ។ ក្រសួងតែងតែជំរុញឱ្យប្រជាកសិករធ្វើការដាំដុះពូជស្រូវដែលមានតម្លៃខ្ពស់លើទីផ្សារ ពិសេសពូជស្រូវក្រអូប ប៉ុន្តែមិនអាចធ្វើការដាំដុះតែស្រូវក្រអូបតែមួយប្រភេទបាននោះទេ គឺអាស្រ័យទៅតាមប្រព័ន្ធអេកូឡូស៊ីដំណាំស្រូវ និងតម្រូវការទីផ្សារ។ ម៉្យាងទៀត ក្រសួងបាននិងកំពុងជំរុញផលិតកម្មគ្រាប់ពូជមានគុណភាពល្អតាមរយៈគម្រោងជាមួយដៃគូអភិវឌ្ឍន៍ និងសហគមន៍អភិវឌ្ឍន៍កសិកម្មសម្រាប់បម្រើក្នុងផលិតកម្មដំណាំស្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ ការផលិតគ្រាប់ពូជស្រូវមានគុណភាពល្អ នៅមិនទាន់បំពេញតម្រូវការបានគ្រប់គ្រាន់ ដោយសារខ្វះការចូលរួមវិនិយោគពីវិស័យឯកជន ផ្នែកម៉ាស៊ីន និងឧបករណ៍កែច្នៃគ្រាប់ពូជដំណាំ ហើយយន្តការនៃការពិនិត្យបញ្ជាក់គុណភាពក៏មិនទាន់ដំណើរការបានល្អនៅឡើយ។ ជាវិធានការត្រូវអនុវត្តបន្តរួមមាន៖

- បន្តជំរុញឱ្យប្រជាកសិករធ្វើការប្រើប្រាស់ពូជស្រូវក្រអូបស្របតាមប្រព័ន្ធអេកូឡូស៊ីដំណាំស្រូវ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ
- ជំរុញការងារផលិតកម្មគ្រាប់ពូជស្រូវមានគុណភាពល្អ ដោយមានការចូលរួមពីវិស័យឯកជន សហគមន៍កសិកម្ម និងដៃគូអភិវឌ្ឍន៍នានា
- ពង្រឹងការត្រួតពិនិត្យគុណភាពនិងផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាព តាមរយៈការបង្កើតនាយកដ្ឋានពូជដំណាំ
- បន្តលើកទឹកចិត្តដល់វិស័យឯកជនចូលរួមវិនិយោគលើផលិតកម្ម និងការកែច្នៃគ្រាប់ពូជស្រូវស្របតាមស្តង់ដា តាមរយៈការលើកទឹកចិត្តអនុគ្រោះពន្ធពីរាជរដ្ឋាភិបាល។

- បន្តជំរុញការងារពិសោធស្រាវជ្រាវបន្សុទ្ធ និងអភិវឌ្ឍន៍ពូជស្រូវដែលមានសក្តានុពលទីផ្សារ ធន់នឹងបម្រែបម្រួលអាកាសធាតុ
- បង្កើតមជ្ឈមណ្ឌលសម្រិតសម្រាំងនិងកែច្នៃគ្រាប់ពូជស្រូវដែលបំពាក់ដោយឧបករណ៍ទំនើប
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមកសិដ្ឋាននិងស្ថានីយកសិកម្ម
- បន្តរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងពូជដំណាំ និងអនុវត្តឱ្យមានប្រសិទ្ធភាព។

## III- លទ្ធផលជារួម

នៅក្នុងឆ្នាំ២០១៩នេះ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានកូនរដូវប្រាំងកើតឡើងនៅតាមបណ្តាខេត្តមួយចំនួន ពិសេសមានគ្រោះរាំងស្ងួតក្នុងអំឡុងខែសីហានិងដើមខែកញ្ញា និងជាចុងក្រោយគឺគ្រោះទឹកជំនន់បានកើតមានក្នុងអំឡុងខែតុលា ដែលបានបង្កការលំបាកដល់ដំណើរការបង្កបង្កើនផលដំណាំ និងបណ្តាលឱ្យខូចខាតដំណាំស្រូវប្រមាណជាង៦៧ពាន់ហិកតា។ ទោះបីជួបប្រទះបញ្ហាប្រឈមយ៉ាងនេះក៏ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រើប្រាស់គ្រប់មធ្យោបាយ និងបានផ្តល់សម្ភារកសិកម្មដើម្បីជួយអន្តរាគមន៍មានដូចជា៖ ពូជស្រូវ ពូជបន្លែ ពូជសត្វ បសុឱសថ និងមធ្យោបាយអន្តរាគមន៍ផ្សេងៗទៀតដែលចាំបាច់ និងបានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ ដោយយកចិត្តទុកដាក់ណែនាំដល់ប្រជាកសិករ អនុវត្តនូវវិធានការទប់ស្កាត់លើការបាត់បង់ក្រោយពេលប្រមូលផល ទាំងបរិមាណនិងគុណភាពស្រូវ។ ក្រសួងក៏បានអនុវត្តការងារវាយតម្លៃទិន្នផល និងបរិមាណផលស្រូវបានច្បាស់លាស់ និងតាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវរដូវប្រាំង ព្រមទាំងជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹកនិងឧតុនិយម និងអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការសម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង។

បន្ថែមលើសពីនេះ ក្រសួងបានចេញសេចក្តីណែនាំនានាដើម្បីចាត់វិធានការសមស្រប តាមស្មារតីនៃសារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល។ ក្រសួងក៏បានផ្សព្វផ្សាយបច្ចេកទេសដល់កសិករក្នុងការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ជំរុញការប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ និងការប្រើប្រាស់ឧបករណ៍ព្រោះ ដើម្បីកាត់បន្ថយបរិមាណគ្រាប់ពូជ និងថ្លៃដើមផលិតកម្ម។ បញ្ហាផលិតភាពទាបនៃផលិតកម្មកសិកម្ម ពិសេសផលិតកម្មដំណាំស្រូវ ជាកង្វល់មួយដែលត្រូវប្រឹងប្រែងដោះស្រាយ ដោយក្រសួងបាននិងកំពុងជំរុញការបង្កបង្កើនផលស្រូវតាមរបៀបទំនើប បែបស៊ីជម្រៅជាលក្ខណៈប្រពលវប្បកម្ម និងប្រើបច្ចេកវិទ្យាថ្មីៗ ស្របតាមចរន្តសកលភាវូបនីយកម្ម។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម សំដៅជំរុញលើកកម្ពស់ផលិតភាពកសិកម្ម ទាំងបរិមាណនិងគុណភាព ដោយធានាបានសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាន និងកំពុងស្រូបទាញនូវទុនវិនិយោគពីអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសកាន់តែច្រើនឡើងជាលំដាប់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ទោះបីជួបប្រទះនូវកត្តាអវិជ្ជមានខ្លះៗក៏ដោយ។

### ១. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២០,៨% (គិតតាមថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣៣,៨% និងវិស័យសេវាកម្មប្រមាណ៣៩,១%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេង

ទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពី២៦,៦% ដល់២០,៨% ក្នុងចន្លោះឆ្នាំ២០១៥-២០១៩ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងសេវាកម្មផ្សេងទៀតមានការកើនឡើង។

**ក្រាហ្វិកទី១៖ បង្ហាញពីការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ**




**ប្រភព៖** ក្រសួងផែនការឆ្នាំ២០១៩ (ការវាយតម្លៃជំហានដំបូង)

ទោះជាយ៉ាងនេះក្តី បើពិនិត្យទៅលើតម្លៃបន្ថែមសរុប (គិតតាមតម្លៃបច្ចុប្បន្ន) នៃវិស័យកសិកម្ម (Agricultural Gross Value Added-GVA) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៥ ៩៣៨ ពាន់លានរៀលនៅឆ្នាំ២០១០ ដល់ ១៩ ៥១៦ពាន់លានរៀលនៅឆ្នាំ២០១៥ និងបានបន្តកើនដល់ ២២ ៧៨៦ពាន់លានរៀលនៅឆ្នាំ២០១៩។

**ក្រាហ្វិកទី២៖ បង្ហាញពីការកើនឡើងតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០១៩ (ការវាយតម្លៃជំហានដំបូង)

## ២. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

នៅឆ្នាំ២០១៩នេះ ការចូលរួមចំណែកនៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបរបស់វិស័យកសិកម្ម រួមមាន៖ ផ្នែកដំណាំ ៥៧,៦៧% ផ្នែកផលិតកម្មសត្វ១១,១១% ផ្នែកជលផល២៤,៣០% និងផ្នែកព្រៃឈើ៦,៩១%។ ជាការកត់សម្គាល់ ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងវិស័យកសិកម្ម (ការចូលរួមចំណែកច្រើនជាងគេ

ក្នុងវិស័យទាំងមូល)។ ផលិតកម្មសត្វក៏ជាមុខព្រួញសំខាន់មួយទៀតក្នុងការផ្គត់ផ្គង់តម្រូវការសាច់ក្នុងស្រុក និងបម្រើឱ្យការនាំចេញ ដែលផ្នែកទាំងនេះត្រូវជំរុញអភិវឌ្ឍន៍ឱ្យបានខ្លាំងក្លាផងដែរ។

**ក្រាហ្វិកទី៣៖ បង្ហាញពីការចូលរួមនៃអនុវិស័យកសិកម្ម (%)**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០១៩ (ការវាយតម្លៃជំហានដំបូង)

## ៣. ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម

អត្រាកម្លាំងពលកម្មកសិកម្មធៀបនឹងពលកម្មសរុបបានបន្តធ្លាក់ចុះពី ៤៨,៧%នាឆ្នាំ២០១៣ មកត្រឹម ៣៧% ឆ្នាំ២០១៧។ យន្តូបនីយកម្មកសិកម្ម បានចូលមកជំនួសការបាត់បង់កម្លាំងពលកម្ម ដោយក្នុងឆ្នាំ២០១៩ នេះ ការរៀបចំដីដោយប្រើប្រាស់គ្រឿងយន្តកសិកម្មមានចំនួនប្រមាណជាង៩៨% (ឆ្នាំ២០១៦មានតែ៩១% និងឆ្នាំ២០១៧ មានប្រមាណ៩៣,៦%) និងការប្រមូលផលដោយគ្រឿងយន្តមានប្រហែលជាង៧០%។

**តារាងទី១៖ ប្រៀបធៀបកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**

| កម្លាំងពលកម្ម | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៣ | | | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី |
| ចំនួនពលកម្មសរុប (ពាន់នាក់) | ៧ ៩៥១ | ៤ ០៦៨ | ៣ ៨៨២ | ១០ ៤១៦ | ៥ ០៥៦ | ៥ ៣៦០ |
| កសិកម្ម (%) | **៤៨,៧** | ៤៧,៤ | ៥០,០ | **៣៧,០** | ៣៥,១ | ៣៩,០ |
| ឧស្សាហកម្ម (%) | ១៩,៩ | ២០,៥ | ១៩,២ | ២៦,២ | ២៧,៣ | ២៥,១ |
| សេវាកម្ម (%) | ៣១,៥ | ៣២,១ | ៣០,៨ | ៣៦,៨ | ៣៧,៦ | ៣៥,៩ |
| ផ្សេងៗ | - | - | - | - | ០,១ | - |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |

ប្រភព៖ ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ច)

# IV- លទ្ធផលតាមអនុវិស័យ

## ១. បង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម

### ក. ផលិតកម្មដំណាំស្រូវ

ក្នុងឆ្នាំ២០១៩នេះ ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៣,៣២៨លានហិកតា ស្មើនឹង ១១៥% នៃផែនការ ក្នុងនោះស្រូវរដូវវស្សាមានចំនួន ២,៧៣១លានហិកតា និងស្រូវរដូវប្រាំងមានចំនួន ០,៥៩៧ លានហិកតា ដែលផ្ទៃដីដាំដុះសរុបនេះ ថយចុះប្រមាណ០,២១% ធៀបនឹងផ្ទៃដីដាំដុះនៅឆ្នាំ២០១៨។ ផ្ទៃដីប្រមូលផល

សរុបមានចំនួន ៣,២៦៣លានហិកតា ក្នុងនោះស្រូវរដូវវស្សាមានចំនួន ២,៦៧១លានហិកតា ស្រូវរដូវប្រាំងមានចំនួន ០,៥៩២លានហិកតា។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១០,៨៨៥លានតោន គឺប្រហាក់ប្រហែលនឹងឆ្នាំ២០១៨ ក្នុងនោះបរិមាណផលស្រូវរដូវវស្សា ទទួលបានប្រមាណ ៨,២៦៩លានតោន និងបរិមាណផលស្រូវរដូវប្រាំង ទទួលបានប្រមាណ ២,៦១៦លានតោន ដោយមានអតិរេកស្រូវជាង ៥,៧៦លានតោន គិតជាអង្ករស្មើនឹង ៣,៦៩លានតោន។ ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំទទួលបាន ៣,៣៣៥តោន/ហិកតា ដែលថយចុះជាងឆ្នាំមុនចំនួន ០,៥៤% ស្មើនឹង១៨គីឡូក្រាម/ហិកតា ក្នុងនោះទិន្នផលស្រូវវស្សាទទួលបាន ៣,០៩៥ តោន/ហិកតា និងទិន្នផលស្រូវប្រាំងទទួលបាន ៤,៤១៨តោន/ហិកតា។

តាមរយៈលទ្ធផលសម្រេចបានខាងលើនេះបង្ហាញថា ស្ថានភាពផលិតកម្មដំណាំស្រូវនៅឆ្នាំ២០១៩-២០២០នេះនៅតែល្អប្រសើរ ធានាបានសន្តិសុខស្បៀង និងអតិរេកស្រូវសម្រាប់ការកែច្នៃនាំចេញ បើទោះជាបានទទួលរងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដូចជា គ្រោះរាំងស្ងួតនៅដើមរដូវនិងចុងរដូវវស្សា កង្វះខាតទឹកនៅរដូវប្រាំង និងគ្រោះទឹកជំនន់ដែលធ្វើឱ្យផ្ទៃដីដាំដុះ ទិន្នផលមធ្យមប្រចាំឆ្នាំ និងបរិមាណផលស្រូវសរុប មានការថយចុះធៀបនឹងឆ្នាំ២០១៨-២០១៩។

ការរក្សាបាននូវស្ថានភាពល្អប្រសើរខាងលើ គឺដោយសារការផ្តល់សេវាបណ្តុះបណ្តាលនិងផ្ទេរបច្ចេកទេសទំនើប ការប្រើប្រាស់ធាតុចូលកសិកម្មកាន់តែល្អប្រសើរ និងកំណើនយន្តូបនីយកម្មកសិកម្ម (ផ្ទៃដីភ្ជួររាស់ដាំដុះដំណាំស្រូវដោយគ្រឿងយន្តកសិកម្មបានកើនឡើងចំនួន ២% ការប្រើប្រាស់ត្រាក់ទ័រកើនឡើង ៤% និងគោយន្តកើនឡើង៦% ធៀបនឹងឆ្នាំ២០១៨) និងអន្តរាគមន៍ទាន់ពេលវេលារបស់រាជរដ្ឋាភិបាល តាមរយៈប្រព័ន្ធស្បៀងបម្រុងកម្ពុជា។ អនុវត្តផលិតកម្មគ្រាប់ពូជស្រូវមានគុណភាពល្អសរុបបានចំនួន ៥ ៦២២,៩០តោន ក្នុងនោះគ្រាប់ពូជចុះបញ្ជីបានចំនួន ១២៥,២០តោន និងគ្រាប់ពូជវិញ្ញាបនបត្របានចំនួន ៥ ៤៩៧,៧០តោន។

លើសពីនេះ ប្រព័ន្ធស្បៀងបម្រុងកម្ពុជាបានបញ្ចេញគ្រាប់ពូជស្រូវសរុបចំនួន១ ១៥២តោន ដើម្បីស្តារការខូចខាតដំណាំស្រូវចំនួន ១១ ៩៨៨ហិកតា នៅក្នុងខេត្តចំនួន៩ ដែលរងគ្រោះដោយគ្រោះរាំងស្ងួត និងទឹកជំនន់ដោយមានអ្នកទទួលផលសរុបចំនួន ១៥ ៦៤១គ្រួសារ។

**ក្រាហ្វិកៈ បង្ហាញពីកំណើនបរិមាណផល និងទិន្នផលនៃផលិតកម្មដំណាំស្រូវឆ្នាំ២០១៥-២០១៩**




## ខ. ផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៩-២០២០

នៅឆ្នាំ២០១៩ ផ្ទៃដីផលិតកម្មដំណាំសាកវប្បកម្មសម្រេចបានចំនួន ៩៤ ៥៤១ហិកតា លើសឆ្នាំមុនចំនួន ៩ ១៩៦ហិកតា ស្មើនឹង១១% ក្នុងនោះផ្ទៃដីដាំដុះរដូវវស្សាមានចំនួន ៥៦ ៩១៥ហិកតា និងផ្ទៃដីដាំដុះរដូវប្រាំងមានចំនួន ៣៧ ៦២៦ហិកតា។ បរិមាណផលសរុបទទួលបានចំនួន ៨៧៩ ៦៩៦តោន លើសឆ្នាំមុនចំនួន ៨២ ១៣៧តោន ដែលក្នុងនោះបរិមាណផលដំណាំសាកវប្បកម្មរដូវវស្សាមានចំនួន ៥១២ ៧០១តោន និងបរិមាណផលដំណាំសាកវប្បកម្មរដូវប្រាំងមានចំនួន ៣៦៧ ១២០តោន។ ផលិតកម្មដំណាំសំខាន់ៗរួមមាន ដំណាំបន្លែអនុវត្តលើផ្ទៃដីចំនួន ៥៧ ២៦២ហិកតា ទទួលបានបរិមាណផលចំនួន ៦៨២ ០១២តោន ដំណាំស្វាយអនុវត្តលើផ្ទៃដីចំនួន ១២៤ ៣១៩ហិកតា ទទួល

បានបរិមាណផលចំនួន ១ ៤៤៨ ៦៧៧តោន ដំណាំមៀនប៉ៃលិនអនុវត្តលើផ្ទៃដីចំនួន ១៤ ៤២២ហិកតា ទទួលបានបរិមាណផលចំនួន ១៤៤ ៧៦២តោន ដំណាំចេកអនុវត្តលើផ្ទៃដីចំនួន ៣៥ ១១១ហិកតា ទទួលបានបរិមាណផលចំនួន ៦១៥ ៤៧៨តោន ដំណាំស្រកានាគអនុវត្តលើផ្ទៃដីចំនួន ៧៩៩ហិកតា ទទួលបានបរិមាណផលចំនួន ១០ ៥៧៤តោន។

នាពេលបច្ចុប្បន្ននេះ ផលិតកម្មដំណាំបន្លែ និងឈើហូបផ្លែបាននិងកំពុងមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ តាមរយៈការបញ្ចូលបច្ចេកទេសទំនើបទៅក្នុងប្រព័ន្ធផលិតកម្មដូចជា ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពប្រព័ន្ធដំណក់ ប្រព័ន្ធបាចសាច និងផ្ទះសំណាញ់ ដើម្បីបង្កើនផលិតកម្មមួយដែលកាន់តែមានភាពប្រកួតប្រជែងទាំងគុណភាព និងសុវត្ថិភាព។ ជាក់ស្តែងក្នុងឆ្នាំ២០១៩ គ្រួសារកសិករសរុបចំនួន ២ ០០០គ្រួសារ បានបំពាក់នូវប្រព័ន្ធស្រោចស្រពដំណក់ទឹក ផ្ទះសំណាញ់ចំនួន ៦៥កន្លែង ត្រូវបានសាងសង់នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ពិពិធកម្មកសិកម្មកប់ស្រូវ និងក្នុងខេត្តគោលដៅទាំងប្រាំបី និងបានជ្រើសរើសកែលម្អតូបលក់បន្លែសុវត្ថិភាពចំនួន ១៦កន្លែង។ លើសពីនេះទៀត បានជ្រើសរើសក្រុមកសិករផលិតបន្លែសុវត្ថិភាពចំនួន ៦៤ក្រុម ដើម្បីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាពជាមួយក្រុមហ៊ុន។

**ក្រាហ្វិកៈ បង្ហាញពីកំណើនផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៥-២០១៩**




**គ. ផលិតកម្មដំណាំឧស្សាហកម្មឆ្នាំ២០១៩-២០២០**

ផ្ទៃដីផលិតកម្មដំណាំឧស្សាហកម្មសម្រេចបានចំនួន ៩៦៤ ៦៤៧ហិកតា ក្នុងនោះ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរដូវវស្សាមានចំនួន ៨៨៥ ៣៧៣ហិកតា និងដំណាំឧស្សាហកម្មរដូវប្រាំងមានចំនួន ៧៩ ២៧៤ហិកតា។ បរិមាណផលដំណាំឧស្សាហកម្មសរុបទទួលបានចំនួន ១៥ ១៣៩ ៦៧២តោន ថយជាងឆ្នាំមុនចំនួន ៧០៨ ១៣១តោន ដែលបរិមាណផលរដូវវស្សាមានចំនួន ១៤ ២៧៧ ៩២១តោន និងបរិមាណផលរដូវប្រាំងមានចំនួន ៨៦១ ៧៥១តោន។ ជាការកត់សម្គាល់ក្នុងនោះ ផ្ទៃដីដាំដុះដំណាំដំឡូងមីសម្រេចបានចំនួន ៦៥៦ ៨៦៨ហិកតា ដោយទទួលបានបរិមាណផលចំនួន ១៣ ៥១២ ៧៥៥តោន ដំណាំស្វាយចន្ទីបានចំនួន ២២៨ ៣០៨ហិកតា ដោយទទួលបានបរិមាណផលចំនួន ២០៨ ៧៦៩តោន និងដំណាំពោតក្រហមបានចំនួន ២០០ ០៣៦ហិកតា ដោយទទួលបានបរិមាណផលចំនួន ៨៩៥ ៤៣៦តោន សម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ។

**ក្រាហ្វិកៈ បង្ហាញពីស្ថានភាពផលិតកម្មដំណាំឧស្សាហកម្មឆ្នាំ២០១៥-២០១៩**



### ឃ. ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលដំណាំកសិកម្ម

ការយកចិត្តទុកដាក់លើបញ្ហាសុវត្ថិភាពស្បៀង និងសុខភាពជូនប្រជាពលរដ្ឋ បានចាប់ផ្តើមជាមួយនឹងការបង្កើតឱ្យមានកម្មវិធីវិធានការចម្រុះគ្រប់គ្រងដំណាំ (National IPM Programme) នៅក្នុងឆ្នាំ១៩៩៣។ ការអនុវត្ត IPM ដែលមានគោលបំណងជួយកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្មនៅក្នុងប្រព័ន្ធផលិតកម្ម បានជួយថែរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី/ក្សេត្របរិស្ថាន និងលើកកម្ពស់សុវត្ថិភាពស្បៀង។ ក្នុងពេលបច្ចុប្បន្ននេះ កិច្ចខិតខំប្រឹងប្រែងបន្ថែមដើម្បីលើកកម្ពស់សុវត្ថិភាពស្បៀងកំពុងត្រូវបានជំរុញតាមរយៈការអនុវត្តប្រព័ន្ធផលិតកម្មធានាសុវត្ថិភាពស្បៀង មានដូចជា៖ ការអនុវត្តកសិកម្មល្អសម្រាប់បន្លែនិងផ្លែឈើ និងការអនុវត្តកសិកម្មសរីរាង្គ។ គិតត្រឹមដំណាច់ឆ្នាំ២០១៩ កសិដ្ឋានដាំដុះបន្លែចំនួន៥១កសិដ្ឋាន ត្រូវបានចុះបញ្ជីជាកសិដ្ឋានអនុវត្តកសិកម្មល្អ (CamGAP)។

ការវិនិយោគកន្លងមកនេះ បានធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានគួរកត់សម្គាល់ក្នុងវិស័យកសិកម្ម ដែលបានប្រែក្លាយកម្ពុជាពីប្រទេសដែលជួបប្រទះបញ្ហាឱនភាពស្បៀង មកជាប្រទេសដែលសម្រេចបានសន្តិសុខស្បៀងនៅក្នុងឆ្នាំ១៩៩៥ ហើយបច្ចុប្បននេះជាប្រទេសដែលមានអតិរេកផលិតផលកសិកម្មរាប់លានតោនក្នុងមួយឆ្នាំៗសម្រាប់បម្រើឱ្យឧស្សាហកម្មកែច្នៃក្នុងស្រុក និងសម្រាប់ការនាំចេញ។ ជាក់ស្តែងក្នុងឆ្នាំ២០១៩កន្លងមកនេះ កម្ពុជាសម្រេចបានការនាំចេញផលិតផលកសិកម្មសរុបប្រមាណជាង ៦,៩លានតោន មានតម្លៃប្រមាណជាង ១ ៩៥០លានដុល្លារអាមេរិក។ ដោយឡែក ការនាំចេញផលិតផលដំណាំកសិកម្មផ្លូវការឆ្នាំ២០១៩ (កត់ត្រាដោយប្រព័ន្ធភូតគាមអនាម័យជាតិ) សម្រេចបានចំនួន ៤ ៨៧៦ ៩៥៣តោន កើនឡើងប្រមាណ ១៣,២០% ធៀបនឹងការនាំចេញសម្រេចបានក្នុងឆ្នាំ២០១៨។

ការនាំអង្ករចេញក្នុងឆ្នាំ២០១៩ សម្រេចបានចំនួន ៦២០ ១០៦តោន ទៅកាន់ទិសដៅ៥៩ប្រទេស ក្នុងនោះការនាំចេញទៅប្រទេសចិនបានច្រើនជាងគេគឺ ២៤៨ ១០៥តោន ស្មើនឹង៤០,៧៣% ទៅសហគមន៍អឺរ៉ុប (២៥ប្រទេស) បានចំនួន ២០២ ៩៩០តោន ស្មើនឹង៣២% ទៅប្រទេសក្នុងតំបន់អាស៊ាន (៦ប្រទេស) បានចំនួន ៨៣ ១៦៤តោន ស្មើនឹង១៣,៤១% និងទៅ២៧ប្រទេសផ្សេងៗទៀតបានចំនួន ៨៥ ៨៤៧តោន ស្មើនឹង១៣,៨៤% នៃការនាំចេញអង្ករសរុប។ ទោះបីបរិមាណនាំចេញអង្ករក្នុងឆ្នាំ២០១៩ មានការថយចុះបន្តិច (-0,៩%) ក៏ដោយក៏បរិមាណនាំចេញអង្ករក្រអូបគ្រប់ប្រភេទមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលទំហំនៃការនាំចេញមានចំនួន ៥៣១ ៦៤៨តោន ស្មើនឹង៨៥,៧៤% គឺកើនលើសឆ្នាំមុនចំនួន ៣៨ ០៥១តោន ហើយអង្ករសចម្រុះមានចំនួនតែ ៨១ ២៩១តោន ស្មើនឹង១៣,១១% និងអង្ករចំហុយចំនួនតែ ៧ ១៦៧តោន ស្មើនឹង១,១៦% នៃការនាំចេញអង្ករសរុប។ កំណើននៃបរិមាណនាំចេញអង្ករក្រអូប បានបង្ហាញអំពីការទទួលស្គាល់នូវគុណភាពល្អ ពិសេសរបស់អង្ករក្រអូបកម្ពុជាដោយទីផ្សារអន្តរជាតិ និងម៉្យាងទៀតបានបញ្ជាក់អំពីការរីកចម្រើននៅក្នុងឧស្សាហកម្មស្រូវ អង្ករកម្ពុជា ដែលបាននិងកំពុងពិពិធកម្មផ្តោតលើមុខទំនិញមានឧត្តមភាពប្រៀបធៀប ដែលជាបច្ច័យមួយជួយឱ្យកម្ពុជាអាចបង្កើតបាននូវឧត្តមភាពប្រកួតប្រជែងពិតប្រាកដរបស់ខ្លួន នៅក្នុងឧស្សាហកម្មកែច្នៃនាំចេញអង្ករនៅក្នុងទីផ្សារអន្តរជាតិនាពេលខាងមុខ។ លើសពីនេះ ការនាំចេញស្រូវក្រៅផ្លូវការមានចំនួន ២ ១៥៥ ១០២តោន នៅក្នុងឆ្នាំ២០១៩នេះ។

ការនាំចេញផលិតផលសំខាន់ៗក្រៅពីអង្កររួមមាន៖ ចំណិតដំឡូងមីក្រៀមបានចំនួន ១ ៦២៦ ១៦៥តោន ដំឡូងមីស្រស់បានចំនួន ១ ៦០៨ ៤៥០តោន ម្សៅដំឡូងមីបានចំនួន ៥៦ ៨៧៤តោន គ្រាប់ស្វាយចន្ទីបានចំនួន ២០២ ៣១៨តោន ផ្លែចេកស្រស់បានចំនួន១៥៧ ៨១២តោន គ្រាប់ពោតបានចំនួន១១៩ ៩៩៣តោន សណ្តែកបាយបានចំនួន ៩ ៣៧០តោន សណ្តែកសៀងបានចំនួន ៥៧ ២៥០តោន ម្ទេសស្រស់បានចំនួន ៥៥ ៥១៣តោន ម្រេចបានចំនួន ៣ ៦៩៣តោន និងផ្លែស្វាយស្រស់បានចំនួន ៥៨ ១៦២តោន និងដំណាប់ស្វាយបាន ចំនួន ២ ៧១២ តោន។

ក្រៅពីនេះ យើងបានចរចាបើកទីផ្សារ និងពង្រីកទំហំនៃការនាំចេញផលិតផលដំណាំសំខាន់ៗបន្ថែមទៀតរួមមាន៖ (១)ទីផ្សារប្រទេសចិន៖ បានចុះបញ្ជីបន្ថែមម៉ាស៊ីនកិនស្រូវចំនួន១៨ទៀត ដើម្បីពង្រីកសមត្ថភាពនាំចេញ

អង្ករបន្ថែមទៅកាន់ប្រទេសចិន បានចុះបញ្ជីសហគ្រាសផលិត កែច្នៃ និងវេចខ្ចប់ផលិតផលផ្លែចេកស្រស់ចំនួន ៩ សហគ្រាស កំពុងដំណើរការចរចាពិធីសារស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញផ្លែស្វាយស្រស់ និងផ្លែមៀនប៉ៃលិន ទៅកាន់ទីផ្សារប្រទេសចិន និង(២) ទីផ្សារប្រទេសកូរ៉េ៖ បានបញ្ចប់ពិធីសារស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យ និងចុះបញ្ជីសហគ្រាសនាំចេញផ្លែស្វាយស្រស់ទៅកាន់សាធារណរដ្ឋកូរ៉េ ការនាំចេញផ្លែស្វាយស្រស់លើកទីមួយទៅកាន់ទីផ្សារប្រទេសកូរ៉េបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០កន្លង មកនេះ។ (៣)ទីផ្សារប្រទេសថៃ៖ បានចាប់ផ្តើមនីតិវិធីចរចាបើកទីផ្សារសម្រាប់ផ្លែមៀនប៉ៃលិន។

**ក្រាហ្វិក៖ បង្ហាញពីស្ថានភាពនៃការនាំចេញកសិផលសរុប និងការនាំចេញអង្ករផ្លូវការឆ្នាំ២០១៥-២០១៩**




ការវិភាគគុណភាព ជីវសុវត្ថិភាព និងប្រសិទ្ធភាពធាតុចូលកសិកម្មដូចជា ពូជដំណាំ ជីកសិកម្ម ថ្នាំកសិកម្ម សំណាកដី និងកាកសំណល់ថ្នាំកសិកម្ម សរុបបានចំនួនសំណាក ៣ ៧២៨សំណាក ដោយទទួលបានចំណូលចំនួន ៩០១ ៥៤២ ០០០ រៀល គឺកើនឡើង៦,៧១% ធៀបនឹងចំណូលឆ្នាំ២០១៨។

**ង. ការចងក្រង និងចុះបញ្ជីសហគមន៍កសិកម្ម**

ក្នុងឆ្នាំ២០១៩ សហគមន៍កសិកម្មចំនួន៧៤សហគមន៍ត្រូវបានបង្កើត ហើយនៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន ១ ១៩០សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៤០ ០៩១នាក់ ក្នុងនោះមានសមាជិកនារីចំនួន ៨៧ ៨៩២នាក់ ហើយមានប្រាក់ភាគហ៊ុនសរុបចំនួនជាង ៤០ ៧៧៣លានរៀល ស្មើនឹងជាង ១០លានដុល្លារអាមេរិក និងដើមទុនសរុបចំនួនជាង ៩១ ០៨៤លានរៀល ស្មើនឹងជាង ២២,៧លានដុល្លារអាមេរិក។ ក្នុងចំណោមសហគមន៍កសិកម្មទាំង ១ ១៩០ មានសហគមន៍កសិកម្មចំនួន ១៦៥សហគមន៍បានធ្វើអាជីវកម្មចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ក្នុងនោះរួមមាន ការផលិតស្រូវក្រអូប (៩៣សហគមន៍) ស្រូវសរីរាង្គ (៤៣សហគមន៍) បន្លែសុវត្ថិភាព (១៦សហគមន៍) ដំឡូងមី (៩សហគមន៍) ម្រេច (២សហគមន៍) ស្ករត្នោត (១សហគមន៍) និងសណ្តែកខៀវ (១សហគមន៍)។

ក្រៅពីនេះ យើងបានចងក្រងសហគមន៍កសិកម្មទៅជាសហភាពសហគមន៍កសិកម្ម ដែលបច្ចុប្បន្នទូទាំងប្រទេសមានសហភាពសហគមន៍កសិកម្មសរុបចំនួន១០ ដែលមានសមាជិកជាសហគមន៍កសិកម្មចំនួន ១៦៨ និងមានដើមទុនសរុបចំនួនជាង ១ ៦៤១លានរៀល។ ជាពិសេសជាងនេះទៀត យើងបានបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលជារចនាសម្ព័ន្ធចាត់តាំងកំពូលរបស់សហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មនៅកម្ពុជា។

**ក្រាហ្វិក៖ បង្ហាញពីកំណើនចំនួនសហគមន៍កសិកម្មឆ្នាំ២០០៣-២០១៩**




## ច. ការគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្ម

**ការទប់ស្កាត់ការធ្លាក់ចុះគុណភាពដី៖** បានធ្វើការវាយតម្លៃការហូរច្រោះដី និងការបាត់បង់សារធាតុចិញ្ចឹមនៅលើចម្ការដំណាំរបស់កសិករចំនួន២០កន្លែង ស្ថិតនៅឃុំរស្មីសង្ហារ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ដោយប្រៀបធៀបកម្រិតនៃការហូរច្រោះដីលើដំណាំពោតដែលដាំដុះតាមទម្លាប់របស់កសិករ (ភ្ជួរដីចំនួន២-៣ដង គ្មានដំណាំគម្របដី) និងតាមបច្ចេកទេសកសិកម្មអភិរក្ស (ភ្ជួរដីចំនួន១ដង មានដំណាំគម្របដីដែលត្រូវបានកិនគ្របដី) ក្នុងកម្រិតជម្រាល៣-៥%។ លទ្ធផលបឋមបានបង្ហាញថា ការដាំដុះតាមទម្លាប់របស់កសិករ បង្កឱ្យមានការហូរច្រោះដីខ្លាំងជាងការដាំដុះតាមគោលការណ៍កសិកម្មអភិរក្ស ហើយកម្រិតនៃការហូរច្រោះដីអាស្រ័យនឹងកម្រិតជម្រាល។ ក្នុងកម្រិតជម្រាល៥% ការហូរច្រោះដីមានប្រមាណជា ៤២ត/ហត ចំពោះការដាំតាមទម្លាប់កសិករ រីឯការដាំតាមគោលការណ៍កសិកម្មអភិរក្សមានចំនួនតែ៣ត/ហតប៉ុណ្ណោះ។ ចំពោះកម្រិតនៃការហូរច្រោះដីនៅជម្រាល៣% នៅមានកម្រិតទាបខ្លាំងមិនគួរឱ្យកត់សម្គាល់ទេ (៤-១០ត/ហត) (ក្រាហ្វិក/Figure 1.2)។ ការដាំដំណាំតាមគោលការណ៍កសិកម្មអភិរក្សដូចចែងក្នុងពិសោធន៍នេះបានជួយកាត់បន្ថយការហូរច្រោះដីយ៉ាងច្រើន ទោះក្នុងកម្រិតជម្រាលណាក៏ដោយ។ យោងតាមលទ្ធផលនៃការស្រាវជ្រាវរយៈពេល៩ឆ្នាំក្នុងស្រុករតនៈមណ្ឌលបានបង្ហាញថា គោលការណ៍កសិកម្មអភិរក្សជួយកែលម្អសុខភាពដីនិងគុណភាពដី ដោយបានបង្កើនបរិមាណសារធាតុសរីរាង្គកាបូនក្នុងដីបាន ៣៣% និងបរិមាណអាសូត(N)ក្នុងដីបាន៥៥% ចំណែងកម្រិតជ្រាបទឹកចូលក្នុងដីបានកើនឡើងប្រហែល២ដង។ ដូច្នេះការដាំដុះដំណាំតាមគោលការណ៍កសិកម្មអភិរក្សមានផលប្រយោជន៍ល្អខ្លាំងជាងការដាំតាមទម្លាប់កសិករ។



**បម្រែបម្រួលការប្រើប្រាស់ដីកសិកម្ម៖** បានធ្វើការវាយតម្លៃអំពីការប្រែប្រួលការប្រើប្រាស់ដីកសិកម្មនៅក្នុងខេត្តកំពង់ចាមក្នុងរយៈពេល១៥ឆ្នាំ (២០០២-២០១៧)។ ក្រោយពីការបែងចែកជាពីរខេត្តនេះ មានក្រឡាផ្ទៃសរុបចំនួន ៤៥៤ ៩០២ហិកតា។ ការសិក្សានេះបានរកឃើញថា ក្នុងកំឡុងឆ្នាំ២០០២-២០១៧ ការប្រើប្រាស់ដីកសិកម្មនៅក្នុងខេត្តកំពង់ចាមមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់គឺកើនឡើង១៩% ចំណែកឯក្រឡាផ្ទៃគម្របព្រៃឈើមានការថយចុះ៨% វាលស្មៅបានថយចុះ៣% និងគម្ពោតព្រៃបានថយចុះ១១%។ កំណើនផ្ទៃដីប្រើប្រាស់ក្នុងវិស័យកសិកម្មភាគច្រើនគឺដីដាំដំណាំដំឡូងមី ស្វាយចន្ទី និងស្រូវ (តារាង១)។

តារាង១: បម្រែបម្រួលការប្រើប្រាស់ដីកសិកម្មនៅក្នុងខេត្តកំពង់ចាម (២០០២–២០១៧)។

សម្គាល់៖ LUC – Land Use Change (បម្រែបម្រួលការប្រើប្រាស់ដី), Ha – hectare។

| ល.រ | ក្រឡាផ្ទៃការប្រើប្រាស់ដី (ហ.ត) | ប្រភេទប្រើប្រាស់ដី | បម្រែបម្រួលការប្រើប្រាស់ដី (%) |
|---|---|---|---|
| 1 | 86849.08 | ដីកសិកម្ម | 19 |
| 2 | -37620.01 | គម្របដីព្រៃឈើ | -8 |
| 3 | -15094.88 | វាលស្មៅ | -3 |
| 4 | -47820.93 | ព្រៃគុម្ពោត | -11 |
| 5 | -1639.93 | ដីនិងថ្ម | 0 |
| 6 | -70.84 | ទីប្រជុំជន | 0 |
| 7 | 15397.50 | ផ្ទៃទឹក | 3 |

**ការអង្កេតនិងចាត់ថ្នាក់ដីកសិកម្ម៖** បានចុះអង្កេតលក្ខណៈរូបរបស់ដី និងចាត់ថ្នាក់ក្រុមដីបានចំនួន១៥លើកសរុបមាន១៥៨ចំណុច នៅភូមិចំនួន១៣៩ ឃុំ/សង្កាត់ចំនួន៧១ និងក្រុង/ស្រុកចំនួន៨ ក្នុងខេត្តកំពង់ធំ និងបានធ្វើផែនទីចំណាត់ថ្នាក់ដី(១៖៥០០ ០០០)សម្រាប់ខេត្តកំពង់ធំរួចរាល់ជាស្ថាពរ។ ដីក្នុងខេត្តកំពង់ធំប្រមាណជា៧០% ជាដីខ្សាច់ឬល្បាយខ្សាច់ដែលស្ថិតក្នុងក្រុមដីប្រទះឡាងនិងព្រៃខ្មែរ ហើយជាប្រភេទដីដែលមានសក្តានុពលដីជាតិទាប (Acrisols)។



### ឆ. ការពិសោធន៍ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម

- បានដាំដុះបន្សុទ្ធប្រភេទពូជស្រូវប្រពៃណីចំនួន០៣ពូជ គឺពូជស្រូវកេន ពូជស្រូវម៉ាការី និងពូជស្រូវក្រសាំងទៀប សម្រាប់ផលិតជាគ្រាប់ពូជគ្រឹះ ដើម្បីផ្សព្វផ្សាយក្នុងឆ្នាំ២០២០។
- សហការជាមួយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក្រោមការគាំទ្រថវិកាពីកម្មវិធី CAVAC បញ្ចេញប្រភេទពូជស្រូវថ្មីមួយឈ្មោះ "**សែនក្រអូប០១**" ដែលជាប្រភេទពូជស្រូវក្រអូប អង្ករបាយឆ្ងាញ់ និងកំពុងពេញនិយមនៅលើទីផ្សារក្នុងស្រុកក៏ដូចជាអន្តរជាតិសម្រាប់កសិករប្រើប្រាស់។
- បានបង្កាត់និងបញ្ចេញប្រភេទពូជពោតអ៊ីប្រ៊ីតសម្រាប់ផលិតចំណីសត្វ **CHM01 (Cambodia Hybrid Maize 01)** ចំនួន១ពូជ សម្រាប់កសិករប្រើប្រាស់ ដែលនេះជាពូជពោតអ៊ីប្រ៊ីតលើកទី១ សម្រាប់ប្រទេសកម្ពុជា។
- បាននិងកំពុងប្រមូលប្រភេទពូជដំណាំសាកវប្បកម្មដែលមានវត្តមាននៅកម្ពុជាចំនួន ៦៨ប្រភេទ សម្រាប់ដាំដុះវាយតម្លៃចរិតលក្ខណៈនិងអភិរក្ស ក្នុងនោះរួមមានដំណាំបន្លែចំនួន ២៣ប្រភេទ ដំណាំគ្រឿងទេសចំនួន ៧ប្រភេទ ដំណាំឈើហូបផ្លែចំនួន ១៥ប្រភេទ និងរុក្ខជាតិលម្អចំនួន ២៣ប្រភេទ។
- បានប្រមូលពូជដំណាំឧស្សាហកម្ម១៣៥ពូជ ក្នុងនោះមានពូជដំឡូងមី ២៦ប្រភេទ ពូជមន ២៧ប្រភេទ និងពូជដង្កូវនាង ៤ប្រភេទ (Golden Silk ពូជភ្នំស្រុក A&B និង CK174) ពូជកប្បាស ៥៦ប្រភេទ ពូជសណ្តែកបាយ១០ប្រភេទ ពោតក្រហម ៥ប្រភេទ ពោតស១ប្រភេទ ស្វាយចន្ទី ៥ប្រភេទ សណ្តែកសៀង ៤ប្រភេទ និងម្រេច១ប្រភេទ។
- បានធ្វើសមូហកម្មពូជដោយបានថែរក្សា ផលិត និងវាយតម្លៃធនធានសេនេទិចដំណាំសរុបចំនួន ៣៣៥ ពូជ មានដូចជា៖ ដំណាំធញ្ញជាតិ ដំណាំគម្របដី ដំណាំចំណីសត្វសម្រាប់បំពេញសេចក្តីត្រូវការក្នុងការស្រាវជ្រាវ និងការផ្សព្វផ្សាយដល់កសិករប្រើប្រាស់ក្នុងការបង្កើនជីជាតិ និងធ្វើពិពិធកម្មដំណាំក្នុងប្រព័ន្ធដាំដុះកសិកម្ម។
- បានធ្វើពិសោធន៍ស្រាវជ្រាវ និងវាយតម្លៃលើវិធានការការពារដំណាំ និងភូតគាមអនាម័យដូចជាការពិសោធន៍ជីវសុវត្ថិភាពថ្នាំកសិកម្ម។
- បានចុះសិក្សានិងអង្កេតតាមដាន ព្រមទាំងប្រមូលសំណាកនៃសមាសភាពចង្រៃលើដំណាំ និងឃ្លាំងស្តុកកសិផល ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីសមាសធាតុចង្រៃលើដំណាំដូចជា ម្រេច មៀនប៉ៃលិន ចេក ស្វាយចន្ទី ស្វាយ ស្រកានាគ។ល។ បានកំណត់អត្តសញ្ញាណកម្មសមាសភាពចង្រៃសំខាន់ៗដូចជា ពពួកដង្កូវហ្វូងប្រភេទថ្មី (Fall Army Worm-FAW) ជំងឺស្រពោនស្លឹកលើដំណាំចេក (Fusarium Wilt) និងសមាធាតុចង្រៃលើដំណាំម្រេចមានសត្វល្អិតចំនួន៥ប្រភេទ និងជំងឺ៥ប្រភេទ ពួកដង្កូវស៊ីរូងដើម និងមូសតែលើ ដំណាំស្វាយចន្ទី ជំងឺច្រេះស្លឹកលើដំណាំសណ្តែកបាយ ពពួករុយចោះស្វាយលើដំណាំស្វាយ និងខ្ទួតលើអង្ករ ១០ប្រភេទ។

### ជ. ការងារបណ្តុះបណ្តាលបច្ចេកទេសកសិកម្មក្នុងអនុវិស័យដំណាំ

បានបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសកសិកម្ម មន្ត្រីផ្សព្វផ្សាយកសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មម្ចាស់កសិដ្ឋាន និងកសិករគំរូ និងសហគមន៍កសិកម្មសរុបចំនួន ២១ ៦២៧នាក់ ក្នុងនោះស្ត្រីចំនួន ៦ ៦៤៩នាក់ អំពីបច្ចេកទេសកសិកម្មថ្មីៗទំនើប ការគ្រប់គ្រងកសិដ្ឋាន ការត្រួតពិនិត្យគុណភាពនិងផលិតពូជដំណាំ បង្ហំបច្ចេកទេសដំណាំស្រូវ ដំណាំសាកវប្បកម្ម ដំណាំឧស្សាហកម្ម វិធានការចម្រុះគ្រប់គ្រងនិងថែរក្សាជីជាតិដី កសិកម្មអភិរក្ស វិធានការចម្រុះគ្រប់គ្រងដំណាំ កសិកម្មវៃឆ្លាតនឹងអាកាសធាតុ ការអនុវត្តកសិកម្មល្អ កសិកម្មសរីរាង្គ សុវត្ថិភាព និងជីវសុវត្ថិភាពប្រើប្រាស់ថ្នាំកសិកម្ម វិធានការការពារដំណាំ អនាម័យនិងភូតគាមអនាម័យ ផលិតភាពនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់គ្រឿងយន្តកសិកម្ម ប្រព័ន្ធបច្ចេកវិទ្យាស្រោចស្រពទំនើប ការគ្រប់គ្រងនិងធ្វើអាជីវកម្មក្នុងសហគមន៍កសិកម្ម និងការគ្រប់គ្រងស្ថិតិដំណាំ។

ចងក្រង បោះពុម្ព និងចែកចាយសន្ទានុក្រមសមាសភាពចង្រៃលើដំណាំសំខាន់ៗចំនួន ៧ ០០០ច្បាប់ សៀវភៅកត់ត្រាស្តីពីការអនុវត្តកសិកម្មល្អចំនួន១ ០០០ច្បាប់ ព្រឹត្តិបត្រឯកសារបច្ចេកទេសស្តីពីការគ្រប់គ្រងជំងឺម៉ូសាអ៊ិចលើដំណាំដំឡូងមី (Cassava Mosaic Disease) ចំនួន ១២ ០០០ច្បាប់ និងវីដេអូឃ្លីបបច្ចេកទេសគ្រប់គ្រងដង្កូវហ្វូងថ្មី (FAW) ចំនួន ២ ០០០ច្បាប់ បច្ចេកទេសគ្រប់គ្រងជំងឺស្រពោនស្លឹកចេកចំនួន ២ ០០០ច្បាប់ បច្ចេកទេសគ្រប់គ្រងសុវត្ថិភាពចំណីអាហារចំនួន ១០ ០០០ច្បាប់ ឯកសារបណ្តុះបណ្តាលស្តីពីកសិកម្មល្អចំនួន ២ ០០០ច្បាប់ ឯកសារបច្ចេកទេសស្តីពីសត្វល្អិត និងជំងឺលើដំណាំ៣០មុខចំនួន ២០ ០០០ច្បាប់ រៀបចំរូបសញ្ញាជាតិ និងស្ទីគ័រស្តីពីការអនុវត្តកសិកម្មល្អ និងឯកសារវីដេអូឃ្លីបគោលការណ៍ណែនាំស្តីពីការនាំចេញផ្លែស្វាយ និងផ្លែកចេកស្រស់ និងឯកសារបែបបទនៃការផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ០០០ច្បាប់ ។

**ឈ.ការពង្រឹងសមត្ថភាពអង្គភាពនិងសេវាគាំទ្រ**

ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តនានា ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់សម្រាប់បម្រើឱ្យអនុវិស័យដំណាំកសិកម្មដែលរួមមាន អនុក្រឹត្យស្តីពីការបង្កើត និងប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំ ចំណុះឱ្យអគ្គនាយកដ្ឋានកសិកម្ម ប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាពូជដំណាំ ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ ផែនការយុទ្ធសាស្ត្រពូជដំណាំ ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលកម្រងសេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍អនុវិស័យដំណាំកសិកម្មឆ្នាំ២០១៩-២០២៣។ ដោយឡែក ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តដែលកំពុងដំណើរការរៀបចំរួមមាន សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន និងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ សេចក្តីព្រាងប្រកាសស្តីពីវិធានកសិកម្មសរីរាង្គ និងរូបសញ្ញាជាតិសម្រាប់អនុវត្តក្នុងខ្សែច្រវាក់ផលិតកម្មស្ពៀង និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំសាកវប្បកម្ម។

**ញ. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ជាអង្គភាពជំនាញបានប្រមូល និងអភិរក្សប្រភេទពូជដំណាំកសិកម្ម បង្កើតប្រភេទពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃប្រភេទពូជដំណាំដែលបានបញ្ចេញ រួមទាំងផ្សព្វផ្សាយនូវពូជទាំងនោះ និងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ គ្រប់គ្រងសារធាតុចិញ្ចឹមដំណាំនិងជីជាតិដី ការពារ និងកម្ចាត់កត្តាចង្រៃមុនពេលនិងក្រោយពេលប្រមូលផល បណ្តុះបណ្តាលធនធានមនុស្ស រួមទាំងចងក្រង បោះពុម្ព និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ សៀវភៅ ព្រមទាំងឯកសារបច្ចេកទេស ជូនដល់អ្នកពាក់ព័ន្ធ និងកសិករទូទាំងប្រទេស។ ជាក់ស្តែងការងារជាច្រើនត្រូវបានអនុវត្ត ហើយខាងក្រោមនេះគឺជាសមិទ្ធផលសំខាន់ៗ៖

១- **ការអភិរក្សប្រភេទពូជដំណាំកសិកម្ម៖** បានប្រមូលប្រភេទពូជដំណាំថ្មីៗទៀតចំនួន២៩៩សំណាកមករក្សាទុក ព្រមទាំងបានដាំវាយតម្លៃនិងកំណត់លក្ខណៈពូជបន្លែ០៤មុខ បានសរុបចំនួន ១៧៨សំណាក។ ជារួមគិតត្រឹមដំណាច់ឆ្នាំ២០១៩នេះ ពូជដំណាំចំនួន៣៨មុខ ដែលសរុបទាំងអស់មានចំនួន ៩ ១១១បញ្ជិត/សំណាក បានអភិរក្សនៅក្នុងធនាគារពន្ធុរបស់ CARDI។

២- **បញ្ចេញប្រភេទពូជស្រូវ សែនក្រអូប០១៖** បានបញ្ចេញប្រភេទពូជស្រូវចំនួន០១ពូជ ដែលជាឯកត្តៈជម្រើសចេញពីក្រុមប្រភេទពូជសែនក្រអូប ហើយដែលត្រូវបានគណៈកម្មការបញ្ចេញប្រភេទពូជដំណាំដាក់ឈ្មោះថា សែនក្រអូប០១។ សែនក្រអូប០១ ជាប្រភេទពូជស្រូវស្រាលមិនប្រកាន់រដូវ មានអាយុកាលជាមធ្យម១០៥ថ្ងៃ (ព្រោះ) និង១១៥ថ្ងៃ (ស្ទូង) គ្រាប់អង្ករសថ្លា មានបណ្តោយ៧,១៥មម បទ្ទារ១,៩៥មម អាមីឡូស១៦% ផ្តល់ទិន្នផលមធ្យម ៣,៩ត/ហត និងអាចដល់ ៥,៨ត/ហត ហើយមានក្លិនក្រអូបស្រាល។ ប្រភេទពូជស្រូវនេះ មិនមានលក្ខណៈធន់ទ្រាំទៅនឹងជំងឺ និងសត្វល្អិតចង្រៃឡើយ។

៣- **ការងារបង្កាត់ពូជស្រូវ៖** បានជ្រើសរើសឯកត្តៈនៃពូជស្រូវដំណើបខ្មៅចំនួន១០សម្រាប់ធ្វើការជ្រើសរើសបន្ត បានជ្រើសរើសកូនបង្កាត់ជំនាន់ទី២ ដែលបានមកពីការបង្កាត់រវាងប្រភេទពូជផ្ការំដួលជាមួយរាំងជ័យ និងខា

១១ ចំនួនប្រមាណ១៥០ និងបានដាំតាមដានស្រឡាយស្រូវដើម្បីអភិវឌ្ឍន៍រកពូជដែលធន់នឹងការជ្រុះគ្រាប់ ធន់នឹងទឹកជំនន់ និងពូជដែលមានសក្តានុពលផលខ្ពស់ និងគុណភាពល្អជាងមួយពាន់ស្រឡាយ។

៤- **ប្រភេទពូជស្រូវធន់ទ្រាំទៅនឹងជំងឺខ្នារអំបោះត្នោត៖** បានធ្វើការវិភាគតាមជីវបច្ចេកវិទ្យា (DNA) លើប្រភេទពូជស្រូវ ដែលបានបញ្ចេញដោយ CARDI ចំនួន៣១ និងឃើញថាមានប្រភេទពូជស្រូវចំនួន២១ធន់ទ្រាំល្អទៅនឹងជំងឺ និង១០ទៀតធន់ទ្រាំមធ្យម។

៥- **បង្កើតផែនទីក្រុមដីដាំដុះស្រូវចំនួន០២ស្រុក៖** បានធ្វើការសិក្សាវាយតម្លៃធ្វើចំណាត់ថ្នាក់ដីដាំដុះស្រូវ និងផលិតផែនទីក្រុមដីរបស់ស្រុកបារាយណ៍ និងស្រុកតាំងគោកខេត្តកំពង់ធំ។ ឯកសារព័ត៌មានលម្អិត និងផែនទីទាំងពីរនឹងត្រូវបោះពុម្ពផ្សាយក្នុងរបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំ២០១៩។ ទន្ទឹមនឹងនេះ បានចុះសិក្សានិងវាយតម្លៃចំនួន៦៦ប្រូហ្វីលដីនៅខេត្តចំនួនបី និងបានបញ្ចូលព័ត៌មានប្រូហ្វីលដីចំនួន៦៦កន្លែងនេះ ទៅក្នុងប្រព័ន្ធទិន្នន័យគ្រឹះនៃដី ហើយដែលជាសរុបមានចំនួន ២ ០៤៤ទីតាំង។







៦- **ការផ្លាស់ប្តូរទម្លាប់របស់កសិករក្នុងផលិតកម្មស្រូវ៖** លទ្ធផលនៃការអង្កេតជាមួយកសិករក្នុងខេត្តចំនួន៦-១១ (២៥០គ្រួសារ/ខេត្ត) រយៈពេលជាច្រើនឆ្នាំបានបង្ហាញថា តម្លៃពលកម្មប្រចាំថ្ងៃជាមធ្យមបានកើនពី៣ ៥០០រៀល ក្នុងឆ្នាំ២០០៣ ទៅ ៧ ៨០០រៀលក្នុងឆ្នាំ២០០៨ និង ១៧ ២០០រៀលក្នុងឆ្នាំ២០១៥ រួចបន្តកើនឡើងជាលំដាប់រហូតដល់ ២២ ២០០រៀលក្នុងឆ្នាំ២០១៨ ទន្ទឹមនឹងអត្រាប្តូរប្រាក់មានការប្រែប្រួលបន្តិចបន្តួចក្នុង១ដុល្លារអាមេរិកគឺពី ៣ ៩០០ រៀលក្នុងឆ្នាំ២០០៣ ទៅ ៤ ០៥០រៀលក្នុងឆ្នាំ២០១៨។ ជាមួយគ្នានេះ ការភ្ជួររាស់បានផ្លាស់ប្តូរទៅប្រើគ្រឿងយន្តដែលមាន៥៣%ក្នុងឆ្នាំ២០០៣ ទៅ ៨៨%ក្នុងឆ្នាំ២០១៥ និងបន្តកើនដល់៩៩%ក្នុងឆ្នាំ២០១៨។ ការច្រូតកាត់ដោយប្រើម៉ាស៊ីនកំបៃបានកើនឡើងយ៉ាងខ្លាំងក្នុងប្រមាណ១០ឆ្នាំចុងក្រោយនេះ ដែលក្នុងឆ្នាំ២០០៣ មិនមានការប្រើប្រាស់ ទៅប្រើប្រាស់៦០%ក្នុងឆ្នាំ២០១៥ និងកើនដល់៨៩%ក្នុងឆ្នាំ២០១៨។

**ក្រាហ្វិក១៤. បម្រែបម្រួលតម្លៃពលកម្ម ការប្រើប្រាស់គ្រឿងយន្តភ្ជួររាស់ដី និងច្រូតកាត់ស្រូវ**




វិធីសាស្ត្រដាំដុះមានការប្រែប្រួលពីស្ទូងមកព្រោះយ៉ាងខ្លាំងក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ពិសេសសម្រាប់ស្រែវស្សាដែលកើនពីព្រោះ២៥%ក្នុងឆ្នាំ២០០៩ ទៅដល់៨៨%ក្នុងឆ្នាំ២០១៨។ ស្រូវដើមរដូវវស្សាមានការកើនពី

៨១%ក្នុងឆ្នាំ២០១០ ទៅដល់៩៨%ក្នុងឆ្នាំ២០១៨ ហើយស្រូវប្រាំងបានកើនពី៩៣%ក្នុងឆ្នាំ២០០៩ ដល់ទៅ១០០% ក្នុងឆ្នាំ២០១៨។

**ក្រាហ្វិក១៥. និន្នាការដាំដុះស្រូវដោយពង្រោះសម្រាប់ស្រូវវស្សា ប្រាំង ដើមរដូវវស្សា និងមធ្យមរយៈពេល១០ឆ្នាំ**




**៧- ប្រសិទ្ធភាពនៃការប្រើប្រាស់កំបោរលើដំណាំស្ពៃខៀវ និងស្ពៃតឿនៅក្រុមដីស្រែប្រទះឡាងបន្ទាប់ពីប្រមូលផលស្រូវវស្សា៖** ការមិនប្រើប្រាស់កំបោរកសិកម្ម (CaCO3) ជាទូទៅបន្លែទទួលបានទិន្នផលមធ្យមទាប ដោយដំណាំស្ពៃខៀវទទួលបាន ២៣,៧ត/ហ.ត និងដំណាំស្ពៃតឿទទួលបាន ២៥,៧ត/ហ.ត។ ចំណែកការប្រើប្រាស់កម្រិតជីតាមទម្លាប់កសិករ (N=204, $P_2O_5$=108, $K_2O$=81) ដោយមិនដាក់កំបោរកសិកម្ម ទទួលបានទិន្នផលទាបជាងគេ គឺស្ពៃខៀវបាន២២,៥ត/ហ.ត និងស្ពៃតឿបាន ១៨,៥ត/ហ.ត (តារាង១ខ)។ ការប្រើប្រាស់ជីតាមកម្រិតណែនាំ (N=200, $P_2O_5$=93, $K_2O$=240) ដោយមិនដាក់កំបោរកសិកម្ម ធ្វើឲ្យទិន្នផលស្ពៃខៀវកើនដល់ ២៤,៦ត/ហត និងស្ពៃតឿដល់ ២៥,៧ត/ហ.ត (៦ខ)។ ការបន្ថែមកំបោរកសិកម្មក្នុងកម្រិត២ត/ហត ធ្វើឲ្យទិន្នផលស្ពៃខៀវកើនដល់២៧,៩ត/ហត និងស្ពៃតឿ៣១,៦ត/ហត។

**តារាង១. ទិន្នផលពិសោធន៍កំបោរ (៦ក) និងពិសោធន៍ជីបូកកំបោរ (៦ខ) លើដំណាំស្ពៃខៀវនៅខេត្តកំពត និងស្ពៃតឿនៅខេត្តសៀមរាប ឆ្នាំ២០១៨-២០១៩**

| ក) បរិមាណកំបោរ | ទិន្នផលមធ្យម (ត/ហត) | | ខ) ការប្រើប្រាស់ជី និងកំបោរ (CaCO3) | ទិន្នផលមធ្យម (ត/ហត) | |
|---|---|---|---|---|---|
| (CaCO3) (ត/ហត) | ស្ពៃខៀវ | ស្ពៃតឿ | | ស្ពៃខៀវ | ស្ពៃតឿ |
| 0.0 | 23.7 | 25.7 | កម្រិតជីកសិករ + គ្មានកំបោរ | 22.5 | 18.5 |
| 0.5 | 28.4 | 29.6 | កម្រិតជីកសិករ + កំបោរ២ត/ហត | 24.6 | 25.7 |
| 1.0 | 29.9 | 36.0 | កម្រិតជីណែនាំ + គ្មានកំបោរ | 24.8 | 21.5 |
| 2.0 | 27.4 | 41.1 | កម្រិតជីណែនាំ + កំបោរ២ត/ហត | 27.9 | 31.6 |

**៨- ការប្រើប្រាស់ជី NPK ធ្យូងអង្កាម និងពេលវេលាស្រោចស្រពទឹកលើទិន្នផលពោតអឺប្រ៊ីដ៖** លទ្ធផលពិសោធន៍ចំនួន៣កន្លែង ជារួមបានបង្ហាញថា ក). កសិករប្រើប្រាស់ជីក្នុងកម្រិត N=180, $P_2O_5$=109, $K_2O$=54 គក្រ/ហ.ត ខ្ពស់ជាងកម្រិតណែនាំរបស់វិទ្យាស្ថានកាឌីដែលមានត្រឹមតែ N=135, $P_2O_5$=90, $K_2O$=45 ប៉ុណ្ណោះ ខ). ការប្រើប្រាស់ជីច្រើនតាមទម្លាប់កសិករ មិនបានជួយឲ្យកើនទិន្នផលពោតឡើយនៅពេលស្រោចទឹក៥ថ្ងៃម្តង តែផ្ទុយទៅវិញផលពោតបានទាបជាងការប្រើប្រាស់ជីតាមកម្រិតណែនាំនៅពេលស្រោចទឹក៧ថ្ងៃម្តង គ).ការស្រោចស្រពរយៈពេល៧ថ្ងៃម្តងធ្វើឲ្យពោតផ្តល់ផលច្រើនជាងការពន្យារពេលស្រោចស្រព២ថ្ងៃនៅពេលប្រើប្រាស់តែជីគីមីសុទ្ធ និងគ). ការបន្ថែមធ្យូង

អង្កាម៥ត/ហតទៅលើកម្រិតជីទាំងពីរ បានជួយបង្កើននូវទិន្នផលពោតពី២,៤ ទៅ៥,៦% នៅពេលស្រោចស្រពរៀងរាល់៧ថ្ងៃម្តង ប៉ុន្តែប្រសិទ្ធភាពនេះបានកើនរហូតដល់១៤,៨ ទៅ២៧,៥% នៅពេលស្រោចស្រព៩ថ្ងៃម្តង។

ក្រាហ្វិក១៦. ទិន្នផលពោតអ៊ីប្រ៊ីតទទួលបានពីការប្រើប្រាស់ជីគីមី (NKP) តាមកសិករ (FFP) និងតាមកម្រិតណែនាំរបស់វិទ្យាស្ថានកាឌី (CRF) និងជីគីមី+ធ្យូងអង្កាម (៥ត/ហត) (NPK+BC) ក្រោមរបបទឹកស្រោចស្រព៧ថ្ងៃម្តង (7d) និង៩ថ្ងៃម្តង (9d)




**៩- ពិពិធកម្មដំណាំមានស្រូវវស្សាជាមូលដ្ឋានលើក្រុមដីប្រទះឡាង៖** តាមលទ្ធផលសិក្សាបង្ហាញបញ្ជាក់ថា ក). ក្នុងរដូវវស្សាកសិករដាំដុះប្រភេទពូជស្រូវផ្ការំដួលទទួលបានប្រាក់ចំណេញដុល៩៥៥ដុល្លារ/ហត ខ)ក្នុងករណីមានទឹកស្រោចស្រពបន្ថែម កសិករអាចធ្វើស្រូវដើមរដូវវស្សាបន្ថែមពីលើស្រូវវស្សា ដោយប្រើប្រាស់ប្រភេទពូជសែនក្រអូប និងអាចទទួលបានប្រាក់ចំណេញសរុបទាំងពីររដូវបាន ១ ៨៥៨ដុល្លារ/ហ.ត គ). ក្នុងករណីមានទឹកស្រោចស្រពបន្ថែមតិចតួចកសិករអាចដាំដំណាំឆៃថាវ ឪឡឹក និងសណ្តែកបាយ ដែលមានអាយុកាលខ្លី និងត្រូវការទឹកតិច ក្នុងរដូវប្រាំងបន្ទាប់ពីប្រមូលផលស្រូវវស្សាហើយភ្លាម។ ក្នុងដំណាំទាំងបីមុខនេះ ដំណាំឆៃថាវអាចឲ្យកសិករទទួលប្រាក់ចំណេញដុលសរុបជាមួយស្រូវវស្សា ឬជាមួយស្រូវដើមរដូវវស្សាបានច្រើនជាងគេ គឺអាចបានពី៥ ៣៥១ ដល់៥ ៤០២ដុល្លារ/ហ.ត និងឃ). ក្នុងករណីមានទឹកស្រោចស្រពគ្រប់គ្រាន់ ការដាំឆៃថាវក្នុងរដូវប្រាំង ដាំស្រូវសែនក្រអូបក្នុងដើមរដូវវស្សា និងដាំស្រូវផ្ការំដួលក្នុងរដូវវស្សា អាចឲ្យកសិករទទួលបានប្រាក់ចំណូលសរុបប្រចាំឆ្នាំចំនួនជិត៨ ៥០០ដុល្លារ និងទទួលប្រាក់ចំណេញដុលរហូតដល់ ៦ ៣០៦ដុល្លារ/ហត/ឆ្នាំ។

**តារាង២. ទិន្នផល ចំណាយ ចំណូល និងចំណេញដុលរបស់ឆៃថាវ ឪឡឹក សណ្តែកបាយ និងស្រូវក្នុងរដូវផ្សេងៗ និងពិពិធកម្មដំណាំលើផ្ទៃដីមួយហិកតាក្នុងមួយឆ្នាំនៃក្រុមដីប្រទះឡាង**

| រដូវ | ប្រភេទដំណាំ | ទិន្នផល | ចំណាយ | ចំណូល | ចំណេញដុល (ដុល្លារ/ហត) | | | | |
|---|---|---|---|---|---|---|---|---|---|
| | | (គក្រ/ហត) | (ដុល្លារ/ហត) | (ដុល្លារ/ហត) | មួយរដូវ | ប្រាំង+ដើមរដូវវស្សា | ប្រាំង+ វស្សា | ដើមរដូវវស្សា+វស្សា | ប្រាំង+ដើមរដូវវស្សា+វស្សា |
| | ឆៃថាវ | 39,375 | 1,459 | 5,906 | **4,447** | **5,351** | **5,402** | | **6,306** |
| ប្រាំង | ឪឡឹក | 15,620 | 1,285 | 1,562 | **277** | **1,181** | **1,232** | | **2,136** |
| | សណ្តែកបាយ | 700 | 720 | 1,050 | **330** | **1,234** | **1,285** | | **2,189** |
| ដើមរដូវវស្សា | ស្រូវសែនក្រអូប | 5,218 | 401 | 1,305 | **904** | | | **1,858** | |
| វស្សា | ផ្ការំដួល | 4,249 | 320 | 1,275 | **955** | | | | |

**១០- ការអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ៖** បានធ្វើទិវាស្រែចំនួន១៣លើកមានកសិករចូលរួម៦០៤នាក់ (នារី ៦២%) បណ្តុះបណ្តាលកសិករចំនួន៤៥លើកមានកសិករចូលរួម១ ៨០០នាក់ (នារី៥២%) និងវគ្គបណ្តុះបណ្តាលជំនាញនៅ CARDI ចំនួន៥លើក មានសិក្ខាកាមចូលរួម១៥១នាក់ (នារី២១%)។ បោះពុម្ពឯកសារចំនួន

៣០ ៣៤០ច្បាប់និងបែងចែកឯកសារសរុបចំនួន ១៩ ៨៩៣ច្បាប់។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់ CARDI តាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ១ ០៥៧ ៣៨៣នាក់ គិតជាមធ្យមចំនួន ២ ៩០៥នាក់/ថ្ងៃ លើសឆ្នាំ២០១៨ ចំនួន៨៧៤នាក់/ថ្ងៃ (៤៣%)។ ជាមួយនោះ បានផ្តល់ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវនូវគ្រាប់ពូជគ្រឹះផ្ការំដួល និងដំណើបស្បៃមង្គលចំនួន៤តោន ថ្វាយព្រះមហាក្សត្រចែកជូនប្រជាជននាពិធីច្រត់ព្រះនង្គ័ល បានចែកគ្រាប់ពូជគ្រឹះចំនួន៤៧៥គក្រនៃពូជស្រូវផ្កាមាលតីជូនដល់អគ្គនាយកដ្ឋានកសិកម្ម និងគ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ជូនអតិថិជនចំនួន២,៦តោន និងបានចែកគ្រាប់ពូជស្រូវជូនកសិករចំនួន៣៤០គ្រួសារនៅខេត្តត្បូងឃ្មុំ ឧត្តរមានជ័យ តាកែវ និងព្រៃវែងសរុប ១,៧តោន សម្រាប់ផលិតក្នុងរដូវវស្សា និងរដូវទឹកស្រកឆ្នាំនេះទុកជាគ្រាប់ពូជសម្រាប់ប្រើប្រាស់ឆ្នាំបន្ទាប់ ដោយក្នុងរដូវវស្សានេះកសិករចំនួន២១០គ្រួសារនៅខេត្តត្បូងឃ្មុំ និងឧត្តរមានជ័យផលិតបានគ្រាប់ពូជសរុបចំនួន៣៣តោន។ CARDI បានផលិតគ្រាប់ពូជស្រូវសរុបចំនួន៦៤តោន និងបានលក់ជូនអតិថិជនចំនួន៨,៥តោន។

### ដ. ការងារគ្រប់គ្រងសម្ភារកសិកម្ម

**ដ.១ ការងារគ្រប់គ្រងសម្ភារកសិកម្ម៖** ឆ្នាំ២០១៩នេះ ក្រសួងបានផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មសរុបចំនួន២៣៥ក្រុមហ៊ុន ក្នុងនោះការចុះបញ្ជិកាថ្នាំកសិកម្មបានចំនួន ៩៥ក្រុមហ៊ុន សរុបចំនួន ១ ៥១៥មុខ ការចុះបញ្ជិកាជីកសិកម្មបានចំនួន ១៤០ក្រុមហ៊ុន សរុបចំនួន ១ ១៩៦មុខ។ ទន្ទឹមនឹងនេះ ការផ្តល់លិខិតអនុញ្ញាតសុំនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២២៦ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុននាំចូលថ្នាំកសិកម្មមានចំនួន ៦១ក្រុមហ៊ុន ក្រុមហ៊ុននាំចូលជីកសិកម្មចំនួន ១០៧ក្រុមហ៊ុន ក្រុមហ៊ុននាំចូលថ្នាំកសិកម្ម និងជីកសិកម្មមានចំនួន ៥៨ក្រុមហ៊ុន។

**តារាងលទ្ធផលស្តីពីការផ្តល់លិខិតអនុញ្ញាតសុំនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម៖**

| ការនាំចូលតាមខែ | ថ្នាំកសិកម្ម | ជីកសិកម្ម |
|---|---|---|
| មករា | ៣.០១១,០០០ តោន | ២២០.១៩៤,៩៦០ តោន |
| កុម្ភៈ | ៨.០៧៩,២០០ តោន | ១៦២.៩៥៣,០២១ តោន |
| មីនា | ៥.២៥០,០០០ តោន | ៦៤.៣២៦,៥០០០ តោន |
| មេសា | ៤.៤៥១,៤០០ តោន | ៧៨.៩២៨,០០០ តោន |
| ឧសភា | ៦.៥៧៩,០០០ តោន | ៧៣.៤៦៥,០០០ តោន |
| មិថុនា | ៩.៧១៦,២២០ តោន | ៨៣.៨៩០,០០០ តោន |
| កក្កដា | ១២.៥៤៨,០២០ តោន | ៦៩.៥២៥,៥០១ តោន |
| សីហា | ៦.៥៨៧,០០០ តោន | ១០៧.៨០២,២៥០ តោន |
| កញ្ញា | ៩.៦២៥,០០៩ តោន | ៦០.០៥៣,០៣២២ តោន |
| តុលា | ៥.២៩៥,០៣៥ តោន | ៤៥.១២២,០០០ តោន |
| វិច្ឆិកា | ៥.៩៥២,០០០ តោន | ១៣៣.៩៧០,០០០ តោន |
| ធ្នូ | ៤.០០៤,០០០ តោន | ៤៩.៣៨៥,០០០ តោន |
| សរុបប្រចាំឆ្នាំ២០១៩ | ៨១.០៩៧,៨៨៤០ តោន | ១.១៤៩.៦១៥,២៦៤២ តោន |

ចំពោះការផ្តល់លិខិតអនុញ្ញាតសុំនាំចេញមានចំនួន០២ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុននាំចេញថ្នាំកសិកម្មចំនួន០១ក្រុមហ៊ុន ស្មើនឹង៥០០តោន និងក្រុមហ៊ុននាំចេញជីកសិកម្មចំនួន០១ក្រុមហ៊ុន ស្មើនឹង៦០០តោន។

### តារាងប្រៀបធៀបការអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចាប់ពីឆ្នាំ២០១៦ ដល់២០១៩៖

| ឈ្មោះសម្ភារកសិកម្ម | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ |
|---|---|---|---|---|
| ថ្នាំកសិកម្ម | ៤១ ៦៤៩,២ តោន និង ១០៩ គីឡូក្រាម | ៥៣ ៤៨៥, ២៤២ តោន | ៦១ ៥៣៧,៧២៩ តោន | ៨១ ០៩៧,៨៨៤០ តោន |
| ជីកសិកម្ម | ៩៩០ ៩១៩,៣៩៧ តោន | ៨៤២ ៧០៦, ៦២ តោន | ១ ០៨៤ ២៣៩,៧១៦តោន | ១ ១៤៩ ៦១៥,២៦៤២ តោន |

### ៤.២ ការងារផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង៖

- បានរៀបចំកិច្ចប្រជុំស្តីពីស្ថានភាពជាក់ស្តែងការធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប ក្រោមអធិបតីភាព **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានអ្នកចូលរួមសរុបចំនួន១៥៤នាក់។
- បានរៀបចំសិក្ខាសាលាស្តីពីនីតិវិធីស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មដែលបានប្រព្រឹត្តទៅពីថ្ងៃទី១២-១៣ ខែកញ្ញា ឆ្នាំ២០១៩ នៅសណ្ឋាគារស្ទឹងសង្កែរ ខេត្តបាត់ដំបង ក្រោមអធិបតីភាព ឯកឧត្តម **ឡោ រស្មី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមពីពាណិជ្ជករថ្នាំកសិកម្ម និងជីកសិកម្មចំនួន១២០នាក់។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តកំពត តាកែវ កំពង់ស្ពឺ រតនគិរី ស្ទឹងត្រែង បន្ទាយមានជ័យ ក្រចេះ ឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ មណ្ឌលគិរី ពោធិ៍សាត់ និងបាត់ដំបង ដែលមានអ្នកចូលរួមសរុបចំនួន៨៤៦នាក់។
- បានសហការជាមួយគម្រោង CAVAC រៀបចំសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីគោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មាន និងគំរូស្លាកសញ្ញាព័ត៌មាននៃថ្នាំកសិកម្ម ក្រោមអធិបតីភាពឯកឧត្តមថ្នាក់ដឹកនាំក្រសួងទទួលបន្ទុក ថ្នាក់ដឹកនាំនាយកដ្ឋាននីតិកម្មកសិកម្ម និងថ្នាក់ដឹកនាំនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ធំ បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ឆ្នាំង ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង មណ្ឌលគិរី និងតាកែវ សរុបអ្នកចូលរួមមានចំនួន ១ ១៨៦នាក់។
- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករលក់ដុំ លក់រាយថ្នាំកសិកម្ម និងជីកសិកម្ម បានចំនួន ០៨ខេត្ត គឺខេត្តសៀមរាប បន្ទាយមានជ័យ ព្រៃវែង កំពង់ធំ បាត់ដំបង ព្រះសីហនុ កំពត និងតាកែវ ដោយមានអ្នកចូលរួមសរុប២៩៦នាក់។

### ៤.៣ ការងារត្រួតពិនិត្យ និងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម៖

ក្រសួងបានធ្វើសំណើសុំចាត់បញ្ជូនមន្ត្រីជំនាញចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយរបស់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "នាយកដ្ឋាននីតិកម្មកសិកម្ម" បានចំនួន១០១ក្រុមហ៊ុន ស្មើនឹង ១២១លើក ក្នុងនោះ ក្រុមហ៊ុននាំចូលថ្នាំកសិកម្មសរុបចំនួន២៩លើក ក្រុមហ៊ុននាំចូលជីកសិកម្មសរុបចំនួន៦០លើក និងក្រុមហ៊ុននាំចូលថ្នាំកសិកម្ម។ ចំពោះជីកសិកម្ម សរុបចំនួន៣២លើក ដែលមានបរិមាណសរុប (១) ថ្នាំកសិកម្មសរុបចំនួន១ ០៣៤មុខ ស្មើនឹង ២១ ៩៣៣,៨៦ តោន និង (២) ជីកសិកម្មសរុបចំនួន៥៤៦មុខ ស្មើនឹង ២៣០ ០៤៩,៦១ តោន។

### ៨.៤ ការចុះអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្ម៖

ឆ្នាំ២០១៩ ក្រសួងបានចាត់ក្រុមការងារអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មឱ្យចុះទៅធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តគោលដៅសរុបចំនួន១៥ខេត្ត ស្មើនឹង១៨លើក រួមមានខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពត ខេត្តតាកែវ ខេត្តក្រចេះ និងខេត្តព្រៃវែង ដែលបានត្រួតពិនិត្យលើដេប៉ូសរុបចំនួន ១៣២ដេប៉ូ និង០១គ្រឹះស្ថានរបស់ក្រុមហ៊ុន និងបានសម្រេចពិន័យអន្តរកាលសរុបចំនួន១៣ករណី ស្មើនឹង ៣៦ ០០០ ០០០រៀល បង់ចូលថវិការដ្ឋ។ ជាមួយគ្នានេះ ក្រសួងបានធ្វើការសម្រេចពិន័យអន្តរការណ៍ជាប្រាក់ចំពោះក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម ដែលខកខានពុំបានប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចំនួន០៨ក្រុមហ៊ុន ស្មើនឹង០៨ករណី ដែលមានទឹកប្រាក់សរុបចំនួន ១១ ២០០ ០០០រៀល។

### ៨.៥ ការងារអភិវឌ្ឍន៍បទដ្ឋានគតិយុត្ត៖

បទដ្ឋានគតិយុត្តដែលបានសម្រេចជាធរមាន៖ (១) ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលកម្រងសេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២) ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលអត្រារង្វាន់លើកទឹកចិត្តលើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៣) ប្រកាសលេខ៣១៣ ប្រក.កសក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះ បទដ្ឋានគតិយុត្តដែលបានពុំទាន់ចូលជាធរមានរួមមាន (១)សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី "គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ (២) ថ្នាំកសិកម្មការបោះចោលសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម"។

## ៩. ការងារកសិ-ឧស្សាហកម្ម

ក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានកសិ-ឧស្សាហកម្ម បានដំណើរការការងាររបស់ខ្លួន ដោយសហការជាមួយស្ថាប័នក្រោមឱវាទក្រសួង និងក្រៅក្រសួង ព្រមទាំងធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដែលមានសកម្មភាព និងទទួលបានលទ្ធផលដូចខាងក្រោម៖

### ១. ការងាររៀបចំលិខិតបទដ្ឋានច្បាប់ និងគតិយុត្ត

ក្រសួងបាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០៣០ និងសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការស្នើសុំនិងចេញវិញ្ញាបនបត្របញ្ជាក់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ សេចក្តីព្រាងប្រកាសស្តីពីស្លាកសញ្ញាបញ្ជាក់ គុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍អនុវត្តអនាម័យល្អក្នុងវិស័យកសិកម្ម និងសេចក្តីព្រាងសារាចរ/ប្រកាសនីតិវិធីនៃការចុះបញ្ជីអ្នកប្រមូលទិញផលិតផលកសិកម្មនិងចំណីអាហារ។

### ២. ការងារស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

- បានជំរុញការលើកកម្ពស់យល់ដឹងពីគុណភាពសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម វិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីនៃការគ្រប់គ្រងបៃតងសម្រាប់អភិវឌ្ឍន៍កសិកម្ម ការគ្រប់គ្រងនិងបច្ចេកវិទ្យាកែច្នៃផលិតផលកសិកម្ម និងសុវត្ថិភាពចំណីអាហារ ឧស្សាហកម្មអាហារនិងអាហារឡើងមេ (CNRIFFI) សុវត្ថិភាពចំណីអាហារ និងបច្ចេកទេសខ្សែច្រវាក់ផលិតកម្មផលិតផលកសិកម្មទំនើប ការត្រួតពិនិត្យ និងគ្រប់គ្រងកាកសំណល់ថ្នាំពុលកសិកម្ម នៅក្នុងផលិតផលកសិកម្ម ការការពារការពុលមេតាណុល និង

សារធាតុគីមីផ្សេងៗទៀតនៅក្នុងផលិតផលស្រាស តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាចំនួន១២លើក ដែលមានអ្នកចូលរួមសរុបចំនួន ៥៣០នាក់

- បានត្រួតពិនិត្យឡើងវិញនូវវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅបន្តនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន អង្គការជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធចំនួន ១៨៧នាក់
- បានលើកកម្ពស់ការយល់ដឹងពីផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមរយៈការបណ្តុះបណ្តាលលើការអនុវត្តកិច្ចសន្យាពីផលិតកម្មដំណាំដំឡូងមីរវាងកសិករជាមួយក្រុមហ៊ុនហ្គ្រីនលីឌឺ (Green Leaders) ពីការផ្គត់ផ្គង់ស្ករត្នោតរវាងក្រុមហ៊ុនស៊ីកនេតឈ័រ អហ្វ អេស៊ា និងសហគមន៍កសិកម្មឈូកសាមគ្គីមានជ័យនៅខេត្តកំពង់ធំ និងសហគមន៍កសិកម្មត្នោតកំពង់ស្ពឺនៅខេត្តកំពង់ស្ពឺ ព្រមទាំងបានសហការជាមួយសហគមន៍ស្វាយចន្ទី VINACA ប្រទេសវៀតណាម ដើម្បីរៀបចំផែនការសកម្មភាព និងកំណត់ទីតាំងដែលត្រូវទទួលពូជស្វាយចន្ទី ២០ ០០០កូន។ ជាមួយគ្នានេះដែរ ក្រសួងក៏បានរៀបចំសេចក្តីព្រាងប្រកាសអំពីនីតិវិធីស្នើសុំ និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ
- បានចុះធ្វើការអប់រំផ្សព្វផ្សាយស្តីពីការការពារពុលមេតាណុល និងសារធាតុគីមីផ្សេងទៀត ក្នុងផលិតផលស្រាស ចុះប្រមូលនិងចងក្រងទិន្នន័យសហគ្រាសកែច្នៃផលិតផលកសិកម្ម ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារបស់កសិករ សហគមន៍ កសិកម្ម និងការដាំដំណាំដំឡូងមី ឯកសារបច្ចេកទេសក្រោយប្រមូលផល គោលការណ៍អនាម័យល្អក្នុងវិស័យកសិកម្ម
- បានចុះផ្សព្វផ្សាយ និងរៀបចំវេទិកាភ្ជាប់ទំនាក់ទំនងរវាងកសិករនឹងទីផ្សារចំនួន២៧លើក ដែលមានអ្នកចូលរួមសរុប ១ ៧២០នាក់។

### ៣. ការងារមន្ទីរពិសោធន៍

ក្នុងឆ្នាំ២០១៩នេះ ក្រសួងបានវិភាគរកកាកសំណល់ថ្នាំពុលកសិកម្មប្រភេទ Tricyclazole នៅក្នុងអង្ករចំនួន ១១សំណាក វិភាគរកវត្តមានសមាសភាព Organophosphate ដូចជា Acephate, Diazinon, Dimethoate, and Malathion នៅក្នុងបន្លែស្ពៃក្តោប ផ្កាខាត់ណា ប៉េងប៉ោះ សាឡាត និងត្រសក់ចំនួន១០សំណាក វិភាគរកវត្តមានមេរោគបង្កជំងឺក្នុងចំណីអាហារដូចជាៈ បាក់តេរីសរុប (Total Plate Count) បាក់តេរីអ៊ីកូឡាយ (E-Coli) បាក់តេរីសាល់ម៉ូណេឡា (Samonella spp) បាក់តេរីបង្កជំងឺក្នុងពោះវៀន (Enterobacteriaceae) នៅក្នុងសាច់ ស៊ុត ផលិតផលកែច្នៃ និងបន្លែ សរុបចំនួន៥០សំណាក។ ជាមួយគ្នានេះ ក៏បានវិភាគរកប្រូតេអ៊ីននៅក្នុងអង្ករ អាហារផ្អាប់ដូចជាៈ ផ្អកត្រី ប្រហុក កាពិ និងទឹកត្រីសរុបចំនួន ៣៧សំណាក វិភាគរកវត្តមានបូរ៉ាក់ ដោយប្រើតេស្តឃីត (Test Kit) នៅក្នុងសាច់ប៉ាតេ ប្រហិតសាច់គោ មីគីឡូ គុយទាវ សរសៃធំ និងអាហារផ្សេងទៀតចំនួន១៨សំណាក និងវិភាគរកមេតាណុល (Methanol) ក្នុងស្រាស និងស្រាសត្រាំថ្នាំចំនួន១០សំណាក។

### ៤. ការងារអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានរៀបចំបង្កើតអនុគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មនៅថ្នាក់រាជធានីខេត្តបានចំនួន ២៤រាជធានី/ខេត្ត
- បានកែសម្រួលសេចក្តីសម្រេចលេខ៤៨៩ សសរ.កសក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម
- បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុនមួយចំនួន ក្នុងគោលបំណងជួយជំរុញលើកទឹកចិត្តប្រជាកសិករ អ្នកវិនិយោគ និងអ្នកពាក់ព័ន្ធឲ្យយល់ដឹងពីផលប្រយោជន៍នៃការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម

- ឆ្នាំ២០១៩ មានសហគមន៍កសិកម្មចំនួន១០៨សហគមន៍ ក្រុមកសិករ សមាគមន៍ និងកសិករផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនធំៗចំនួន ៤៩៨កិច្ចសន្យា ដែលមាននៅក្នុងខេត្តចំនួន១៤ គឺខេត្តកំពង់ស្ពឺ ព្រះវិហារ ព្រៃវែង បាត់ដំបង កណ្តាល កំពង់ធំ សៀមរាប តាកែវ រតនៈគិរី បន្ទាយមានជ័យ ត្បូងឃ្មុំ ក្រចេះ ឧត្តរមានជ័យ និងប៉ៃលិន
- ប្រភេទផលិតផលសំខាន់ៗដែលបានចុះកិច្ចសន្យាមានដូចជា ស្រូវមាន១៤៤កិច្ចសន្យាក្នុងបរិមាណចំនួន ១២០ ៩៦៤,៥៨តោន ពោតមាន០៤កិច្ចសន្យាក្នុងបរិមាណ ៨៨៩,៨៤តោន បន្លែផ្លែឈើស្រស់មាន០៨កិច្ចសន្យាក្នុងបរិមាណ ១៦៩,៨២តោន សណ្តែកបាយមាន០១កិច្ចសន្យាក្នុងបរិមាណ ៧,៥ តោន ការចិញ្ចឹមមាន់សាច់មាន១៥៤កិច្ចសន្យាក្នុងបរិមាណ ៤ ៦៦៤,២៦៦តោន ការចិញ្ចឹមជ្រូកសាច់មាន១៤៣កិច្ចសន្យាក្នុងបរិមាណ ៣០ ៥០៣,២០តោន បន្លែមានចំនួន២៣កិច្ចសន្យា ក្នុងបរិមាណ ២ ៤៣០តោន សណ្តែកខៀវមាន០១កិច្ចសន្យាក្នុងបរិមាណ១០តោន ដំឡូងមីមាន១៨កិច្ចសន្យាក្នុងបរិមាណ ១០ ១៣៩ តោន និងស្ករត្នោតមាន០២កិច្ចសន្យាក្នុងបរិមាណ ១០៦តោន។




កៅស៊ូធម្មជាតិត្រូវបានដាំជាលើកដំបូងនៅកម្ពុជានាឆ្នាំ១៩១០ នៅស្រុកព្រៃនប់។ រហូតដល់ឆ្នាំ១៩២១ ទើបមានការដាំជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំដោយក្រុមហ៊ុនវិនិយោគធំៗរបស់បារាំង នៅក្នុងខេត្តកំពង់ចាម និងក្រចេះ។ មកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាត្រូវបានពង្រីកផ្ទៃដីជាង ៦៤ ០០០ហិកតា ក្នុងនោះផ្ទៃដីចៀរមានជាង ៣៩ ០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូបានជាង ៥០ ០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុក និងការនាំចេញទៅបរទេស។

កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រមួយប្រភេទដែលផ្តល់ប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិដល់សង្គមទាំងមូលនិងបរិស្ថាន ជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ និងមុខរបរមានស្ថិរភាពជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក ផ្តល់ឈើសម្រាប់ប្រើប្រាស់ផលិតគ្រឿងសង្ហារឹម ជាឈើតន្ទនៈ ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតង ដើម្បីចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាពិភពលោកដ៏ចម្បងមួយក្នុងពេលបច្ចុប្បន្ននិងពេលអនាគត។

**១. ផ្ទៃដីកៅស៊ូ**

នៅឆ្នាំ២០១៩នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤០៥ ៦៧១ហិកតា បើធៀបទៅនឹងឆ្នាំ២០១៨ ដែលមានចំនួន ៤៣៦ ៦៨២ហិកតា ថយចុះចំនួន ៣១ ០១១ហិកតា ស្មើនឹង៧%។ ការថយផ្ទៃដីនេះ ភាគច្រើនកើតមាននៅលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយក្រុមហ៊ុនមួយចំនួនផ្លាស់ប្តូរមុខដំណាំ ព្រោះដីមិនសមស្របនឹងដំណាំ

កៅស៊ូ និងក្រុមហ៊ុនមួយចំនួនទៀតគ្រប់គ្រងថែទាំកៅស៊ូមិនបានល្អ និងភ្លើងឆេះនៅរដូវប្រាំង។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺ៖ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន ២៤៤ ៥៦៨ហិកតា ស្មើនឹង៦០% និងកៅស៊ូគ្រួសារមានចំនួន ១៦១ ១០៣ហិកតា ស្មើនឹង៤០% នៃផ្ទៃដីកៅស៊ូសរុប។

**តារាងទី៦៖ ផលិតកម្មកៅស៊ូ២០១៥-២០១៩**

| ល.រ | ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩/២០១៨ (Δ%) |
|---|---|---|---|---|---|---|---|---|---|
| 1 | ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្ម | ពាន់ហ.ត | 239,1 | 278,2 | 280,2 | 275,6 | 244,6 | -11,2 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 149,9 | 154,5 | 156,1 | 161,1 | 161,1 | 0,0 |
| | | **សរុប** | **ពាន់ហ.ត** | **389,0** | 432,7 | 436,3 | 436,7 | 405,7 | -7,1 |
| 2 | ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្ម | ពាន់ហ.ត | 34,7 | 40,7 | 69,7 | 82,1 | 117,2 | 42,8 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 76,5 | 86,3 | 100,5 | 119,8 | 133,3 | 11,3 |
| | | **សរុប** | **ពាន់ហ.ត** | **111,2** | 127,0 | 170,2 | 201,9 | 250,5 | 24,1 |
| 3 | ផលិតផលកៅស៊ូ | កសិឧស្សាហកម្ម | ពាន់តោន | 39,3 | 43,5 | 83,6 | 90,6 | 135,0 | 49,0 |
| | | កៅស៊ូគ្រួសារ | ពាន់តោន | 87,6 | 101,6 | 109,7 | 129,5 | 152,6 | 17,8 |
| | | **សរុប** | **ពាន់តោន** | **126,9** | 145,2 | 193,3 | 220,1 | 287,6 | 30,7 |

### ២. ការងារផលិតកម្មកៅស៊ូ

ឆ្នាំ២០១៩នេះ៖ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន ២៥០ ៤៧៧ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៨ ដែលមាន ២០១ ៩៤៧ហិកតា កើនឡើងចំនួន ៤៨ ៥៣០ហិកតា ឬស្មើនឹង២៤,១%។ ផលិតផលកៅស៊ូសម្រេចបានចំនួន ២៨៧ ៦៣៨តោន ធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន ២២០ ១០០តោន គឺកើនឡើងចំនួន៦៧ ៥៣៨តោន ស្មើនឹង៣០,៦៩%។ ទិន្នផលមធ្យមមានចំនួន ១ ១៤៨គ.ក្រ./ហ.ត បើធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន១ ០៩០ គ.ក្រ/ហ.ត គឺកើនឡើងចំនួន ៥៨គ.ក្រ./ហ.ត. ស្មើនឹង៥,៣២%។

**ក្រាហ្វិក២០៖ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១៥-២០១៩**



## ៣. ការងារធុរកិច្ចកៅស៊ូ

ការនាំចេញកៅស៊ូឆ្នាំ២០១៩ សម្រេចបានចំនួន ២៨២ ០៧១តោន ស្មើនឹងទឹកប្រាក់ ៣៧៦ ៩៤២ ១៥១ ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៨ ដែលការនាំចេញមានចំនួន ២១៧ ៥០០តោន គិតជាទឹកប្រាក់សរុប ២៨៦ ៦០៨ ១១៧ ដុល្លារអាមេរិក គឺបរិមាណនាំចេញកើនឡើងចំនួន ៦៤ ៥៧១តោន ស្មើនឹង២៩,៦៩% និងប្រាក់ចំណូលកើនប្រមាណ ៩០ ៣៣៤ ០៣៤ដុល្លារអាមេរិក ស្មើនឹង៣១,៥២%។ តម្លៃកៅស៊ូនាំចេញជាមធ្យមថ្លៃ១ ៣៣៦,៣៤ដុល្លារអាមេរិក/តោន បើធៀបនឹងឆ្នាំ២០១៨ តម្លៃមធ្យមស្មើនឹង១ ៣១៧,៧៤ដុល្លារអាមេរិក/តោន ឃើញថា មានការកើនឡើងចំនួន១៨,៦ដុល្លារអាមេរិក/តោន ស្មើនឹង១,៤១%។

**ក្រាហ្វិក២១៖ ផលិតកម្មនិងការនាំកៅស៊ូចេញឆ្នាំ២០១៥-២០១៩**




នៅក្នុងឆ្នាំ២០១៩នេះ រោងចក្រ សិប្បកម្មកែច្នៃ ផលិតផលកៅស៊ូមានសរុបចំនួន១៥៥កន្លែង នៅក្នុងខេត្តចំនួន ១១ (កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ និងប៉ៃលិន) គឺកើនឡើងចំនួន៨កន្លែង ស្មើនឹង៥,៤៤% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ ដែលមានតែ១៤៧កន្លែង។ ក្នុងចំណោមរោងចក្រ សិប្បកម្មចំនួន១៥៥កន្លែង មានរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមបច្ចេកទេស (Technically Specified Rubber: TSR) ចំនួន៤៦កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹក (Rubber Sheet: RS) ៖ សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតមានផ្សែង (Ribbed smoked sheet: RSS) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (Air-dried sheet: ADS) មានចំនួន៩៧កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (Rubber Wood Factory: RWF) ចំនួន១១កន្លែង។

**ក្រាហ្វិក២២៖ ចំនួនរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូឆ្នាំ២០១៥-២០១៩**



**៤. ការងារផែនការ ហិរញ្ញវត្ថុ**

ចំណូលឆ្នាំ២០១៩ អនុវត្តបានចំនួន១ ២៧២ ៣០៦ ៥៧៦រៀល (៣១២ ១០៥ដុល្លារអាមេរិក) ក្នុងនោះ ការជួលដីក្រុមហ៊ុនទាំង០៧មានចំនួន ១ ១៤៧ ៧១៤ ៩១១រៀល (២៨៣ ៥៣៩ដុល្លារអាមេរិក) ប្រាក់ពិន័យមានចំនួន ២២ ១០៤ ៣៤៣រៀល (៥ ៤១១ដុល្លារអាមេរិក) និងការជួលអចលវត្ថុ (អសង្ហារឹម) ក្រុមហ៊ុននីហ័រណែអាហ័រណែកៅស៊ូចំនួន ៩៤ ០០៥ ២៥៦រៀល (២៣ ១៥៤ដុល្លារអាមេរិក)។ បើធៀបនឹងគោលដៅចំនួន១ ៤៨៣ ៥០០ ០០០រៀល (៣៦១ ៨២៩ដុល្លារអាមេរិក) មានការថយចុះចំនួន ២១១ ១៩៣ ៤២៤រៀល(៥១ ៥១០ដុល្លារអាមេរិក) ស្មើនឹង ១៤,២៤%។ ការថយចុះនេះដោយសារឆ្នាំនេះចម្ការកៅស៊ូឡាបានសៀកពុំទាន់បង់ប្រាក់ឈ្នួលឆ្នាំ២០១៩ មានចំនួន ១៧៥ ៨០០ ០០០រៀល។

**៥. ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលផ្នែកកៅស៊ូ**

ក្នុងគម្រោងថវិកាកម្មវិធីនៅក្នុងឆ្នាំ២០១៩នេះ បានចុះបើកវគ្គផ្សព្វផ្សាយ បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដូចជា៖

(១). ការបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ ចុះបើកវគ្គបណ្តុះបណ្តាលការបើកមុខចៀរដំបូង និងបច្ចេកទេសចៀរជ័រកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅខេត្តគោលដៅចំនួន០៧ខេត្ត ដោយមានកសិករចូលរួមសរុប៣៧៦នាក់ (ស្រី៩៩នាក់)។ វគ្គបណ្តុះបណ្តាលនេះ កសិករបានទទួលចំណេះដឹងទាំងមេរៀនទ្រឹស្តី និងការអនុវត្តចៀរជ័រលើដើមកៅស៊ូជាក់ស្តែងនៅនឹងកន្លែង សំដៅឲ្យការយកផលរបស់ពួកគាត់មានរយៈពេលយូរអង្វែង ទទួលបានទិន្នផលខ្ពស់ និងត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសចៀរជ័រកៅស៊ូ។

(២). ការងារផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ ចុះបើកវគ្គផ្សព្វផ្សាយ បច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅខេត្តគោលដៅទាំង១០ ដោយមានកសិករចូលរួមសរុប៤៨៩នាក់ (ស្រី១០០នាក់)។ កសិករដែលបានចូលរួមទទួលបានឯកសារមេរៀន និងស្តាប់ការធ្វើបទបង្ហាញរបស់វាគ្មិន និងឆ្លើយបំភ្លឺរាល់ចម្ងល់ និងសំនួរនានាតាមមេរៀននីមួយៗ ដើម្បីឲ្យកសិករអ្នកដាំកៅស៊ូ និងមានបំណងដាំកៅស៊ូទទួលបានចំណេះដឹងនេះយកទៅអនុវត្តលើការជ្រើសរើសពូជ ការងារដាំដុះនិងថែទាំ ការព្យាបាលជំងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស សំដៅឱ្យទទួលបានលទ្ធផលល្អ។

(៣). ការងារពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ ចងក្រងបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅខេត្តគោលដៅបានចំនួន០២សហគមន៍ រួមមានខេត្តសៀមរាប និងឧត្តរមានជ័យ។ ការបង្កើតសហគមន៍នេះដើម្បីលើកកម្ពស់អំណាចចរចាទីផ្សាររបស់ប្រជាកសិករ កាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្មរបស់ប្រជាកសិករជាសមាជិកសហគមន៍ ផលិតកសិផលឬផ្តល់សេវាកម្មណាដែលកសិករម្នាក់ៗមិនអាចធ្វើបាន ទទួលបានព័ត៌មានទីផ្សារ និងពង្រីកឱកាសទីផ្សារកសិផលរបស់កសិករ លើកកម្ពស់គុណភាពកសិផលឬផលិតផលរបស់កសិករ និងបង្កើនប្រាក់ចំណូលគ្រួសាររបស់កសិករជាសមាជិកសហគមន៍។ ជាមួយនោះ ការចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារបានចំនួន៦សហគមន៍ នៅខេត្តគោលដៅចំនួន០៦។

(៤). ការងារផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ បានចុះបើកវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូចំនួន១២លើក នៅខេត្តគោលដៅចំនួន ដែលមានប្រតិបត្តិករកៅស៊ូចូលរួមសរុបចំនួន៧០០នាក់។

(៥). ការងារបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល បានចុះបើកវគ្គសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោលចំនួន០១វគ្គ ដែលមានរយៈពេល០៣ថ្ងៃ នៅខេត្តព្រះវិហារ មានមន្ត្រីមកពីការិយាល័យកៅស៊ូតាមបណ្តាខេត្តចំនួន២៣ខេត្ត សរុបចំនួន៤១នាក់ (ស្រី១១នាក់)។ វគ្គបណ្តុះបណ្តាលនេះ សំដៅបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីកសិកម្មខេត្ត ឲ្យក្លាយជាមន្ត្រីបង្គោលលើជំនាញកៅស៊ូ និងក្លាយជាអ្នក

ផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូ ពិសេសកសិករកៅស៊ូគ្រួសារ ដើម្បីជំរុញអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព។

(៦). ការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការ និងនិយោជិតចម្ការកៅស៊ូកសិឧស្សាហកម្ម បានបើកវគ្គបណ្តុះបណ្តាល ស្តីពីស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិពិភពលោកដល់មន្ត្រីរាជការចំនួន០២លើក នៅខេត្តកំពត និងខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុប៨៨នាក់។ ជាមួយនោះ បានបើកវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំថវិកាកម្មវិធី" ចំនួន០១វគ្គ ដែលប្រព្រឹត្តទៅនៅខេត្តកំពង់ធំ ដោយមានការចូលរួមពីមន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ និងមន្ត្រីការិយាល័យកៅស៊ូតាមខេត្តសរុបចំនួន៤១នាក់។ ការបើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញដល់មន្ត្រីរាជការលើប្រធានបទ ព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងចំនួន០១លើក ដោយមានអ្នកចូលរួមសរុប៤៥នាក់។ វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយពី "ទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារ" បានចំនួន៧លើកនៅខេត្តគោលដៅចំនួន៧ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣៦៣នាក់។ បើកវគ្គបណ្តុះបណ្តាលធនធានមនុស្ស និងផ្ទេរនូវបច្ចេកវិទ្យាតាមរយៈការសម្របសម្រួលទស្សនកិច្ចសិក្សា ដឹកនាំសរសេរសារណាបញ្ចប់ការសិក្សារបស់និស្សិតចំនួន០៨នាក់ និងបានបញ្ជូនមន្ត្រីចំនួន៦នាក់ ទៅបង្រៀននិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

(៧). ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងតម្លៃកៅស៊ូ បានចុះបើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងផ្នែកកៅស៊ូ នៅស្រុកគោលដៅចំនួន០៩ក្នុង០៩ខេត្ត ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប៤៥០នាក់។ ជាមួយនោះ បានផ្សាយតម្លៃកៅស៊ូប្រចាំសប្តាហ៍តាមប៉ុស្តិ៍វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM103.5) នឹងបន្តផ្ទាល់ទៅតាមបណ្តាខេត្តចំនួន៤ នៅខេត្តបាត់ដំបង FM106.3 ខេត្តកំពង់ចាម FM99.3 ខេត្តកំពង់ធំ FM104 និងខេត្តសៀមរាប (FM107) បានចំនួន៤៨ដង (៤ដង/ខែ) ដើម្បីឱ្យកសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូក្តាប់បានតម្លៃកៅស៊ូលើទីផ្សារតាមតំបន់ក្នុងប្រទេស និងក្រៅប្រទេស។ បោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែបានចំនួន ២ ១៦០ច្បាប់ សម្រាប់ចែកជូនកសិករកៅស៊ូគ្រួសារ និងអ្នកពាក់ព័ន្ធក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងបន្ថែមអំពីអនុវិស័យកៅស៊ូ។

(៨). ការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដូចជា បានបញ្ជូនមន្ត្រីជំនាញចំនួន២៧នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុងស្រុកស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ មុខងារសាធារណៈ ជំរឿនកសិកម្ម យេនឌ័រ។ល។ បញ្ជូនមន្ត្រីចំនួន០១នាក់ទៅបន្តការសិក្សា និងវគ្គបណ្តុះបណ្តាលបច្ចេកទេសនៅក្រៅប្រទេសបានចំនួន៥នាក់ និងចូលរួមព្រឹត្តការណ៍សំខាន់ៗថ្នាក់អន្តរជាតិ ដែលទាក់ទងនឹងឧស្សាហកម្មកៅស៊ូធម្មជាតិ។

**៦. ការងារពិសោធស្រាវជ្រាវកៅស៊ូ**

ក្នុងឆ្នាំ២០១៩នេះ វសកក បានអនុវត្តនិងបន្តការងារស្រាវជ្រាវ និងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបមាន៦២ពិសោធន៍។ ការងារស្រាវជ្រាវ និងពិសោធន៍បានចូលរួមជំរុញការអភិវឌ្ឍលើគ្រប់ផ្នែកដំណាំកៅស៊ូ ទាំងផ្នែកបច្ចេកទេស សុរុវ្ឌិកម្មក្លូនកៅស៊ូ គុណភាពជ័រកៅស៊ូ និងតម្លៃផលិតកម្ម។ ក្នុងការបង្កើនផលិតភាពកៅស៊ូ វសកក បានយកចិត្តទុកដាក់ដល់ការស្រាវជ្រាវបង្កាត់ពូជកៅស៊ូសំដៅបង្កើតនូវក្លូនកៅស៊ូកម្ពុជា ដែលមានសក្តានុពលបន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានទិន្នផលខ្ពស់ និងលូតលាស់ល្អសមស្របនឹងលក្ខខណ្ឌបរិស្ថាននៃប្រទេសកម្ពុជា ការស្រាវជ្រាវសរីរវិទ្យា និងអាជីវកម្ម និងការស្រាវជ្រាវអំពីការដាំដុះនិងការពារ។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ វសកក បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ជាមួយគ្នានោះ បានបណ្តុះបណ្តាលនូវធនធានមនុស្សតាមរយៈការបង្ហាត់បង្រៀននិស្សិតនៅតាមគ្រឹះស្ថានសិក្សា និងសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សាចម្ការពិសោធន៍ និងការដឹកនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។

វសកក បាននិងកំពុងអនុវត្តលើការស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ រួមមាន៖ (១) ស្រាវជ្រាវបង្កាត់ពូជ តាមដាន និងវិភាគទិន្នន័យ បញ្ចូលទិន្នន័យគ្រប់ឡូតិ៍ពិសោធន៍ក្លូនទាំងនៅខាងក្នុងនិងខាងក្រៅស្ថានីយគ្រប់ចំនួន៦២ និងការថែទាំថ្នាលបណ្តុះកូនកៅស៊ូលើផ្ទៃដី០,៣៥ហិកតា (២) អនុវត្តការងារបំបៅកូនកៅស៊ូបានចំនួន៦៨ក្លូន និងថ្នាលបណ្តុះកូនកៅស៊ូថ្មីលើផ្ទៃដី០,៣៥ហិកតា (កាប់ចង្អូរនិងច្រកដីចូលក្នុងថង់ថ្នាលបណ្តុះកូនកៅស៊ូបានចំនួន៣៥០០០ថង់ និងដាក់គ្រាប់បណ្តុះក្នុងថង់សម្រាប់ថ្នាលបណ្តុះកូនកៅស៊ូចំនួន៣៥០០០ថង់) និងថែដំណាំគ្របដីចំនួន៣ប្រភេទនៅប្លុក៤២BNW រួមមាន Stylosanthes guiannsis, Mucuna aterrinum និងការដាក់ជីបំប៉នកូនកៅស៊ូចំនួន២ លើកលើផ្ទៃដីចំនួន៦៨,៥ហិកតា ព្រមទាំងបានបាញ់ថ្នាំព្យាបាលជំងឺផ្កាកុលាប នៅតាមប្រគៀបមែកកៅស៊ូចាប់ ពីអាយុ៣ឆ្នាំទៅ១០ឆ្នាំ បាន២ដងលើផ្ទៃដីចំនួន២១២ហិកតា (៣) ការស្រាវជ្រាវអំពីការដាំដុះ និងជំងឺ (ថែទាំដំណាំចន្លោះរងកៅស៊ូនៅប្លុក៥២CS ចំនួន៥ប្រភេទគឺ ចេក ខ្នុរ ស្វាយ ម្នាស់ ស្វាយចន្ទី និងកូនកៅស៊ូចម្ការពិសោធចំនួន៩០,២៥ហិកតា) ដោយតាមដាននិងប្រមូលទិន្នន័យនៃឥទ្ធិពលនៃដំណាំគម្រប ដំណាំចន្លោះរង ដី ដង់ស៊ីតេដាំ ប៉ារ៉ាម៉ែត្រក្សេត្របរិស្ថាន ទៅលើការលូតលាស់ និងទិន្នផលដើមកៅស៊ូ (៤) តាមដាន ស្រង់ បញ្ចូល និងវិភាគទិន្នន័យសរីរវិទ្យាទឹកជ័រ ចំនួន៨៤៨សំណាក និង (៥) ពិសោធន៍តាមដានទិន្នន័យក្លូនកៅស៊ូថ្មី ចំនួន១៧ក្លូន៖ ៥ក្លូនពីចម្ការកៅស៊ូ SOCFIN-KCDនិង១២ក្លូនពី RRI-CATAS (ប្រទេសចិន)។

វសកក បាននិងកំពុងអនុវត្តផ្នែកមន្ទីរពិសោធន៍យថាប្រភេទរួមមាន៖ (១).ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៣៦៨ភាគសំណាកដើម្បីសម្រាប់ធ្វើការវាយតម្លៃសមត្ថភាព និងគុណភាពកៅស៊ូបញ្ជាក់តាមបច្ចេកទេស (២). ការរៀបចំធ្វើតេស្ត និងរបាយការណ៍វិភាគលទ្ធផលនៃការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន សម្រាប់ធានាការទទួលស្គាល់ជាផ្លូវការ (៣). ធ្វើតេស្ត Round Robin ចំនួន២លើកជាមួយប្រទេសម៉ាឡេស៊ី (៤). ចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូTSR និងមន្ទីរពិសោធន៍មូលដ្ឋានបាន៥ក្រុមហ៊ុនក្នុងគោលបំណងផ្តល់ការអនុញ្ញាតសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងការទទួលស្គាល់ផ្លូវការជាមន្ទីរពិសោធន៍មូលដ្ឋានពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា រួមមាន៖ (១) ក្រុមហ៊ុនស៊ី ២.ខេ.ស៊ី.អ.អភិវឌ្ឍន៍កៅស៊ូ ខូ.,អិលធីឌី (២) ក្រុមហ៊ុនហ៊ង អាន ម៉ាង យ៉ាង ខេ អភិវឌ្ឍន៍កៅស៊ូ ខូ., អិលធីឌី (៣) ក្រុមហ៊ុនដុង ភូក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ., អិលធីឌី (៤) ក្រុមហ៊ុនភឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ., អិលធី (៥) ក្រុមហ៊ុនសុកហ៊ួន។

### ៧. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្នុងឆ្នាំ២០១៩ បានពិនិត្យកែសម្រួលឡើងវិញសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ បានចេញសារាចរណែនាំ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព រៀបចំសេចក្តីព្រាងសារាចរស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស។ ដោះស្រាយបញ្ហាការលួចជ័រកៅស៊ូនៅបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចបានមួយចំនួន ហើយបានចូលរួមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរបស់ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី និងចូលរួមដោះស្រាយការរំលោភកាន់កាប់ដីចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគិរី ជាមួយអាជ្ញាធរខេត្តនិងស្ថាប័នពាក់ព័ន្ធ។

### ៨. ការងារសហប្រតិបត្តិការអន្តរជាតិផ្នែកកៅស៊ូ

#### ៨.១. សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)

ព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលជាសមាជិកពេញសិទ្ធិក្នុងសមាគម ANRPC នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ហើយកម្ពុជាក៏ជាប្រធានសមាគម ANRPC សម្រាប់ឆ្នាំ២០១៥-២០១៦នេះផងដែរ។ ឆ្នាំ២០១៩នេះ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះបើកកិច្ចប្រជុំដំបូងរបស់ក្រុមការងារនិន្នភាពកៅស៊ូធម្មជាតិនៃសមាគមន៍បណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ នៅសណ្ឋាគារអង្គរប៉ារ៉ាឌីខេត្តសៀមរាបរយៈពេល៣ថ្ងៃ ប្រព្រឹត្តទៅប្រកបដោយភាពរលូនល្អនិងជោគជ័យ។

ក្រៅពីនេះនៅក្នុងឆ្នាំ២០១៩ បានចូលរួម (១). វគ្គបណ្តុះបណ្តាលស្តីពី "ការស្រាវជ្រាវនិងការវិភាគទីផ្សារកៅស៊ូធម្មជាតិ" នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី (២). កិច្ចប្រជុំលើកទី៦របស់ក្រុមជំនាញ ANRPC ផ្នែកស្ថិតិភាវូនីយកម្មតម្លៃកៅស៊ូពិភពលោកនៅប្រទេសថៃ (៣). សិក្ខាសាលាស្តីពី "ការផ្គត់ផ្គង់ តម្រូវការ និងការធ្វើម៉ូឌែលឧស្សាហកម្មកៅស៊ូធម្មជាតិ" នៅប្រទេសមីយ៉ានម៉ា (៤) សិក្ខាសាលាស្តីពីទៅរកប្រសិទ្ធភាពខ្សែច្រវាក់នៃការផ្គត់ផ្គង់" នៅប្រទេសថៃ (៥). សន្និសីទ កិច្ចប្រជុំ និងសន្និបាតរបស់ ANRPC នៅទីក្រុងហ្សាកាតាប្រទេសឥណ្ឌូនេស៊ី (៦). ចូលរួមកិច្ចប្រជុំស្តីពី "ការផ្លាស់ប្តូរយន្តការដើម្បីដោះស្រាយបញ្ហាថ្លៃកៅស៊ូរយៈពេលខ្លី" នៅប្រទេសថៃ និង(៧). កិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេសផ្នែកការពាររុក្ខជាតិនៅគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

**៨.២. ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ**

ឆ្នាំ២០១៩នេះ (១). ចូលរួមសន្និសីទនិងកិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB International Rubber Conference and IRRDB Annual Meeting) នៅប្រទេសមីយ៉ាន់ម៉ាចំនួន០១លើក (២) ចូលរួមសិក្ខាសាលានៅប្រទេសម៉ាឡេស៊ីចំនួន០១លើក (៣) ចូលរួមសិក្ខាសាលានៅប្រទេសចិន និង(៤) ចូលរួមសិក្ខាសាលានៅប្រទេសថៃចំនួន០១លើក។

**៨.៣. ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD: Agence Française de Développement)**

ក្នុងឆ្នាំ២០១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) បានធ្វើលិខិតទៅទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ AFD ដើម្បីសុំការគាំទ្រលើគម្រោងអភិវឌ្ឍន៍សហគមន៍កសិកម្មកៅស៊ូគ្រួសារដោយផ្តោតលើសមាសភាគចំនួនបី រួមមាន៖

- ការពង្រឹងនិងបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារ។
- ការបង្កើតសិប្បកម្មកែច្នៃនិងផ្តល់ប្រឹក្សាបច្ចេកទេសកែច្នៃដល់សហគមន៍កៅស៊ូគ្រួសារ។
- ការលើកកម្ពស់គុណភាពផលិតផលកៅស៊ូរបស់កសិករដើម្បីលក់ដល់ទីផ្សារអន្តរជាតិ។

**៨.៤. មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្មសម្រាប់ការអភិវឌ្ឍ**

នៅក្នុងឆ្នាំ២០១៩ ជំនាញការ CIRAD បានបំពេញបេសកកម្មចំនួន២ដងនៅកម្ពុជា ដើម្បីពិភាក្សា និងរៀបចំការងារស្រាវជ្រាវ។ អគ្គនាយកដ្ឋានកៅស៊ូ និងមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិ ដើម្បីអភិវឌ្ឍន៍កសិកម្ម (CIRAD) ប្រទេសបារាំង បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាទូទៅ (GMOU) កាលពីថ្ងៃទី ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ក្នុងគោលបំណងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរយៈពេលវែង រវាងភាគីទាំងពីរក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា ដោយផ្តោតលើ(១) សេដ្ឋកិច្ចសង្គម (២) ការអនុវត្តកសិកម្មល្អ (៣) បច្ចេកវិទ្យាគុណភាពកៅស៊ូ (៤) ការប្រើប្រាស់និងវាយតម្លៃគុណភាពដីនិងជី (៥) ការធ្វើផែនទីនិងកំណត់តំបន់ដាំដុះ (៦) ជីវ-បច្ចេកវិទ្យា (Bio-Technology) (៧) បរិស្ថាននិងការប្រែប្រួលអាកាសធាតុ (៨) ការកសាងធនធានមនុស្ស (៩) ទស្សនៈកិច្ចសិក្សា និង(១០) ការផ្លាស់ប្តូរកម្មវិធីសិក្សាសម្រាប់មន្ត្រីជំនាញនៃអង្គភាពទាំងពីរ។

**៨.៥. កិច្ចសហប្រតិបត្តិការជាមួយ CATAS**

ក្នុងឆ្នាំ២០១៩ CATAS បានគាំទ្រសកម្មភាព ដូចជា៖ (១) ទស្សនកិច្ចមន្ត្រីទៅប្រទេសចិនចំនួន៤លើក (២) បានបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រីចំនួន៩រូបនៅប្រទេសចិន និង(៣) បន្តការពិសោធន៍រួមគ្នានៅកម្ពុជាលើការងារស្រាវជ្រាវអំពីការព្យាបាលជំងឺស្ងួតផ្ទាំងចៀរ ការបំបៅមីនី (Mini Budding) កូនកៅស៊ូបំបៅក្នុងបំពង់ (Root trainer) និងការងារច្បារបង្កាត់ពូជ។ ភាគី CATAS ក៏បានជួយបានជួយរៀបចំមន្ទីរពិសោធន៍គីមីកសិកម្ម ដី និងស្លឹកដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

### ៨.៦. កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិននៅឆ្នាំ២០១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គសិក្ខាចំនួន៣គឺ (១) សិក្ខាសាលាស្តីពី “Modern practical Agriculture Technology and poverty Reduction Experience” (២) សិក្ខាសាលាស្តីពី “Agriculture and Animal Husbandry Technology for Cambodia” និង (៣) សិក្ខាសាលាស្តីពី “Information Technology Applications in Agriculture for Developing Countries”។

### ៨.៧. ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម

- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ សម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម លើកទី១២ (12th CLV DTA JCC) ដែលប្រព្រឹត្តទៅនៅសាលាខេត្តក្រចេះ

- បានឯកភាពលើរបាយការណ៍ចុងក្រោយនៃគម្រោងផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម ដែលភាគីវៀតណាមបានកែសម្រួល និងបានធ្វើរបាយការណ៍អំពីការឯកភាពគ្នារវាងកម្ពុជា-វៀតណាម ជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ក្រៅពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជាក៏បានចូលជាសមាជិកពេញសិទ្ធិនៃសមាគមន៍កៅស៊ូអន្តរជាតិ (International Rubber Association: IRA) និងក្រុមប្រឹក្សាធុរកិច្ចកៅស៊ូអាស៊ាន (Asian Rubber Buiness Council: ARBC) ផងដែរ។

## ២. ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

ផលិតកម្មសត្វមានសក្តានុពលក្នុងការរួមចំណែកបង្កើតការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ច និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ អនុវិស័យនេះជាផ្នែកមួយសំខាន់សម្រាប់ទ្រទ្រង់ដល់វិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់បញ្ចូលវិស័យកសិកម្មក្នុងចតុកោណទី៤ មុំទី១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយផ្អែកលើខ្សែច្រវាក់តម្លៃ និងដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍអនុវិស័យនេះ ជាមួយនឹងការគិតគូរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការប្រកួតប្រជែងទីផ្សារ ពិសេសការបន្ថយថ្លៃដើមផលិត និងអនាម័យសាច់។

ក្នុងឆ្នាំ២០១៩ ផលិតកម្មសត្វមានការកើនឡើង ជាពិសេសការចិញ្ចឹមសត្វសម្រាប់ឧស្សហកម្ម។ ជាក់ស្តែង សត្វចិញ្ចឹមសរុបបានកើនដល់៤៥,៨៥លានក្បាល គឺកើនលើសឆ្នាំ២០១៨ ចំនួន៣,៣% ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពផលិតសាច់សម្រាប់បម្រើតម្រូវការក្នុងស្រុកបានប្រមាណ២៣៩ពាន់តោន ឬស្មើនឹង៨២% នៃតម្រូវការសាច់សរុបប្រមាណ២៩០ពាន់តោនក្នុងមួយឆ្នាំ។

ទន្ទឹមនឹងនេះ ដោយមានការត្រៀមលក្ខណៈបានល្អ និងយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេតតាមដាន ស្រាវជ្រាវប្រភពចម្លងជំងឺ និងមានប្រព័ន្ធរាយការណ៍ស្ថានភាពសុខភាពសត្វជាប្រចាំ ករណីផ្ទុះជំងឺឆ្លងត្រូវបានរកឃើញ និងរាយការណ៍បានឆាប់រហ័ស និងបានចាត់វិធានការឆ្លើយតបទាន់ពេលវេលា។

### ២.១. លទ្ធផលនៃការជំរុញផលិតកម្មសត្វ

#### ២.១.១ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបក្នុងឆ្នាំ២០១៩នេះ មានចំនួន ៣២,០៤លានក្បាល ក្នុងនោះមានគោចំនួន ២,៧៧លានក្បាល ក្របីចំនួន៤៤៧ពាន់ក្បាល ជ្រូកចំនួន១,០៣លានក្បាល បក្សីចំនួន២៧,៧៦លានក្បាល

សេះចំនួន៤ពាន់ក្បាល ចៀមចំនួន៦៤៨ក្បាល ពពែចំនួន២៨ពាន់ក្បាល និងដំរីចំនួន១៨ក្បាល។ បើប្រៀបធៀបឆ្នាំ២០១៨ ស្ថិតិសត្វសរុបថយចុះ៦,៧% ក្នុងនោះគោ ក្របីថយ៥,៩% ជ្រូកថយ៤៦,៧% និងបក្សីថយ៤,១%។

**តារាង៨៖ ស្ថិតិផលិតកម្មសត្វ លក្ខណៈគ្រួសារពីឆ្នាំ២០១៥-២០១៩**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀប |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ២០១៩/២០១៨ |
| ១ | គោ | ២ ៩០៣ ៤២០ | ២ ៨៩៧ ១២៦ | ២ ៩៥១ ៣៥៩ | ២ ៩១៧ ៣០២ | ២ ៧៦៩ ៨៨៥ | -៥,0% |
| ២ | ក្របី | ៥០៦ ១៦៥ | ៥២៣ ៣២០ | ៥០៨ ៤៥៨ | ៥០០ ៧៧៨ | ៤៤៧ ១៦៧ | -១០,៧% |
| ៣ | គោ-ក្របី | ៣ ៤០៩ ៥៨៥ | ៣ ៤២០ ៤៤៦ | ៣ ៤៥៩ ៨១៧ | ៣ ៤១៨ ០៨០ | ៣ ២១៧ ០៥២ | -៥,៩% |
| ៤ | កម្លាំងអូសទាញ | ១ ១៣២ ០៩៧ | ១ ០៥១ ៦២៥ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | -១៤,១% |
| ៥ | ជ្រូក | ២ ៣៥៧ ៨៣៩ | ២ ៣៧១ ២៨៣ | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | -៤៦,៧% |
| ៦ | បក្សី | ២៦ ៦៨៨ ៦៧៥ | ២៨ ៤០២ ៤៨៦ | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | -៤,១% |
| ៧ | សេះ | ៧ ៦៣៧ | ៥ ៦១០ | ៥ ០៥៥ | ៤ ២០៧ | ៣ ៧៧១ | -១០,៤% |
| ៨ | ចៀម | ៣៧៨ | ៤០០ | ៤៦១ | ៤៥៩ | ៦៤៨ | +៤១,២% |
| ៩ | ពពែ | ២៣ ៣២១ | ២២ ៧១៩ | ២៨ ៥៤២ | ២៥ ៧៤៧ | ២៧ ៧៤០ | +៧,៧% |
| ១០ | ដំរី | ៦៤ | ៦៣ | ៦៣ | ៥៨ | ១៨ | -៧១,៤% |
| សរុប | | ៣២ ៤៨៧ ៤៩៩ | ៣៤ ២២៣ ០០៧ | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | -៦,៧% |

**ក្រាហ្វិកទី២៣៖ ផលិតកម្មសត្វជាលក្ខណៈគ្រួសារឆ្នាំ២០១៥ -២០១៩**




## ២.១.២. ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០១៩ សរុបមានចំនួន១៣,៨១លានក្បាល ក្នុងនោះគោ ក្របីមានចំនួន១០ពាន់ក្បាល ជ្រូកមានចំនួន១,១៥លានក្បាល បក្សីមានចំនួន១២,៦៣លានក្បាល សេះចំនួន៣០ក្បាល និងស្វាចំនួន១៤ពាន់ក្បាល។ បើប្រៀបធៀបឆ្នាំ២០១៨ ការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មមានការកើន៣៧,៦% ក្នុងនោះជ្រូកកើន៤២,១% និងបក្សីកើន៣៧,១%។ ដោយឡែកគោ ក្របីថយចុះ១១,៨% និងសេះថយ ចុះ៦៦,៣%។

**តារាង៩៖ ស្ថិតិផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀប |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ២០១៩/២០១៨ |
| ១ | គោ | ១៣ ២៨៩ | ២៣ ១៨៨ | ២០ ៣៦៣ | ១១ ២៣២ | ៩ ៨៧៧ | -១២,១% |
| ២ | ក្របី | ៦៣ | ១៩៤ | ១៩៨ | ២១៧ | ២១៨ | +០,៥% |
| ៣ | គោ-ក្របី | ១៣ ៣៥២ | ២៣ ៣៨២ | ២០ ៥៦១ | ១១ ៤៤៩ | ១០ ០៩៥ | -១១,៨% |
| ៤ | ជ្រូក | ៤១៦ ៥២៥ | ៥៩៩ ៣៤១ | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | +៤២,១% |
| ៥ | បក្សី | ៧ ៨៣០ ៣៩៨ | ៧ ៣៣១ ២៧៥ | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | +៣៧,១% |
| ៦ | សេះ | ៥២ | ៦៤ | ៨២ | ៨៩ | ៣០ | -៦៦,៣% |
| ៧ | ចៀម | ៣១ | ៦៧ | ០ | ០ | ០ | ០ |
| ៨ | ពពែ | ៥ ៥៤៧ | ៦ ២៥៨ | ៣៦៥ | ៧០០ | ០ | ០ |
| ៩ | ស្វា | - | - | - | - | ១៤ ០៧៩ | +១០០% |
| ១០ | ទន្សាយ | - | - | - | - | - | ០ |
| សរុប | | ៨ ២៦៥ ៩០៥ | ៧ ៩៦០ ៣៨៧ | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | +៣៧,៦% |

**ក្រាហ្វិកទី២៤៖ ស្ថិតិផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្មពីឆ្នាំ២០១៥ -២០១៩**




### ២.១.៣. ស្ថិតិសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួមផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល០៥ឆ្នាំចុងក្រោយនេះ មានអត្រាកំណើនគួរឱ្យកត់សម្គាល់គឺមានចំនួន៤០,៧៥លានក្បាលនៅឆ្នាំ២០១៥ កើនដល់៤៥,៨៥លានក្បាលនៅឆ្នាំ២០១៩ ក្នុងនោះមានគោចំនួន២,៧៨លានក្បាល ក្របីចំនួន៤៤៧ពាន់ក្បាល ជ្រូកចំនួន២,១៨លានក្បាល បក្សីចំនួន៤០,៣៩លានក្បាល សេះចំនួន៣ ៨០១ក្បាល ចៀមចំនួន៦៤៨ក្បាល ពពែចំនួន២៨ពាន់ក្បាល ដំរីចំនួន១៨ក្បាល ស្វាចំនួន១៤ពាន់ក្បាល និងទន្សាយចំនួន១៨៥ក្បាល។ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ មានអត្រាកំណើន៣,៣% ក្នុងនោះបក្សីកើន៥,៨% ចៀមកើន៤១,២% និងពពែកើន៤,៩% ដោយឡែកគោ ក្របីថយចុះ៥,៩% និងជ្រូកថយចុះ២០,៤%។

### តារាង១០៖ ស្ថិតិផលិតកម្មសត្វសរុបចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មពីឆ្នាំ២០១៥-២០១៩

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀបឆ្នាំ ២០១៩/២០១៨ |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| ១ | គោ | ២ ៩១៦ ៧០៩ | ២ ៩២០ ៣១៤ | ២ ៩៧១ ៧២២ | ២ ៩២៨ ៥៣៤ | ២ ៧៧៩ ៧៦២ | -៥,១% |
| ២ | ក្របី | ៥០៦ ២២៨ | ៥២៣ ៥១៤ | ៥០៨ ៦៥៦ | ៥០០ ៩៩៥ | ៤៤៧ ៣៨៥ | -១០,៧% |
| ៣ | គោ ក្របី | ៣ ៤២២ ៩៣៧ | ៣ ៤៤៣ ៨២៨ | ៣ ៤៨០ ៣៧៨ | ៣ ៤២៩ ៥២៩ | ៣ ២២៧ ១៤៧ | -៥,៩% |
| ៤ | កម្លាំងអូសទាញ | ១ ១៣២ ០៩៧ | ១ ០៥១ ៦២៥ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | -១៤,២% |
| ៥ | ជ្រូក | ២ ៧៧៤ ៣៦៤ | ២ ៩៧០ ៦២៤ | ៣ ០៧៤ ២៨៣ | ២ ៧៤៧ ៨៥៥ | ២ ១៨៥ ៩២៤ | -២០,៤% |
| ៦ | បក្សី | ៣៤ ៥១៩ ០៧៣ | ៣៥ ៧៣៣ ៧៦១ | ៣៦ ២៤៤ ៩៣៩ | ៣៨ ១៦៦ ៧៥១ | ៤០ ៣៩៥ ៤៥៣ | +៥,៨% |
| ៧ | សេះ | ៧ ៦៨៩ | ៥ ៦៧៤ | ៥ ១៣៧ | ៤ ២៩៦ | ៣ ៨០១ | -១១,៥% |
| ៨ | ចៀម | ៤០៩ | ៤៦៧ | ៤៦១ | ៤៥៩ | ៦៤៨ | +៤១,២% |
| ៩ | ពពែ | ២៨ ៨៦៨ | ២៨ ៩៧៧ | ២៨ ៩០៧ | ២៦ ៤៤៧ | ២៧ ៧៤០ | +៤,៩% |
| ១០ | ដំរី | ៦៤ | ៦៣ | ៦៣ | ៥៨ | ១៨ | -៦៩,០% |
| ១១ | ស្វា | - | - | - | - | ១៤ ២២៨ | +១០០,០% |
| ១២ | ទន្សាយ | - | - | - | - | ១៨៥ | +១០០,០% |
| **សរុប** | | **៤០ ៧៥៣ ៤០៤** | **៤២ ១៨៣ ៣៩៤** | **៤២ ៨៣៤ ១៦៨** | **៤៤ ៣៧៥ ៣៩៥** | **៤៥ ៨៥៥ ១៤៣** | +៣,៣% |

### ក្រាហ្វិកទី២៥៖ ស្ថិតិផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ពីឆ្នាំ២០១៥-២០១៩




### ២.១.៤. ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី ៨,២៦លានក្បាលនៅឆ្នាំ២០១៥ ឡើងដល់១៣,៨១លានក្បាលនៅក្នុងឆ្នាំ២០១៩។ ឆ្នាំ២០១៩នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានកំណើន៣៧,៦% ក្នុងនោះផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្មមានកំណើន៤២,១% និងផលិតកម្មបក្សីមានកំណើន៣៧,១%។ អត្រានៃកំណើនផលិតសត្វលក្ខណៈពាណិជ្ជកម្មនេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា មានការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមាន ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។

**ប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម បានកើនពី២៣% នៅឆ្នាំ២០១៨ ដល់៣០% ក្នុងឆ្នាំ២០១៩។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ បានថយចុះពី ៧៧% នៅឆ្នាំ២០១៨ មក៧០% ក្នុងឆ្នាំ២០១៩។

### តារាងទី១១៖ ស្ថិតិសត្វតាមបែបផែនផលិតកម្មពីឆ្នាំ២០១៥-២០១៩

| បែបផែន ផលិតកម្មសត្វ | ស្ថិតិផលិតកម្មសត្វសរុប ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀបឆ្នាំ ២០១៩/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| លក្ខណៈគ្រួសារ | ៣២ ៤៨៧ ៤៩៩ | ៣៤ ២២៣ ០០៧ | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | -៦,៧% |
| លក្ខណៈពាណិជ្ជកម្ម | ៨ ២៦៥ ៩០៥ | ៧ ៩៦០ ៣៨៧ | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | +៣៧,៦% |
| សរុប | ៤០ ៧៥៣ ៤០៤ | ៤២ ១៨៣ ៣៩៤ | ៤២ ៨៣៤ ១៦៨ | ៤៤ ៣៧៥ ៣៩៥ | ៤៥ ៨៥៥ ១៤៣ | +៣,៣% |

### ក្រាហ្វិកទី២៦៖ ប្រៀបធៀបអត្រាតាមបែបផែនផលិតកម្មសត្វពីឆ្នាំ២០១៥-២០១៩




### តារាង១២៖ អត្រាស្ថិតិផលិតកម្មសត្វសរុប ៥ឆ្នាំចុងក្រោយពីឆ្នាំ២០១៥-២០១៩

| បែបផែន ផលិតកម្មសត្វ | អត្រាស្ថិតិផលិតកម្មសត្វសរុប ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀបឆ្នាំ ២០១៩/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| លក្ខណៈគ្រួសារ | ៨០% | ៨១% | ៨០% | ៧៧% | ៧០% | -៧% |
| លក្ខណៈពាណិជ្ជកម្ម | ២០% | ១៩% | ២០% | ២៣% | ៣០% | +៧% |

### ក្រាហ្វិកទី២៧៖ ប្រៀបធៀបអត្រានៃផលិតកម្មសត្វពីឆ្នាំ២០១៥-២០១៩




**ប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពី៣០% នៅឆ្នាំ២០១៨ ដល់៥៣% ក្នុងឆ្នាំ២០១៩។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ បានថយចុះពី៧០% នៅឆ្នាំ២០១៨ មក៤៧% ក្នុងឆ្នាំ២០១៩។

## តារាង១៣៖ ស្ថិតិផលិតកម្មជ្រូក ៥ឆ្នាំចុងក្រោយពីឆ្នាំ២០១៥-២០១៩

| បែបផែន ផលិតកម្មជ្រូក | ស្ថិតិផលិតកម្មជ្រូក ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀបឆ្នាំ ២០១៩/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| លក្ខណៈគ្រួសារ | ២ ៣៥៧ ៨៣៩ | ២ ៣៧១ ២៨៣ | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | -៤៦,៧% |
| លក្ខណៈពាណិជ្ជកម្ម | ៤១៦ ៥២៥ | ៥៩៩ ៣៤១ | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | +៤២,១% |
| សរុប | ២ ៧៧៤ ៣៦៤ | ២ ៩៧០ ៦២៤ | ៣ ០៧៤ ២៨៣ | ២ ៧៤៧ ៨៥៥ | ២ ១៨៥ ៩២៤ | -២០,៤% |

## ក្រាហ្វិកទី២៨៖ ប្រៀបធៀបអត្រានៃផលិតកម្មជ្រូកពីឆ្នាំ២០១៥-២០១៩




**ប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្ម បានកើនពី២៤% នៅឆ្នាំ២០១៨ ដល់៣១% ក្នុងឆ្នាំ២០១៩។ ដោយឡែកអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ បានថយចុះពី ៧៦% នៅឆ្នាំ២០១៨ មក៦៩% ក្នុងឆ្នាំ២០១៩។

## តារាង១៤៖ ស្ថិតិផលិតកម្មបក្សីតាមបែបផែនផលិតកម្មពីឆ្នាំ២០១៥-២០១៩

| បែបផែន ផលិតកម្មបក្សី | ស្ថិតិផលិតកម្មបក្សី ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀបឆ្នាំ ២០១៩/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| លក្ខណៈគ្រួសារ | ២៦ ៦៨៨ ៦៧៥ | ២៨ ៤០២ ៤៨៦ | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | -៤,១% |
| លក្ខណៈពាណិជ្ជកម្ម | ៧ ៨៣០ ៣៩៨ | ៧ ៣៣១ ២៧៥ | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | +៣៧,១% |
| សរុប | ៣៤ ៥១៩ ០៧៣ | ៣៥ ៧៣៣ ៧៦១ | ៣៦ ២៤៤ ៩៣៩ | ៣៨ ១៦៦ ៧៥១ | ៤០ ៣៩៥ ៤៥៣ | +៥,៨% |

## ក្រាហ្វិកទី២៩៖ ប្រៀបធៀបបែបផែនផលិតកម្មបក្សីពីឆ្នាំ២០១៥-២០១៩



**តារាង១៥៖ អត្រាស្ថិតិផលិតកម្មបក្សីតាមបែបផែនផលិតកម្មពីឆ្នាំ២០១៥-២០១៩**

| បែបផែន ផលិតកម្មបក្សី | អត្រាស្ថិតិផលិតកម្មជ្រូក ៥ឆ្នាំចុងក្រោយ (២០១៥-២០១៩) | | | | | ប្រៀបធៀបឆ្នាំ ២០១៩/២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | |
| លក្ខណៈគ្រួសារ | ៧៧% | ៧៩% | ៧៩% | ៧៦% | ៦៩% | -៧% |
| លក្ខណៈពាណិជ្ជកម្ម | ២៣% | ២១% | ២១% | ២៤% | ៣១% | +៧% |

**ក្រាហ្វិកទី៣០៖ ប្រៀបធៀបអត្រានៃបែបផែនផលិកម្មបក្សីពីឆ្នាំ២០១៥-២០១៩**




### ២.១.៥. តម្រូវការសត្វ និងសាច់

ផ្អែកតាមរបាយការណ៍របស់អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ ការបរិភោគសាច់សត្វនៅកម្ពុជាក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៧,៦០គីឡូក្រាម ក្នុងនោះមានសាច់គោ ក្របី៥គីឡូក្រាម សាច់ជ្រូក៩,២៩គីឡូក្រាម សាច់បក្សី៣,៣គីឡូក្រាម និងសាច់សត្វផ្សេងៗទៀត០,០១គីឡូក្រាម។

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់ការបរិភោគមានការកើនឡើងគួរឱ្យកត់សម្គាល់គឺកើនពី២៧២ពាន់តោននៅឆ្នាំ២០១៥ ឡើងដល់២៩០ពាន់តោននៅក្នុងឆ្នាំ២០១៩ ហើយលទ្ធភាពផ្គត់ផ្គង់ក្នុងស្រុកក៏កាន់តែមានការកើនឡើងផងដែរ គឺកើនពី២០៩ពាន់តោននៅឆ្នាំ២០១៥ ឡើងដល់២៣៩ពាន់តោននៅក្នុងឆ្នាំ២០១៩។ នៅក្នុងឆ្នាំ២០១៩នេះ តម្រូវការសាច់សរុបមាន២៩០ពាន់តោន ក្នុងនោះ សាច់គោ ក្របី៨២ពាន់តោន សាច់ជ្រូក១៥៣ពាន់តោន សាច់បក្សី៥៤ពាន់តោន និងសាច់ផ្សេងទៀត១៦៥តោន ផលិតកម្មសត្វក្នុងស្រុកមានលទ្ធភាពអាចផ្គត់ផ្គង់សាច់បានប្រមាណ២៣៩ពាន់តោន ឬស្មើនឹង៨២% ក្នុងនោះសាច់ គោ ក្របី៨៩ពាន់តោន (៨១២ពាន់ក្បាល) សាច់ជ្រូក១០៣ពាន់តោន (២,០៥លានក្បាល) និងសាច់បក្សី៤៧ពាន់តោន (៣៩,១២លានក្បាល)។ បរិមាណដែលខ្វះខាតត្រូវបាននាំចូលដើម្បីបំពេញតម្រូវការបន្ថែម ជាក់ស្តែងនៅក្នុងឆ្នាំ២០១៩ កម្ពុជាបាននាំចូលសាច់ និងផលិតផលសត្វមួយចំនួនមានជ្រូកសាច់រស់ចំនួន៥៧៤ពាន់ក្បាល ពពែរស់ចំនួន៥ ៨៣៩ក្បាល និងមាន់រស់ចំនួន៦,៩១លានក្បាល និងសាច់ចម្រុះចំនួន២ ៩២៩តោន (សាច់ជ្រូក មាន់ ទា ក្រួច សាច់គោក្របី ប្រហិត ហ្រ្វូម៉ា...)។

**តារាង១៦៖ តម្រូវការប្រើប្រាស់ ការផ្គត់ផ្គង់ និងការបំពេញបន្ថែមឆ្នាំ២០១៩**

| ប្រភេទសត្វ | តម្រូវការប្រើប្រាស់ | | លទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក | | កង្វះខាត (ផែនការ) | |
|---|---|---|---|---|---|---|
| | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល |
| គោ ក្របី | ៨២ ៤៥០ | ៧៥០ | ៨៩ ៣៩៥ | ៨១២ | ៦ ៩២៥ | ៦៣ |
| ជ្រូក | ១៥៣ ១៩២ | ៣ ០៦៤ | ១០២ ៧៨៦ | ២ ០៥៦ | -៥០ ៤០៦ | -១ ០០៨ |
| បក្សី | ៥៤ ៤១៧ | ៤៥ ៣៤៨ | ៤៦ ៩៥៤ | ៣៩ ១២៩ | -៧ ៤៦៣ | -៦ ២១៩ |
| ផ្សេងៗ | ១៦៥ | ១៤ | - | - | -១៦៥ | -១៤ |
| **សរុប** | **២៩០ ២២៤** | | **២៣៩ ១១៥** | - | **-៥១ ១០៩** | |

## ក្រាហ្វិក៣១៖ តម្រូវការសាច់សរុប លទ្ធភាពផ្គត់ផ្គង់ និងកង្វះខាត




## ក្រាហ្វិក៣២៖ តម្រូវការសាច់សរុប តាមប្រភេទសាច់សត្វ




## ក្រាហ្វិក៣៣៖ លទ្ធភាពផ្គត់ផ្គង់សាច់សរុបតាមប្រភេទសាច់សត្វ




## ក្រាហ្វិក៣៤៖ កង្វះខាតសាច់សរុបតាមប្រភេទសាច់សត្វ



### ២.១.៦. ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ ជារួមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោក្របីចំនួន៨៣ពាន់ក្បាល ជ្រូកពូជ (មេ បា កូន) ចំនួន៥៨ពាន់ក្បាល កូនមាន់ពូជចំនួន៥៦ពាន់ក្បាល ស្វាក្តាមចំនួន៨៩ពាន់ក្បាល ចំណីផ្អែចំនួន៧ពាន់តោន ស្បែកគោក្របីប្រឡាក់អំបិលចំនួន៨ពាន់តោន និងទឹកដោះគោចំនួន១២ពាន់តោន។ ក្នុងឆ្នាំ២០១៩ បាននាំចេញគោ ក្របីចំនួន៥៦ពាន់ក្បាល មេជ្រូកពូជចំនួន២០០ក្បាល ស្វាក្តាមចំនួន១៦ពាន់ក្បាល ចំណីផ្អែចំនួន១ ០១១តោន ស្បែកគោក្របីប្រឡាក់អំបិលចំនួន១ ៤៤០តោន ទឹកដោះគោស្រស់ចំនួន៣ ៩៨៤តោន និងរោមទាចំនួន៨តោន។

**តារាងទី១៧៖ ស្ថិតិនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វពីឆ្នាំ២០១៥-២០១៩**

| ប្រភេទសត្វ និងផលិតផលសត្វ | ឯកតា | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|---|---|---|---|
| គោ ក្របី | ក្បាល | ៧ ៣៣៥ | ៦ ២៣៥ | ១១ ២៤០ | ៦ ៧៨៦ | ៥៦ ២១៨ | ៨៣.៧៥៧ |
| ជ្រូកពូជ (មេ បា) | ក្បាល | ២ ០២១ | ១ ២៥០ | ១ ១៤០ | ៥០៥ | ២០០ | ៦.៩៣៣ |
| ជ្រូកពូជ (កូន) | ក្បាល | ១៣ ៣០៥ | ៣៤ ២០០ | | ៥ ០០០ | | ១០២.៩០៥ |
| ស្វាក្តាម | ក្បាល | ៤ ១៨០ | ៥១ ៥៣០ | ៦ ៩៣៤ | ១០ ៤៧២ | ១៦ ១៩៦ | ៧៧.៦៤៦ |
| កូនមាន់ | ក្បាល | | ៥៦ ០០០ | | | | ៥៦.០០០ |
| សាច់គោ | តោន | | ៦៨ | ៧ | ១២ | | ៨៧ |
| ទឹកដោះគោ | តោន | | | ៤៥១ | ៧ ៥៥៨ | ៣ ៩៨៤ | ៨.០០៩ |
| ចំណីផ្អែ | តោន | ១ ៦៥២ | ១ ៣៧០ | ១ ៣៦៥ | ១ ៤៩៤ | ១ ០១១ | ៧.០៦៣ |
| រោមសត្វ | តោន | ៦៣ | ៥០ | ២៨ | ២៤ | ៨ | ២២៨ |
| ស្បែកគោ ក្របី ជ្រូក | តោន | ២ ២៥៤ | ១ ៤៨៣ | ១ ៩៧២ | ១ ២៧៥ | ១ ៤៤០ | ១៨.៦០៤ |

### ២.១.៧. កម្មវិធីកែលម្អពូជ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសបង្កាត់សិប្បនិម្មិតគោ និងជ្រូក ព្រមទាំងផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតគោ និងជ្រូកដល់មន្ត្រីជំនាញផលិតកម្មនិងបសុព្យាបាលទាំង២៥រាជធានី ខេត្ត។ តាមរយៈការអនុវត្តកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាបន្នអនុវិស័យផលិតកម្មសត្វ បានបង្កើតមជ្ឈមណ្ឌល និងកន្លែងបង្កាត់សិប្បនិម្មិតគោបានចំនួន១១កន្លែង នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងខេត្តឧត្តរមានជ័យ ព្រមទាំងមជ្ឈមណ្ឌល និងកន្លែងបង្កាត់សិប្បនិម្មិតជ្រូក១២កន្លែងនៅក្នុងខេត្តចំនួន១១ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង តាកែវ ឧត្តរមានជ័យ ត្បូងឃ្មុំ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

នៅឆ្នាំ២០១៩ ការបង្កាត់សិប្បនិម្មិតគោបានចំនួន៨៣៣ក្បាល ដោយមេកើតកូនបានចំនួន៣៣៨ក្បាល (ញី១៧៦ក្បាល) ស្មើនឹង៤០% មេដែលបានបង្កាត់សិប្បនិម្មិតមិនទាន់កើតកូនចំនួន៤៩៥ក្បាលស្មើនឹង៦០%។ ការបង្កាត់ដោយសិប្បនិម្មិតគោមានការចូលរួមចំណែកពីវិស័យឯកជនផងដែរ ប៉ុន្តែតួលេខនៃការកើតកូនគោមិនស្មើទៅនឹងតួលេខបង្កាត់ពីព្រោះគោដើមមានរយៈពេល០៩ខែនិង១០ថ្ងៃ ដូច្នេះមេគោមួយចំនួនត្រូវកើតកូននៅឆ្នាំបន្ទាប់ និងបង្កាត់សិប្បនិម្មិតជ្រូកបានចំនួន១០ ០៣៦ក្បាល បង្កើតកូនជ្រូកបានចំនួន១២៣ ៣៤៧ក្បាល (ក្នុងនោះញីចំនួន៦៤ ៣០០ ក្បាល)។ ជាការកត់សម្គាល់ពិនិត្យឃើញថា ពូជជ្រូកត្រូវបានកែលម្អយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស។

### ២.១.៨. អំពីចំណីសត្វ

ការងារចម្បងគឺការរៀបចំកម្មវិធីកែលម្អចំណីសត្វ ផ្សព្វផ្សាយពូជស្មៅដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់។ បច្ចុប្បន្នបានពង្រីកកម្មវិធីដំណាំចំណីសត្វនៅទូទាំង២៥រាជធានី ខេត្ត សរុបមានកន្លែងធ្វើបង្ហាញចំនួន១ ០៣២កន្លែង លើផ្ទៃដីចំនួន៣៨៤,៣៨ហិកតា។

បច្ចុប្បន្នមានក្រុមហ៊ុន ដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជាមានចំនួន១៦ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុនស៊ីភី អេហ្គ្រីម៉ាស្ទ័រ ហ្គ្រីនហ្វីត បេតាហ្គ្រោ ញ៉ូវហូប ស៊ីជេ ជេជីដាងហ្វីដ អ៊ីស្តហូប សាណាហ្គ្រូ អិមភិក.អេស៊ីអិមស៊ី ស៊ីខេវ៉ាយអ៊ី អិលវីអេស វើលដ៍វេត ភីជិបប៉េលយូអ ជីហ្វេរ អេអេនធី ហ្វីដ និងក្រុមហ៊ុនដេហឺស ធីអិមអេច និងមានរោងចក្រផលិតចំណីសត្វសរុបចំនួន១៨កន្លែង ដែលមានសមត្ថភាពអាចផលិតចំណីសត្វបានប្រមាណជាង២លានតោន/ឆ្នាំ។ នៅក្នុងឆ្នាំ២០១៩ ក្រុមហ៊ុនដែលបាននិងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្មមានចំនួន១៥ក្រុមហ៊ុន មានរោងចក្រផលិតចំណីសត្វចំនួន១៧កន្លែង ផលិតចំណីសត្វបានប្រមាណជាង១,១៧លានតោន ស្មើនឹង៥៦% នៃសមត្ថភាពផលិតរបស់រោងចក្រ។

ម៉្យាងទៀត ក្រៅពីចំណីសត្វដែលផលិតបាននៅក្នុងស្រុក ក៏មានក្រុមហ៊ុនមួយចំនួនទៀត បាននាំចូលបន្ថែមនូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ដើម្បីបំពេញសេចក្តីត្រូវការប្រើប្រាស់ និងផលិតចំណីសត្វក្នុងស្រុក។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៩ កម្ពុជាបាននាំចូលនូវចំណីសត្វចំនួន២៣៥ពាន់តោន វត្ថុធាតុដើមចំនួន១៦៨ពាន់តោន និងសារធាតុបន្ថែមចំនួន១១ពាន់តោន បសុឱសថ៣ ៦២៨តោន វ៉ាក់សាំង៨ ២២២តោន សម្ភារបសុពេទ្យនិងឧបករណ៍ចិញ្ចឹមសត្វ ១២ ៨៩៣តោន។

### ២.១.៩. ការគ្រប់គ្រងកាកសំណល់សត្វ

ការសាងសង់ឡជីវឧស្ម័នត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យសាងសង់យ៉ាងទូលំទូលាយ ដើម្បីគ្រប់គ្រងកាកសំណល់សត្វ ដោយបានទាញយកនូវថាមពលកកើតឡើងវិញ និងផ្តល់នូវជីធម្មជាតិ។ កម្មវិធីឡជីវឧស្ម័នជាតិបានអនុវត្តតាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ សាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន២៧ ៩៨២ឡ ក្នុងខេត្តចំនួន១៣ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ និងខេត្តត្បូងឃ្មុំ។ ដោយឡែកក្នុងឆ្នាំ២០១៩ កម្មវិធីឡជីវឧស្ម័នជាតិសាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន៧៤៩ឡ។

ម៉្យាងទៀត គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជាចិនចំនួន១៥០០ឡ ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក៏បានចាប់ដំណើរការអនុវត្តនៅចុងឆ្នាំ២០១៩ នេះដែរ ដោយបានធ្វើការបណ្តុះបណ្តាលបច្ចេកទេសសាងសង់ឡដល់មន្ត្រីជំនាញ និងក្រុមជាងសាងសង់ឡចាប់ផ្តើមពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ នៅក្នុងខេត្តគោលដៅទាំង០៧ មានខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង ព្រះវិហារ និងខេត្តត្បូងឃ្មុំ។ នៅក្នុងវគ្គបណ្តុះបណ្តាលនីមួយៗ បានអនុវត្តជាក់ស្តែងពីការសាងសង់ឡជីវ-ឧស្ម័នចំនួន០៥ឡ ដែលសរុបខេត្តគោលដៅទាំង០៧ ការអនុវត្តសាងសង់ឡសម្រេចបាន៣៥ឡ។

**ក្រាហ្វិកទី៣៥៖ ស្ថិតិសាងសង់ឡជីវឧស្ម័នគ្រួសារតាមបណ្តាខេត្តពីឆ្នាំ២០០៦-២០១៩**



### ក្រាហ្វិកទី៣៦៖ ស្ថិតិសាងសង់ឡជីវឧស្ម័នគ្រួសារឆ្នាំ២០០៦-២០១៨




## ២.២. ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ

សកម្មភាពសំខាន់ៗក្នុងផ្នែកនេះ គឺការពង្រឹងសុខភាពសត្វ អនាម័យសត្វ សាច់ និងផលិតផលសត្វ ដែលផ្តោតសំខាន់លើការត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព ពង្រឹងការផ្តល់សេវាបសុព្យាបាល កាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ និងការផ្គត់ផ្គង់សាច់ប្រកបដោយអនាម័យ គុណភាព និងសុវត្ថិភាពនៅលើទីផ្សារ ដើម្បីការពារសុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។

### ២.២.១. ការលើកកម្ពស់សុខភាពសត្វ

នៅឆ្នាំ២០១៩នេះ ក្រសួងបានពង្រឹងសកម្មភាពចុះត្រួតពិនិត្យសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីទប់ស្កាត់បទល្មើសចរាចរណ៍សត្វ និងការធ្វើអាជីវកម្មសត្វ បានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធបានបន្តអនុវត្តសេចក្តីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ។ ជាលទ្ធផលក្នុងរយៈពេលមួយឆ្នាំនេះ នៅទូទាំងប្រទេសបានធ្វើការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វ និងបានបង្ក្រាបបទល្មើសចរាចរណ៍សត្វ និងផលិតផលសត្វសរុប១០៩ករណី ក្នុងនោះ បានចុះត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន៣៤៨ករណី និងបង្ក្រាបបទល្មើសបានចំនួន៦២ករណី (ដឹកជញ្ជូនមាន់រស់២៧ករណី ជ្រូករស់២៥ករណី ទារស់០២ករណី ប្រហិត និងផលិតផលកែច្នៃ០២ករណី ចុះឆែកឆេរ បង្ក្រាបបទល្មើសក្នុងសត្តឃាតដ្ឋាន ទីតាំងប្រមូលផ្តុំ និងចែកចាយសត្វជ្រូកបាន០៦ករណី) និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តបង្ក្រាបបទល្មើសបានចំនួន៤៧ករណី (ដឹកជញ្ជូនមាន់រស់០៧ករណី ជ្រូករស់៣០ករណី គោរស់០១ករណី និងផលិតផលកែច្នៃពីសត្វ០៩ករណី)។ ជាមួយគ្នានេះដែរ ធ្វើការអង្កេតតាមដាន បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការណ៍ជីវសុវត្ថិភាព និងកម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០១៩ រួមមាន៖

- ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់ ឈាមខ្មៅ និងសារទឹកសរុបចំនួន ១ ៤៣១ ១២៧ក្បាល ចាក់វ៉ាក់សាំងការពារជំងឺឆ្លងលើជ្រូកចំនួន ១ ៤៦៩ ៣៩៧ ក្បាល ចាក់វ៉ាក់សាំងការពារជំងឺបក្សីបានចំនួន ១៣ ២៨១ ២៤៧ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺឆ្កែ និងឆ្មាចំនួន ១៨ ០៩៣ក្បាល។
- ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន២៩២ ៥៤៦លើក។

- ក្នុងឆ្នាំ២០១៩ ភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេសមានចំនួន ១១ ៧៤៧នាក់ បានបណ្តុះបណ្តាលថ្មីចំនួន៥៩៧នាក់។

### ២.២.២. ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល

សុខភាពសាធារណៈបសុព្យាបាលជាផ្នែកមួយមានភារៈកិច្ចវាយតម្លៃ ផ្តល់ការអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន និងកន្លែងកែច្នៃសាច់ និងផលិតផលសត្វ ដើម្បីធានាសុខភាពសាធារណៈ តាមរយៈការពង្រឹងការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ ដោយបង្កើនសមត្ថភាពមន្ត្រី និងផ្សព្វផ្សាយដល់អាជីវករពាក់ព័ន្ធលើការអនុវត្តវិធានអនាម័យសត្វ សាច់ និងផលិតផលសត្វ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ចុះផ្សព្វផ្សាយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ អនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ខ្ពស់ រៀបចំចងក្រងឯកសារបច្ចេកទេសនានា និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ផលិតផលសត្វ ការពិឃាតសត្វតាមបទដ្ឋានបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ព្រមទាំងបានបំពាក់បំប៉នបង្កើនសមត្ថភាពដល់មន្ត្រីប្រចាំការនៅតាមសត្តឃាតដ្ឋាន និងអ្នកពាក់ព័ន្ធលើជំនាញត្រួតពិនិត្យសុខភាពសត្វ អនាម័យសាច់ និងផលិតផលសត្វចំនួន២៨០នាក់ បានបណ្តុះបណ្តាលបច្ចេកទេសស្តីពីការពិឃាតសត្វជ្រូក គោ ក្របី ប្រកបដោយមនុស្សធម៌ចំនួន១៤វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៥០៧នាក់ (ស្ត្រីចំនួន៨១នាក់)។

គិតមកដល់ដំណាច់ឆ្នាំ២០១៩នេះ សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន២២៥កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨ មានចំនួន១១៦កន្លែង សត្តឃាតដ្ឋានអនុក្រឹត្យ១០៨ និងវិនិយោគចំនួន៥១កន្លែង និងសត្តឃាតដ្ឋានវិនិយោគចំនួន៥៨កន្លែង ក្នុងនោះសត្តឃាតដ្ឋានពិឃាតគោទំនើបលំដាប់អន្តរជាតិនៅខេត្តតាកែវចំនួន០១កន្លែង និងសត្តឃាតដ្ឋានពិឃាតបក្សីទំនើបនៅខេត្តកណ្តាលចំនួន០១កន្លែង។ បើទោះបីសត្តឃាតដ្ឋានកើនជាលំដាប់ ប៉ុន្តែចំនួននេះមិនទាន់គ្រប់គ្រាន់ទាំងបរិមាណ និងមិនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើការបង្កើត និងគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វនៅឡើយ។ ទោះបីយ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងខិតខំណែនាំបទដ្ឋានបច្ចេកទេសអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វបន្ថែមទៀត។

## ២.៣. ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល និងនីតិកម្ម

### ២.៣.១. ការងារផ្សព្វផ្សាយបច្ចេកទេស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីផ្សព្វផ្សាយ សម្ភាសន៍ វេទិកាសាធារណៈ សម្រាប់អ្នកពាក់ព័ន្ធលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយឯកសារបទសម្ភាសន៍ វីដេអូអប់រំបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មាន សេចក្តីណែនាំ សារាចរ ប្រកាស និងឯកសារពាក់ព័ន្ធនានាតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ ហ្វេសប៊ុក និងចែកជូនការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ និងសាធារណៈជននូវឯកសារបង្ហាញពីការចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ។ លើសពីនេះទៀត មន្ត្រីជំនាញបានរៀបប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិកដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធសរុបចំនួន២ ៧៦១នាក់ (ស្ត្រីចំនួន១ ២១៤នាក់) ចុះប្រមូលទិន្នន័យស្តីពីការចិញ្ចឹមសត្វរបស់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីរៀបចំសហគមន៍ចិញ្ចឹមសត្វក្នុងខេត្តចំនួន១១ មានគ្រួសារសរុប៣៩១គ្រួសារ និងបណ្តុះបណ្តាលសហគមន៍ចិញ្ចឹមសត្វសរុបចំនួន៩១នាក់ (ស្ត្រី៥៨នាក់) ផ្សព្វផ្សាយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងបទដ្ឋានគតិយុត្តដល់អ្នកពាក់ព័ន្ធក្នុងខេត្តចំនួន១២ ដែលមានអ្នកចូលរួមសរុបចំនួន៦៧១នាក់ ក្នុងនោះស្រីចំនួន១៧០នាក់។

### ២.៣.២. ការងារនីតិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបាននិង

កំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់សំខាន់ៗចំនួន១៥ ក្នុងនោះ មានលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនត្រូវបានរៀបចំរួចរាល់ និងមួយចំនួនទៀតកំពុងស្ថិតក្នុងដំណើរការរៀបចំ និងបន្តពិភាក្សា។

**ក. លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរួចរាល់**

១. គោលការណ៍ណែនាំលេខ០៥៨០ សជស ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យប្រើប្រាស់ និងអនុវត្តសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងបសុឱសថ និងចំណីសត្វ។

២. ប្រកាសអន្តរក្រសួងលេខ១៨២០ កយ.កសក/១៩ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ស្ដីពីការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ជូនមន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ។

៣. ប្រកាសលេខ៤១៤ ប្រក.កសក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិតលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ។

**ខ.លិខិតបទដ្ឋានគតិយុត្តដែលកំពុងពិនិត្យ បន្តការរៀបចំ និងពិភាក្សា**

១. អនុក្រឹត្យស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតផលសត្វ។

២. អនុក្រឹត្យស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃបឋមផលិតសត្វ។

៣. ប្រកាសស្ដីពីនីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីវត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ។

៤. ធ្វើការកែលម្អប្រកាសអន្តរក្រសួងស្ដីពីសេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥. ប្រកាសស្ដីពីនីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

៦. ប្រកាសស្ដីពីនីតិវិធីចុះបញ្ជី និងការគ្រប់គ្រងសហគមន៍សុខភាពសត្វនិងផលិតកម្មសត្វ។

៧. ប្រកាសស្ដីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម សារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចេញ នាំចូល ផលិតលាយផ្សំ និងវេចខ្ចប់ជាថ្មី។

៨. ប្រកាសអន្តរក្រសួងស្ដីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វនិងផលិតកម្មសត្វរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌។

៩. កែសម្រួលប្រកាសស្ដីពីនីតិវិធីនៃការជ្រើសរើស ការបណ្ដុះបណ្ដាល ការគ្រប់គ្រងឱ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ។

១០.ប្រកាសស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេសបសុព្យាបាល សម្រាប់ចរាចរណ៍សត្វនិងផលិតផលសត្វ។

**២.៣.៣. ការងារចុះបញ្ជិកាចំណីសត្វ និងបសុឱសថ**

ក្រុមហ៊ុនចំណីសត្វចំនួន២៩ក្រុមហ៊ុន បានចុះបញ្ជិកាសរុប៦៨២មុខ ក្នុងនោះ ចំណីសត្វចំនួន៤៥៣មុខ សារធាតុបន្ថែមចំនួន២០៦មុខ និងវត្ថុធាតុដើមចំនួន២៣មុខ។ ក្រុមហ៊ុនបសុឱសថចំនួន១៥ក្រុមហ៊ុន បានចុះបញ្ជិកាសរុប៦៨៥មុខ ក្នុងនោះបសុឱសថចំនួន៥២៦មុខ និងវ៉ាក់សាំងចំនួន១៥៩មុខ។

**២.៣.៤. ការងារអធិការកិច្ច**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចាត់មន្ត្រីចុះធ្វើអធិការកិច្ចប្រកាសប្រតិវេទន៍ចំណីសត្វ និងបសុឱសថនៅតាមដេប៉ូលក់ចំណីសត្វ និងបសុឱសថក្នុងបណ្ដារាជធានី ខេត្តចំនួន៥៥ដេប៉ូ។ ជាលទ្ធផលមន្ត្រីជំនាញបានរកឃើញនូវចំណុចខ្វះខាតមួយចំនួន មិនទាន់បាន

អនុវត្តតាមបមាណីយឱ្យបានត្រឹមត្រូវដូចជា៖

១).ក្រុមហ៊ុនភាគច្រើនមិនទាន់បានរៀបចំឯកសារប្រកាសប្រតិវេទន៍បានសមស្របសម្រាប់មន្ត្រីចុះធ្វើអធិការកិច្ចនូវចំណីសត្វ និងបសុឱសថ ២).ក្រុមហ៊ុនមួយចំនួនបានប្រើប្រាស់សំបកវេចខ្ចប់ពុំត្រឹមត្រូវតាមការណែនាំ ឬតាមប្រភេទចំណីសត្វ (ក្លែងបន្លំស្លាកសញ្ញាព័ត៌មាន) និង ៣).ការលក់ចំណីសត្វ និងបសុឱសថមិនបានបកប្រែជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ចំណី និងបសុឱសថ។ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វបានណែនាំដល់ក្រុមហ៊ុន ដែលនៅខ្វះចន្លោះខាងលើ ត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តដែលបានចូលជាធរមាន។

## ២.៤. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ

### ២.៤.១.ការងារស្រាវជ្រាវសុខភាពសត្វ

បច្ចុប្បន្នវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺឆ្លងសត្វសំខាន់ៗ ពិនិត្យកោសិកា/ជាលិកា វះពិនិត្យសត្វ ពិនិត្យគ្រាប់ឈាម វិភាគចំណីសត្វ ភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ កាកសំណល់បសុឱសថ ផលិតមេជីវិត ធ្វើការបង្កក ពិនិត្យគុណភាព និងបណ្តុះបណ្តាលមន្ត្រីជំនាញលើការងារស្រាវជ្រាវ។

**ក.ធ្វើរោគវិនិច្ឆ័យជំងឺសត្វ**

គោ ក្របី ជ្រូក បក្សី ឆ្កែ ឆ្មា ស្វា ចៀម ពពែមានដូចជា ជំងឺផ្តាសាយបក្សី ញូវកាស ប៉េស្តទា អាសន្នរោគប៉េស្តជ្រូក ជ្រូកត្រចៀកខៀវ សាល់ម៉ូណែលឡូស៊ីស អីកូលី កូលីហ្វម ប៉េស្តជ្រូកអាហ្វ្រិក ក្លូស្ត្រីឌីយ៉ូម សារទឹក អុតក្តាមបូសខ្យល់ ឈាមខ្មៅ រលូតកូន ឆ្កែឆ្កួត ឡិបតូស្ពីរ៉ូស៊ីស ស៊ីហ្សេលឡា ប៊ីវីរុស អេសអរវី ធីអិលវី កាំហ្វីឡូបាក់ទែរលោកទងសួត។ ក្រៅពីនោះមានជំងឺបណ្តាលមកពីចំណីអាហារ (សាច់ និងផលិតផលសាច់សត្វ ចំណីសត្វ ទឹកដោះគោ ស្បែកគោ) និងជំងឺបង្កដោយប៉ារ៉ាស៊ីតនៅលើសត្វ។ ឆ្នាំ២០១៩ វិទ្យាស្ថានបានយកវត្ថុវិភាគមកធ្វើរោគវិនិច្ឆ័យជំងឺសរុបចំនួន ២៧ ៧៧១វត្ថុវិភាគ ក្នុងនោះរកឃើញ វត្ថុមានជំងឺប៉េស្តជ្រូកអាហ្វ្រិកក្នុងខេត្តចំនួន០៥គឺ ខេត្តរតនៈគិរី ត្បូងឃ្មុំ ស្វាយរៀង តាកែវ និងខេត្តកណ្តាល។ បន្ថែមពីនេះ វិទ្យាស្ថានបានអង្កេតតាមដាននូវវត្ថុមានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងរាជធានី ខេត្តចំនួន១០ (ភ្នំពេញ កំពត កណ្តាល កំពង់ចាម កំពង់ធំ មណ្ឌលគីរី ព្រៃវែង សៀមរាប ស្វាយរៀង និងខេត្តតាកែវ) រកឃើញវត្ថុមានវីរុសផ្តាសាយបក្សី H5N6 H7N4 និង H9N2 និងជំងឺឆ្កែឆ្កួតចំនួន០២ករណី នៅខេត្តបន្ទាយមានជ័យ និងខេត្តស្វាយរៀង។

**ខ. វិភាគចំណីសត្វ**

វិភាគគុណភាពចំណីសត្វបាន២៤៨ប្រភេទ ដោយពិនិត្យទៅលើប៉ារ៉ាម៉ែតសំខាន់ៗមួយចំនួនដូចជា ប្រូតេអ៊ីន ខ្លាញ់ ផូស្វរ សារធាតុសសៃ សំណើម ផេះ ជាតិម្សៅ និងវត្ថុធាតុដើមផ្សំចំណីសត្វ ដើម្បីធានាថាចំណីសត្វដែលដាក់លក់នៅលើទីផ្សារពិតជាមានគុណភាពល្អត្រឹមត្រូវប្រាកដមែន និងបានចុះទៅសិក្សាពីសក្តានុពលដំណាំចំណីសត្វនៅតាមបណ្តាលខេត្តមួយចំនួន។

**គ. ភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ**

ភាពស៊ាំនឹងឱសថប្រឆាំងនឹងមេរោគកំពុងចោទជាបញ្ហាដល់សុខភាពមនុស្ស សត្វ និងបរិស្ថាននៅក្នុងប្រទេសជាច្រើននៅលើពិភពលោក។ ការប្រើប្រាស់អង់ទីប៊ីយ៉ូទិកនៅក្នុងការចិញ្ចឹមសត្វនៅកម្ពុជា អាចនាំទៅរកភាពស៊ាំនឹងឱសថ ដោយសារមិនមានការគ្រប់គ្រងច្បាស់លាស់។ ឆ្លើយតបទៅនឹងបញ្ហានេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបាន និងកំពុងរៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងការគ្រប់គ្រងការប្រើប្រាស់បសុឱសថក្នុងផលិតកម្មសត្វ ក៏ដូចជាគោលការណ៍ណែនាំផ្នែកបច្ចេកទេស ដើម្បីបញ្ចៀសហានីភ័យដែលអាចកើតមានតាមរយៈការប្រើប្រាស់ឱសថក្នុងផលិតកម្មសត្វ។ វិទ្យាស្ថានក៏បានធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពនៃភាពស៊ាំនឹងបសុឱសថនៅកម្ពុជា ដោយវិភាគលើវត្ថុវិភាគសាច់ជ្រូក និងសាច់មាន់ចំនួន៤៩៦វត្ថុវិភាគមកពីទីផ្សារក្នុងរាជធានី ខេត្តទាំង២៥

ដែលលទ្ធផលបង្ហាញថា សាច់ទាំងនោះមានការប្រឡាក់ប្រឡូសបាក់តេរីសាល់ម៉ូណែលឡា (សាច់ជ្រូក៣១% និងសាច់មាន់៤៥%) និងស្តាហ្វីឡូកុកគុស (សាច់ជ្រូក៣១% និងសាច់មាន់៤២%)។

**ឃ. វិភាគកាកសំណល់បសុឱសថ**

សមត្ថភាពមន្ត្រីមន្ទីរពិសោធន៍វិភាគគុណភាពបសុឱសថ និងកាកសំណល់បសុឱសថ បានពង្រឹងតាមរយៈការចូលរួមសាកល្បងម៉ាស៊ីន UPLC-MS MS លើការវិភាគបសុឱសថ សំណល់បសុឱសថ នៅក្នុងនិងក្រៅប្រទេស។ មន្ទីរពិសោធន៍បានទទួលឧបករណ៍ Cham II ជាប្រភេទតេស្តដែលផ្តល់លទ្ធផលឆាប់រហ័សសម្រាប់ប្រើប្រាស់ ដើម្បីពិនិត្យរកកាកសំណល់បសុឱសថនៅក្នុងសាច់ និងផលិតផលមានដើមកំណើតពីសត្វផងដែរ។ ដូច្នេះវិទ្យាស្ថានអាចវិភាគរកកាកសំណល់បសុឱសថបានមួយចំនួន ប៉ុន្តែមិនទាន់រលូននៅឡើយ ដោយសារខ្វះខាតសារធាតុគីមី និងសម្ភារឧបករណ៍មួយចំនួនទៀត។ វិទ្យាស្ថានបានវិភាគរកសំណល់អង់ទីប៊ីយ៉ូទិកក្រុមតេត្រាស៊ីគ្លីន និងស៊ុលហ្វា នៅក្នុងសាច់ជ្រូកចំនួន០៨វត្ថុវិភាគយកមកពីផ្សារលើ និងផ្សារវាលរេញ ខេត្តព្រះសីហនុ ដែលលទ្ធផលនៃការវិភាគបង្ហាញថាមិនមានវត្ថុមានកាកសំណល់អង់ទីប៊ីយ៉ូទិក។ វិទ្យាស្ថានក៏បានសហការជាមួយអ្នកជំនាញជនជាតិរុស្ស៊ី ដើម្បីធ្វើការពិសោធន៍សាកល្បងបសុឱសថជំរុញការលូតលាស់ដែលមិនមែនជាអ័រម៉ូនលើសត្វជ្រូក គោ និងមាន់នៅរាជធានីភ្នំពេញ កំពង់ចាម និងតាកែវ។ ក្រៅពីនោះ វិទ្យាស្ថានបានបង្កើនសមត្ថភាពដល់មន្ត្រីជំនាញតាមរយៈការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវចំនួន៣១៦រូប និងអង្កេត តាមដាន ស្រាវជ្រាវជំងឺចំនួន៣៣៦រូប ធ្វើរោគវិនិច្ឆ័យចំនួន១៨រូប និងវិភាគអេពីដេមីសាស្ត្រក្នុងការបង្ការនិងទប់ស្កាត់ជំងឺចំនួន៦៥រូប។

**ង. ការងារស្រាវជ្រាវផលិតកម្មសត្វ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានស្ថានីយពិសោធន៍ស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វចំនួន២កន្លែងសម្រាប់ធ្វើការពិសោធន៍ស្រាវជ្រាវពូជសត្វគឺ ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ មានគោសរុបចំនួន១១៦ក្បាល បច្ចុប្បន្នគោសល់ចំនួន១០៤ក្បាល និងស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា ចិនមានជ្រូកសរុបចំនួន៦៥៨ក្បាល បច្ចុប្បន្នជ្រូកនៅសល់ចំនួន១៣៨ក្បាល។

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បានសិក្សាស្រាវជ្រាវពូជសត្វល្អៗ ដែលមានស្រាប់ក្នុងស្រុក ដើម្បីផលិតមេជីវិត ធ្វើការបង្កក ពិនិត្យគុណភាព បង្កាត់សិប្បនិម្មិត ដើម្បីកាត់បន្ថយការនាំចូលមេជីវិតបង្កកពីបរទេស។ នៅឆ្នាំ២០១៩នេះ វិទ្យាស្ថានបានផលិតទឹកមេជីវិតគោបង្កកចំនួន១ ៥១០កម្រិត និងបានធ្វើការចែកទៅតាមបណ្តាខេត្តនានាចំនួន៦០០កម្រិត ក្នុងនោះខេត្ត ព្រៃវែង២០០កម្រិត ពោធិ៍សាត់៨០កម្រិត តាកែវ១៨០កម្រិត និងខេត្តស្វាយរៀង១៤០កម្រិត។ នៅឆ្នាំ២០១៩នេះ បង្កាត់សិប្បនិម្មិតគោពិសោធន៍បាន៤៧ក្បាល និងបង្កើតកូនគោបាន៣៨ក្បាល។

**២.៥. ការងារពង្រឹងសមត្ថភាពអង្គភាព សេវាគាំទ្រ និងការអភិវឌ្ឍន៍ធនធានមនុស្សក្នុងផលិតកម្មសត្វ**

**២.៥.១. ការពង្រឹងការគ្រប់គ្រងអង្គភាព**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចថ្នាក់ដឹកនាំជាមួយនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន ការិយាល័យ មន្ទីរពិសោធន៍ និងស្ថានីយចិញ្ចឹមពូជសត្វស្របតាមតាមអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសលេខ៣៨១ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ស្របតាមការតែងតាំងរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជារួមមន្ត្រីបម្រើការងារសុខភាពសត្វ និង

ផលិតកម្មសត្វមានចំនួនសរុប៨៨៤រូប ស្រី១៩៧រូប ក្នុងនោះមន្ត្រីបម្រើការងារនៅថ្នាក់កណ្តាល (អគ្គនាយកដ្ឋាន) មានចំនួន២៨៨រូប ស្ត្រី៨៨រូប និងមន្ត្រីបម្រើការងារនៅទូទាំង២៥ រាជធានី ខេត្ត មានសរុបចំនួន៥៩៦រូបស្រី១០៩រូប។

### ២.៥.២ ការអភិវឌ្ឍន៍ធនធានមនុស្ស

ឆ្លើយតបទៅនឹងការកំណត់អាទិភាពនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ដល់ការបង្កើនសមត្ថភាពមន្ត្រីជាបន្តបន្ទាប់ ទាំងសមត្ថភាពរៀបចំ និងអនុវត្តផែនការ និងសមត្ថភាពបច្ចេកទេសសម្រាប់ផ្តល់សេវាសុខភាពសត្វ និងផលិតកម្មសត្វឱ្យកាន់តែប្រសើរថែមទៀត ដោយបានកៀរគរជំនួយ និងការគាំទ្រនានាពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ ផ្តោតលើអាទិភាពនៃការសិក្សាពីតម្រូវការបណ្តុះបណ្តាលទាំងចំណេះដឹង សមត្ថភាពគ្រប់គ្រង និងសមត្ថភាពបច្ចេកទេស ដែលរួមមានជាអាទិ៍ការបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រនិងកុមារ ឃោសនាអប់រំពីការប្រើប្រាស់អង់ទីប៊ីយូទិចដោយការទទួលខុសត្រូវនៅក្នុងវិស័យកសិកម្ម ការងាររដ្ឋបាលនិងបុគ្គលិក ពង្រឹងការរៀបចំ និងគ្រប់គ្រងគម្រោង ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ ជំនាញគណនេយ្យ ការរៀបចំផែនការតាមទម្រង់P3 P4 ការតាមដានត្រួតពិនិត្យ វាយតម្លៃ និងនីតិវិធីទូទាត់ថវិកា និងរៀបចំរបាយការណ៍តាមទម្រង់ M1 និង M2 ប្រកបដោយគុណភាព ដោយបានបណ្តុះបណ្តាល និងសិក្ខាសាលា០៦លើក ដែលមានអ្នកចូលរួមចំនួន៤៨០នាក់។

### ២.៥.៣ ការងាររៀបចំផែនការ

ឆ្នាំ២០១៩ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រនានា ផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម កសាងផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ សម្រាប់ត្រៀមរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារសម្រាប់អនុវត្តបន្ត ដោយធ្វើបច្ចុប្បន្នភាពលើផែនការ និងលើកទិសដៅសំខាន់ៗលើឯកសារមួយចំនួន រួមមាន (១) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ (២)ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ (៣)ផែនការថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាលប្រចាំឆ្នាំ២០២០។

### ២.៥.៤ ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

សេវាសំខាន់ៗដែលអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននិងកំពុងអនុវត្តរួមមានការត្រួតពិនិត្យ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសត្វ និងផលិតផលសត្វ ការវិភាគគុណភាពចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម សមាសធាតុគ្រប់ប្រភេទ ការផ្តល់លិខិតអនុញ្ញាតធ្វើចរាចរណ៍សត្វ និងផលិតផលសត្វ ការអនុញ្ញាតនាំចេញ នាំចូល នាំឆ្លងកាត់សត្វរស់ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតសម្រាប់បង្កើតសត្តឃាតដ្ឋាន លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម និងបង្ក្រាបល្មើសចលនាសត្វ និងផលិតផលសត្វ។ ជាផ្នែកមួយស្ថិតនៅក្នុងកម្មវិធីទី២ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វមានអនុកម្មវិធីចំនួន៥ ក្នុងឆ្នាំ២០១៩ អនុវត្តបានចំនួន៩៨,៤%។

ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ នៅឆ្នាំ២០១៩ បានប្រមូលចំណូលសរុបចំនួន ១១ ៩១៩ ៧៤៩ ៥០៨រៀល ធៀបនឹងឆ្នាំ២០១៥ មានកំណើន៧១,៣៦% និងធៀបនឹងឆ្នាំ២០១៨ មានកំណើន២៣,៣៤% ដែលក្នុងនោះថ្នាក់កណ្តាលកើនឡើង២៣,៩៨% និងរាជធានី ខេត្តកើនឡើង២២,១៦% (ក្នុងកំណើន២២,១៦%នេះ មិនមានតួលេខចំណូលឆ្នាំ២០១៩ ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តក្រចេះទេ

ព្រោះច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្តពុំបានញែកចំណូលដែលពាក់ព័ន្ធសេវាសុខភាពសត្វ និងផលិតកម្មសត្វឡើយ)។

### ២.៥.៥. ការងារសហប្រតិបត្តិការផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ និងអង្គការអន្តរជាតិលើផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ ដែលរួមមាន៖ OIE, FAO, ASEAN, EU, CHINA, ACIAR, IAEA, JICA, KOICA, AVSF, PIN, VSO, 2KR, UNIDO, DTRA។

កម្មវិធី និងគម្រោងគាំទ្រការអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ រួមមាន៖ គម្រោងថវិកាតាមកម្មវិធីរបស់រដ្ឋាភិបាល កម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន៖ អនុវិស័យជលផល និងអនុវិស័យផលិតកម្មសត្វ គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមហាអនុតំបន់មេគង្គ គម្រោងជីវៈសុវត្ថិភាពមូលដ្ឋានសម្រាប់គ្រប់គ្រងហានីភ័យជំងឺសត្វនៅកម្ពុជា គម្រោងគាំទ្រការចិញ្ចឹមសត្វដោយនិរន្តរភាព កម្មវិធីឡជីវឧស្ម័នរដ្ឋាភិបាលចិន និងកម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ (NBP)។

## ៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម

នៅក្នុងឆ្នាំ២០១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលជលផលជាសេនាធិការបានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើសនេសាទ ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយជាដើម។ល។ ដោយឡែក ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀតបានកំពុងពិនិត្យ ធ្វើវិសោធនកម្មកែសម្រួល និងអនុម័ត ដើម្បីដាក់ឱ្យអនុវត្តជានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល។

### ៣.១. ការអភិវឌ្ឍន៍សហគមន៍នេសាទ

នៅក្នុងឆ្នាំ២០១៩នេះ សហគមន៍នេសាទទូទាំងប្រទេសមានចំនួនសរុប៥១៦សហគមន៍ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រចំនួន៤១ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា១៤៧ ៥១៨គ្រួសារ។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៤២៤ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៣.២. ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅផ្នែកជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេស មានកន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង ដែលមកដល់ពេលនេះមានចំនួនសរុបទូទាំងប្រទេសចំនួន៦៧៧កន្លែង (សហគមន៍៥២៦កន្លែង)។ មកដល់ឆ្នាំ២០១៩នេះ បានបោះបង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផល៨ម៉ែត្រចំនួន២០៣បង្គោល និងកំពស់១២ម៉ែត្រចំនួន៨៧បង្គោល សាងសង់ស្នាក់ការល្បាតខ្នាតតូចចំនួន២៩ខ្នង ស្នាក់ការល្បាតខ្នាតធំចំនួន៤ខ្នង និងស្នាក់ការបេតុង៩ខ្នង ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតរួមមាន៖ បានអភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន៧ ០០០ហ.ត នៅតាមតំបន់ឆ្នេរ ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន៨០ហិកតា រៀបចំអន្លង់ត្រីមេពូជនៅតំបន់មេគង្គលើក្នុងខេត្តក្រចេះនិងស្ទឹងត្រែង លែងកូនត្រីនិងកូនបង្កងចំនួន៤,៦លានក្បាលទៅក្នុងបឹងធម្មជាតិនិងត្រីមេពូជជាច្រើនតោន ការអភិរក្សធនធានជលផលកំពុងរងគ្រោះថ្នាក់ ដូចជា អណ្តើកសរសៃ អណ្តើកសមុទ្រ កន្ធាយក្បាលកង្កែប ក្រពើត្រី ផ្សោតទឹកសាប ផ្សោតទឹកប្រៃ និងសេះសមុទ្រ។ល។

ដែលធ្វើឱ្យចំនួនកើនឡើងចន្លោះពី៥-១០% ទម្លាក់ប្រអប់បេតុងចំនួន១៥៥ប្រអប់សម្រាប់ជាជម្រកសិប្បនិម្មិត និងរារាំងការនេសាទដោយអួនអូស និងចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើចំនួន៤០០កសិដ្ឋាន។

### ៣.៣. ការបង្ក្រាបបទល្មើសជលផល

មន្ទីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ បានសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ទោះបីខ្វះកម្លាំង មធ្យោបាយធ្វើដំណើរ និងថវិកាក៏ដោយ ពិសេសបានយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលមិនឱ្យមានការលួចចូលធ្វើនេសាទអណាធិបតេយ្យឡើយ។ លទ្ធផលជាក់ស្តែង បង្ក្រាបបទល្មើសជលផលសរុបចំនួន៣ ១០១ករណី (សមុទ្រ២២៨ករណី) ប្រៀបធៀបឆ្នាំមុនថយចុះចំនួន១០៣ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន ២ ៨១៧ករណី ពិន័យអន្តរការណ៍ចំនួន ១៣១ករណី បញ្ជូនទៅតុលាការចំនួន ១៥៣ករណី ជាប់ពន្ធនាគារចំនួន ១០២នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន ២៤៣ ៦៨៧ ០០០ រៀល។ ចំពោះវត្ថុតាងរឹបអូស និងបំផ្លាញចោលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង១ ១៤៩ ២០២ម៉ែត្រ បង្គោល/ចម្រឹងចំនួន៥៧៥ ៧៣១ដើម លូស្បៃមុង និងសាច់អួនចំនួន ២៩ ៩៨១មាត់ ឧបករណ៍ឆក់ត្រីចំនួន៤០២គ្រឿង សម្រាស់ចំនួន៦៣ ១៨៣ម៉ែត្រក្រឡា លបកែច្នៃចំនួន ១០ ៩៤៤គ្រឿង និងលែងត្រីចម្រុះចូលក្នុងធម្មជាតិចំនួន ៤៧ ២៨៦គីឡូក្រាម។

បានប្រជុំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍ថ្នាក់ដឹកនាំនៅតាមមូលដ្ឋានចំនួន២០០វគ្គ អ្នកពាក់ព័ន្ធចូលរួមចំនួន ៤ ១៨៦នាក់ ក្នុងនោះស្ត្រីចំនួន ៩៣៨នាក់។

### ៣.៤. ផលនេសាទ និងវារីវប្បកម្ម

ផលនេសាទ និងវារីវប្បកម្មសរុបមានចំនួន៩០៨ ៥០៨តោន ថយចុះជាងឆ្នាំមុនចំនួន១ ៦៤៥តោន ឬថយ ០,១៨% ក្នុងនោះមាន៖

- ផលនេសាទទឹកសាប: ៤៧៨ ៨៥០តោន ថយចុះ៥៦ ១៥៥តោន ស្មើនឹង-១០,៥០%
- ផលនេសាទសមុទ្រ: ១២២ ២៥០តោន កើនឡើង១ ១៥០តោន ស្មើនឹង០,៩៥%
- ផលវារីវប្បកម្ម: ៣០៧ ៤០៨តោន កើនឡើង៥៣ ៣៦០តោន ស្មើនឹង២១,០០%

ដោយឡែក ការចិញ្ចឹមក្រពើឆ្នាំ២០១៩ អនុវត្តបាន៤១២ ៨១១ក្បាល កើនលើសឆ្នាំមុន២ ៨១១ក្បាល និងផលិតកូនត្រីពូជបាន២២២ ០០០ ០០០ក្បាល កើនលើសឆ្នាំមុន១២ ០០០ ០០០ក្បាល។

**ក្រាហ្វិក៣២៖ ផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ២០១៥-២០១៩**




### ៣.៥. ការបង្កើតស្រះជម្រកត្រីសហគមន៍

មកដល់ឆ្នាំ២០១៩នេះ ខណ្ឌរដ្ឋបាលជលផលខេត្តបានបង្កើតស្រះជម្រកត្រីសហគមន៍បានចំនួន៨៩៥កន្លែង ក្នុងនោះខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។

### ៣.៦. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃ និងគុណភាព

ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាពមានសក្តានុពលមួយយ៉ាងសំខាន់ សម្រាប់អនុវិស័យជលផលក្នុងការចូលរួមចំណែកផ្គត់ផ្គង់សន្តិសុខស្បៀង អាហារូបត្ថម្ភ ជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ក្នុងឆ្នាំ២០១៩នេះ រដ្ឋបាលជលផលបានរៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួនរួមមាន៖ បានរៀបចំសេចក្តីព្រាងស្តីពីផែនការសកម្មភាពយុទ្ធសាស្ត្រនៃខ្សែច្រវាក់តម្លៃជលផល សម្រាប់អនុវត្តឆ្នាំ២០២០-២០៣០ បានរៀបចំគោលការណ៍ស្តីពីអនុវត្តអនាម័យល្អ (GHP) ការផលិតល្អ (GMP) និងគោលការណ៍ហាសិប (HACCP) និងបានបោះពុម្ពចំនួន១ ០០០ច្បាប់ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និងបែបបទស្នើសុំវិញ្ញាបនបត្រសុខភាពសម្រាប់ការនាំចេញ និងនាំចូលផល ផលិតផលជលផល បានរៀបចំសេចក្តីព្រាងប្រកាសដាក់ឱ្យប្រើប្រាស់កម្មវិធីតាមដានលើសំណល់បសុឱសថ និងសារធាតុគីមីក្នុងផលិតផលវារីវប្បកម្ម បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការចុះបញ្ជីលើផល ផលិតផលជលផលសម្រាប់ការនាំចេញ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តអនាម័យល្អ និងការអនុវត្តផលិតកម្មល្អសម្រាប់ផល ផលិតផលជលផល។ ទន្ទឹមនឹងនេះ រដ្ឋបាលជលផលបាននិងកំពុងយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផល ផលិតផលជលផលនាំចេញ នាំចូល ព្រមទាំងបានអនុវត្តនូវកម្មវិធីតាមដានលើសំណល់នៃបសុឱសថ និងសារធាតុគីមីក្នុងផលិតផលវារីវប្បកម្ម ដើម្បីជំរុញការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

### ៣.៧. ការសិក្សាស្រាវជ្រាវជលផល

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការល្អ ដោយបានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដូចជា EU, UNIDO, MRC, FAO, WWF, IUCN World Fish Center ជាដើម។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់ ពិសេសលើសកម្មភាពមួយចំនួនដូចជា៖ ការសិក្សាស្រាវជ្រាវជីវសាស្ត្រវារីសត្វ សិក្សាតាមដានផលនេសាទតាមដាយត្រី សិក្សាតាមដានប្រភេទកូនត្រី សិក្សា DNA ប្រភេទត្រីទឹកសាប សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍ និងការពងកូនរបស់ត្រីនៅតំបន់មេគង្គលើ និងសិក្សាតាមដានសុខភាពអេកូឡូស៊ីនៅកម្ពុជា (Ecological Health Monitoring in Cambodia)។ លទ្ធផលស្រាវជ្រាវត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល។

### ៣.៨. ការងារហិរញ្ញវត្ថុ

ប្រាក់ចំណូលពីសេវានានាផ្នែកជលផលមានចំនួន ២ ២៨៧ ៥០០ ១៦៨រៀល ក្នុងនោះ មានប្រាក់ចំណូលពីថ្លៃឈ្នួលដាយត្រីចំនួន ១ ០១៧ ៦១៦ ៥០០រៀល ថ្លៃឈ្នួលដែននេសាទសមុទ្រចំនួន ៦០៣ ២២២ ៥០០រៀល ចំណូលកិច្ចសន្យាម៉ៅការចិញ្ចឹមក្រពើរដ្ឋចំនួន ១ ០០០ ០០០រៀល សេវាសាធារណៈចំនួន ២២០ ៤៨០ ០០០រៀល ការជួលទ្រព្យសម្បត្តិអចល័តចំនួន ១៥៣ ៧៨៣ ៧៩៨រៀល ផលពីការផាកពិន័យចំនួន ១៣០ ៣០៧ ០០០រៀល ផលហិរញ្ញវត្ថុ (សំណែស ចំណាយ) ចំនួន ៥៦ ៧១០ ៤០០រៀល។

## ៤. លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ខ្ពស់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរឹង ព្រមទាំងសម្រេចបាននូវលទ្ធផលធំៗជាច្រើន ដូចជាបានចេញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះពីមន្ទីរកសិកម្មរាជធានីខេត្ត ទៅជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត និងបានដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ ជាមួយគ្នានេះ បានចេញប្រកាសលេខ៦៥២ ប្រក.កសក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីការផ្ទេរធនធាន និងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ

និងរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ អនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទី និងភារកិច្ចរបស់ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ច និងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើ និងជលផល ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងវាយតម្លៃថាមានប្រសិទ្ធភាពខ្ពស់។

ការគ្រប់គ្រងព្រៃឈើ គិតមកដល់ឆ្នាំ២០១៩ នេះ ទទួលបានលទ្ធផលដូចខាងក្រោម៖

## ៤.១ ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ

### ក- សហគមន៍ព្រៃឈើ

គិតត្រឹមឆ្នាំ២០១៩ បានបង្កើតសហគមន៍ព្រៃឈើសរុបចំនួន៦៣៦សហគមន៍ គ្របដណ្តប់លើផ្ទៃដី៥១៦ ៨១៧ ហ.ត ក្នុងនោះ ក្រសួងបានចេញប្រកាសចំនួន៤៩៤សហគមន៍ លើផ្ទៃដី៤៤៣ ៣២៩ហ.ត និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤៩៤សហគមន៍ លើផ្ទៃដី៣៦៩ ៧១០ហ.ត និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៩៤សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ៦៣ ២៥៤ហ.ត។ ការបង្កើតសហគមន៍ព្រៃឈើមានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់។

**ចំនួនសហគមន៍ព្រៃឈើឆ្នាំ២០១៥-២០១៩**




| | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|
| ចំនួនសហគមន៍ព្រៃឈើសរុប | 499 | 580 | 610 | 614 | 636 |
| ចំនួនសហគមន៍ព្រៃឈើទទួលបានប្រកាស | 404 | 404 | 464 | 484 | 494 |

### ខ- គម្របព្រៃឈើ

ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១០-២០១៤ តាមទិន្នន័យគម្របព្រៃឈើនៅឆ្នាំ២០១០ មានផ្ទៃដីសរុបទំហំ១០ ៣៦៣ ៧៨៩ហ.ត ស្មើនឹង៥៧,០៧% និងផ្ទៃដីពុំមានគម្របព្រៃឈើមានទំហំសរុប ៧ ៧៩៦ ៨៨៥ ស្មើនឹង៤២,៩៣% នៃផ្ទៃដីសរុប។ នៅឆ្នាំ២០១៤ ឃើញថា ផ្ទៃដីគម្របព្រៃឈើមានទំហំ៨ ៩៨៥ ១៦៣ហ.ត ស្មើនឹង៤៩,៤៨% និងដីមិនមែនគម្របព្រៃឈើមានទំហំសរុប៩ ១៧៥ ៥១០ហិកតា ស្មើនឹង៥០,៥២% នៃផ្ទៃដីសរុប។ បច្ចុប្បន្នបាននិងកំពុងធ្វើការបកស្រាយគម្របព្រៃឈើឆ្នាំ២០១៨ ក្នុងនោះបានបញ្ចប់ការទាញយករូបភាពផ្កាយរណប (Landsat 8) និងបញ្ចប់ការបកស្រាយចំណាត់ថ្នាក់ប្រភេទព្រៃឈើនីមួយៗ។

### គ- ការគ្រប់គ្រងផល អនុផលព្រៃឈើ

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៧១គ្រឿង និងយានយន្តចំនួន ១០៧គ្រឿង ជូនក្រុមហ៊ុនចំនួន ០៦ និងអ្នកស្នើសុំចំនួន ០៣ នាក់

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន១៣ និងអ្នកស្នើសុំចំនួន ០៥ ដែលមានឈើហ៊ុបមូលចំនួន ៣៣ ១០៣ម៉ែត្រគ្រីគុណ ឈើអារចំនួន៤ ១៨៤ម៉ែត្រគ្រីគុណ ឈើប្រណីតចំនួន ១០៨ម៉ែត្រគ្រីគុណ និង ៧៤៣គីឡូក្រាម ឈើជ្រុងចំនួន ២ ៧៩០ម៉ែត្រគ្រីគុណ កូនឈើចំនួន ២០០ ០១៨ដើម អុសចម្រុះចំនួន ៥៣ ១៨១ស្ទែរ ជន្លង់ម្រេចចំនួន ២៣៩ដើម សសរចំនួន ៥៦ដើម ធ្យូងចំនួន ១៨ ២១៧គីឡូក្រាម គ្រាប់ស្លែង

ចំនួន ៥៣៧គីឡូក្រាម គល់ផ្ចង់និងគល់បេងចំនួន ៥៩០គីឡូក្រាម ពកបេងចំនួន ៣៩៤គីឡូក្រាម និងជ័រទឹកចំនួន ៤៨២តោន

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើសាជាថ្មី ជូនក្រុមហ៊ុន ឈុន ហុង ក្រុមហ៊ុនទ្រីភាព និងអ្នកស្នើសុំមានលោក អ៊ឹង ឃ្លូ លោក យ៉េង ឃន លោក ជន សុរិន។

**ឃ- ការងារដាំឈើ**

- បានថែទាំចម្ការឈើចាស់ ចម្ការពូជឈើ និងឡូត៍បង្ហាញកសិ-រុក្ខកម្មចំនួន ៩៨០ហិកតា នៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន ០៤ ទីតាំង ស្ថិតក្នុងខេត្តកំពង់ធំ សៀមរាប ព្រះសីហនុ និងខេត្តស្វាយរៀង

- បានថែទាំចម្ការរុក្ខទិវាសរុបចំនួន ៦០ហិកតា ស្ថិតនៅក្នុងខេត្តកំពត កណ្តាល តាកែវ កំពង់ធំ និងខេត្តក្រចេះ បានរៀបចំពិធីរុក្ខទិវាថ្នាក់ជាតិ ០៩ កក្កដា ឆ្នាំ២០១៩ ដែលប្រារព្ធឡើងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ លើផ្ទៃដីទំហំ ១០ហិកតា ដោយបានដាំកូនកកោះ គគីរ ផ្ចង់ អង្កាញ់ និងក្រញូងចំនួន១០ ៦៩៥ដើម ព្រមទាំងបានបោះបង្គោលថ្ម និងព័ទ្ធរបងលួសប្រវែង១ ៥០០ម៉ែត្រ

- បានបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្មក្នុងសហគមន៍ចំបក់ហោះ ស្ថិតនៅស្រុករវៀងខេត្តព្រះវិហារ និងបានដាំរួចលើផ្ទៃដីទំហំ ១២ហិកតា គ្រប់ចំនួនតាមផែនការប្រចាំឆ្នាំ២០១៩ មានដំណាំកសិកម្ម (កូនស្វាយចន្ទីចំនួន ២ ៥០០ដើម ចេកចំនួន ១ ៣៥០ដើម និងកូនឈើប្រភេទគ្រញូង បេង និងផ្ចង់ចំនួន ២ ៧០០ដើម)។

**ង- ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**

- បានពិនិត្យបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ១០ក្រុមហ៊ុន ស្មើនឹង ១០កន្លែង ហើយបានពិនិត្យពន្យារសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើមានចំនួន ១៩ក្រុមហ៊ុន ស្មើនឹង ២២កន្លែង និងបានចុះសិក្សាអត្រាកែច្នៃកូនឈើអង្កត់ផ្ចិតទំហំ ១៥-៣០ស.ម ចំនួន ០៥ក្រុមហ៊ុន ស្មើនឹង ០៦កន្លែង

- បាននាំចេញផលិតផលរានទេវតា គ្រឿងសង្ហារិម ជើងសាឡុង និងឈើអារកែច្នៃ (ទោល-បន្ទារអតិបរមា ២៥ស.ម) ទៅក្រៅប្រទេស (ជប៉ុន អាមេរិក ចិន វៀតណាម និងថៃ) មានបរិមាណចំនួន ២ ១៧៨ ម៣ និងជ័រទឹកចំនួន ២៩១តោន ដោយក្រុមហ៊ុនចំនួន០៧

- បាននាំចូលផលិតផលប្រភេទឈើ **MDF, Wood Panel, CHANFUTA,** (ពីប្រទេសចិន កុងហ្គោ កាមេរូន និងអ៊ូហ្គង់ដា) និងឈើកែច្នៃមានបរិមាណចំនួន ១ ៦៨១ម៣ ដោយក្រុមហ៊ុនចំនួន ០៤

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១៣ មានបរិមាណផលិតផលឈើកែច្នៃ (ទោលបន្ទារអតិប្បរមា២៥ស.ម ប្រភេទលេខ១ ក្តារការ៉ូក្រាល គ្រឿងសង្ហារឹម និងជើងសាឡុង) ចំនួន ២ ៨៣០ម៣ ឈើអាកាស្យាកាត់ជាកង់ៗចំនួន ១ ៦៣២ស្ទែរ និងអនុផលព្រៃឈើ (ជ័រទឹក សង្ហារិមឬស្សីកែច្នៃ និងឈើចន្ទន៍ ក្រស្នាកែច្នៃ) ចំនួន ២៦៨តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន០៤ មានបរិមាណផលិតផលឈើកែច្នៃ (**Wood Panel, CHANFUTA, MDF, DOUSSIE** និង **MUSSIVI**) ចំនួន ១ ៧៥២ ម៣

- បានសម្របសម្រួលទំនាក់ទំនងការងារ និងចូលរួមកិច្ចប្រជុំក្រៅប្រទេសចំនួន២៧លើក សិក្ខាសាលាក្រៅប្រទេសចំនួន២៦លើក សន្និសិទក្រៅប្រទេសចំនួន០៧លើក និងទស្សនកិច្ចសិក្សាក្រៅប្រទេសចំនួន០៥លើក

- គម្រោងសហប្រតិបត្តិការក្នុងរដ្ឋបាលព្រៃឈើសរុបមានចំនួន ១០គម្រោង។

## ៤.២ ពង្រឹងការគ្រប់គ្រងសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ និងសត្វព្រៃ

**ក-ការពង្រឹងការស្រាវជ្រាវ ថែរក្សា និងអភិវឌ្ឍសត្វព្រៃ និងជីវចម្រុះ**

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន១០លើក នៅខេត្តមណ្ឌលគិរី ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ កោះកុង និងរតនគិរី ដោយបានរឹបអូសសាច់សត្វជ្រូកព្រៃចំនួន៩៦គីឡូក្រាម សាច់ សត្វឈ្លូសចំនួន២៩ គីឡូក្រាម រណាយន្តចំនួន០២គ្រឿង ដោះអន្ទាក់ចំនួន៣០ខ្សែ បានឃើញជ្រូកព្រៃ០១ក្បាល ងាប់ដោយជាប់អន្ទាក់ សត្វត្រកួតរស់ចំនួន១៥ក្បាល សត្វអន្សងរស់ចំនួន០២ក្បាល អណ្តើករស់ចំនួន០៨ក្បាល

- បានសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន ដោយចុះផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃចំនួន០៤លើក នៅខេត្តមណ្ឌលគិរី កំពង់ធំ ពោធិ៍សាត់ និងខេត្តក្រចេះ ដោយមានអ្នកចូលរួម សរុបចំនួន៤៥០នាក់ (ស្ត្រីចំនួន២៧៧នាក់) និងបានចែកជូនផ្ទាំងរូបភាពអប់រំ៤៥០សន្លឹក និងអាវយឺតចំនួន៤៥០អាវ

- កសិដ្ឋានចំនួន០៦កន្លែង បានថែរក្សា និងបង្កាត់ពូជស្វាក្តាមសរុបចំនួន៥៣ ២១៣ក្បាល ក្នុងនោះ កូនកើត ក្នុងខែចំនួន១៥ ៦៩៧ក្បាល

- ដឹកជញ្ជូនក្នុងស្រុកចំនួន៣ ៧៧៨ក្បាល និងដឹកជញ្ជូនឆ្លោះទៅក្រៅប្រទេសមានចំនួន ១៥ ៤២៩ក្បាល

- បានផ្តល់លិខិតអនុញ្ញាតថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារចំនួន៤១ច្បាប់ ក្នុងនោះ ៣០ច្បាប់សម្រាប់ ថែរក្សាសត្វត្រចៀកកាំ និង ១១ច្បាប់ទៀតសម្រាប់ថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតមានទីតាំងស្ថិតនៅរាជធានី ភ្នំពេញ ខេត្តកំពង់ចាម ព្រៃវែង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ កោះកុង តាកែវ សៀមរាប បន្ទាយមានជ័យ រតនគិរី និងមណ្ឌលគិរី

- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនផាត់ភ្នំពេញឯ.កចំនួន០២ច្បាប់ មានសត្វដំរីស្រុក ញីចំនួន០២ក្បាល ដឹកចេញពីស្រុកកែវសីមា ខេត្តមណ្ឌលគិរី ឆ្ពោះទៅកាន់សួនសត្វភ្នំពេញ សាហ្វារី រាជធានីភ្នំពេញ និង ០១ច្បាប់ទៀតមានសត្វកវែងចំនួន០២ក្បាល ដឹកចេញពីខេត្តកោះកុង ឆ្ពោះទៅកាន់សួនសត្វភ្នំពេញសាហ្វារី រាជធានីភ្នំពេញ

- បានចុះត្រួតពិនិត្យកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាម និងជំរុញការចុះបញ្ជីថែរក្សា សត្វព្រៃជាលក្ខណៈគ្រួសារចំនួន ២៩លើក ត្រូវជា ២៦២ទីតាំង ក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កំពត ព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង សៀមរាប ព្រះវិហារ កំពង់ធំ រតនគិរី បាត់ដំបង កែប ក្រចេះ ស្វាយរៀង ព្រៃវែង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តតាកែវ។

**ខ-ការសិក្សាស្រាវជ្រាវ និងស្តារព្រៃឈើឡើងវិញ**

- បានរៀបចំវគ្គបណ្តុះបណ្តាលសរុបចំនួន១៨លើកស្តីពីការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពគម្រោង ការសរសេរផែនការគ្រប់គ្រងព្រៃសហគមន៍ និងការវិភាគទិន្នន័យសារពើភ័ណ្ឌព្រៃឈើ បច្ចេកទេសធ្វើឲ្យរហាល និងការធ្វើអនាម័យព្រៃ ការងារគ្រប់គ្រងស្តារព្រៃឈើឡើងវិញ ការអនុវត្តកសិ-រុក្ខកម្មទប់ស្កាត់ការហូរច្រោះដី កសិកម្មចម្រុះ ការគ្រប់គ្រងសារធាតុចិញ្ចឹម ការប្រែប្រួលអាកាសធាតុ ការផលិតផែនទី ការផ្សព្វផ្សាយពីផែនការ អេកូកសិកម្ម ការគ្រប់គ្រងដីប្រកបដោយនិរន្តរភាព ការប្រើប្រាស់ឧបករណ៍ GPS ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងសិទ្ធិរបស់សមាជិកសហគមន៍ព្រៃឈើ ការកត់ត្រាទិន្នន័យទីវាលតាមកម្មវិធីល្បាតស្មាត (SMART) ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងការប្រើប្រាស់ជ្រូន ការអភិរក្សសត្វព្រៃ និងកម្មវិធីស្តារសត្វទោចមុជនៅឧទ្យានអង្គរ ដែលមានអ្នកចូលរួមសរុបចំនួន ៧២៨នាក់ ក្នុងនោះមានស្ត្រីចំនួន ២៩៧នាក់

- បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងការអនុវត្តគម្រោងពីឆ្នាំ២០១១-២០១៩ និងរៀបចំផែនការសកម្មភាពថវិកាឆ្នាំ២០២០ នៅខេត្តកោះកុង និងខេត្តមណ្ឌលគិរី ដោយមានអ្នកចូលរួមសរុបចំនួន១៣២នាក់ (មានស្ត្រី១៨នាក់)។

## ៤.៣ ការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ

- បានកំពុងថែរក្សាសត្វព្រៃចំនួន ១ ៤៨៦ក្បាល (បក្សីចំនួន ៥៣ប្រភេទ ថនិកសត្វចំនួន ៤១ប្រភេទ និងល្មូនចំនួន ១៣ប្រភេទ) និងសង្គ្រោះសត្វព្រៃថ្មីចំនួន ១ ១០៥ក្បាល និងព្យាបាលចំនួន ២៧០ក្បាល

- បានស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ១ ២៧៥ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗ ចំនួន០៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ដោះលែងក្រពើភ្នំពូជសុទ្ធ២០ក្បាល ទៅក្នុងដែនជម្រកធម្មជាតិនៅស្ទឹងខៀវខេត្តកោះកុង និងតាមដានប្រចាំឆ្នាំវត្តមានក្រពើភ្នំតាមវិធីសាស្ត្រពំនុះកាត់ទទឹងដែនជម្រកនៅតំបន់ឆាយរាប អូរសោម ស្ទឹងដាច់ ដំណាក់ត្លុង ស្ទឹងអារ៉ែង ស្ទឹងខៀវ បានរកឃើញលាមកក្រពើភ្នំចំនួន៩៣ដុំ ដានជើងចំនួន៤២កន្លែង និងឃើញក្រពើផ្ទាល់ចំនួន ១២ក្បាល និងបានតាមដានក្រពើភ្នំដែលបានដោះលែងក្នុងឆ្នាំ២០១៨ តាមរយៈ Radio tracking ដោយបានរកឃើញក្រពើភ្នំលែងចំនួន០៧ ក្បាល និងស្នាមដាន០១ កន្លែង

- បានជួសជុលផ្លូវដោយក្រាលគ្រួសក្រហមបាន ១៥ ១០៦ ម៉ែត្រការ៉េ ជួសជុលផ្លូវភ្លើងប្រវែង ២១ ០០០ ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ៥២ ហិកតា នៅក្នុងតំបន់សួនសត្វ។

## ៤.៤ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

- បានផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងព្រៃឈើចំនួន៣៨លើក នៅខេត្តកំពង់ស្ពឺ កោះកុង បន្ទាយមានជ័យ ឧត្តរមានជ័យ ក្រចេះ មណ្ឌលគិរី កំពត តាកែវ ស្ទឹងត្រែង រតនគិរី កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប ព្រះវិហារ និងកំពង់ធំ សមាជិកចូលរួមសរុបចំនួន១ ៤៦៣នាក់ (ស្ត្រី៥៦៦នាក់) និងចែកឯកសារចំនួន៨៣០ច្បាប់

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន១ ២០១ករណី ក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន៥៩៨ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន៦០៣ករណី

- បានធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃ តាមរយៈសាលក្រម និងដីកាសម្រេចរបស់សាលាដំបូងខេត្តព្រះវិហារចំនួន៤៣ករណី និងបង់ពិន័យដោយតុលាការសរុបចំនួន១៥ករណី និងបានណែនាំកែលម្អសំណុំរឿងបទល្មើសព្រៃឈើដល់រដ្ឋបាលព្រៃឈើមូលដ្ឋានចំនួន០៧ករណី។

**ក្រាហ្វិកទី៣៤៖ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើពីឆ្នាំ២០១៥-២០១៩**




**ក្រាហ្វិក៣៥៖ បទល្មើសព្រៃឈើពិន័យអន្តរការណ៍ និងទៅតុលាការពីឆ្នាំ២០១៥-២០១៩**




# ៥. លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

## ៥. ១. ការលើកកម្ពស់ការកសាង និងការអនុវត្តគោលនយោបាយ និងការវិនិយោគឯកជនកសិកម្ម

ក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ក្នុងគោលដៅជំរុញការធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចរបស់ប្រទេស ជាពិសេសការប្រែប្រួលពីប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការងាររៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តមួយចំនួនដូចខាងក្រោម៖

### ក. លទ្ធផលនៃការរៀបចំផែនការ គោលនយោបាយ និងការគ្រប់គ្រងការងារវិនិយោគ

### ក.១ លទ្ធផលនៃការរៀបចំផែនការ គោលនយោបាយ

- ក្រសួងបានបង្កើតក្រុមការងារបច្ចេកទេសកសាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យម និងវែង តាមរយៈសេចក្តី សម្រេច លេខ ៣៥២ សសរ.កសក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩
- បានដាក់ឆ្លងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះស្តីពីកសិកម្មនិងទឹក (TWGAW) អំពីសេចក្តីព្រាងបឋមផែនការមេវិស័យកសិកម្មឆ្នាំ២០៣០
- បានរៀបចំកិច្ចប្រជុំក្នុងកម្រិតបច្ចេកទេសជាបន្តបន្ទាប់ ដើម្បីពិនិត្យពិភាក្សា និងប្រមូលធាតុ តាមរយៈការពិនិត្យឡើងវិញនូវរាល់ឯកសារគោលនយោបាយជាតិ និងគោលនយោបាយវិស័យពាក់ព័ន្ធ ផែនការយុទ្ធសាស្រ្ត ផែនការអភិវឌ្ឍន៍ និងឯកសារសំខាន់ៗពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាគោលគំនិតសម្រាប់ដាក់បញ្ចូលទៅក្នុងឯកសារគោលនេះ
- បានពិនិត្យនិងធ្វើការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពរបស់វិស័យទាំងមូល និងពិនិត្យពិភាក្សាស៊ីជម្រៅលើការកំណត់ចក្ខុវិស័យ (Vision) គោលបំណងអភិវឌ្ឍន៍ (Development Goal) គោលដៅយុទ្ធសាស្រ្ត (Strategic Objectives) ក្របខ័ណ្ឌយុទ្ធសាស្រ្ត (Strategy Frameworks) ផែនការសកម្មភាពអនុវិស័យ (Sub sector plans, Activities: Crops, Livestock, Fisheries and Forestry) ធនធានហិរញ្ញវត្ថុ (Financial Resources) ការសម្របសម្រួលអនុវត្ត ការតាមដាន និងវាយតម្លៃ (Implementation Coordination and M&E)។

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន០៣លើក ជាមួយអង្គភាពជំនាញថ្នាក់កណ្ដាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត និងជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន សំដៅប្រមូលធាតុចូលបន្ថែមទៀត ជាពិសេស ធាតុចូលដែលមានលក្ខណៈជាអន្តរវិស័យដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម។
- បានរៀបចំពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ជាផ្លូវការកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ក្នុងគោលបំណងបង្កើនការយល់ដឹងឲ្យកាន់តែស៊ីជម្រៅ និងជំរុញឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះ សម្រេចបានតាមគោលដៅដែលបានកំណត់ដើម្បីចូលរួមការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការជំរុញវិស័យកសិកម្មឱ្យមានលក្ខណៈទំនើប និងអភិវឌ្ឍន៍។
- ក្រសួងបានរៀបចំនិងអនុម័តលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ដែលមានមានទឹកប្រាក់សរុបចំនួន១ ៣៤៧ ០៥៧ លានរៀល ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១ ២៥៦ ៦៣៤ លានរៀល និងថវិការបស់ដៃគូអភិវឌ្ឍន៍ចំនួន ៩០ ៤២៣ លានរៀល
- ក្រសួងបានរៀបចំផែនការសកម្មភាព និងថវិកាក្នុងក្របខ័ណ្ឌថវិកាកម្មវិធីឆ្នាំ២០២០ មានទឹកប្រាក់សរុបចំនួន២៩៩ ០៧៦ លានរៀល ក្នុងនោះថវិកាសម្រាប់អង្គភាពថវិកាថ្នាក់កណ្ដាលមានចំនួន ១៨៥ ០៧៤ លានរៀល និងថវិកាអង្គភាពថវិកាថ្នាក់រាជធានីខេត្តចំនួន ១១៤ ០០២លានរៀល សម្រាប់អនុវត្តកម្មវិធីអាទិភាពចំនួន០៥ គឺកម្មវិធីទី១ស្ដីពីការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច កម្មវិធីទី២ស្ដីពីការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ កម្មវិធីទី៣ស្ដីពីការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម កម្មវិធីទី៤ស្ដីពី ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ និងកម្មវិធីទី៥ស្ដីពីការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស
- បានរៀបចំរបាយការណ៍និងវាយតម្លៃលើការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលជារួម គឺការអនុវត្តសកម្មភាពសម្រេចបាន៩៣,៧៣% និងការចំណាយថវិកាអស់៩៧,០២% ។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងណែនាំលើការងាររៀបចំគម្រោងសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ២០២១-២០២២។
- បានរៀបចំរបាយការណ៍សមិទ្ធផលការងារក្នុងវិស័យកសិកម្ម ក្នុងចូលរួមអនុវត្តនូវគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (២) គោលនយោបាយជាតិ ស្ដីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ (៣) គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ (៤) គោលនយោបាយជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ២០១៦-២០២៦ គោលដៅអភិវឌ្ឍន៍ប្រកបចីរភាព២០១៦-២០៣០។

### គ.៣ លទ្ធផលនៃការគ្រប់គ្រងការងារវិនិយោគ

ក្នុងឆ្នាំ២០១៩នេះ គម្រោងវិនិយោគសរុបចំនួន ២២៩គម្រោង ដែលមានប្រភពមកពីក្នុងស្រុក និងមកពីបរទេស ក្នុងនោះរួមមាន៖

| ល.រ | ឈ្មោះប្រទេស | ចំនួនគម្រោង |
|---|---|---|
| ០១ | កម្ពុជា | ១១១គម្រោង |
| ០២ | វៀតណាម | ៥១គម្រោង |
| ០៣ | ចិន | ២៩គម្រោង |
| ០៤ | កូរ៉េ | ៨គម្រោង |
| ០៥ | ម៉ាឡេស៊ី | ៧គម្រោង |

| | | |
|---|---|---|
| ០៦ | ឥណ្ឌា | ៥គម្រោង |
| ០៧ | សិង្ហបូរី | ៤គម្រោង |
| ០៨ | ថៃ | ៤គម្រោង |
| ០៩ | អាមេរិក | ៣គម្រោង |
| ១០ | អ៊ីស្រាអែល | ២គម្រោង |
| ១១ | អូស្ត្រាលី | ២គម្រោង |
| ១២ | អង់គ្លេស | ២គម្រោង |
| ១៣ | ន័រវេស | ១គម្រោង |
| **សរុប** | **១៣ប្រទេស** | **២២៩គម្រោង** |

**គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាខេត្តចំនួន១៩ខេត្តគោលដៅ**

| ល.រ | ឈ្មោះខេត្ត | ចំនួនគម្រោង | ទំហំផ្ទៃដី (ហិកតា) |
|---|---|---|---|
| ០១ | រតនគីរី | ២៧ | ១២៤ ៦៧០ |
| ០២ | មណ្ឌលគិរី | ២៥ | ១៥៤ ៧៦៥ |
| ០៣ | ស្ទឹងត្រែង | ៩ | ៦៥ ១៣៤ |
| ០៤ | ក្រចេះ | ៤៩ | ២៣០ ២៧៣ |
| ០៥ | កំពង់ធំ | ២៥ | ៩២ ៥៦៨ |
| ០៦ | កំពង់ចាម | ១ | ២ ៤០០ |
| ០៧ | ត្បូងឃ្មុំ | ៩ | ៩ ២៥៥ |
| ០៨ | ព្រះវិហារ | ៣១ | ២០២ ៧១៣ |
| ០៩ | ឧត្តរមានជ័យ | ៩ | ៤៣ ៣៧០ |
| ១០ | សៀមរាប | ៣ | ១៣ ២៣៩ |
| ១១ | បន្ទាយមានជ័យ | ២ | ៥ ៣៩០ |
| ១២ | បាត់ដំបង | ២ | ៦ ២៤៥ |
| ១៣ | ពោធិ៍សាត់ | ៣ | ៣១ ០៣៤ |
| ១៤ | កំពង់ស្ពឺ | ១៨ | ៩៦ ៨០៦ |
| ១៥ | កោះកុង | ៧ | ៤៩ ០២៣ |
| ១៦ | ព្រះសីហនុ | ៤ | ១៦ ២៣២ |
| ១៧ | កំពត | ៤ | ១៨ ៣០២ |
| ១៨ | ស្វាយរៀង | ១ | ៨១៩ |

**លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច៖**

- ឈូសឆាយបានចំនួន ៥០៧ ៥១០ ហិកតា ដាំដុះបានចំនួន ៤០២ ៧៦០ហិកតា (ប្រៀបធៀបឆ្នាំ២០១៨ មានការថយចុះផ្ទៃដីឈូសឆាយចំនួន ២៥ ០២០ហិកតា និងផ្ទៃដីដាំដុះចំនួន ១៨ ៥៥២ហិកតា
- សាងសង់ប្រព័ន្ធផ្លូវបានចំនួន ១៦ ៨៦៧គីឡូម៉ែត្រ កើនឡើង ១៨២គីឡូម៉ែត្រ
- ប្រើប្រាស់កំលាំងពលកម្មសរុបចំនួន ៤៤ ៩១២នាក់ ក្នុងនោះ បុគ្គលិកខ្មែរចំនួន ៥ ៧៤១ នាក់ កម្មករខ្មែរចំនួន ១៥ ១៥៣នាក់ កម្មករអណ្តែតចំនួន ២១ ៧៣៥នាក់ និងបុគ្គលិកបរទេសចំនួន ២ ២៨៣នាក់។

- បានចុះបញ្ជីដីឯកជនរបស់រដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ច បានចំនួន១២៩គម្រោង និងមិនទាន់ចុះបញ្ជីដីចំនួន ១០០គម្រោង កើនបាន១០គម្រោងធៀបឆ្នាំ២០១៨
- ស្នើសុំបំពេញនីតិវិធីធ្វើអនុបយោគដីពីដីឯកជនសាធារណៈរបស់រដ្ឋ មកជាឯកជនរបស់រដ្ឋបាន ចំនួន ១៤៦គម្រោង កើនបាន ០៦គម្រោងធៀបឆ្នាំ២០១៨
- អនុវត្តតាមខ្លឹមសារបទបញ្ជាលេខ០១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់ រាជរដ្ឋាភិបាល និងខ្លឹមសារសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីតាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចដឹកនាំដោយ ឯកឧត្តម **ប៉ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាន ចុះហត្ថលេខាលើកិច្ចសន្យា និងកិច្ចសន្យាកែតម្រូវកិច្ចសន្យាបាន សរុបចំនួន ៦៤គម្រោង លើផ្ទៃដីសរុបចំនួន ៣១១ ៤២៣ហិកតា ក្នុងនោះ ចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុនបានចំនួន ០៣គម្រោង លើផ្ទៃដី ៧ ៥៤៨ហិកតា និង ចុះកិច្ចសន្យាកែសម្រួលកិច្ចសន្យា ដើមបានចំនួន ៦១គម្រោង លើផ្ទៃដីចំនួន ៣០៣ ៨៧៥ហិកតា
- បានសហការចុះប្រមូលចំណូលពីការផ្តល់សម្បទានដីសេដ្ឋកិច្ច៖ ដោយចំណូលបានមកពីការប្រមូលថ្លៃសម្បទានដី សេដ្ឋកិច្ចសរុបចំនួន២ ៤១១ ៣៩២ ដុល្លារសហរដ្ឋអាមេរិក ចំណូលបានមកពីការបង់សួយសារ និង បុព្វលាភផល អនុផល ព្រៃឈើ ៣ ០៤១ ៨៦៣ ដុល្លារអាមេរិក និង៤ ៦២៦ ៤៩៣ ៨១៧ រៀល។

### ក.៤. ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកសិកម្ម និងប្រព័ន្ធទីផ្សារកសិផល

ក្រសួងបានពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកសិកម្ម និងប្រព័ន្ធទីផ្សារកសិផលដូចខាងក្រោម៖

- បានរៀបចំសិក្ខាសាលាស្តីពីការប្រមូល និងប្រើប្រាស់ទិន្នន័យស្ថិតិកសិកម្មរបស់មន្ត្រីថ្នាក់ខេត្តស្រុក
- បានចុះធ្វើអង្កេតស្ទង់ទិន្នផលស្រូវ និងធ្វើការអង្កេតថ្លៃដើមផលិតផលដំណាំស្រូវ
- បានចូលរួមនិងសហការជាមួយក្រសួងផែនការ លើការងាររៀបចំធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៩
- បានចុះពិនិត្យតាមដានល្បឿនការងារបង្កបង្កើនផល និងស្ថានភាពគ្រោះធម្មជាតិ ការតាមដានការងារត្រួតពិនិត្យវាយតម្លៃលើការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា សម្រាប់ធ្វើតុល្យភាពស្បៀងប្រចាំឆ្នាំ
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំ និងតម្លៃលក់រាយនៅតាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានីខេត្តចំនួន២៥
- ផ្តល់និងចែកចាយព្រឹត្តិបត្រប្រចាំខែជូនក្រសួង ស្ថាប័ន អង្គភាពជំនាញ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) គ្រឹស្ថានអប់រំកសិកម្មនានា
- ផ្សព្វផ្សាយតម្លៃទីផ្សារកសិកម្មតាមព្រឹត្តិបត្រព័ត៌មានទីផ្សារកសិកម្ម តាមប្រព័ន្ធ SMS និងគេហទំព័រ www.agriculturalmarketinformation.org.kh
- ចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផល ចុះអង្កេតសិក្សាទីតាំងប្រមូលទិន្នន័យ និងទីផ្សារផលិតផលកសិកម្ម ទូទាំងប្រទេស ព្រមទាំងចុះសិក្សាចរាចរស្រូវក្នុងស្រុក និងការនាំចេញទៅប្រទេសជិតខាងតាមបណ្តាខេត្ត
- បានកសាងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាលដែលមានអ្នកចូលរួមសរុបចំនួន៨៧០នាក់ ក្នុងនោះស្ត្រី២១៨នាក់ ស្តីពីការផ្សារភ្ជាប់កសិករទៅទីផ្សារ ប្រព័ន្ធSMS ការប្រើប្រាស់សេវាព័ត៌មានទីផ្សារកសិកម្មតាមគេហទំព័រ និងសារជាអក្សរ(SMS)ថ្មី។

### ៥.២. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តរៀបចំផែនការថវិកា ដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "**ជំរុញកំណើនកសិកម្មនិងបង្កើនការនាំចេញផលិតផលកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាព តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្មបង្កើនតម្លៃបន្ថែមនិងពង្រីកការប្រកួតប្រជែងទីផ្សារព្រមទាំងរក្សាបានតុល្យភាពនៃការប្រើប្រាស់ដីកសិកម្ម និងធានាការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយនិរន្តរភាព**"។

ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៥ អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២០អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

ឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលកញ្ចប់ថវិកាសម្រាប់ចំណាយក្នុងការអនុវត្តចង្កោមសកម្មភាពនៃអនុកម្មវិធី កម្មវិធី សរុបចំនួន **២៨០ ៩២៤ លានរៀល**។ ថវិកានេះត្រូវបានបែងចែកសម្រាប់រដ្ឋបាលកណ្តាលចំនួន**១៧១ ៣២៥លានរៀល** និងមន្ទីររាជធានីខេត្តចំនួន **១០៩ ៥៩៩លានរៀល**។ ទន្ទឹមនឹងនេះ ក្រសួងត្រូវប្រមូលចំណូលមិនមែនសារពើពន្ធបង់ចូលថវិការដ្ឋទៅតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ដែលមានទឹកប្រាក់សរុបចំនួន **៤១ ៤៨៧លានរៀល** ក្នុងនោះរដ្ឋបាលកណ្តាលចំនួន **៣៩ ២៨៦,៨លានរៀល** និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្តចំនួន**២ ២០០,២លានរៀល**។

ចំពោះលទ្ធផលនៃការអនុវត្តថវិកាក្នុងឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលដូចខាងក្រោម:

**១-ផ្នែកចំណូល:**

ក្រសួងសម្រេចអនុវត្តប្រមូលចំណូលសរុបបានចំនួន **៥៨ ២១៥,៥ លានរៀល** គឺស្មើនឹង១៤០,៣%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន **៥៤ ១៨០ លានរៀល** គឺស្មើនឹង១៣៧,៩% ធៀបនឹង ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩។ ការកើនឡើងនូវប្រាក់ចំណូលគឺដោយសារ (១)ចំណូលពីថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមួយចំនួនបានបង់សងបំណុលឆ្នាំចាស់ (២)ផលពីការគ្រប់គ្រងរដ្ឋបាល ការចេញលិខិតអនុញ្ញាតពាក់ព័ន្ធការងារជលផល និងការងារសុខភាពសត្វនិងផលិតកម្មសត្វ (៣)ចំណូលពីការត្រួតពិនិត្យអនាម័យសាច់ និង ផលដំណាំផ្សេងៗ និង(៤) ការកើនឡើងចំណូលពីការផាកពិន័យអន្តរការណ៍ បទល្មើសព្រៃឈើ ពិន័យតាមសាលក្រមតុលាការ ការលក់ឡៃឡុងវត្ថុតាងនិងការផាកពិន័យផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ។ ដោយឡែកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត អនុវត្តប្រមូលចំណូលបានចំនួន **៤ ០៣៥,៥លានរៀល** គឺស្មើនឹង ១៨៣,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ។ ការកើនឡើងនូវទឹកប្រាក់ចំណូលគឺដោយសារ (១)ចំណូលពីផលនេសាទ ដែលផែនការនៃចំណូលនេះត្រូវបានគ្រោងនៅរដ្ឋបាលកណ្តាល ប៉ុន្តែមន្ទីរបានកត់ត្រាជាចំណូលរបស់ មន្ទីរស្របតាមលិខិតលេខ៤៨២៦សហវ.អទចចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២) ការផាកពិន័យពីបទល្មើសផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ។

**២-ផ្នែកចំណាយ**

ក្នុងឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តចំណាយថវិកាសរុបបានចំនួន **២៧២ ៨៦៩,៨លានរៀល** គឺស្មើនឹង៩៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុក្នុងនោះ(១)រដ្ឋបាលកណ្តាលអនុវត្តបានចំនួន **១៦៨ ២០៨,៣លានរៀល** គឺស្មើនឹង៩៨,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ចំណាយចរន្តសម្រេចបានចំនួន **១៦២ ៣១០,៤ លានរៀល** ស្មើនឹង១០៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ការអនុវត្តចំណាយចរន្តខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុនេះ គឺដោយការបន្ថែមឥណទានថវិកាសម្រាប់អនុវត្តគម្រោងអន្តរាគមន៍ទប់ស្កាត់ និងកម្ចាត់ជំងឺមួសាអ៊ីកលើដំណាំ

ជំទ្បងមីនិងចំណាយអន្តរាគមន៍ទប់ស្កាត់ការរាលដាលជំងឺប៉េសជ្រូកអាហ្វ្រិក និងការបន្ថែមតណទានថវិកាជំពូក៦៤ សម្រាប់ទូទាត់បញ្ចប់ប្រាក់វង្វាន់ឆ្នាំ២០១៨។ ចំពោះការចំណាយមូលធនអនុវត្តបានចំនួន **៥ ៩៩៧,៩លានរៀល** ស្មើនឹង៣៦,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ សម្រាប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តបានចំនួន**១០៤ ៦៦១,៥ លានរៀល** គឺស្មើនឹង៩៥,៥%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។

## ៥.៣. ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

### ៥.៣.១. ការគ្រប់គ្រងធនធានមនុស្ស

ក្នុងឆ្នាំ២០១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន៥ ៩៣៩នាក់ នារី ១ ៤៥៣នាក់ ស្មើនឹង២៤,៤៦% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន២ ៩១៥នាក់ នារី៨៣៣នាក់ ស្មើនឹង ២៨,៥៧% ថ្នាក់រាជធានី ខេត្តមានចំនួន៣ ០២៤នាក់ នារី៦២០នាក់ ស្មើនឹង២០,៥០%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន១១៣នាក់ នារី១៧នាក់ និងចូលនិវត្តន៍មុនអាយុចំនួន១១នាក់ នារី០១នាក់ ដាក់មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន៥៩នាក់ នារី១៩នាក់ និងបានលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន ៤៦នាក់ នារី១១នាក់ (បោះបង់ការងារ លាឈប់ពីការងារ និងមរណៈភាព)។ ក្រសួងបានធ្វើការប្រឡងប្រជែងជ្រើសរើស មន្ត្រីក្របខ័ណ្ឌថ្មីចំនួន១២០នាក់ (ក្របខ័ណ្ឌ"ក"ចំនួន១១៧នាក់ នារីចំនួន៣៨នាក់ និង"ខ"ចំនួន ០៣នាក់ និងបានតែងតាំង និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការបានចំនួន៤២៣នាក់ នារីចំនួន១១៧នាក់។

ផ្អែកតាមក្រាហ្វិកនៃស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការក្នុងរយៈពេល០៥ឆ្នាំ (២០១៥-២០១៩) ឃើញថាចំនួនក្របខ័ណ្ឌបានថយចុះជាបន្តបន្ទាប់ទន្ទឹមនឹងក្របខ័ណ្ឌថ្មីទទួលបាន មិនមានតុល្យភាពនឹងក្របខ័ណ្ឌដែលបានបាត់បង់។ ករណីនេះជាបញ្ហាប្រឈមសម្រាប់ការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើឱ្យសម្រេចជោគជ័យនូវផែនការយុទ្ធសាស្ត្ររបស់ក្រសួង ។

### ៥.៣.២. ការអភិវឌ្ឍធនធានមនុស្ស

នៅក្នុងនីតិកាលកន្លងមកនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលបានកំណត់អាទិភាពចម្បងចំនួន៤ គឺ៖ ផ្លូវ ទឹក ភ្លើង និងមនុស្ស ។ ប៉ុន្តែនៅក្នុងបរិបទសេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យាទំនើបប្រកបដោយឧត្តមភាព និងការប្រកួតប្រជែងដែលមានសន្ទុះយ៉ាងខ្លាំងក្លា រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាពបានផ្តល់ការយកចិត្ត ទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍធនធានមនុស្សមានន័យថា ប្រែក្លាយអាទិភាពចម្បងចំនួន៤គឺ៖ មនុស្ស ផ្លូវ ភ្លើង និងទឹក។

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស"របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកបដោយគុណវុឌ្ឍិខ្ពស់តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យម និងរយៈពេលវែងទាំងក្នុង និងក្រៅប្រទេស។

ជាក់ស្តែងក្នុងឆ្នាំ២០១៩កន្លងមកនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន២ ២៦៨នាក់ នារីចំនួន ៤៩៧នាក់។ វគ្គបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីនិងមធ្យមសរុបមានចំនួន១ ៣៥២នាក់ នារី៣០៥នាក់ និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសសរុបមានចំនួន៩១៦នាក់ នារីចំនួន១៩២នាក់ ក្នុងនោះ៖ វគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមមានចំនួន៨៩២នាក់ នារីចំនួន១៨៣នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលវែងមានចំនួន ២៤នាក់ នារីចំនួន ០៩នាក់ (ថ្នាក់បរិញ្ញាបត្រចំនួន០២នាក់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន១៤នាក់ នារី០៥នាក់ និងថ្នាក់បណ្ឌិតមានចំនួន០៨នាក់ នារី០៤នាក់)។




### ៥.៣.៣. ការងារបណ្តុះបណ្តាលនិសិត្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មចំនួនបីគឺ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.វ.ភ.ក) វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប (វ.ជ.ក.ព.ល) និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម(វ.ជ.ក.ក.ច)។

តារាងស្ថិតិមន្ត្រី គ្រូបង្រៀន និស្សិត របស់គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី ឆ្នាំ២០១៨-២០១៩ មានដូចខាងក្រោម៖

| ល.រ | គ្រឹះស្ថានសិក្សា | បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | បរិញ្ញាបត្ររង | | បឋម | | គ្មានជំនាញ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | សាកវិទ្យាល័យភូមិន្ទកសិកម្ម | | | | | | | | | | | | | | |
| ក | *<u>ចំនួនមន្ត្រី</u>* | ៣០ | ៥ | ១០៤ | ៣៣ | ២៧ | ១០ | - | - | ៦ | ៥ | - | - | ១៦៧ | ៥៣ |
| ខ | *<u>ចំនួននិស្សិត</u>* | ៣៣ | ៣ | ៣៤ | ១៥ | ២៩៤៩ | ១១៦៩ | ១៣៥ | ៤២ | - | - | - | - | ៣១៥១ | ១២២៩ |
| | អាហារូបករណ៍ | - | - | - | - | ៨២៥ | ៣៩១ | ៤ | ១ | - | - | - | - | ៨២៩ | ៣៩២ |
| | សិក្សាបង់ថ្លៃ | ៣៣ | ៣ | ៣៤ | ១៥ | ២១២៤ | ៧៧៨ | ១៣១ | ៤១ | - | - | - | - | ២៣២២ | ៨៣៧ |
| ២ | វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | | | | | | | | | | | | | | |
| ក | *<u>ចំនួនមន្ត្រី</u>* | ៦ | ០ | ៤៣ | ១២ | ៦៨ | ២៣ | ៣ | ០ | - | - | ៣ | ២ | ១២៣ | ៣៧ |
| ខ | *<u>ចំនួននិស្សិត</u>* | - | - | - | - | ៦៦៦ | ២៨៧ | ១៩៧ | ៦៣ | ១៣០ | ៦៩ | - | - | ៩៩៣ | ៤១៩ |
| | អាហារូបករណ៍ | - | - | - | - | ៤៦១ | ២២១ | ៦៩ | ៣១ | ១៣០ | ៦៩ | - | - | ៦៦០ | ៣២១ |
| | សិក្សាបង់ថ្លៃ | - | - | - | - | ២០៥ | ៦៦ | ១២៨ | ៣២ | - | - | - | - | ៣៣៣ | ៩៨ |
| ៣ | វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | | | | | | | | | | | | | | |
| ក | *<u>ចំនួនមន្ត្រី</u>* | - | - | ៣៥ | ៦ | ២១ | ១០ | ១ | ០ | - | - | - | - | ៥៧ | ១៦ |
| ខ | *<u>ចំនួននិស្សិត</u>* | - | - | - | - | ៤៣៥ | ១៨៣ | ៩៨ | ៣០ | - | - | - | - | ៥៣៣ | ២១៣ |
| | អាហារូបករណ៍ | - | - | - | - | ២៤៩ | ១២២ | ៨២ | ២៨ | - | - | - | - | ៣៣១ | ១៥០ |
| | សិក្សាបង់ថ្លៃ | - | - | - | - | ១៨៦ | ៦១ | ១៦ | ២ | - | - | - | - | ២០២ | ៦៣ |

ក្នុងរយៈពេល០៥ឆ្នាំនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលនិស្សិតឱ្យចូលរៀន និងបញ្ចប់ការសិក្សាដោយជោគជ័យ មានដូចក្រោម៖

## តារាងទី១៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

| និស្សិត / ឆ្នាំសិក្សា | បរិញ្ញារង | | បរិញ្ញា | | បរិញ្ញាជាន់ខ្ពស់ | | បណ្ឌិត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៤-២០១៥ | ៥២ | ១៣ | ១ ២៣៤ | ៣០៩ | ១៩ | ៥ | ០ | ០ | ១ ៣០៥ | ៣២៧ |
| ២០១៥-២០១៦ | ៩៣ | ២០ | ១ ០២៤ | ៣០២ | ៣៧ | ៩ | ១ | ១ | ១ ១៥៥ | ៣៣២ |
| ២០១៦-២០១៧ | ៥១ | ១០ | ៥៨៦ | ១៨៧ | ១៣ | ៣ | ០ | ០ | ៦៥០ | ២០០ |
| ២០១៧-២០១៨ | ៥ | ៣ | ៤៦០ | ១៤២ | ០ | ០ | ០ | ០ | ៤៦៥ | ១៤៥ |
| ២០១៨-២០១៩ | ៤៩ | ១២ | ៥៨៩ | ២២៩ | ២២ | ៤ | ០ | ០ | ៦៦០ | ២៤៥ |
| សរុប | ២៥០ | ៥៨ | ៣ ៨៩៣ | ១១៦៩ | ៩១ | ២១ | ១ | ១ | ៤ ២៣៥ | ១ ២៤៩ |

## តារាងទី២៖ ស្ថិតិនិស្សិតចូលរៀនសរុបរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

| និស្សិត / ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | អនុបណ្ឌិត | | បណ្ឌិត | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៤-២០១៥ | ៨៦ | ១៩ | ៧៨៩ | ២៦០ | ៣៥ | ១១ | ១១ | ០ | ៩២១ | ២៩០ |
| ២០១៥-២០១៦ | ៩៣ | ២០ | ៩៤៥ | ៣៦៤ | ៤០ | ១៣ | ០ | ០ | ១ ០៧៨ | ៣៩៧ |
| ២០១៦-២០១៧ | ៦១ | ១៧ | ៩២០ | ៣៣៩ | ៦០ | ២៤ | ០ | ០ | ១ ០៤១ | ៣៨០ |
| ២០១៧-២០១៨ | ៧២ | ១៩ | ៧៦៨ | ៣០៣ | ០ | ០ | ០ | ០ | ៨៤០ | ៣២២ |
| ២០១៨-២០១៩ | ៧៩ | ២៧ | ៨៨៨ | ៣៩៦ | ១៧ | ៦ | ០ | ០ | ៩៨៤ | ៤២៩ |
| សរុប | ៣៩១ | ១០២ | ៤ ៣១០ | ១ ៦៦២ | ១៥២ | ៥៤ | ១១ | ០ | ២ ៧៤៥ | ១ ៨១៨ |

## តារាងចំនួននិស្សិតចូលរៀនរបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៤-២០១៥ | ១៤០ | ៣១ | ១៦១ | ៤១ | ៣០១ | ៧២ |
| ២០១៥-២០១៦ | ១៧០ | ៥០ | ២៥៨ | ៨៥ | ៤២៨ | ១៣៥ |
| ២០១៦-២០១៧ | ១១៩ | ៤៩ | ១០៤ | ៤០ | ២២៣ | ៨៩ |
| ២០១៧-២០១៨ | ១១៩ | ៣៤ | ១៨០ | ៧៩ | ២៩៩ | ១១៣ |
| ២០១៨-២០១៩ | ៥៣ | ២៣ | ២៣៦ | ១១៦ | ២៨៩ | ១៣៩ |
| សរុប៥ឆ្នាំ | **៦០១** | **១៨៧** | **៩៣៩** | **៣៦១** | **១៥៤០** | **៥៤៨** |

## តារាងចំនួននិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៤-២០១៥ | ៣៩៦ | ១៥ | ៣៧៨ | ១១១ | ៧៧៤ | ១២៦ |
| ២០១៥-២០១៦ | ១០៤ | ២៤ | ២៨៨ | ១០៨ | ៣៩២ | ១៣២ |
| ២០១៦-២០១៧ | ១៣៧ | ៥២ | ២០៧ | ៧៣ | ៣៤៤ | ១២៥ |
| ២០១៧-២០១៨ | ១១០ | ៤៣ | ១៦៥ | ៤៧ | ២៧៥ | ៩០ |

| | | | | | | |
|---|---|---|---|---|---|---|
| ២០១៨-២០១៩ | ១៤៩ | ៤០ | ១៩៧ | ៧២ | ៣៤៦ | ១១២ |
| សរុប៥ឆ្នាំ | ៨៩៦ | ១៧៤ | ១២៣៥ | ៤១១ | ២១៣១ | ៥៨៥ |

តារាងសង្ខេបសមិទ្ធផលរបស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៤-២០១៥ | ៨៩ | ៤៦ | ១៤៦ | ៤៣ | ១៣៣ | ៦៤ |
| ២០១៥-២០១៦ | ១១៦ | ៣២ | ១០៥ | ៦១ | ១៦៨ | ៨២ |
| ២០១៦-២០១៧ | ៦៥ | ១៦ | ១២២ | ៧០ | ២០១ | ១០២ |
| ២០១៧-២០១៨ | ៦២ | ២៦ | ១៩៦ | ១១៥ | ២៥៨ | ១៤១ |
| ២០១៨-២០១៩ | ៥៨ | ១៨ | ១៩៣ | ១០៨ | ២២០ | ១២១ |
| សរុប៥ឆ្នាំ | ៣៩០ | ១៣៨ | ៧៦២ | ៣៩៧ | ៩៨០ | ៥១០ |

តារាងចំនួននិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៤-២០១៥ | ២២១ | ៧០ | ២៤៤ | ១២៣ | ៤៦៥ | ១៩៣ |
| ២០១៥-២០១៦ | ៨២ | ៤៦ | ១៩៥ | ៩៩ | ២៧៧ | ១៥៤ |
| ២០១៦-២០១៧ | ១១៤ | ៤៨ | ១៨៩ | ៧៣ | ៣០៣ | ១២១ |
| ២០១៧-២០១៨ | ៥៣ | ១៥ | ១៤១ | ៥៤ | ១៩៤ | ៦៩ |
| ២០១៨-២០១៩ | ៤៤ | ១៧ | ៩៥ | ៣១ | ១៣៩ | ៤៨ |
| សរុប៥ឆ្នាំ | ៥១៤ | ១៩៦ | ៨៦៤ | ៣៨០ | ១៣៧៤ | ៥៨៥ |

គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានកំពុងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ តាមរយៈការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសេវាកម្ម សម្រាប់សហគមន៍ ក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសកលភាវូបនីយកម្ម។

នៅឆ្នាំ២០១៩ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេភាគី និងពហុភាគី កាន់តែល្អប្រសើរ ជាមួយដៃគូអភិវឌ្ឍន៍នានា។ ជាក់ស្តែង សាកលវិទ្យាល័យភូមិន្ទកសិកម្ម មានកិច្ចសហប្រតិបត្តិការ ជាមួយសហភាពអឺរ៉ុប (EU) អង្គការសុខភាពសត្វពិភពលោក (OIE) ជំនួយការរបស់ទីភ្នាក់ងារអាមេរិក (USAID) មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មប្រកបដោយនិរន្តភាព និងអាហារូបត្ថម្ភ (CESAIN) អង្គការ SIIL សម្រាប់កម្មវិធីមន្ទីរពិសោធន៍នវានុវត្តប្រកបដោយចីរភាព មជ្ឈមណ្ឌលអូស្ត្រាលី សម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ក្រុមប្រឹក្សានៃប្រទេសស៊ុយអ៊ែត (Sweden Council) និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។ ចំពោះវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប បាននឹងកំពុងបន្តអនុវត្តកម្មវិធីដែលបានចុះអនុស្សរណៈ និងកិច្ចព្រមព្រៀងជាមួយស្ថាប័នជាតិនិងអន្តរជាតិ និងត្រៀមបន្តឆ្នាំ២០២០។ ចំពោះវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម នៅឆ្នាំ

២០១៩ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ KOICA និងសាកលវិទ្យាល័យជាតិ Kangwon របស់សាធារណរដ្ឋកូរ៉េ ដើម្បីបង្កើនគុណភាព និងនវានុវត្តន៍របស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ដែលមានជំនាញការចូលរួមចំនួន ១៥រូប និងបណ្តុះបណ្តាលដល់មន្ត្រីចំនួន២៥រូប ព្រមទាំងបន្តអនុវត្តកម្មវិធីកសាងធនធានមនុស្ស ផ្នែកមន្ទីរពិសោធន៍របស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាមបន្ថែមទៀត។ ជាងនេះទៅទៀត សាកលវិទ្យាល័យ Shinju និងក្រុមហ៊ុន Shikibo Co. Ltd. នៃប្រទេសជប៉ុន បានបង្កើតបន្ទប់ពិសោធន៍ដង្កូវនាងព្រៃ នៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ដោយមាននិស្សិតចូលរួមសិក្សា និងស្រាវជ្រាវ ចំនួន១១នាក់។

ក្រៅពីការងារសហប្រតិបត្តិការខាងលើ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានទទួលនូវកម្មវិធីផ្លាស់ប្តូរនិស្សិត និងមន្ត្រីរាជការ ទៅប្រទេសអេស្ប៉ាញ ថៃឡង់ដ៏ ជប៉ុន ចិន និងប្រទេសអ៊ីស្រ្តាអែល សរុបចំនួន២៣៥នាក់ (និស្សិតចំនួន២៣២នាក់ និងមន្ត្រីរាជការចំនួន០៣នាក់) ដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍លើវិស័យកសិកម្ម។

### ៥.៤. ការងារសវនកម្មផ្ទៃក្នុង

ក្នុងឆ្នាំ២០១៩ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានខិតខំអនុវត្តភារកិច្ចរបស់ខ្លួនមានការរីកចម្រើនច្រើនទាំងការគ្រប់គ្រងលិខិតស្នាម ទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស អង្គភាពថវិកា ការកសាងរចនាសម្ព័ន្ធ និងការធ្វើសវនកម្មផ្ទៃក្នុងតាមនីតិវិធីស្តង់ដា ទទួលបានលទ្ធផលដូចខាងក្រោម៖

- ទទួលលិខិតចូលចំនួន៧០០លិខិត បញ្ជូនលិខិតចេញចំនួន៤៥៥លិខិត និងសរុបរបាយការណ៍ស្តីពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែនីមួយៗ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនក្រសួង ព្រមទាំងចរាចរឯកសារ នានាក្នុងនាយកដ្ឋានបានទាន់ពេលវេលា។
- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១៨ ធ្វើការបែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខាបច្ចេកទេស ថែទាំ ជួសជុល និងផ្គត់ផ្គង់ សម្រាប់បម្រើការងារ។
- រៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ ផែនការថវិកាឆ្នាំ២០២០ និងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២០។
- ចុះធ្វើសវនកម្មចំនួន៤៧សវនដ្ឋាន ស្មើនឹង៩៥,៩១% នៃផែនការ៤៩សវនដ្ឋាន
- បានផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អចំនួន៣១៥អនុសាសន៍
- ការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន៥០,៦៦% នៃផែនការចំនួន៥០%។

### ៥.៥. ការងារអធិការកិច្ច

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងចំនួន២៤អង្គភាព (តាមផែនការចំនួន១៤អង្គភាព និងតាមការណែនាំផ្ទាល់ពីក្រសួងមានចំនួន១០ អង្គភាព)។
- ទទួលពាក្យបណ្តឹងបានចំនួន០៣ករណី ក្នុងនោះបណ្តឹងអនាមិកចំនួន០២ករណី និងអញ្ជើញអ្នកពាក់ព័ន្ធមកធ្វើការបំភ្លឺទាំង០៣ករណី។
- បានធ្វើរបាយការណ៍លម្អិតរាយការណ៍ អំពីចំណុចល្អ ចំណុចខ្វះខាតដែលត្រូវកែលម្អ និងមានវិធានការចំពោះអង្គភាពដែលបានធ្វើអធិការកិច្ចរួចជាបន្តបន្ទាប់ ព្រមទាំងចេញលិខិតកែលម្អសរុបចំនួន២១លិខិត។
- បានអញ្ជើញអ្នកពាក់ព័ន្ធមកធ្វើការបំភ្លឺលើពាក្យបណ្តឹង និងធ្វើរបាយការណ៍ ជូនក្រសួងពីចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន និងពីវិធានការត្រូវកែលម្អសរុបចំនួន០៣លិខិត និងឱ្យម្ចាស់ពាក្យបណ្តឹងដែល

បានប្តឹងពីបទល្មើសព្រហ្មទណ្ឌ បង្វែរពាក្យបណ្តឹងទៅប្តឹងស្ថាប័នដែលមាន សមត្ថកិច្ចផ្សេងចំនួន០១ លិខិត។

- បានបើកវគ្គបណ្តុះបណ្តាលចំនួន០១វគ្គ ស្តីពីវិធីសាស្ត្រតាមដានការ អនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយមានសិក្ខាកាមចូលរួមសរុប១២៧រូប (ស្ត្រី២០រូប) មកពីអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នាយកដ្ឋាននីតិកម្មកសិកម្ម នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំង២៥ និងបានចូលរួមវគ្គបណ្តុះបណ្តាល ផ្សេងៗទៀតចំនួន ០៣លើក។

### ៥.៦. ការងារសហប្រតិបត្តិការអន្តរជាតិ

នៅក្នុងឆ្នាំ២០១៩ លិខិត និងឯកសារពាក់ព័ន្ធ ត្រូវបានសម្របសម្រួលរៀបចំជូនថ្នាក់ដឹកនាំក្រសួង ព្រមទាំងមន្ត្រីនៃអង្គភាពជំនាញក្រោមឱវាទក្រសួង ដើម្បីចូលរួមសិក្ខាសាលា ទស្សនកិច្ច ទិវា កិច្ចប្រជុំ សិន្នសីទ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេសសរុបចំនួន៤៣១រូប ហើយការទទួលជួបភ្ញៀវអន្តរជាតិរបស់ថ្នាក់ដឹកនាំក្រសួង និងការទទួលរៀបចំកិច្ចប្រជុំ ទិវា ព្រមទាំងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីមួយចំនួននៅក្នុងប្រទេសក៏ត្រូវបានសម្របសម្រួលរៀបចំផងដែរ ដូចមានរៀបរាប់លម្អិតក្នុងតារាងទី១, ២, ៣, ៤ ខាងក្រោម ៖

តារាងទី១ ៖ ចំនួននៃការទទួលជួបភ្ញៀវអន្តរជាតិរបស់ថ្នាក់ដឹកនាំក្រសួង

| ល.រ | ទទួលជួបពិភាក្សាការងារជាមួយ | ចំនួននៃការទទួលជួប | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | ស្ថាប័នរដ្ឋ (ក្រសួង ទីភ្នាក់ងារ ។ល។) | ៧ | ការទទួលជួបភ្ញៀវអន្តរជាតិក្នុងន័យកៀរគរជំនួយបច្ចេកទេសនិងថវិកា ព្រមទាំងការគាំទ្រនិងកិច្ចសហការគ្នាទៅវិញទៅមកសំដៅអភិវឌ្ឍន៍ វិស័យកសិកម្មនិងកសិពាណិជ្ជកម្ម |
| ២ | ស្ថានទូត | ៧ | |
| ៣ | អង្គការអន្តរជាតិ | ៨ | |
| ៤ | វិស័យឯកជន | ៥ | |
| ៥ | ផ្សេងទៀត | ៦ | |
| | សរុប | ៣៣ | |

តារាងទី២ ៖ ចំនួននៃការចូលរួមកិច្ចប្រជុំ ទិវា ទស្សនកិច្ច សន្និសីទនៅក្រៅប្រទេសរបស់ថ្នាក់ដឹកនាំក្រសួងនិងមន្ត្រី

| ល.រ | ការចូលរួមក្នុងព្រឹត្តិការណ៍ | ចំនួនព្រឹត្តិការណ៍ | ចំនួនសមាជិកប្រតិភូ | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| I. | ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី | | | ១.ចរចាកៀរគរជំនួយបច្ចេកទេសថវិកា ពង្រឹងកិច្ចសហការ ដកស្រង់ចែករំលែកបទពិសោធន៍ ព្រមទាំងបច្ចេកទេស។<br><br>២.ពិនិត្យនិងអនុម័តលិខិតបទដ្ឋានតំបន់ MOU និងឯកសារបច្ចេកទេស គោលការណ៍ណែនាំ ស្តង់ដារ និងបទដ្ឋានបច្ចេកទេស ។ល។ |
| ១ | កិច្ចប្រជុំ | ៤១ | ១៣១ | |
| ២ | ទិវា | ៧ | ១២ | |
| ៣ | ទស្សនកិច្ច | ៧ | ១៨ | |
| ៤ | សន្និសីទ | ៥ | ១១ | |
| II. | ក្រោមក្របខ័ណ្ឌអាស៊ាន | | | |
| ១ | កិច្ចប្រជុំ | ៤២ | ១២៦ | |
| ២ | ទស្សកិច្ច | ១ | ២ | |
| | សរុបរួម | ១០៣ | ៣០០ | |

តារាងទី៣ ៖ ចំនួនមន្ត្រីនិងចំនួននៃការចូលរួមសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលនៅក្រៅប្រទេសរបស់មន្ត្រី

| ល.រ | ការចូលរួមក្នុងព្រឹត្តិការណ៍ | ចំនួនព្រឹត្តិការណ៍ | ចំនួនមន្ត្រី | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| I. | ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី | | | ១.ពិភាក្សា ផ្លាស់ប្ដូរបទពិសោធន៍ បច្ចេកទេស និងនវានុវត្តន៍កសិកម្ម<br>២.ពិភាក្សានិងឯកភាពរួមគ្នាលើស្ដង់ដារ និងបទដ្ឋានបច្ចេកទេស និងផ្លាស់ប្ដូរនិងទទួលនូវបច្ចេកវិទ្យាកសិកម្មថ្មីនៅតំបន់អាស៊ាន។ |
| ១ | សិក្ខាសាលា | ៣៧ | ៨៥ | |
| ២ | វគ្គបណ្ដុះបណ្ដាល | ៩ | ២៦ | |
| II. | ក្រោមក្របខ័ណ្ឌអាស៊ាន | | | |
| ១ | សិក្ខាសាលា | ៥ | ១០ | |
| ២ | វគ្គបណ្ដុះបណ្ដាល | ៤ | ១០ | |
| | សរុបរួម | ៥៥ | ១៣១ | |




តារាងទី៤ ៖ ចំនួននៃការសម្របសម្រួលរៀបចំកិច្ចប្រជុំ ទិវា និងវគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីនៅក្នុងប្រទេស

| ល.រ | ការរៀបចំព្រឹត្តិការណ៍ | ចំនួនព្រឹត្តិការណ៍ | ចំនួនអ្នកចូលរួម | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| ១ | កិច្ចប្រជុំ | ៤ | ២៥៦ | ស្បៀងអាហារពិភពលោក UNCCD និងការសម្របសម្រួលកសិពាណិជ្ជកម្មក្រោម WTO។ |
| ២ | ទិវា | ២ | ១១៥០ | |
| ៣ | វគ្គបណ្ដុះបណ្ដាលរយៈពេលខ្លី/សិក្ខាសាលា | ៤ | ១៦៤ | |
| | សរុប | ១០ | ១.៥៧០ | |

ក. ការចុះអនុស្សារណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀង ៖

ស្ថិតនៅក្រោមក្របខ័ណ្ឌទ្វេភាគី ឬពហុភាគី ដំណើរការ និងនីតិវិធីត្រូវបានពិនិត្យ និងសម្របសម្រួលរៀបចំជូនថ្នាកដឹកនាំក្រសួង និងថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួង ដើម្បីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន០៦ សេចក្ដីប្រកាសរួមចំនួន០១ និងកំណត់ហេតុចំនួន០១ ចំណែកនៅក្រោមក្របខ័ណ្ឌអាស៊ាន ថ្នាក់ដឹកនាំបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន០១ និងលិខិតតុបករណ៍បន្តសុពលភាពអនុស្សរណៈនៃការយោគយល់គ្នាចំនួន០១។

| ល.រ | អនុស្សរណៈ/កិច្ចព្រមព្រៀង | រវាង | កាលបរិច្ឆេទចុះហត្ថលេខា | សុពលភាព |
|---|---|---|---|---|
| I | ក្រោមក្របខ័ណ្ឌទ្វេភាគី ឬពហុភាគី | | | |
| | ១. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី | | | |
| ១ | ការផ្លាស់ប្តូរព័ត៌មានក្នុងវិស័យកសិកម្ម | ក.ស.ក និង កូរ៉េ | ០៤/០៤/២០១៩ | ២ ឆ្នាំ |
| ២ | កិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យកសិកម្ម | ក.ស.ក និង កូរ៉េ | ០៣/០៤/២០១៩ | ២ ឆ្នាំ |
| ៣ | អាទិភាពជាយុទ្ធសាស្ត្រសម្រាប់ភាពជាដៃគូស្រាវជ្រាវកសិកម្ម | ក.ស.ក និង ACIAR | ០៥/១១/២០១៩ | ១០ ឆ្នាំ |
| ៤ | ការជម្រុញការស្រាវជ្រាវនិងការអនុវត្តគ្រឿងយន្តកសិកម្មនិងបច្ចេកវិទ្យាកសិកម្មវៃឆ្លាត | ក.ស.ក និង ចិន | ១៩/១១/២០១៩ | មិនបានបញ្ជាក់ |
| ៥ | កិច្ចសហប្រតិបត្តិការលើវិស័យជលផលនិងវារីវប្បកម្ម | ជ.ផ/ក.ស.ក និង FAF/រុស្ស៊ី | ១១/០៧/២០១៩ | មិនបានបញ្ជាក់ |
| ៦ | កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម | ក.ស.ក និង MAFRA/កូរ៉េ | ២៥/១១/២០១៩ | ៥ ឆ្នាំ |
| | ២. សេចក្តីប្រកាស | | | |
| ១ | សេចក្តីប្រកាសរួម | ក.ស.ក, ចិន និង UNIDO | ១៧/០៦/២០១៩ | មិនបានបញ្ជាក់ |
| | ៣. កំណត់ហេតុ | | | |
| ១ | ធ្វើអធិការកិច្ចនៅមូលដ្ឋានសម្រាប់សិក្សាអំពីលទ្ធភាពជាក់ស្តែងនៃការជួយកម្ពុជាក្នុងការកសាងផែនការអភិវឌ្ឍន៍ទំនើបកម្មកសិកម្ម | ក.ស.ក និង ចិន | ១១/០៤/២០១៩ | មិនបានបញ្ជាក់ |
| II | ក្រោមក្របខ័ណ្ឌអាស៊ាន | | | |
| | ១. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី | | | |
| ១ | កិច្ចសហប្រតិបត្តិការអាស៊ានលើគ្រោងការណ៍លើកកម្ពស់ផលិតផលកសិកម្មនិងព្រៃឈើ | អាស៊ាន | ១៥/១០/២០១៩ | ៥ ឆ្នាំ |
| | ២. លិខិតតុបករណ៍ | | | |
| ១ | លិខិតតុបករណ៍បន្តសុពលភាពអនុស្សរណៈនៃការយោគយល់គ្នារវាងអាស៊ាននិងចិនស្តីពីកិច្ចសហប្រតិបត្តិការអនាម័យនិងភូតគាមអនាម័យ | អាស៊ាន និង ចិន | ១៥/១០/២០១៩ | ៥ ឆ្នាំ |

ខ. ការអនុម័តឯកសារបច្ចេកទេស និងគោលការណ៍ណែនាំក្រោមក្របខ័ណ្ឌអាស៊ាន ៖

នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានលើកទី៤១ ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀតដែលបានប្រព្រឹត្តទៅនៅប្រទេសប្រ៊ុយណេដារ៉ូសាឡឹម ថ្នាក់ដឹកនាំក្រសួងបានពិនិត្យនិងអនុម័តលើឯកសារបច្ចេកទេស ព្រមទាំងគោលការណ៍ណែនាំរបស់ក្រុមការងារតាមវិស័យរបស់អាស៊ានសរុបចំនួន២៨ ដូចខាងក្រោម ៖

| ល.រ | ឯកសារបានអនុម័ត | អង្គភាពទទួលបន្ទុកអនុវត្ត |
|---|---|---|
| ១ | សំណើលទ្ធផលនៃការរៀបចំឯកសារពាក់ព័ន្ធនឹងវិស័យស្បៀង កសិកម្ម និងព្រៃឈើសម្រាប់ឆ្នាំ២០២០ | អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង |
| ២ | គោលការណ៍ណែនាំរបស់អាស៊ានសម្រាប់យកគំរូ (សំណាក) មុខទំនិញជាគ្រាប់ធញ្ញជាតិដែលមានបរិមាណច្រើន | អគ្គនាយកដ្ឋានកសិកម្ម |
| ៣ | បញ្ជីកម្រិតអតិបរិមានៃកាកសំណល់ថ្នាំកសិកម្មចំនួន០៦មុខ របស់អាស៊ានដែលបានធ្វើសុខដុមរមណីកម្ម | អគ្គនាយកដ្ឋានកសិកម្ម |
| ៤ | លទ្ធផលនៃការពិនិត្យកែសម្រួលបញ្ជីកម្រិតកាកសំណល់ថ្នាំកសិកម្មចំនួន ៤៩មុខ របស់អាស៊ាន | អគ្គនាយកដ្ឋានកសិកម្ម |
| ៥ | នីតិវិធីសម្រាប់ពិនិត្យកែសម្រួលស្តង់ដារនៃការអនុវត្តកសិកម្មល្អរបស់អាស៊ាន | អគ្គនាយកដ្ឋានកសិកម្ម |
| ៦ | សៀវភៅណែនាំអំពីការត្រួតពិនិត្យជាផ្លូវការនៃការអនុវត្តកសិកម្មល្អរបស់អាស៊ាន - ប្រព័ន្ធនៃការធានាគុណភាពសម្រាប់ផ្លែឈើនិងបន្លែរបស់អាស៊ាន | អគ្គនាយកដ្ឋានកសិកម្ម |
| ៧ | សៀវភៅណែនាំអំពីការបញ្ជាក់វិញ្ញាបនបត្រនៃការអនុវត្តកសិកម្មល្អរបស់អាស៊ាន - ប្រព័ន្ធនៃការធានាគុណភាពសម្រាប់ផ្លែឈើនិងបន្លែរបស់អាស៊ាន | អគ្គនាយកដ្ឋានកសិកម្ម |
| ៨ | នីតិវិធីសម្រាប់ពិនិត្យកែសម្រួលស្តង់ដារកសិកម្មសរីរាង្គរបស់អាស៊ាននិងការធ្វើវិសោធនកម្មឧបសម្ព័ន្ធភ្ជាប់ជាមួយ | អគ្គនាយកដ្ឋានកសិកម្ម |
| ៩ | សៀវភៅណែនាំរបស់អាស៊ានអំពីការបណ្តុះបណ្តាលដែលទាក់ទងនឹងការអនុវត្តស្តង់ដារកសិកម្មសរីរាង្គរបស់អាស៊ាន | អគ្គនាយកដ្ឋានកសិកម្ម |
| ១០ | សៀវភៅណែនាំដែលបានកែសម្រួលសម្រាប់ប្រើប្រាស់ជាវិធីក្នុងការវាយតម្លៃឲ្យមានភាពស្របគ្នានៃស្តង់ដារកសិកម្មសរីរាង្គរបស់អាស៊ាន | អគ្គនាយកដ្ឋានកសិកម្ម |
| ១១ | ស្តង់ដាររបស់អាស៊ានសម្រាប់ ក. Calamansi/Musk ខ. ក្រូចឆ្មា គ. ស្លឹកគ្រៃ ឃ. ធាងគ្រៃ និង ង. ប៉េងប៉ោះ | អគ្គនាយកដ្ឋានកសិកម្ម |
| ១២ | សៀវភៅណែនាំអំពីជីវសុវត្ថិភាពរបស់អាស៊ានសម្រាប់ការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្ម | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ១៣ | ស្តង់ដាររបស់អាស៊ានសម្រាប់ការអនុវត្តការផលិតល្អ (GMP) សម្រាប់ផលិតផលបសុសត្វ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ១៤ | យុទ្ធសាស្ត្រនៃតំបន់អាស៊ានស្តីពីការត្រួតពិនិត្យនិងបង្ការជំងឺផ្តាសាយជ្រូកសម្រាប់ឆ្នាំ២០១៩-២០២៥ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ១៥ | គោលការណ៍ណែនាំរបស់អាស៊ានស្តីពីវ៉ាក់សាំងការពារ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ១៦ | ការអនុវត្តការចិញ្ចឹមសត្វល្អសម្រាប់សត្វចៀមនិងពពែ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ១៧ | ការអនុវត្តការចិញ្ចឹមសត្វល្អសម្រាប់គោយកទឹកដោះ | អគ្គនាយកដ្ឋានសុខភាពសត្វនិង ផលិតកម្មសត្វ |
| ១៨ | ការអនុវត្តការចិញ្ចឹមសត្វល្អសម្រាប់គោយកសាច់ រួមទាំងក្របីយកសាច់ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ១៩ | ការអនុវត្តការចិញ្ចឹមសត្វល្អសម្រាប់សត្វទា | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ២០ | គោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការគ្រប់គ្រងខ្សែច្រវាក់ត្រជាក់សម្រាប់អាហារសមុទ្រ | រដ្ឋបាលជលផល |
| ២១ | គោលការណ៍ណែនាំបច្ចេកទេសថ្នាក់តំបន់ស្តីពីប្រព័ន្ធផ្តល់ព័ត៌មានទាន់ហេតុការណ៍អំពីការសង្គ្រោះបន្ទាន់នូវសុខភាពវារិសត្វ | រដ្ឋបាលជលផល |

| | | |
|---|---|---|
| ២២ | ឯកសារទស្សនៈទានសម្រាប់ការបង្កើតបណ្ដាញរបស់អាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត | រដ្ឋបាលជលផល |
| ២៣ | វិធីសាស្ត្រវាយតម្លៃការចូលរួមរបស់សហគមន៍ព្រៃឈើកម្រិតតំបន់ | រដ្ឋបាលព្រៃឈើ |
| ២៤ | សៀវភៅណែនាំថ្នាក់តំបន់ស្ដីពីកសិរុក្ខកម្មសម្រាប់ភាពធន់នៃដីទៅនឹងការប្រែប្រួលអាកាសធាតុ | រដ្ឋបាលព្រៃឈើ |
| ២៥ | គោលការណ៍ណែនាំរបស់អាស៊ានស្ដីពីការតាមដាននិងការទប់ស្កាត់ការជួញដូរសត្វព្រៃ | រដ្ឋបាលព្រៃឈើ |
| ២៦ | ក្រមប្រតិបត្តិស្ម័គ្រចិត្តរបស់អាស៊ានស្ដីពីការនាំចូលសម្រាប់ក្រុមហ៊ុនអាជីវកម្មព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ២៧ | គោលការណ៍ណែនាំទូទៅរបស់អាស៊ានស្ដីពីម្ហូបអាហារហាឡាល់ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| ២៨ | សៀវភៅណែនាំអំពីជីវសុវត្ថិភាពសម្រាប់ការចិញ្ចឹមសត្វទំពារអៀងជាលក្ខណៈពាណិជ្ជកម្ម | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |

គ. កិច្ចព្រមព្រៀងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ៖

នៅក្នុងឆ្នាំ២០១៩ នេះ មានអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួន១១ បានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយក្រសួង ដែលមានគម្រោងសរុបចំនួន១៣ គិតជាថវិកាសរុបចំនួន ២៩.៧៨៤.០៨២,០០ ដុល្លារអាមេរិក និង ៥.០០០.០០០ អឺរ៉ូ។ ឈ្មោះអង្គការ និងគម្រោង រួមទាំងថវិកា ដូចមានរៀបរាប់លម្អិតក្នុងតារាងខាងក្រោម ៖

| ល.រ | ឈ្មោះអង្គការ | ឈ្មោះគម្រោង | រយៈពេលគម្រោង | ថវិកាគម្រោង |
|---|---|---|---|---|
| ១ | JVC | លើកកម្ពស់សន្តិសុខស្បៀងរបស់សហគមន៍ជនបទតាមរយៈវិធីសាស្ត្រធ្វើកសិកម្មអេកូឡូស៊ីនិងគ្រប់គ្រងធនធានធម្មជាតិចម្រុះ | ២០១៩-២០២១ | ៥៣២.៤០០ $ |
| ២ | KINAL FOUNDATION | រៀបចំកម្មវិធីប្រកួតប្រជែងបង្កើតស្នាដៃស្រាវជ្រាវផ្នែកកសិកម្ម (ពានរង្វាន់ត្នោតមាស) | ២០១៩-២០២០ | គ្មានបញ្ជាក់ |
| ៣ | HEKS CAMBODDIA | លើកកម្ពស់វិស័យម្រេចនៅកម្ពុជា | ២០១៩-២០២២ | ៧៦២.១២១ $ |
| ៤ | CWS | លើកកម្ពស់ជីវភាពប្រជាជនកម្ពុជានៅជនបទ | ២០១៩- ២០២១ | ៤៣៧.៦២១ $ |
| ៥ | ADRA | លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មទីផ្សារតាមរយៈនិរន្តរភាពផលិតកម្ម | ២០១៩- ២០២៣ | ២.០៩៥.២៩១ $ |
| ៦ | IIRR | ការព្យាករណ៍អាកាសធាតុតាមរដូវកាលនិងការធានារ៉ាប់រងហានិភ័យពីការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម | ២០១៩-២០២២ | ៤៣២.០៤១ $ |
| ៧ | WILDLIFE ALLIANCE | កម្មវិធីសង្គ្រោះនិងថែរក្សាការពារសត្វព្រៃ | ២០១៩-២០២១ | ២.៦៤៣.៧៣៤ $ |
| ៨ | FREE THE BEAR | កម្មវិធីជួយសង្គ្រោះនិងអភិរក្សខ្លាឃ្មុំកម្ពុជា | ២០១៩-២០២២ | ១.២៣៦.០០០ $ |
| ៩ | VSO | បង្កើនលទ្ធភាពទទួលបានទីផ្សារសម្រាប់ជនក្រីក្រ | ២០១៩-២០២០ | ១៣១.៩៩២ $ |
| ១០ | DANA ASIA | មជ្ឈមណ្ឌលខ្មែរ-ជប៉ុនបណ្ដុះបណ្ដាលចិញ្ចឹមមាន់ | ២០១៩-២០២២ | ៩៩៥.៤២០ $ |
| ១១ | FAO | កសាងភាពធន់នៃវិស័យកសិកម្មទៅនឹងអាកាសធាតុ និងមហន្តរាយដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកប | ២០១៩-២០២០ | ៥០០.០០០ $ |

| | | | | |
|---|---|---|---|---|
| | | ដោយចីរភាពនៅអាស៊ី | | |
| ១២ | FAO | អភិវឌ្ឍសមត្ថភាពនៅក្នុងប្រព័ន្ធនវានុវត្តន៍កសិកម្ម ៖ ការពង្រីកក្របខ័ណ្ឌកសិកម្មតំបន់ត្រូពិច | ២០១៩-២០២៣ | ៥.០០០.០០០ € |
| ១៣ | FAO | ការបំពេញបន្ថែមការគាំទ្រដល់កម្មវិធីនៅកម្ពុជា សម្រាប់ភាពរីកចម្រើនលូតលាស់ប្រកបដោយបរិយាប័ន្ននិងចីរភាពក្នុងវិស័យជលផល៖ សម្រាប់សមាសភាគនេសាទ | ២០១៩-២០២៤ | ២០.០១៧.៤៦២ $ |

### ៥.៦.៣. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា

#### ក. កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

ASPIRE គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានរយៈពេល៧ឆ្នាំ ចាប់ផ្ដើមពីឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០២២។ គោលដៅជារួមនៃកម្មវិធីASPIRE គឺកាត់បន្ថយភាពក្រីក្រនិងបង្កើនភាពធន់របស់គ្រួសារកសិករខ្នាតតូច និងគ្រួសារកសិករងាយរងគ្រោះចំនួន១៤៤ ០០០គ្រួសារ តាមរយៈ ការបង្កើនតម្លៃផលិតកម្មកសិកម្ម និងតម្លៃទ្រព្យសម្បត្តិគ្រួសារកសិករគោលដៅក្នុងរង្វង់២០% និង ២៥% តរៀងគ្នា។ គិតត្រឹមឆ្នាំ២០១៩ កម្មវិធី ASPIRE បាននិងកំពុងអនុវត្តនៅខេត្តគោលដៅចំនួន២០ ហើយឆ្នាំ២០២០ នឹងបញ្ចូលខេត្តថ្មីចំនួន៤ទៀត គឺខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តឧត្តរមានជ័យ។

ក្នុងឆ្នាំ២០១៩នេះ កម្មវិធីសម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖

#### ក.១ ការរៀបចំនិងអនុវត្តគោលនយោបាយគាំទ្រវិស័យកសិកម្ម

ឯកសារគោលនយោបាយគាំទ្រដល់ការអភិវឌ្ឍន៍វិស័យកសិកម្មត្រូវបានរៀបចំដាក់ឱ្យប្រើប្រាស់ និងខ្លះកំពុងដំណើរការរៀបចំ ដែលរួមមាន៖ (១)ការវិនិយោគលើវិស័យកសិកម្មនិងការវិនិយោគលើការងារផ្សព្វផ្សាយកសិកម្មនៅប្រទេសកម្ពុជា (២)ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ និង(៣) គោលនយោបាយអភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម ហើយកំពុងរៀបចំ (១)ផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ (២)ផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២៥រាជធានី-ខេត្ត (៣)ការពិនិត្យឡើងវិញគោលនយោបាយផ្សព្វផ្សាយកសិកម្ម និង(៤) ការកែលម្អប្រព័ន្ធតាមដាននិងវាយតម្លៃការប្រើប្រាស់ថវិកាកម្មវិធី។

#### ក.២ ការអភិវឌ្ឍសមត្ថភាពសម្រាប់សេវាកម្មផ្សព្វផ្សាយកសិកម្ម

ការអភិវឌ្ឍសមត្ថភាពក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មត្រូវបានរៀបចំដោយសាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការផ្សព្វផ្សាយ ការគ្រប់គ្រងចំណេះដឹង និងការពង្រឹងសមត្ថភាពធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយនិងដើម្បីគាំទ្រដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកផ្តល់សេវាផ្សព្វផ្សាយផ្សេងទៀត ដើម្បីធ្វើឲ្យប្រាកដថា ការផ្សព្វផ្សាយនិងសេវាប្រឹក្សាបច្ចេកទេសត្រូវបានកែលម្អ ហើយកសិករ និងអ្នកផលិតកសិផលទាំងឡាយ អាចទទួលនិងប្រើប្រាស់សេវាផ្សព្វផ្សាយប្រកបដោយគុណភាពខ្ពស់ មានភាពច្នៃប្រឌិតថ្មីធន់នឹងការប្រែប្រួលអាកាសធាតុនិងការអនុវត្តន៍កសិកម្មល្អ។ សមិទ្ធិផលសម្រេចបានរួមមាន គោលការណ៍ណែនាំស្តីពីកិច្ចដំណើរការសេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករនិងអតិថិជន ការបញ្ចូលឯកសារកសិកម្មសរុបចំនួន ៤៨០ឯកសារក្នុងគេហទំព័រផ្សព្វផ្សាយកសិកម្ម www.khmeragri.info ហើយទទួលបានការចូលមើលចំនួន១៦៩ ០៧៨នាក់ និងមានអតិថិជនទាញយកឯកសារចំនួន៥៣ ៤១៧នាក់ ការជ្រើសរើសអ្នកផ្តល់សេវាកម្មផ្នែកផ្សព្វផ្សាយបានចំនួន២០៧អង្គភាព ការជ្រើសរើសមន្ត្រីបច្ចេកទេសធ្វើជាមន្ត្រីបង្គោលសម្រាប់មជ្ឈមណ្ឌលទទួលនិងឆ្លើយតបសំណួរបច្ចេកទេស ការដាក់ឲ្យដំណើរការមណ្ឌលបណ្តុំព័ត៌មានកសិកម្ម ការបណ្តុះបណ្តាលភ្នាក់ងារ

ផ្សព្វផ្សាយកសិកម្មចំនួន៤២៤នាក់ ការធ្វើបច្ចុប្បន្នភាពលើគោលការណ៍ណែនាំក្នុងការអនុវត្តកិច្ចសន្យាខាងក្រៅ គោលការណ៍ណែនាំស្តីពីការពិនិត្យគុណផលក្នុងការផ្សព្វផ្សាយវិធីសាស្ត្រចំណេះដឹងទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការបណ្តុះបណ្តាលគ្រូបង្គោលបានចំនួន៨៤នាក់ ការគាំទ្របច្ចេកទេសលើប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំស្តីពីការភ្ជាប់ផលិតផលកសិកម្មទៅទីផ្សារ ការគាំទ្របច្ចេកទេសស្តីពីប្រព័ន្ធកសិកម្មចម្រុះតាមតំបន់ក្បៀត្រ-បរិស្ថាន ការរៀនសូត្រពីកសិករទៅកសិករ ការបង្កើតកម្មវិធីសិក្សាសម្រាប់ថ្នាក់អនុបណ្ឌិតផ្នែកផ្សព្វផ្សាយកសិកម្ម ការបង្កើតកម្មវិធីសិក្សាកម្រិតអនុបណ្ឌិត និងការសិក្សាតាមអេឡិកត្រូនិកនៅតាមសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប។

**ក.៣ ការផ្តល់សេវាផ្សព្វផ្សាយដែលមានភាពល្អប្រសើរ**

វិធីសាស្ត្រផ្សព្វផ្សាយកសិកម្មចំនួន៥ត្រូវបានអនុវត្តដែល (១)កិច្ចសន្យាជួលអ្នកខាងក្រៅក្នុងការផ្តល់សេវាផ្សព្វផ្សាយ (២)តាមរយៈសហគមន៍កសិកម្ម ឬអង្គការកសិករ (៣)តាមរយៈពីកសិករទៅកសិករ (៤)ភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន និង(៥)មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តជាអ្នកអនុវត្តសកម្មភាពផ្ទាល់។

គិតត្រឹមឆ្នាំ២០១៩ គ្រួសារកសិករចំនួន ១០៣ ១៩៧គ្រួសារ ក្នុងចំណោម ១៤៤ ០០០ គ្រួសារ បានទទួលផលពីការអនុវត្តកម្មវិធី បានចងក្រងបណ្តុំអាជីវកម្មបានចំនួន ១ ២៥១ បណ្តុំ ដែលប្រកបអាជីវកម្មផលិតកម្មដំណាំ សត្វ ព្រៃឈើ និងជលផល ការបង្កើតបណ្តាញទីផ្សារនៅតាមផ្សារទំនើបៗ ដូចជា ផ្សារអ៊ីអនម៉ល ខ្មែរសរីរាង្គកសិដ្ឋានរីករាយ សួនធម្មជាតិ ជាដើម។ល។ ការបង្កើតភាពជាដៃគូ ជាមួយក្រុមហ៊ុនឯកជន ឬអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម ការគាំទ្រដល់សហគមន៍កសិកម្ម ឬអង្គការកសិករបានជាង ១៥០សហគមន៍ និងការសាងសង់ផ្ទះសំណាញ់បានចំនួន១២៣កន្លែង ដែលស្មើនឹងផ្ទៃដីសរុបប្រមាណជាជាង៤៤ ០០០ម៉ែត្រការ៉េ។

**ក.៤ ហេដ្ឋារចនាសម្ព័ន្ធដែលជួយដល់ការធ្វើកសិកម្មធន់នឹងអាកាសធាតុ**

លេខាធិការដ្ឋានគ.ជ.អ.ប (NCDD-S) អនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់នឹងអាកាសធាតុ បានចំនួន ១១៥គម្រោង នៅក្នុងឃុំចំនួន ២២០ឃុំ ប្រជុំធ្វើ VRA ដើម្បីរៀបចំផែនទីងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងបានបញ្ចូលវិធានការដែលធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍឃុំរយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំសង្កាត់បានចំនួន ៦៤ឃុំ រៀបចំសិក្ខាសាលាស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុដើម្បីពិនិត្យនិងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ស្រុកបានចំនួន៣២ស្រុក។

**ខ. កសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើងវិញក្នុង វិស័យកសិកម្ម** (S-RET)

S-RET គឺជាគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដែលទទួលបានការគាំទ្រថវិកាពីមូលនិធិបរិស្ថានពិភពលោក (GEF)។ គោលដៅរបស់គម្រោង គឺធ្វើឱ្យកាន់តែប្រសើរជីវភាពរស់នៅរបស់កសិករក្រីក្រតាមជនបទនៃខេត្តគោលដៅចំនួន៥ គឺខេត្តកំពត កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ តាមរយៈការពង្រីកឱ្យកាន់តែទូលាយនូវការទទួលយក និងប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ (RET) ក្នុងគាំទ្រការផលិត ការកែច្នៃ និងការធ្វើអាជីវកម្មកសិកម្មរបស់កសិករ។

ទន្ទឹមនឹងនេះ គម្រោងក៏បានពង្រីកទៅខេត្តទាំងអស់ដែលគាំទ្រដោយកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដែលកម្មវិធីនេះកំពុង អនុវត្តសកម្មភាពនៅខេត្តគោលដៅចំនួន ២៤ ក្នុងទូទាំងប្រទេសកម្ពុជា។ គម្រោង S-RET មានរយៈពេល ៤ ឆ្នាំ ចាប់ផ្តើមពីខែតុលា ឆ្នាំ២០១៦ ដល់ខែធ្នូ ឆ្នាំ២០២០ ដោយមានថវិកាសរុបចំនួន ៤,៦ លានដុល្លារអាមេរិក។

រហូតមកដល់ពេលនេះ គម្រោងបានជ្រើសរើសអង្គភាព និងក្រុមហ៊ុនឯកជនចំនួន ១១ ឱ្យធ្វើការសាកល្បង និងបង្ហាញអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ RET ក្នុងផលិតកម្មកសិកម្ម និងការកែច្នៃកសិផល រួមមាន៖ (១) ម៉ូទ័រប្ដូមទឹក ប្រើថាមពលព្រះអាទិត្យចំនួន ២១១ គ្រឿង ក្នុងខេត្តតាកែវ កំពត និងខេត្ត ៩ ទៀត ដែលគាំទ្រដោយកម្មវិធី ASPIRE (២) ទូភ្ញាស់ស៊ុតមាន់ ប្រើថាមពលព្រះអាទិត្យចំនួន ១៣៩ គ្រឿង ក្នុងខេត្តតាកែវ ស្វាយរៀង និងខេត្តព្រៃវែង (៣) ធុងអនាម័យ សម្រាប់ដុតកម្ដៅកូនមាន់ចំនួន ១៧៤ កញ្ចប់ ក្នុងខេត្តតាកែវ កណ្ដាល ព្រៃវែង និងខេត្តកំពង់ឆ្នាំង (៤) ឧបករណ៍ហាលសម្ងួត ប្រើថាមពលព្រះអាទិត្យចំនួន ៥៧ គ្រឿង ក្នុងខេត្តកណ្ដាល ព្រៃវែង និងខេត្តកំពង់ឆ្នាំង (៥) ប្រព័ន្ធកម្ដៅទឹកសម្រាប់ត្រាំ និងលាងសម្អាតបន្លែ និងផ្លែឈើ ប្រើថាមពលព្រះអាទិត្យ ចំនួន ១៥ គ្រឿង ក្នុងខេត្តកណ្ដាល ស្វាយរៀង បាត់ដំបង និងរាជធានីភ្នំពេញ (៦) ការដាំបន្លែលើទឹក ប្រើថាមពលព្រះអាទិត្យចំនួន ៧ បណ្ដុំ ដែលមានចំនួន ២១ ថ្នាល សម្រាប់សហគមន៍ក្នុងខេត្តកំពត និងខេត្តព្រៃវែង (៧) ទូភ្ញាស់ និងចិញ្ចឹមចង្រឹត ប្រើថាមពលព្រះអាទិត្យចំនួន ១២ គ្រឿង ក្នុងខេត្តស្វាយរៀង (៨) ប្រព័ន្ធសូឡាផ្គួបជាមួយជីវឧស្ម័ន សម្រាប់ដំណើរការសត្តឃាតដ្ឋានចំនួន ៩ ទីតាំង ក្នុងខេត្តបាត់ដំបង កំពត កណ្ដាល កំពង់ឆ្នាំង និងខេត្តតាកែវ (៩) ម៉ាស៊ីនកែច្នៃចំណីសត្វ ប្រើថាមពលព្រះអាទិត្យចំនួន ១២ គ្រឿង និងធុងត្រជាក់ប្រើថាមពលព្រះអាទិត្យ សម្រាប់រក្សាទុកវ៉ាក់សាំងចំនួន ៣ គ្រឿង ក្នុងខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង ។

ម៉្យាងវិញទៀត គម្រោងក៏បានជ្រើសរើសក្រុមហ៊ុនចំនួន ៦ ដើម្បីពង្រីកឲ្យសាយភាយតាមរយៈការបង្កើតបណ្ដាញផ្គត់ផ្គង់ RET ក្នុងខេត្តគោលដៅ។ គម្រោងក៏បានជ្រើសរើសយកកម្មវិធីឡជីវឧស្ម័នជាតិ ដើម្បីតម្លើងឡជីវឧស្ម័នប្រភេទនវានុវត្តន៍ចំនួន ៣ ០០០ កន្លែង និងសាងសង់រោងជីកំប៉ុស្ត សម្រាប់ដាក់ជីឡនិងកាកសំណល់ផ្សេងៗ ចំនួន ៣០០ កន្លែង ដើម្បីប្រើប្រាស់ក្នុងប្រព័ន្ធកសិកម្ម។

កសិករទទួលផលមានចំនួន ២ ៩៣៧ គ្រួសារ បានបង្ហាញនូវការចាប់អារម្មណ៍ខ្ពស់ និងពេញចិត្តក្នុងការចូលរួម និងវិនិយោគលើការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ។ គម្រោង S-RET នឹងជ្រើសរើសក្រុមហ៊ុនដែលបាន និងកំពុងសាកល្បងបច្ចេកវិទ្យាចំនួន១ បន្ថែមទៀត ដើម្បីធ្វើឲ្យសាយភាយ RET នៅទូទាំងប្រទេស។ ទន្ទឹមនេះ គម្រោងកំពុងរៀបចំគោលនយោបាយលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញក្នុងវិស័យកសិកម្មនៅកម្ពុជា ឆ្នាំ២០២០-២០៣០។

**គ. គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជំហាន២**

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជំហានទី២ បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងផ្ដល់ហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីនាថ្ងៃទី០៩ ខែមករាឆ្នាំ២០១៨ មានថវិកាសរុប ៦៦ លាន ដុល្លារអាមេរិក ដែលក្នុងនោះធនាគារអភិវឌ្ឍន៍អាស៊ីបានផ្ដល់ហិញ្ញប្បទាន ៥០ លានដុល្លា រអាមេរិក មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) បានផ្ដល់ហិរញ្ញប្បទាន ១០លានដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ០៦ លានដុល្លារអាមេរិក ។ គម្រោងមានរយៈពេលអនុវត្ត០៥ឆ្នាំ ចាប់ផ្ដើមអនុវត្ត ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ហើយនឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ។ គម្រោងអនុវត្តក្នុងខេត្តគោលដៅ០៧ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រៃវែង ដែលអនុវត្តក្នុង ស្រុក គោលដៅ ៣៧ ឃុំគោលដៅសរុប ២៧០ ឃុំ សង្កាត់ ។ រចនាសម្ព័ន្ធរបស់គម្រោងមានពីរផ្នែក៖(១) ភ្នាក់ងារប្រតិបត្តិ គម្រោង ដែលមានអង្គភាពសម្របសម្រួលការអភិវឌ្ឍរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(២)លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ។ លទ្ធផលរំពឹងទុក(១)មានការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រផលិតភាពកសិកម្ម និងកែលម្អជីវភាព ដោយបង្កើនសមត្ថភាពគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដែលក្នុងនោះមានសកម្មភាពសាងសង់ផ្លូវ ប្រព័ន្ធធារាសាស្ត្រ សម្ភារបរិក្ខារផ្សេងៗដែលជាតម្រូវការរបស់ក្រុមកែលម្អ

ទីផ្សា គាំទ្រក្រុមកែលម្អជីវភាពចាស់ ១២០៥ ក្រុម តាមរយៈសមាគម និងបង្កើតក្រុមកែលម្អជីវភាពថ្មី ៧៥៩ក្រុម និងចងក្រងបង្កើតក្រុមសេវាកម្មយ៉ាងតិច២០០ក្រុម។ ជ្រើសរើសអ្នកផ្តល់ព័ត៌មានចល័តឃុំ សង្កាត់ ២៧០នាក់ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកំណត់ និងធ្វើផែនការឆ្លើយតបទៅនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅកម្រិតឃុំសង្កាត់។ (២)កែលម្អបរិយាកាសសម្រាប់ការបង្កើនផលិតភាពកសិកកម្ម ពិពិធកម្ម កសិកម្ម និងភាពធន់នឹងអាកាសធាតុសម្របសម្រួលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសកម្មភាពគាំទ្រច្រវាក់ផលិតកម្មតម្លៃ និងទំនាក់ទំនងទីផ្សារ ការបង្កើនលទ្ធភាពទទួលបានព័ត៌មានកសិកម្ម និងទិន្នន័យទីផ្សារ (ព័ត៌មានទីផ្សារជនបទ និងខ្សែច្រវាក់ផលិតកម្ម ដំណាំបន្លែ ស្រូវ ការចិញ្ចឹមមាន់ និងចិញ្ចឹមត្រី និង (៣)ការពង្រឹងការគ្រប់គ្រងគម្រោង អនុវត្តរួមគ្នាដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្នុងឆ្នាំ២០១៩ គម្រោងបានចំណាយថវិកា ៥០៤.៤០៩,00 ដុល្លារអាមេរិក ដែលក្នុងនោះជាថវិកាកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ៤១៧.៩៥៨,២១ ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ៨៦.៤៥១,00 ដុល្លារអាមេរិក។ ចំពោះការចំណាយថវិការបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិ សម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសរុប ៣.៣០៦.០៦០,00 ដុល្លារអាមេរិក ក្នុងនោះជាថវិកាកម្ចីហិរញ្ញប្បទាន និងហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានចំនួន ៣.១៧៦.៧៥៥,២០ ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១២៩៣០៥,០០ ដុល្លារអាមេរិក ។ សរុបថវិកាចំណាយរួមរបស់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ ទន្លេសាបជំហាន២ មានចំនួន ៣.៨១០.៤៦៩,៩១ ដុល្លារអាមេរិក (៣០,២៥%)។ ចំពោះផ្នែកខាងកសិកម្ម ការអនុវត្តគម្រោងជាលក្ខណៈរូបវន្តក្នុងឆ្នាំ២០១៩ សម្រេចបាន៥0%ដោយប្រើប្រាស់ពេលវេលាអស់ 100% និងការអនុវត្តគម្រោងជាលក្ខណៈរូបវន្តរបស់គម្រោងមកដល់ពេលបច្ចុប្បន្នសម្រេចបាន ២៦% (លទ្ធផល២ស្មើនឹង ២១%និងលទ្ធផល៣ស្មើនឹង៣0%)។ ***ការចំណាយរបស់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបជំហាន២ ចាប់ពីគម្រោងចាប់ផ្តើមមកដល់បច្ចុប្បន្នមាន ៥៩៩៤៨៤៩,២០ ដុល្លារអាមេរិក (៩,២២%)***។ ផ្នែកកសិកម្មកសិករដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងមានចំនួន ៣៤១៦ គ្រួសារ និងដោយមិនផ្ទាល់ពីគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជំហាន២ មាន ៤១.៩៦៧ គ្រួសារ។ គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កសិករដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងមាន ៣៧.៣00គ្រួសារ (ក្រុមកែលម្អជីវភាព) និងមិនផ្ទាល់ (គម្រោងហេដ្ឋារចនាសម្ព័ន្ធនិងស្រោចស្រព) ពីគម្រោងតាំងពីចាប់ផ្តើមមកដល់បច្ចុប្បន្ននេះមានចំនួន៣៧.៤៨៧៤ គ្រួសារ។ ការអនុវត្តគម្រោងជាលក្ខណៈរូបវន្តក្នុងឆ្នាំ២០១៩ សម្រេចបាន៧0% និងការអនុវត្តគម្រោងជា លក្ខណៈរូបវន្តរបស់គម្រោងមកដល់ពេលបច្ចុប្បន្នបានចំនួន ២៤ %។ ក្នុងឆ្នាំ២០១៩ មានបញ្ហាប្រឈមមួយចំនួន មានដូចជា ការធ្វើបង្ហាញមួយចំនួនត្រូវបានពន្យារពេលដោយសារតែបញ្ហាអាកាសធាតុ និងការជ្រើសរើសកសិករមិនទាន់ពេលវេលា។ នីតិវិធីនៃការជ្រើសរើសសេវាករទី៨ មានភាពស្មុគស្មាញ។ ចំពោះកិច្ចការសិក្សា និងការរៀបចំរបាយការណ៍សុវត្ថិភាព (Safeguards) សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធមានច្រើនរហូតដល់២៧០ឃុំ-សង្កាត់ ដែលនាំឲ្យមានការយឺតយ៉ាវដល់ការដេញថ្លៃ។ ម្យ៉ាងទៀត គ្រួសារក្រ១ ក្រ២ មានចំណាកស្រុកច្រើនដែលនាំឲ្យរាំងស្ទះដល់ដំណើរការបង្កើតក្រុមកែលម្អជីវភាព។ ក្នុងឆ្នាំ ២០២០ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបជំហាន២ នឹងបន្តអនុវត្តផែនការសកម្មភាព និងថវិកា ស្របតាមការអនុម័ត របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី។

### ឃ. កម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា (Cambodia Agricultural Value Chain Program II)

កម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជាជំហ៊ានគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី នៅក្នុងឆ្នាំ២០១៩នេះ កម្មវិធី CAVAC បានកំណត់គោលដៅឡើងវិញ ដោយផ្តោតជាក់លាក់ទៅលើ ការលើកកម្ពស់ការសម្រេចបាននូវការធ្វើពាណិជ្ជកម្ម និងភាពធន់នឹងការប្រែប្រួលអាកាសធាតុលើវិស័យកសិកម្ម ដែលជាដំណោះស្រាយនូវភាពប្រឈមក្នុងដំណាក់កាលផ្លាស់ប្តូរវិស័យកសិកម្ម ទៅក្នុងកសិកម្មទំនើបក្នុងបរិបទសេដ្ឋកិច្ចសម្បូរបែប។ ក្នុងឆ្នាំ ២០១៩នេះ កម្មវិធី CAVAC ទទួលបានលទ្ធផលជារួមមាន៖

**<u>ផលចំណេញនៃការស្រោចស្រពកសិកម្ម:</u>** បានបញ្ចប់ការសាងសង់ និងសេវាស្រោចស្រពកសិកម្ម ១០ ប្រព័ន្ធ ដែលបានស្រោចស្រពលើផ្ទៃដីដាំដុះសរុប ១៩ ៨៤៧ហិកតា និងទទួលបានបរិមាណផល ១០៧ ១៣៤ តោនស្រូវ (គិតជាតម្លៃប្រមាណ១៩ ៤៩៨ ៣៨៨ ដុល្លារអាមេរិក) ដោយមានទិន្នផលមធ្យម ៥,៥តោន/ហិកតា (ក្នុងនោះស្រូវដើមរដូវ ៥,៣តោន/ហិកតា និងស្រូវប្រាំង ៥,៨ តោន/ហិកតា)។

ក្រៅពីនេះ កម្មវិធី CAVAC បានជំរុញការចូលរួមពីគម្រោង និងកម្មវិធីនានាក្នុងវិស័យកសិកម្មដោយបានបញ្ចប់ការរៀបចំប្លង់កែលម្អប្រព័ន្ធស្រោចស្រពព្រែកពោធិ ដែលមានទឹកប្រាក់២៤,៥លានដុល្លារអាមេរិក (មួយផ្នែកនៃគម្រោងកែលម្អប្រព័ន្ធស្រោចស្រពកសិកម្មដែលផ្តល់ថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី-ADB)។ ការសាងសង់ចាប់ផ្តើមនៅក្នុងខែមីនា ឆ្នាំ២០២០ ហើយបន្ទាប់មកនឹងរៀបចំសេវាប្រើប្រាស់ និងថែទាំប្រព័ន្ធស្រោចស្រព។

**<u>ការជំរុញភាពប្រកួតប្រជែងវិស័យកសិកម្ម:</u>** បន្តការគាំទ្រក្នុងឧស្សាហកម្មពូជស្រូវ ដោយបានដាក់ឱ្យប្រើប្រាស់ពូជស្រូវប្រណីតនិងពូជមានគុណភាពខ្ពស់។ ជាលទ្ធផលបានគាំទ្រអគ្គនាយកដ្ឋានកសិកម្ម ក្នុងការសម្រិតសម្រាំង និងការដាក់ប្រើប្រាស់**ពូជសែនក្រអូប១** ដែលបានបញ្ចេញជាផ្លូវការដោយគណៈកម្មាធិការបញ្ចេញពូជ នៅក្នុងខែធ្នូ ឆ្នាំ២០១៩ ពូជស្រូវក្រអូបដែលធន់នឹងការប្រែប្រួលអាកាសធាតុពូជផ្កាមារតី និងជំរុញការប្រើប្រាស់ពូជខា១៥ ក្នុងផលិតកម្មជាមួយរោងម៉ាស៊ីនកិនស្រូវ និងសហគមន៍កសិកម្ម។

បានគាំទ្រអនុវត្តជាផលិតកម្មស្រូវការកិច្ចសន្យា ដោយកសិករ និងសហគមន៍កសិកម្មជាមួយក្រុមហ៊ុនអំម៉ារ៉ូរ៉ាយ ប្រមាណ ៣ ២៤៦ តោន (គិតជាទឹកប្រាក់ចំនួន ៩៧៣ ៨០០ ដុល្លារអាមេរិក។

បានដាក់បញ្ចូលនវានុវត្តន៍ថ្មីៗដូចជា ម៉ាស៊ីនដាំគ្រាប់ស្រូវ (Eli Seeders) ១៤គ្រឿង និងឧបករណ៍ដាំ (Thai Kids) ១៥៥ គ្រឿង ព្រមទាំងឧបករណ៍ លន់ ហោង ដាំគ្រាប់ស្រូវចំនួន៤គ្រឿង តាមរយៈការធ្វើបង្ហាញ និងទិវាស្រែ និងការធ្វើពិព័រណ៍ឧបករណ៍ និងសេវាកសិកម្ម។ តាមរយៈសកម្មភាពនេះ ប្រជាកសិករ និងសហគមន៍កសិកម្មបានទិញម៉ាស៊ីន និងឧបករណ៍ដាំគ្រាប់ទាំងនេះ ប្រើប្រាស់ក្នុងផលិតកម្មស្រូវ។

បានធ្វើបង្ហាញប្រើប្រាស់ឧបករណ៍កៀរពង្រាបដីដោយបច្ចេកវិទ្យាឡាស៊ែរជាមួយក្រុមហ៊ុន ហើយក្នុងឆ្នាំ ២០១៩នេះ ក្រុមហ៊ុនបានលក់ឧបករណ៍កៀរពង្រាបដីដោយបច្ចេកវិទ្យាឡាស៊ែរចំនួន១១គ្រឿង ប្រើប្រាស់ក្នុងផលិតកម្ម និងបានពង្រាបដី ១៦ ៥០៥ហិកតា។ តាមការវាយតម្លៃគឺបានបង្កើនទិន្នផលប្រមាណ0.៥ តោនក្នុង១ហិកតា និងកើនផលស្រូវ ៧០៥ តោនលើសពីដីភ្ជួរធម្មតាដែលគិតជាតម្លៃទឹកប្រាក់ ១២៨ ៣១០ ដុល្លារអាមេរិក។

**<u>ការពង្រឹងបរិយាកាសប្រកួតប្រជែង:</u>** បានគាំទ្រអគ្គនាយកដ្ឋានកសិកម្ម ក្នុងការអនុវត្តគោលនយោបាយពូជដំណាំជាតិក្នុងការបង្កើតក្រុមប្រឹក្សាពូជដំណាំ ប្រកាសគណៈកម្មាធិការបញ្ចេញពូជ និងអនុក្រឹត្យបង្កើតនាយកដ្ឋានពូជដំណាំ ព្រមទាំងបង្កើតប្រព័ន្ធបញ្ជាក់គុណភាពពូជ និងបានប្រើប្រាស់សាកល្បង។

បានគាំទ្រអគ្គនាយកដ្ឋានកសិកម្ម បង្កើតសន្ទានុក្រមស្តីពីសមាសភាពចង្រៃនៅកម្ពុជា និងបានបោះពុម្ពចែកចាយចំនួន៧ ០០០ ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីសមាសភាព និងវិធានការការពារដំណាំអនាម័យនិងភូតគាមអនាម័យ។ បានសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា ផ្សព្វផ្សាយពីនីតិវិធីអនុវត្តអនាម័យ និងភូតគាមអនាម័យនាំចេញអង្ករទៅប្រទេសចិន និងសហការជាមួយមជ្ឈមណ្ឌលអន្តរជាតិ

ស្រាវជ្រាវកសិកម្មតំបន់ត្រូពិក ពិសោធន៍វាយតម្លៃពូជដំឡូងមីធន់នឹងជំងឺម៉ូសាអ៊ិចវីរុស។ សហការជាមួយនាយកដ្ឋាននីតិកម្មកសិកម្ម រៀបចំសិក្ខាសាលាផ្សព្វផ្សាយ១១លើក ស្តីពីប្រកាសស្លាកសញ្ញាថ្នាំពុលកសិកម្ម នៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ពោធិ៍សាត់ កំពង់ធំ កំពង់ឆ្នាំង ត្បូងឃ្មុំ ព្រៃវែង តាកែវ និងខេត្តមណ្ឌលគិរី។

បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បានធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពស្តីពីការបញ្ជ្រាបយេនឌ័រ ២០១៩-២០២៣ ដោយបង្កើតការទំនាក់ទំនងការដឹកនាំរបស់ស្ត្រីក្នុងរចនាសម្ព័ន្ធស្ថាប័ន ជាពិសេសការដឹកនាំក្នុងសហគមន៍កសិកម្ម។

**ង. គម្រោងជំរុញផលិតកម្មស្បៀង ( Rice SDP)**

កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ និងដាក់ឱ្យដំណើរការនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលមានថវិកាសរុបចំនួន ៨៧,៤៤ លានដុល្លារអាមេរិក។ កម្មវិធីទទួលបានកម្ចី២ប្រភេទ [កម្ចីពីមូលនិធិអភិវឌ្ឍន៍អាស៊ី ( ADF) ចំនួន ៥៥លានដុល្លារអាមេរិក និងកម្ចីពីមូលនិធិសម្រាប់យុទ្ធសាស្ត្រអាកាសធាតុ (SCF) ចំនួន ៥លានដុល្លារអាមេរិក ជំនួយឥតសំណង២ប្រភេទ [ជំនួយពីកម្មវិធីសន្តិសុខស្បៀងនិងកសិកម្មសកល (GAFSP) ចំនួន១៤,៦លានដុល្លារអាមេរិក និងជំនួយពី SCF ចំនួន៤,៥ លានដុល្លារអាមេរិក] និងបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៨,៣៣លានដុល្លារអាមេរិក។ ក្នុងចំនួនថវិកាសរុបខាងលើនេះមាន២៤លានដុល្លារអាមេរិកសម្រាប់រៀបចំគោលនយោបាយ និងឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ និង ៦៣,៤៤លានដុល្លារអាមេរិកសម្រាប់ដំណើរការអនុវត្តសកម្មភាពកម្មវិធីនៅខេត្តគោលដៅ ទាំងបី (ខេត្តបាត់ដំបង ព្រៃវែង និងខេត្តកំពង់ធំ)។ ជាក់ស្តែង ថវិកាដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានសម្រាប់ការអនុវត្តកម្មវិធីខាងលើមានចំនួនសរុប ១២,៦៧៥ លានដុល្លារអាមេរិក។ កាលបរិច្ឆេទបញ្ចប់កម្ចីសម្រាប់ការងាររៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ (Program Loan Closing Date) គឺនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ប៉ុន្តែបានពន្យារពេលចំនួន០៣លើក ដែលក្នុងនោះលើកទី១ រហូតទៅ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ លើកទី២រហូតទៅដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ និង លើកទី៣ រហូតទៅដល់ថ្ងៃទី៣០ មិថុនា ឆ្នាំ២០២១។ ដោយឡែក កាលបរិច្ឆេទនៃការបញ្ចប់ការអនុវត្តសកម្មភាពគម្រោង (Project Loan Closing Date) គឺនៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២០ ប៉ុន្តែបានពន្យារពេលចំនួន០១លើករហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

កម្មវិធី Rice-SDP អនុវត្តដោយក្រសួងចំនួន០៤ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាភ្នាក់ងារប្រតិបត្តិ (EA) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាភ្នាក់ងារអនុវត្តន៍ ( IAs ) នៅថ្នាក់ជាតិ និងខេត្តគោលដៅចំនួន០៣ (ខេត្តកំពង់ធំ បាត់ដំបង និងខេត្តព្រៃវែងដែលជាភ្នាក់ងារអនុវត្តន៍ ( IAs ) នៅថ្នាក់ក្រោមជាតិ។

ក្នុងឆ្នាំ២០១៩នេះ គម្រោងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- កម្មវិធីបានបំពេញលក្ខខណ្ឌនៃការកសាងច្បាប់និងបទដ្ឋានគតិយុត្តក្រោមច្បាប់ដើម្បីសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មស្រូវ-អង្ករដែលធន់នឹងអាកាសធាតុ ចំនួន១២ឯកសារ។
- បានរៀបចំវគ្គបណ្តុះបណ្តាលសរុបចំនួន ០៧ វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន ២២៨ នាក់ (ស្ត្រីចំនួន ៤៩ នាក់ ) និងបានរៀបចំសិក្ខាសាលាសរុបចំនួន០៦ ដោយមានអ្នកចូលរួមសរុបចំនួន ៣៥៤ នាក់ (ស្ត្រីចំនួន ៤៨នាក់ )
- បានបញ្ចប់ទាំងស្រុងនូវការងារវិភាគប្រព័ន្ធក្បេត្របរិស្ថានឃុំ (៩០ឃុំ) ហើយបានបញ្ជូនទិន្នន័យនេះទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើសមាហរណកម្មទៅក្នុងផែនការប្រើប្រាស់ដី

ថ្នាក់ឃុំ (CLUP)។ ទាក់ទងនឹងការងារផលិតផែនទី គម្រោងបានបញ្ចប់សេចក្តីព្រាងលើកទី២នៃផែនទីប្រព័ន្ធក្សេត្របរិស្ថានដំណាំស្រូវ និងចំណាត់ថ្នាក់ប្រភេទដីនៃខេត្តគោលដៅទាំងបី និងកំពុងបន្តរៀបចំបញ្ចប់សេចក្តីព្រាងលើកទី២នៃផែនទីចំណាត់ថ្នាក់ប្រភេទដីផងដែរ។

- បានបញ្ចប់សេចក្តីព្រាងឯកសារដេញថ្លៃ (SPS's NCB និង ICB) និងបានដាក់ជូន ADB នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់ផលិតកម្មស្រូវ-អង្ករដែលធន់នឹងអាកាសធាតុ និងបានបញ្ចប់របាយការណ៍បញ្ជាក់អំពីសុវត្ថិភាពសង្គម (DDR) និងរបាយការណ៍ត្រួតពិនិត្យបរិស្ថានបឋម (IEE) និងគ្រោងដាក់របាយការណ៍ទាំងនេះជូន ADB នៅដើមត្រីមាសទី១ ឆ្នាំ២០២០ ដើម្បីពិនិត្យ និងសម្រេច។
- ការបង្កើនសេវាកម្មគាំទ្រខ្សែច្រវាក់ផលិតកម្មស្រូវ-អង្ករដើម្បីលើកកម្ពស់គុណភាពអង្ករកម្ពុជា គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលសរុបចំនួន ៧០វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន៥ ៧០៣នាក់ (ស្ត្រីចំនួន២ ៨៣៩នាក់) និងវគ្គបណ្តុះបណ្តាលស្តីពីសាលារៀនស្រែកសិករចំនួន១៦៥សាលា (សម្រាប់ផលិតកម្មគ្រាប់ពូជស្រូវ) និង៦០សាលា (សម្រាប់ផលិតកម្មដំណាំស្រូវនិរន្តរភាព) ដែលមានសិក្ខាកាមសរុបចំនួន ៥ ៦២៥ នាក់ (ស្ត្រីចំនួន ២ ៥០០នាក់)។
- បានផលិតគ្រាប់ពូជស្រូវក្រអូបបានចំនួន ២ ៣៦៥ តោន (ស្មើនឹង ៩៩% បើធៀបនឹងទិសដៅកំណត់ ២ ៤០០តោន)។
- បានរៀបចំឯកសារគោលការណ៍ណែនាំបច្ចេកទេសចំនួន០៨ ដោយការរៀបចំ និងការបោះពុម្ពឯកសារទាំងអស់នេះនឹងត្រូវបញ្ចប់នៅដើមខែមីនា ឆ្នាំ២០២០។
- បានរៀបចំស្លាកសញ្ញាដើម្បីបិតលើបាវអង្ករបញ្ជាក់គុណភាពគ្រាប់ពូជស្រូវដែលបានត្រួតពិនិត្យដោយមន្ត្រីអធិការកិច្ច។ បានចុះទីវាលពិនិត្យមើលការងារសាលារៀនស្រែកសិករ (FFSs) និងផលិតកម្មគ្រាប់ពូជស្រូវរបស់សហគមន៍កសិកម្ម និងស្ថានីយកសិកម្ម នៅខេត្តគោលដៅទាំងបី។
- ការសាកល្បង ការធានារ៉ាប់រងដំណាំផ្អែកលើសន្ទស្សន៍អាកាសធាតុ បានប្រគល់ជូនអង្គភាពគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តកម្មវិធី (PMO, MEF) ជាអ្នកអនុវត្ត ហើយអង្គភាព MAFF-NIO ជាអ្នកផ្តល់ការគាំទ្រផ្នែកបច្ចេកទេសកសិកម្មវិញ។
- ការអនុវត្ត និងការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាព គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារត្រួតពិនិត្យនិងវាយតម្លៃគម្រោង និងការងារយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ សរុបចំនួន ៣៥ វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន ១ ៣៨៦នាក់ (ស្ត្រី ៧៥៧នាក់)។
- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងអង្គភាព និងកិច្ចប្រជុំជាមួយអង្គភាពពាក់ព័ន្ធផ្សេងៗដើម្បីសម្របសម្រួលការងារជាបន្តបន្ទាប់ជាមួយមន្ត្រីបង្គោលកសិកម្មក្នុងខេត្តគោលដៅ និងបានចុះបំពេញបេសកកម្មតាមខេត្តគោលដៅទាំងបី ដើម្បីពិនិត្យតាមដានស្ថានភាពជាក់ស្តែង ពិភាក្សាការងារ និងផ្តល់ជំនួយបច្ចេកទេសបន្ថែមជូនអង្គភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត ដើម្បីយកទៅអនុវត្តសកម្មភាពបន្តនៅក្នុងខេត្តរបស់ខ្លួន។

**ច.គម្រោងពិពិធកម្មកសិកម្មកម្ពុជា (WB)**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម និងដោយមានការគាំទ្រពីជំនាញការរបស់ធនាគារពិភពលោក បានរៀបចំគម្រោងមួយឈ្មោះថា **គម្រោងពិពិធកម្មកសិកម្មកម្ពុជា**។ កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជាបានចុះហត្ថលេខារវាងព្រះរាជាណាចក្រកម្ពុជា និងធនាគារពិភពលោក

នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ហើយកិច្ចព្រមព្រៀងឥណទានសម្បទាននេះមានសុពលភាពនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩។ ថវិកាសរុបសម្រាប់គម្រោងមានចំនួន ១០១,៦៧ លានដុល្លារអាមេរិក មានរយៈពេលអនុវត្ត ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤ ដែលក្នុងថវិកាសម្បទានឥណទាន ចំនួន ៩១.៦៧លានដុល្លារអាមេរិកពីធនាគារពិភពលោក និងថវិកាបដិភាគ មានចំនួន១០លានដុល្លារអាមេរិកពីរាជរដ្ឋាភិបាលកម្ពុជា។

ខេត្តគោលដៅគម្រោង រួមមាន៖ កំពង់ឆ្នាំង បាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ ត្បូងឃ្មុំ កំពង់ចាម កណ្ដាល កំពង់ស្ពឺ និងរាជធានីភ្នំពេញ។ គោលបំណងរបស់គម្រោងគឺ ជួយសម្របសម្រួលដល់ការអភិវឌ្ឍខ្សែច្រវាក់ ពិពិធកម្មកសិកម្មក្នុង ខេត្តគោលដៅរបស់គម្រោង និងផ្ដល់ការគាំទ្រក្នុងករណីមានវិបត្តិ ឬសង្គ្រោះបន្ទាន់។

គម្រោងពិពិធកម្មកសិកម្មកម្ពុជា មានសមាសភាគបួនគឺ៖ (ក) ការជំរុញពិពិធកម្មកសិកម្ម (ខ) គាំទ្រលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ) (គ) លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងការត្រួតពិនិត្យគុណភាព (ឃ) ការសម្របសម្រួលការគ្រប់គ្រងគម្រោង និងការតាមដាន និងវាយតម្លៃគម្រោង (ង) ការឆ្លើយតបនៅពេលមានវិបត្តិ។

ក្នុងឆ្នាំ២០១៩ គម្រោងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- អង្គភាពសម្របសម្រួលគម្រោងបានបង្កើត ហើយនាយកគម្រោង និងប្រធានគ្រប់គ្រងគម្រោងក៏ដូចជាមន្ត្រីគម្រោងថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រូវបានចាត់តាំង។
- បានរៀបចំសេចក្ដីពណ៌នាតួនាទីនិងភារកិច្ចរបស់មន្ត្រីគម្រោងថ្នាក់ជាតិ និងថ្នាក់ខេត្ត
- បានរៀបចំសិក្ខាសាលាចាប់ផ្ដើមអនុវត្តគម្រោងដើម្បីផ្សព្វផ្សាយពីគោលបំណង និងគោលដៅគម្រោង និងនីតិវិធីសម្រាប់ការអនុវត្តគម្រោងដែលមានអ្នកចូលរួមប្រមាណ២០០នាក់។
- បានបង្កើតគណៈកម្មាធិការការតម្រង់ទិសគម្រោង (Project Steering Committee “PSC”) ។
- គោលការណ៍អនុវត្តគម្រោង (Project Operations Manual “POM”) ទទួលបានការឯកភាពពីធនាគារពិភពលោក។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំគំរូហត្ថលេខាសម្រាប់ដកប្រាក់ផ្ញើជូនធនាគារពិភពលោក
- អង្គភាពសម្របសម្រួលគម្រោង (Project Coordination Office) បានបើកគណនីចរន្តចំនួនពីរ ដើម្បីទទួលថវិកាពីធនាគារពិភពលោក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ហើយទទួលបានថវិកាបុរេប្រទានចំនួន ៣ ០០០ ០០០ ដុល្លារអាមេរិក (បីលានដុល្លាអាមេរិក) ពីធនាគារពិភពលោក។
- បានសម្របសម្រួលនិងចូលរួមជាមួយបេសកកម្មគាំទ្រការអនុវត្តគម្រោង ដោយបានជួបប្រជុំជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងជួបប្រាស្រ័យផ្ទាល់ជួយកសិករខេត្តគោលដៅ រួមមានខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។ អនុសាសន៍របស់ក្រុមបេសកកម្មបាន និងកំពុងអនុវត្តនាពេលបច្ចុប្បន្ន។
- បានរៀបចំសេចក្ដីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៩-២០២០ (AWPB 2019-2020) ដោយបានផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យនិងអនុម័តតាំងពីដើមខែធ្នូ ឆ្នាំ២០១៩ និងចម្លងជូនធនាគារពិភពលោកជ្រាប។
- បានបង្កើតគណៈកម្មការពិនិត្យ និងអនុម័តឯកសារលទ្ធកម្ម និងគណៈកម្មការពិនិត្យ និងវាយតម្លៃឯកសារលទ្ធកម្ម និងបានជ្រើសរើសទីប្រឹក្សាលទ្ធកម្មជាតិ០១រូប ដើម្បីជួយការងារលទ្ធកម្មរបស់អង្គភាពសម្របសម្រួលគម្រោង។

ឆ. គម្រោងបែកចែកដីសង្គមកិច្ច ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច (LASET-II)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធនាគារពិភពលោក បានអនុវត្តសកម្មភាពរបស់ខ្លួន និងទទួលបានលទ្ធផលដូចខាងក្រោម៖

- បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម (បច្ចេកទេសចិញ្ចឹមសត្វ បច្ចេកទេសដាំបន្លែ ការបង្កើនគុណភាពដីកសិកម្មវៃឆ្លាត ទីផ្សារកសិកម្ម ។ល។ និង។ល។)ដល់សម្បទានិក នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំង ១៥ទីតាំង នៃខេត្តក្រចេះ កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ សរុបចំនួន ១១៣វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៤,៣៩៧នាក់ (ស្រីចំនួន ២៧,១១ នាក់) និងរៀបចំទីកន្លែងធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមមាន់ចំនួន ៩០បង្ហាញ ទីកន្លែងបង្ហាញបច្ចេកទេសដាំបន្លែចំនួន ៨០ បង្ហាញ ទីកន្លែងបង្ហាញប្រព័ន្ធកសិកម្មចម្រុះចំនួន ២ បង្ហាញ ទីកន្លែងបង្ហាញបច្ចេកទេសចិញ្ចឹមត្រីចំនួន១០ បង្ហាញ សរុប ១៨២ បង្ហាញ ដែលមានសិក្ខាកាមចំនួន ៨៤% បានបង្ហាញការពេញចិត្តលើវគ្គបណ្តុះបណ្តាល និង សេវាកម្មកសិកម្មផ្សេងៗ (ការធ្វើបង្ហាញ) របស់គម្រោង និងមានគ្រួសារសម្បទានិកប្រមាណ ៧៥%បានចាប់យកបច្ចេកទេសដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងទិវាបង្ហាញទៅអនុវត្ត។
- រៀបចំក្រុមទុនបង្វិល( Revolving Fund Groups) នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចនៃខេត្តគោលដៅទាំងប្រាំបានចំនួន ៧៥ ក្រុម មានសមាជិកសរុបចំនួន ១៣៣៤នាក់ (ស្រីចំនួន ៨៥៧ នាក់)។ ក្រុមទាំងនេះមានបទបញ្ជាផ្ទៃក្នុង លក្ខន្តិក: ក្រុម និងចាប់ផ្តើមសន្សំ។
- គាំទ្រដល់សហគមន៍កសិកម្មចំនួន០៦ នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចគម្រោងដែលមានសមាជិកចំនួន ៤៦៦ នាក់ (ស្រី៣១៤ នាក់) ភាគហ៊ុនចំនួន ៤៤២៩ ហ៊ុន និងមានទុនសរុប ចំនួន១៨៥ ៨៦៦ ៧០០ រៀល (៤៧,៤៨០ ដុល្លារ)។
- គាំទ្រដល់ក្រុមសន្សំចំនួន៧ នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចគម្រោង ដែលមានសមាជិកសរុបចំនួន២៧៥នាក់(ស្រី១៨៣នាក់)មានទុនសរុបចំនួន១៩២,៦៨៩,៣០០រៀល (៤៨,១៧២ ដុល្លារ)
- ជារួមគម្រោងសម្រេចលទ្ធផលបានចំនួន៥១% នៃផែនការសរុបប្រចាំឆ្នាំ។ ចំណាយថវិកាបានចំនួន ៨៨ ២៥៧.៥៤ ដុល្លារ ស្មើនឹង ៣២% នៃថវិការឆ្នាំ២០១៩ ចំនួន ២៧៥ , ៨៤០.៩៥ ដុល្លារ។

## ៥.៧. ការងារគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មានកសិកម្ម

### ក. ការគ្រប់គ្រងឯកសារ

នៅក្នុងឆ្នាំ២០១៩នេះ បណ្ណាល័យកសិកម្មបានទទួលបោះពុម្ពនិងទិញសៀវភៅបានសរុបចំនួន១,៩០៦ ក្បាល/ច្បាប់ ក្នុងនោះ ៖

- បានទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួល បានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១,៦៥៨ ក្បាល/ច្បាប់
- បានបោះពុម្ព និងទិញបន្ថែម សម្រាប់ដាក់តម្កល់ សរុបចំនួន២៤៨ក្បាល/ច្បាប់
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកដែលមានអ្នកចូលទស្សនាចំនួន៣៨,៩៨៤ដង/នាក់ អ្នកបានបង្កើតគណនីប្រើប្រាស់សរុបចំនួន២,៥៤៣ នាក់
- ការស្កេនឯកសារ ដើម្បីបញ្ចូលក្នុងប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិកបានចំនួន០២ក្បាល
- បញ្ចូលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម និងអត្ថបទផ្សេងៗសរុបចំនួន៤៩២ក្បាល/ច្បាប់ និងឯកសារវីដេអូសរុបចំនួន៧០វីដេអូ

- ជំរុញការផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សេចក្ដីជូនដំណឹង សារាចរណែនាំ សេចក្ដីសម្រេច ប្រកាស និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីជំរុញឲ្យបានទូលំទូលាយលើបណ្ដាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) និងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ខ. ការគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម**

- បញ្ចូលសកម្មភាពរបស់ឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួង ចូលរួមជួបភ្ញៀវ ប្រជុំ និងចូលរួមកម្មវិធីផ្សេងៗ លើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២៥២ ព័ត៌មាន
- តំហែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី)
- ការរចនា និងបង្កើតទម្រង់គេហទំព័រ និងកម្មវិធីស្មាតហ្វូនថ្មីៗបន្ថែមទៀតលើ Mobile App (iOS & Android Platform)
- បានបង្កើតមុខងារថ្មីៗ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មានលើគេហទំព័រ និងកម្មវិធីស្មាតហ្វូន
- បានបញ្ចូលព័ត៌មាន និងរៀបចំឲ្យទាញយកកម្មវិធីប្រើប្រាស់នៅលើ App Store និង Play Store
- ការធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្ដុះបណ្ដាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន១៣ ដូចជា៖ ខេត្តប៉ៃលិន ឧត្តរមានជ័យ កំពង់ឆ្នាំង បាត់ដំបង ព្រះវិហារ ពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពត និងខេត្តកែប
- បន្តរៀបចំកសាងគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្ម ដោយបានរៀបចំកាត់ផែនទីចំនួន១៣ខេត្ត ដូចជា៖ ខេត្តស្វាយរៀង ព្រៃវែង ពោធិ៍សាត់ កែប ព្រះសីហនុ ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង ប៉ៃលិន មណ្ឌលគិរី កំពង់ស្ពឺ កោះកុង និងខេត្តបន្ទាយមានជ័យ និងរៀបចំបង្កើតទំព័រគ្រប់គ្រងទិន្នន័យគ្រោះមហន្តរាយ
- ចុះធ្វើការបណ្ដុះបណ្ដាលការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រកសិកម្ម ប្រព័ន្ធទូរស័ព្ទដៃឆ្លាតវៃក្នុងចុះការប្រមូលទិន្នន័យ និងប្រមូលចងក្រងទិន្នន័យគ្រោះមហន្តរាយ ដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន១២ ដូចជា៖ ខេត្តស្វាយរៀង ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី កណ្ដាល កំពង់ស្ពឺ កែប ព្រះសីហនុ កោះកុង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ
- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលការប្រើប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន១៣ ដូចជា៖ ខេត្តប៉ៃលិន កែប ព្រៃវែង កំពង់ស្ពឺ ព្រះសីហនុ កោះកុង តាកែវ កំពង់ធំ ឧត្តរមានជ័យ កំពង់ឆ្នាំង សៀមរាប កំពង់ចាម និងត្បូងឃ្មុំ។
- ធ្វើបច្ចុប្បន្នភាពបន្ថែមនៅលើគេហទំព័រនៃអង្គភាពធំៗទាំង៥ (រដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ និងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ)
- សម្អាត Catch នៅលើ Cloud server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ)
- តាមដានទិន្នន័យដែល ផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ)។

## ៥.៨. ការលើកកម្ពស់ការងារផ្សព្វផ្សាយ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីផ្នែកការងារ ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន៦៤នាក់ ស្ត្រីចំនួន២៥នាក់ មន្ត្រីផ្សព្វផ្សាយកសិកម្មរាជធានី ខេត្តមានចំនួន១២០នាក់ ស្ត្រីចំនួន៤៦នាក់ មន្ត្រីកសិកម្មស្រុកសរុបចំនួន ៦១១នាក់ ស្ត្រីចំនួន១៣៦នាក់ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំសរុបមានចំនួន ៨៣២ នាក់ ក្នុងនោះមានស្ត្រីចំនួន ៣៦១នាក់ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិសរុបមានចំនួន៧ ៥៦១នាក់ ក្នុងនោះ ស្ត្រីចំនួន៧១៧នាក់។ កសិករគំរូសរុបចំនួន១ ០៨៣នាក់ ក្នុងនោះស្ត្រីចំនួន២៩១នាក់ កសិករឆ្នើមសរុប ចំនួន ៥៦៣នាក់ ក្នុងនោះស្ត្រីចំនួន ២០២នាក់ កសិករគ្រូសរុបចំនួន៤០៥នាក់ ក្នុងនោះស្ត្រីចំនួន១៦៤នាក់។

ឆ្នាំ២០១៩នេះ ការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បានអនុវត្តតាមរយៈ(១) ការបណ្តុះបណ្តាល ការសិក្សា និងវិភាគការអនុវត្តជាក់ស្តែងនៅទីវាល សាលារៀនស្រែកសិករ ការធ្វើស្រែបង្ហាញ ទិវាស្រែ និងទស្សនកិច្ចសិក្សា (២) ផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ បណ្តាញទំនាក់ទំនងសង្គម គេហទំព័រផ្សព្វផ្សាយកសិកម្ម មជ្ឈមណ្ឌលបណ្តុំព័ត៌មានផ្សព្វផ្សាយកសិកម្ម សេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន ពិព័រណ៍កសិកម្ម និងវេទិកាសាធារណៈ និង (៣) ការបោះពុម្ព និងចែកចាយឯកសារបច្ចេកទេសកសិកម្ម។

- បានបណ្តុះបណ្តាល មន្ត្រីកសិកម្ម ឱ្យក្លាយជាទីប្រឹក្សាផ្សព្វផ្សាយកសិកម្មបានចំនួន ៤២៤នាក់ ស្ត្រីចំនួន៩២នាក់ (ក្នុងឆ្នាំ២០១៩ បណ្តុះបណ្តាលបាន៥៤នាក់ ស្ត្រី ១០នាក់) ព្រមទាំងបានធ្វើការវិភាគប្រព័ន្ធកៀស្រ្ត-បរិស្ថានឃុំសរុបចំនួន ៧៦៣ឃុំ ទូទាំងប្រទេស។
- បានបណ្តុះបណ្តាល ស្តីពី ប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្ម ដល់មន្ត្រីកសិកម្មខេត្តសៀមរាប ពោធិ៍សាត់ ក្រចេះ និងខេត្តកំពតដែលមានមន្ត្រីចូលរួមសរុបចំនួន ១០០នាក់ ស្ត្រី ៤៥នាក់ ព្រមទាំងបានចុះប្រមូលទិន្នន័យពីកសិករចំនួន ២ ០០០នាក់ ស្ត្រីចំនួន ១ ២១៣ នាក់
- បានបណ្តុះបណ្តាល ស្តីពី ការអង្កេតនៃការទទួលយក និងសាយភាពបច្ចេកទេសវិទ្យាកសិកម្ម ដល់មន្ត្រីកសិកម្មខេត្តសៀមរាប ពោធិ៍សាត់ ក្រចេះ និងខេត្តកំពត ចំនួន ១០០នាក់ ស្ត្រី ៣៧នាក់ និងចុះប្រមូលទិន្នន័យពីកសិករចំនួន ២ ១៦០នាក់ ស្ត្រីចំនួន ១ ៣៥៨នាក់
- បានបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្ម និងមន្ត្រីពាក់ព័ន្ធលើការប្រើប្រាស់ប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម (ICT) ដល់មន្ត្រីកសិកម្ម ចំនួន ០៧ខេត្ត ដែលមានអ្នកចូលរួមសរុប១៤០នាក់ ស្ត្រីចំនួន៥៧នាក់ និងបានសិក្សាពីតម្រូវការកសិករដែលមាន កសិករចូលរួម ៥២៥នាក់ ស្ត្រីចំនួន ៤១២នាក់
- បានរៀបចំសិក្ខាសាលា ស្តីពី ការរៀបចំគោលការណ៍ណែនាំសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម ចំនួន ១០លើក ដែលមានមន្ត្រីចូលរួមចំនួន ៥២០នាក់ ស្ត្រីចំនួន ៧៨នាក់
- បានរៀបចំសិក្ខាសាលា ស្តីពីការរៀបចំគោលការណ៍ណែនាំសម្រាប់កសិករផ្សព្វផ្សាយកសិកម្មចំនួន ០៨ លើក ដែលមានមន្ត្រីចូលរួមចំនួន ៣៣០នាក់ ស្ត្រីចំនួន ៤៩នាក់
- បានធ្វើការវិភាគប្រព័ន្ធកៀស្រ្ត បរិស្ថានសរុបចំនួន-០៧ឃុំ ក្នុងនោះបានបណ្តុះបណ្តាល ពីការរៀបចំផែនការប្រមូលទិន្នន័យទី២ ដល់មន្ត្រីពាក់ព័ន្ធសម្រាប់សិក្សា និងវិភាគប្រព័ន្ធកសិកម្មបានចំនួន ០៧វគ្គ ដែលមានមន្ត្រីចូលរួម ព្រមទាំងមានការចូលរួមពីក្រុមប្រឹក្សាឃុំ ភូមិចំនួន ១៤០នាក់ ស្ត្រីចំនួន ២៥នាក់ កសិករចូលរួម ១៧៥នាក់ ស្ត្រីចំនួន ២៦នាក់
- បានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេសចំនួន ១៥នាក់ និងចូលរួមសិក្ខាសាលាចំនួន ០៦នាក់ រួមមានប្រទេសចិន វៀតណាម ជប៉ុន កូរ៉េ ហ្វីលីពីន ព្រុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី

- ទស្សនាវដ្ដី ព្រឹត្តិបត្រ និងកូនសៀវភៅបច្ចេកទេសកសិកម្មចំនួន ៤៧ ៨០០ច្បាប់ត្រូវបានបោះពុម្ព និងចែកចាយ។ ផលិតបទយកការណ៍ និងអត្ថបទបច្ចេកទេសកសិកម្មសរុបចំនួន ១៣៦ប្រធានបទ និងបានចាក់ផ្សាយ តាមប្រព័ន្ធព័ត៌មានសាធារណៈទូរទស្សន៍ និងវិទ្យុ ចំនួន ៤៨០លើក ព្រមទាំងបាន ផលិតព័ត៌មានទាក់ទងនឹងការងារកសិកម្មបានចំនួន ២៧០ព័ត៌មាន និងចាក់ផ្សាយបានចំនួន ៥៤០លើក ព្រមទាំងពិព័រណ៍សម្ភារ និងផលិតផលកសិកម្មចំនួន ០៤លើក
- បានផ្សព្វផ្សាយវីដេអូពាក់ព័ន្ធកសិកម្មរួមមានបទយកការណ៍កសិកម្មចំនួន ១០២វីដេអូ បច្ចេកទេស កសិកម្ម ចំនួន៤៣វីដេអូ ឯកសារអត្ថបទបច្ចេកទេសកសិកម្មបានចំនួន ៦៤ឯកសារក្នុងទំព័រហ្វេកប៊ុក របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានដាក់បញ្ចូលឯកសារកសិកម្មក្នុង គេហទំព័រផ្សព្វផ្សាយកសិកម្ម (khmeragri.info) សរុបចំនួន ៤៨៨ឯកសារ ដំណើរការការងារផ្ដល់សេវា ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន សមាជិកសរុប ២១នាក់ មកពីអង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន៨ អង្គភាព។
- សកម្មភាពវគ្គបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្មនៅតាមបណ្ដារាជធានី ខេត្តទាំង២៥ ចំនួន២ ៧៨០ វគ្គ មាននាក់ចូលរួមចំនួន៥២ ៥៧៤នាក់ ក្នុងនោះស្ត្រីមានចំនួន២៨ ៩៣០នាក់។

## ៥.៩. ការងារយេនឌ័រ និងកុមារ

អង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើតឡើង ដើម្បីជាយន្តការសម្របសម្រួលការអនុវត្តគម្រោងពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងការពារ និងអភិវឌ្ឍន៍កុមារក្នុង វិស័យកសិកម្ម។ ក្នុងឆ្នាំ២០១៩នេះ អង្គភាពបានខិតខំបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីសម្រេច បាននូវទិសដៅដែលបានកំណត់ស្របតាមគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ការអភិវឌ្ឍ និងការពារកុមារក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គភាពជំនាញក្រោមឱវាទក្រសួង និងសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ ដូចខាងក្រោម៖

- បានសហការរៀបចំទស្សនកិច្ចសិក្សាស្ដីពី "ភាពជាអ្នកដឹកនាំសហគមន៍កសិកម្ម" ទៅកាន់ប្រទេសថៃ សម្រាប់ថ្នាក់ដឹកនាំ និងសមាជិកក្រុមការងារ យេនឌ័រ និងកុមាររបស់ក្រសួង ចំនួន១០នាក់ (ស្រី៨នាក់) និងប្រធានសហគមន៍កសិកម្មគំរូ ដែលមានស្ត្រីជាថ្នាក់ដឹកនាំ ឬតំណាងចំនួន ២១នាក់ (ស្ត្រី ១៦នាក់) នៅថ្ងៃទី៣-៦ ខែមិថុនា ឆ្នាំ២០១៩
- បានសហការរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្ដីពី លទ្ធផលសម្រេចបានលើការងារបញ្ជ្រាបយេនឌ័រក្នុង វិស័យកសិកម្ម ឆ្នាំ២០១៦-២០១៩ និងលើកទិសដៅអនុវត្តបន្ត ដោយមានអ្នកចូលរួមចំនួន ៥០នាក់ (ស្រី៣៩នាក់) ដែលជាសមាជិកអង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារ ជនបង្គោលយេនឌ័រតាម អង្គភាពអនុវិស័យ និងជនបង្គោលយេនឌ័រនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តកំពត នាថ្ងៃទី ២៤-២៥ ខែមិថុនា ឆ្នាំ២០១៩។
- បានសហការរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់ជាតិស្ដីពី "កសិកម្មដើម្បីអាហារូបត្ថម្ភ" ដល់ថ្នាក់ ដឹកនាំអង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារ សមាជិក សមាជិកា និងជនបង្គោលកុមារនៅថ្នាក់កណ្ដាល និងថ្នាក់ខេត្តនៃខេត្តបាត់ដំបង ពោធិ៍សាត់ និងខេត្តសៀមរាប នាថ្ងៃទី៣០-៣១ខែតុលា ឆ្នាំ២០១៩ សរុប ២៣រូប (ស្រី១៧រូប) នៅខេត្តពោធិ៍សាត់

- បានសហការរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីកសិកម្មស្រុក និងអាជ្ញាធរស្រុក ស្តីពីកសិកម្មដើម្បីអាហារូប-ត្ថម្ភ នៅខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ នៅខែធ្នូ ឆ្នាំ២០១៩ ដោយមានសិក្ខាកាមសរុប ៦៩នាក់ (ស្រី៤០នាក់)
- បានសហការរៀបចំទស្សនកិច្ចសិក្សាស្តីពីលទ្ធផលសម្រេចបានរបស់គម្រោងនូរីស (NOURISH) លើការបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់អាហារូបត្ថម្ភកុមារក្នុងវិស័យកសិកម្ម" នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ ដោយមានអ្នកចូលរួម១៤ រូប (ស្រី៦រូប)
- បានសហការចងក្រង ពិនិត្យ និងកែសម្រួលឯកសារបណ្តុះបណ្តាលសម្រាប់គ្រូបង្គោលស្តីពីកសិកម្មដើម្បីអាហារូបត្ថម្ភ ដែលនឹងត្រូវបោះពុម្ព និងចែកផ្សាយដល់ជនបង្គោលយេនឌ័រ និងកុមារនាពេលខាងមុខ
- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ស្តីពី "កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍លើការងារយេនឌ័រនិងកុមារក្នុងវិស័យកសិកម្ម" Donor coordination meeting" ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ដោយមានការអ្នកចូលរួមចំនួន១៩នាក់ (ស្រី១៤នាក់) អញ្ជើញមកពីអង្គការដៃគូអភិវឌ្ឍន៍ រួមមានតំណាងកម្មវិធី CAVAC អង្គការ Save the Children អង្គការ WE EFFECT អង្គការ SNV ព្រមទាំងតំណាងអគ្គនាយកដ្ឋានកសិកម្ម តំណាងអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ តំណាងរដ្ឋបាលជលផល និងសមាជិក សមាជិកានៃអង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារ
- បានចុះតាមដាន និងវាយតម្លៃកសិករដែលទទួលបានការបណ្តុះបណ្តាលស្តីពី យេនឌ័រ និងការការពារកុមារក្នុងវិស័យកសិកម្ម និងផ្តល់ធាតុចូលកសិកម្មសម្រាប់អនុវត្តសួនបន្លែនៅតាមគ្រួសារ នៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន១០០គ្រួសារ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រស្តីពីការការពារ និងអភិ-វឌ្ឍន៍កុមារ ក្នុងវិស័យកសិកម្ម ឆ្នាំ២០១៦-២០២០ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ នៅស្រុកជើងព្រៃខេត្តកំពង់ចាម (សិក្ខាកាម ៥០នាក់ ស្ត្រី៩០%)
- បានរៀបចំវគ្គបណ្តុះបណ្តាលមាតាបិតា ឬអាណាព្យាបាលកុមារមត្តេយ្យសហគមន៍ស្តីពីអាហារូបត្ថម្ភ និងពលកម្មកុមារក្នុងវិស័យកសិកម្ម នៅឃុំស្រម៉ ស្រុកជើងព្រៃ នៅថ្ងៃទី ២៤-២៦ ខែតុលា ឆ្នាំ២០១៩ និងឃុំកោះសំរោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ (អ្នកចូលរួមសរុប ២៥០នាក់ ស្ត្រី៩០%)
- បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារកុមារ និងលើកទិសដៅអនុវត្តបន្ត នៅខេត្តកំពង់ចាម នាថ្ងៃទី១២-១៣ ខែធ្នូ ឆ្នាំ២០១៩ ដោយមានការចូលរួមពីអង្គភាពអនុវិស័យ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដែលមានសមាសភាពសរុប ៤៥នាក់ ស្ត្រី២៨នាក់
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងត្រួតពិនិត្យឡើងវិញ លើគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ការអភិវឌ្ឍ និងការពារកុមារក្នុងវិស័យកសិកម្ម(២០១៦-២០២០) ដែលនឹងត្រូវបញ្ចប់និងត្រូវធ្វើការកែសម្រួលរៀបចំសម្រាប់រយៈពេល ៥ឆ្នាំបន្ត។

## ៥.១០. ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងឆ្នាំ២០១៩នេះ ក្រសួងបានពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានទទួលលទ្ធផលដូចខាងក្រោម៖

- បានបង្កើតគណៈកម្មការយន្តការដឹកនាំអនុវត្ត នៃកិច្ចដំណើរការកំណែទម្រង់
- បានបង្កើតក្រុមការងារប្រចាំការ ដើម្បីសម្របសម្រួលប្រចាំថ្ងៃលើកិច្ចដំណើរការកំណែទម្រង់
- បានបង្កើតក្រុមជំនួយការលេខាធិការដ្ឋានក្នុងកិច្ចជួយសម្របសម្រួលលើកិច្ចការប្រចាំថ្ងៃ

- បានបង្កើតក្រុមការងារសម្របសម្រួលនៅតាមបណ្តាមន្ទីររាជធានី ខេត្ត ដើម្បីទំនាក់ទំនង និងសម្របសម្រួលពាក់ព័ន្ធលើកិច្ចដំណើរការ នៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើវិសហមជ្ឈការផ្ទេរតាមបែបប្រតិភូកម្មនូវសេវាមុខងាររដ្ឋបាល ទៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងទៅការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក ខណ្ឌនៅថ្នាក់ក្រោមជាតិ(ដែលមានចែងក្នុងជំហានទី១ និងទី២)
- បានរៀបចំសម្របសម្រួល និងធ្វើបច្ចុប្បន្នភាពលើមុខងារសេវារដ្ឋបាល (វិស័យកសិកម្ម) ដែលធ្វើវិសហមជ្ឈការតាមបែបប្រតិភូកម្ម ទៅការិយាល័យច្រកចេញចូលតែមួយ (ក្រុង ស្រុក ខណ្ឌ) ដោយផ្អែកតាមឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈឆ្នាំ២០១៧
- បានរៀបចំសម្របសម្រួលបែបបទ ទម្រង់ពាក្យស្នើសុំ នីតិវិធី លក្ខខណ្ឌភ្ជាប់នានាឱ្យមានភាពសាមញ្ញសម្រាប់អនុវត្តក្នុងការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បានរៀបចំជាបញ្ជីមុខងារបឋមលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលត្រូវធ្វើវិមជ្ឈការផ្ទេរតាមបែបប្រគល់ទៅឱ្យរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ
- បានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការធ្វើវិមជ្ឈការផ្ទេរតាមបែបប្រគល់នូវធនធានរួមមាន (មនុស្ស ថវិកា ទ្រព្យសម្បត្តិ) ភ្ជាប់ដោយមុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានរៀបចំធ្វើវិមជ្ឈការផ្ទេរមុខងារតាមបែបប្រគល់ភាពជាម្ចាស់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩
- បាននិងកំពុងបន្តជំរុញឱ្យអង្គភាពពាក់ព័ន្ធត្រួតពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តនូវមុខងារផ្ទេរតាមបែបប្រតិភូកម្មនៅរាជធានី ខេត្ត និងផ្ទេរតាមបែបប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (ដែលមានចែងក្នុងជំហានទី៣)។

## V- បញ្ហាប្រឈម

ផលិតភាពកសិកម្មនៅមានកម្រិតទាប ការប្រកួតប្រជែងទីផ្សារនៃផលិតផលកសិកម្មនៅពុំទាន់ដោះស្រាយបានប្រសើរនៅឡើយ។ ចំណាកស្រុកនៃកម្លាំងពលកម្មកសិកម្មមកកាន់ទីក្រុង និងទីប្រជុំជនមាននិន្នាការកើនឡើងឥតឈប់ឈរ ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការផលិតកម្មកសិកម្ម។ ការផ្ទេរបច្ចេកទេសកសិកម្មទំនើប និងសមស្របដល់កសិករនៅពុំទាន់បានគ្រប់គ្រាន់ស្របតាមសេចក្តីត្រូវការជាក់ស្តែងនៅឡើយ។ ម៉្យាងវិញទៀត កត្តាប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះរាំងស្ងួតបានវាយលុកមកលើផលិតកម្មដំណាំកសិកម្ម សត្វ និងជលផល។ ការរីកលូតលាស់នៃវិស័យអចលនទ្រព្យ និងនគរូបនីយកម្ម បានធ្វើឱ្យដីកសិកម្មមួយចំនួនប្រែក្លាយទៅជាទីតាំងសំណង់ផ្ទះសម្បែង រោងចក្រ សហគ្រាស ហើយកសិករម្ចាស់ដីមួយចំនួនបានប្តូរមុខរបរពីកសិកម្ម ទៅមុខរបរផ្សេងទៀតតាមជម្រើសដែលពេញចិត្ត។ ដោយឡែក សមត្ថភាពរបស់សហគមន៍កសិកម្មដែលបានបង្កើត ក្នុងគោលបំណងដើម្បីបង្កើនអំណាចតថ្លៃ ការទទួលបាននូវសេវាបច្ចេកទេសនិងឥណទាន គឺត្រូវបានវាយតម្លៃថានៅមានកម្រិត។

ការផ្គត់ផ្គង់ទឹកកសិកម្មនៅពុំទាន់គ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់របស់កសិករនៅឡើយ ហើយហេដ្ឋារចនាសម្ព័ន្ធគាំទ្រកសិកម្មដទៃទៀត ដូចជាផ្លូវកសិដ្ឋានដើម្បីសម្រួលការដឹកជញ្ជូនផលិតផលរបស់កសិករ ប្រព័ន្ធស្តុកទុកឃ្លាំងសម្ងួត ឃ្លាំងត្រជាក់ នៅមិនទាន់បង្កើតបានគ្រប់គ្រាន់សម្រាប់ការធ្វើកសិ-ពាណិជ្ជកម្ម។ ផលិតកម្មសត្វមានបម្រែបម្រួលកំណើនយឺត ដោយមានការលំបាកកន្លងមក និងការប្រឈមដូចជា ជំងឺឆ្លងរាតត្បាត និងកង្វះមធ្យោបាយគ្រប់គ្រាន់លើការការពារនិងកម្ចាត់ ការប្រកួតប្រជែងនៃទីផ្សារសាច់សត្វ ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃ

ចំណីសត្វ និងថ្នាំព្យាបាលសត្វជាដើម។ លើសពីនេះទៀត ការកាប់បំផ្លាញព្រៃឈើ និងការនេសាទខុសច្បាប់នៅតែមានសកម្មភាព ទោះបីមានការបង្ក្រាបយ៉ាងណាក៏ដោយ។

ជាក់ស្តែងក្នុងឆ្នាំ២០១៩នេះ វិស័យឯកជនបានលើកឡើងពីបញ្ហាប្រឈមមួយចំនួនដែលត្រូវជួយដោះស្រាយ។ ផ្នែកឯកជនបានលើកឡើងពីបញ្ហាសំណល់ថ្នាំកសិកម្ម Tricyclazole នៅក្នុងផលិតផលអង្ករ ទោះបីត្រូវបានហាមរួចហើយក៏ដោយ។ ក្រសួងជំរុញអនុវត្តសេចក្តីជូនដំណឹងលេខ២៦៤៥កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីបញ្ឈប់ការនាំចូល ផ្គត់ផ្គង់ចែកចាយ និងប្រើប្រាស់ថ្នាំកសិកម្ម Tricyclazole និងជំរុញការបណ្តុះបណ្តាលផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធឱ្យយល់ដឹងកាន់ទូលំទូលាយបន្ថែមទៀត។ បញ្ហាប្រឈមមួយទៀតគឺការបង់ថ្លៃអាករលើតម្លៃបន្ថែម១០% (VAT=10%) សម្រាប់វិស័យចិញ្ចឹមសត្វ ដែលស្នើផ្នែកឯកជនសុំលើកលែងអាករលើតម្លៃបន្ថែមនេះសម្រាប់វិស័យចិញ្ចឹមសត្វទាំងអស់ ដើម្បីឲ្យអ្នកវិនិយោគអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន។ ប្រាក់កម្ចីគាំទ្រដល់វិស័យចិញ្ចឹមសត្វពីធនាគារអភិវឌ្ឍន៍ជនបទលើវិស័យចិញ្ចឹមសត្វ គួរទទួលបានការគាំទ្រដោយប្រាក់កម្ចីនេះមានអត្រាការប្រាក់ទាប។ វិស័យឯកជនផ្នែកកៅស៊ូស្នើសុំជួយអន្តរាគមន៍សម្រួលអត្រាពន្ធនាំចេញកៅស៊ូ និងស្នើជួយអន្តរាគមន៍ទៅអាជ្ញាធរដែលមានសមត្ថកិច្ចនៅទល់ដែនជួយទប់ស្កាត់ការនាំជ័រកកចេញ។ ផ្នែកឯកជនបានស្នើឱ្យបន្តជួយអន្តរាគមន៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដើម្បីបន្តជួយដោះស្រាយបញ្ហាចុះបញ្ជីដី និងវិវាទដីធ្លីជូនក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច និងបានស្នើឱ្យលើកសំណើរបស់ផ្នែកឯកជនជូនក្រសួងបរិស្ថាន ដើម្បីពិនិត្យនិងមានវិធានការបន្តក្នុងការជំរុញលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានឆាប់។

## VI- ទិសដៅអនុវត្ត

សម្រាប់ឆ្នាំ២០២០-២០២១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅ និងផែនការអនុវត្តប្រកបដោយមុខស្រួច ដូចខាងក្រោម៖

### ១.ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

#### ក. សូចនាករទិសដៅ

- ជំរុញការដាំដុះដំណាំស្រូវទូទាំងប្រទេសក្នុងរង្វង់៣,០៤លានហ.ត ក្នុងនោះ ស្រូវវស្សា ២,៥៨លានហ.ត និងប្រាំង០,៤៦លានហ.ត ជាមួយទិន្នផលសរុប៣,៤០០ត/ហ.ត និងទទួលបានបរិមាណផលស្រូវ១០,៣លានតោន។
- ជំរុញការធ្វើផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម (ដំឡូងឈើ ពោត ដំឡូងជ្វា បន្លែ សណ្តែកបាយ សណ្តែកដី សណ្តែកសៀង អំពៅ ល្ង) ឱ្យបានកើនផ្ទៃដីដាំដុះចំនួន២% និងបរិមាណផលប្រមាណ៤% ។

#### ខ. វិធានការអនុវត្តដើម្បីសម្រេចបានទិសដៅកំណត់

- ជំរុញការអភិវឌ្ឍដំណាំស្រូវ ដោយលើកកម្ពស់ផលិតភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការនាំចេញតាមរយៈសិក្សាស្រាវជ្រាវនិងបន្សុទ្ធពូជស្រូវ ការពង្រឹងការត្រួតពិនិត្យនិងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវ ការផលិតនិងចែកចាយគ្រាប់ពូជស្រូវមានគុណភាពល្អ ការអនុវត្តបង្កំបច្ចេកទេសទំនើប បច្ចេកទេសក្នុងនិងក្រោយ ពេលប្រមូលផល និងការបញ្ជាក់គុណភាព និងសុវត្ថិភាពស្រូវអង្ករ។ ជំរុញការធ្វើពិពិធកម្មស្រូវក្រអូប និងស្រូវដែលមានអាយុកាលខ្លី ធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងលើកកម្ពស់ការអនុវត្តផលិតកម្មដំណាំស្រូវតាមស្តង់ដារ ការអនុវត្តកសិកម្មល្អ ផលិតកម្មស្រូវនិរន្តរភាព និងស្រូវសរីរាង្គ។

- ជំរុញការអភិវឌ្ឍដំណាំសាកវប្បកម្មដោយលើកកម្ពស់ផលិតភាព គុណភាព សុវត្ថិភាព ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក កាត់បន្ថយការនាំចូល និងជំរុញការនាំចេញ តាមរយៈការលើកកម្ពស់ផលិតដំណាំសាកវប្បកម្ម និងពិពិធកម្មប្រភេទដំណាំដែលមានតម្លៃបន្ថែមខ្ពស់ ការអនុវត្តបង្កំបច្ចេកទេសទំនើប (ប្រព័ន្ធផ្ទះសំណាញ់ និងស្រោចស្រពទំនើប) ការប្រមូល បន្សុទ្ធ និងពង្រីកពូជដំណាំដែលមានសក្តានុពលទីផ្សារ ជាពិសេសពង្រីកពូជរុក្ខជាតិលម្អ និងគ្រឿងទេសសំខាន់ៗ ការលើកកម្ពស់ការអនុវត្តកសិកម្មល្អ និងស្តង់ដារកសិកម្មសរីរាង្គលើដំណាំបន្លែ និងឈើហូបផ្លែ ការប្រមូលនិងពង្រឹងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលដំណាំសាកវប្បកម្ម។ ម្យ៉ាងទៀតត្រូវបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំសាកវប្បកម្ម និងរៀបចំយុទ្ធសាស្ត្រតាមដំណាំសំខាន់ៗដូចជាស្វាយ ចេក និងដំណាំបន្លែ និងបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីស្តង់ដារកសិកម្មសរីរាង្គ និងស្តង់ដារដំណាំសំខាន់ៗ។
- ជំរុញការអភិវឌ្ឍដំណាំឧស្សាហកម្ម ដោយលើកកម្ពស់ផលិតភាពនិងគុណភាពដំណាំឧស្សាហកម្មសំខាន់ៗ ឆ្លើយតបនឹងតម្រូវការទីផ្សារ ហើយគាំទ្រការកែច្នៃក្នុងស្រុកនិងការនាំចេញ តាមរយៈការលើកកម្ពស់ផលិតភាព និងពិពិធកម្ម ប្រភេទដំណាំដែលមានតម្លៃបន្ថែមខ្ពស់ ការអនុវត្តបង្កំបច្ចេកទេសទំនើប ការប្រមូល បន្សុទ្ធ និងពង្រីកពូជដំណាំដែលមានសក្តានុពលទីផ្សារ ជាពិសេសពង្រីកពូជរុក្ខជាតិ គ្រឿងទេសសំខាន់ៗ និងកោសិយវប្បកម្ម ពង្រឹងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលដំណាំឧស្សាហកម្ម ព្រមទាំងជំរុញរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំសំខាន់ៗដូចជា ដំណាំដំឡូងមី ស្វាយចន្ទី ពោត ជាដើម។
- ជំរុញការផ្តល់សេវាបច្ចេកទេសកសិកម្មថ្មីនិងបច្ចេកវិទ្យាវៃឆ្លាតនឹងអាកាសធាតុដល់កសិករ និង សហគមន៍កសិកម្ម ដើម្បីទទួលបានទិន្នផលខ្ពស់ និងចំណាយតិច តាមរយៈការជ្រើសរើសនិងការប្រើប្រាស់ពូជធន់ និងមានគុណភាពល្អ បច្ចេកទេសដាំដុះមានផលិតភាពខ្ពស់ ការប្រើប្រាស់ដីនិងទឹកប្រកបដោយប្រសិទ្ធភាព ការកម្ចាត់សមាសភាពចង្រៃប្រកបដោយភាតរបរិស្ថាន ការប្រើប្រាស់គ្រឿងយន្តកសិកម្មនិងបច្ចេកទេសក្រោយពេលប្រមូលផលសមស្រប ដើម្បីលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពឆ្លើយតបទៅតាមតម្រូវការស្តង់ដារនិងការប្រកួតប្រជែងទីផ្សារ។
- បន្តពង្រឹងវិធានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដោយជំរុញការអនុវត្តវិធានការពារដំណាំ ពង្រឹងនិងពង្រីកសមត្ថកិច្ចភូតគាមអនាម័យ ក្នុងការត្រួតពិនិត្យផលិតផលកសិកម្មនាំចេញ-នាំចូល ដើម្បីចូលរួមសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការរាតត្បាត សមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ ទប់ស្កាត់ការធ្លាក់ចុះគុណភាព និងសុវត្ថិភាព ផលិតផលកសិកម្ម ដែលនាំឱ្យប៉ះពាល់ដល់សុខភាពប្រជាជននិងខូចទីផ្សារក្នុងស្រុកនិងទីផ្សារសម្រាប់នាំចេញរបស់កម្ពុជា។ ពង្រឹងនិងពង្រីកសមត្ថភាពមន្ទីរពិសោធន៍ជាតិ ក្នុងការពិនិត្យ វិភាគ និងវាយតម្លៃគុណភាព ធាតុចូលកសិកម្ម (ពូជ ជី ថ្នាំកសិកម្ម) គុណភាពដី និងកម្រិតសំណល់ ធាតុពុលក្នុងផលិតផលកសិកម្ម ដី និងទឹក។
- ពង្រឹងរចនាសម្ព័ន្ធនិងធុរកិច្ចរបស់សហគមន៍កសិកម្ម ឱ្យក្លាយជាសហគ្រាសកសិកម្មទំនើបតាមរយៈការបង្កើតយន្តការគ្រប់គ្រងសហគមន៍កសិកម្ម ដែលរួមមានសម្ព័ន្ធសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និង សហគមន៍កសិកម្ម និងការបន្តធ្វើទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងការផ្តល់ឥណទានដល់សហគមន៍កសិកម្ម និងសហគ្រាសកសិកម្មធុនតូចនិងមធ្យម ដើម្បីប្រមូលទិញកសិផល ការកែច្នៃ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ដូចជា ឃ្លាំងស្តុកកសិផល ឡសម្ងួត ឃ្លាំងត្រជាក់ជាដើម ដើម្បីផ្សារភ្ជាប់កសិករខ្នាតតូចទៅនឹងទីផ្សារ។

- លើកកម្ពស់ផលិតភាពនិងប្រសិទ្ធភាពនៃប្រើប្រាស់គ្រឿងយន្តកសិកម្ម ព្រមទាំងផលិតភាពនិងប្រសិទ្ធភាពការប្រើប្រាស់ទឹកកសិកម្មអនុវត្តបច្ចេកវិទ្យាទំនើប (ស្រោចស្រពដោយបង្ហៀរបញ្ចូលស្រែ ទុយោបំពង់បង្កប់ដី ឧបករណ៍ស្រោចស្រពដំណក់ទឹក សាចទឹកជាដើម)។
- បន្តស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយនិរន្តរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដោយផ្តោតអាទិភាពលើបច្ចេកវិទ្យាកែលម្អដីជាតិដី និងទឹក កសិកម្មវៃឆ្លាតនឹងអាកាសធាតុ យុទ្ធសាស្ត្រគ្រប់គ្រងធនធានដីកសិកម្មដែលមានភាពទន់ភ្លន់ជាមួយការជ្រើសរើសមុខដំណាំដែលមានសក្តានុពលសមស្របនឹងដី ការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មអភិរក្ស និងការពង្រឹងសមត្ថភាពប្រើប្រាស់ព័ត៌មានប្រព័ន្ធផ្កាយរណបនិងបច្ចេកវិទ្យាឌីជីថល។
- ពង្រឹងសមត្ថភាពអង្គភាព និងការអនុក្របខ័ណ្ឌគតិយុត្ត ដើម្បីលើកកម្ពស់ផលិតភាព ប្រសិទ្ធភាពការងារ និងសេវាគាំទ្រ តាមរយៈការបន្តការរៀបចំក្របខ័ណ្ឌគោលនយោបាយ បទដ្ឋានគតិយុត្ត ការកសាងសមត្ថភាព ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងធនធានមនុស្សក្នុងអនុវិស័យដំណាំ។

## ២. ផែនការផលិតកម្មដំណាំកៅស៊ូ

### ក. សូចនាករទិសដៅ

ក្នុងឆ្នាំ២០២០ទិសដៅសំខាន់ៗ ដែលបានគ្រោងនិងត្រូវសម្រេច រួមមាន៖

- ជំរុញបង្កើនផ្ទៃដីចៀរ ឱ្យបាន៣០៦ពាន់ហិកតា
- ជំរុញផលិតកម្មកៅស៊ូឱ្យដល់៣៥៣ពាន់តោន
- ជំរុញការនាំចេញកៅស៊ូឱ្យបានប្រមាណ៣៤៣ពាន់តោន
- រៀបចំបញ្ចប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- អនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២០ ឱ្យសម្រេចបាននូវចំណុចដៅដែលបានកំណត់
- រៀបចំគម្រោងថវិកាកម្មវិធីឆ្នាំ២០២១។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ជំរុញការចងក្រងនិងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តស្វែងរកទីតាំងអនុស្ថានីយនិងចម្ការបង្ហាញបន្ថែម និងបង្កើនសមត្ថភាពស្រាវជ្រាវ ផ្សព្វផ្សាយ និងបង្ហាញ
- ជំរុញការពង្រីកផ្ទៃដីដំណាំកៅស៊ូរបស់ក្រុមហ៊ុនឯកជននិងកៅស៊ូគ្រួសារ ពិសេសចូលរួមពិនិត្យ តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន។
- អនុវត្តនិងពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២០ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី
- ពង្រីកដៃគូសហប្រតិបត្តិការក្នុងការស្វែងរកថវិកានិងបច្ចេកទេសដើម្បីគាំទ្រអភិវឌ្ឍន៍កៅស៊ូគ្រួសារនិងបន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើអនុវិស័យកៅស៊ូ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងលិខិតគតិយុត្តពាក់ព័ន្ធនានា

- ជំរុញការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពនៃថវិកាកម្មវិធីឆ្នាំ២០២១ ការពិនិត្យឡើងវិញនូវអនុកម្មវិធី ចង្កោមសកម្មភាព សូចនាករ ចំណុចដៅសូចនាករ និងថវិកាចំណាយ ដើម្បីឱ្យត្រូវនឹងស្ថានភាពនិងលទ្ធភាពជាក់ស្តែង
- អនុវត្តនិងការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់ការនាំចេញកៅស៊ូ អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ ជំរុញការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក និងសមត្ថកិច្ចនៅតាមច្រកព្រំដែន) ដើម្បីជួយទប់ស្កាត់សកម្មភាពការបើកស្នាក់ការប្រមូលទិញកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត និងការនាំចេញកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសដោយខុសច្បាប់
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ និងអំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- បន្តចូលរួមសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានា។

## ៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

### ក. សូចនាករទិសដៅ

- បង្កើនផលិតផលសាច់កើន៣%ក្នុងមួយឆ្នាំ គឺពី២៤០ពាន់តោននៅឆ្នាំ២០១៩ ដល់២៧០តោននៅឆ្នាំ២០២៣
- បង្កើនអត្រានៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មឱ្យកើន គឺពី២៣% នៅឆ្នាំ២០១៩ ដល់៣០% នៅឆ្នាំ២០២៣។
- កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តផ្តល់សេវាបសុព្យាបាល និងបង្កើនសមត្ថភាព បច្ចេកទេសដល់កសិករចិញ្ចឹមសត្វ តាមរយៈកម្មវិធីចាក់វ៉ាក់សាំងការពារ ពិនិត្យព្យាបាលជំងឺសត្វ អនុវត្តវិធានជីវសុវត្ថិភាព បណ្តុះបណ្តាលបច្ចេកទេស និងអនុវត្តការចិញ្ចឹមសត្វល្អ ជាពិសេសជំរុញផ្លាស់ប្តូរឥរិយាបទពីការចិញ្ចឹមតាមបែបប្រពៃណីទៅជាការចិញ្ចឹមបែបទំនើបសម្រាប់ធ្វើពាណិជ្ជកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន តាមរយៈការកែលម្អពូជ ចំណីមានគុណភាពល្អ និងកាត់បន្ថយជំងឺឆ្លងរាលដាលសត្វ។ ជាមួយគ្នានេះដែរ ផ្តល់ការគាំទ្រធ្វើឱ្យប្រសើរនូវបរិយាកាសវិនិយោគលើការចិញ្ចឹមសត្វ និងផលិតចំណីសត្វ ដើម្បីធ្វើឱ្យថ្លៃដើមផលិតកម្មសត្វទាបដោយការកែច្នៃវត្ថុធាតុដើមក្នុងស្រុកដែលមានស្រាប់។
- បន្តពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ពង្រឹងការអនុវត្តច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលពិឃាតសត្វដល់អាជីវករ។
- បន្តជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំនានា ពង្រឹងសមត្ថភាពមន្ត្រីនិងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើនការត្រួតពិនិត្យនិងធ្វើអធិការកិច្ចអនាម័យសត្វ សាច់ ផលិតផលសត្វ បសុឱសថ ចំណីសត្វ និងចរាចរនាំចេញ នាំចូល នាំឆ្លងកាត់សត្វនិងផលិតផលសត្វ ដើម្បីបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ សុខុមាលភាពសត្វ និងបរិស្ថាន។
- ការបង្កើនសមត្ថភាពមន្ត្រីគ្រប់កម្រិត ដើម្បីផ្ទេរចំណេះដឹងលើជំនាញសុខភាពសត្វ និងផលិតកម្មសត្វដូចជា ការចិញ្ចឹម ការបង្កាត់ពូជសត្វ សុវត្ថិភាពចំណីអាហារ បសុឱសថ ជីវសុវត្ថិភាព ការបង្ការជំងឺ

ខ្សែច្រវ៉ាក់ផលិតកម្មសត្វ ការធ្វើពាណិជ្ជកម្មសត្វដល់វិស័យឯកជន អង្គការដៃគូអភិវឌ្ឍន៍ សហគមន៍ សមាគម កសិករចិញ្ចឹមសត្វ ដើម្បីបង្កើនផលិតភាពសត្វ។ លើសពីនេះទៀត ភ្នាក់ងារសុខភាពសត្វត្រូវបានបណ្តុះបណ្តាលពីជំនាញបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីសម្របសម្រួលជួយពិនិត្យព្យាបាលសត្វ និងផ្តល់ព័ត៌មានពីស្ថានភាពជំងឺសត្វដល់មន្ត្រីជំនាញបានទាន់ពេល។

- ជំរុញលើកទឹកចិត្តសហគមន៍ចិញ្ចឹមសត្វ កសិករចិញ្ចឹមសត្វតាមកិច្ចសន្យា ដើម្បីលើកកម្ពស់ផលិតកម្មសត្វ ធានាបាននូវបរិមាណផ្គត់ផ្គង់ ការពារផលប្រយោជន៍នូវផលិតផលដែលផលិតបានក្នុងការកាត់បន្ថយការនាំចូលសត្វពីបរទេស និងឈានទៅរកការនាំចេញ។
- បន្តពង្រឹងការសិក្សាស្រាវជ្រាវ ការអង្កេតតាមដានជំងឺឆ្លងសត្វ សំដៅរកឱ្យឃើញប្រភពជំងឺ និងឆ្លើយតបទាន់ពេលវេលា ព្រមទាំងពង្រឹងការស្រាវជ្រាវចំណីសត្វ បសុឱសថ ពូជសត្វដែលមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ធន់នឹងជំងឺ លូតលាស់លឿន និងស្របនឹងតម្រូវការទីផ្សារ និងការបង្កាត់ពូជសិប្បនិម្មិត រួមជាមួយនឹងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍ សមត្ថភាពស្រាវជ្រាវ និងបង្កើនធនធាន (មនុស្ស សម្ភារ និងថវិកា) សម្រាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។
- បន្តកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មានជាមួយ វិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍ សមាគម និងកសិករចិញ្ចឹមសត្វពាក់ព័ន្ធនឹងការងារសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីដោះស្រាយបញ្ហាប្រឈមកើតមានឡើងលើការចិញ្ចឹមសត្វ តម្លៃទីផ្សារ ស្ថានភាពជំងឺឆ្លងសត្វ និងការចរាចរសត្វនិងផលិតផលសត្វ។
- បន្តជំរុញលើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រទេសបញ្ជាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលរបស់ខ្លួន។
- បន្តរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្ត នីតិវិធីក្នុងការផ្តល់សេវា និងបច្ចេកទេសបានឆាប់រហ័សដល់អ្នកវិនិយោគ។
- បន្តកិច្ចកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិនានាពាក់ព័ន្ធអនុវិស័យ សុខភាពសត្វ និងផលិតកម្មសត្វ។

## ៤. ផែនការផ្នែកជលផល

### ក. សូចនាករទិសដៅ

- នេសាទទឹកសាប:
  - នេសាទដាយត្រីដាយបង្កងនិងសិប្បកម្ម ១២ ០០០តោន
  - នេសាទគ្រួសារក្នុងដែននេសាទ ៣៤៥ ០០០តោន
  - នេសាទគ្រួសារក្នុងវាលស្រែ ១៤៥ ០០០តោន
- អាជីវកម្មនេសាទសមុទ្រ ១១០ ០០០តោន
- វារីវប្បកម្ម:
  - ការចិញ្ចឹមត្រី-បង្គា ៣៦០ ០០០តោន
  - ការចិញ្ចឹមក្រពើ ៣០០ ០០០ក្បាល
  - ការផលិតកូនត្រីពូជ ២៤០ ០០០ ០០០កូន
- ការកែច្នៃផលនេសាទ:
  - ការកែច្នៃផលនេសាទទឹកសាប ៨២ ០០០តោន
  - ការកែច្នៃផលនេសាទសមុទ្រ ៩ ០០០តោន

- ការផលិតទឹកត្រី ៦០ ០០០ ០០០លីត្រ
- ការនាំចេញផលនេសាទ ២០ ០០០តោន
- ចំណូលថវិកា ៣៨៤ ០០០ ០០០រៀល

**ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់**

- បន្តការផ្សព្វផ្សាយច្បាប់ស្តីពី "ជលផល លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍៧ចំណុច" របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- បន្តពង្រឹងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលឱ្យបានល្អប្រសើរ។
- បន្តជំរុញដល់សង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផលអធិការដ្ឋានរដ្ឋបាលជលផល និងរដ្ឋបាលជលផលថ្នាក់កណ្តាល ពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរឹងបំផុត។
- បន្តពង្រឹងសហគមន៍នេសាទឱ្យទទួលខុសត្រូវលើភាពជាម្ចាស់ នៃការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ដើម្បីសំដៅធានាសហគមន៍នេសាទគ្មានបទល្មើសជលផល។
- បន្តពង្រឹងការងារបង្ក្រាបបទល្មើសជលផល ជាពិសេស ឧបករណ៍ឆក់ ឧបករណ៍ស៊ៃប្បមុង និងឧបករណ៍ភ្លើងពណ៌ជាដើម។
- បន្តលែងកូនត្រីពូជក្នុងតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកក្នុងធម្មជាតិ សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ។
- បន្តពង្រីកការអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលនៅតាមមូលដ្ឋាន។
- បង្កើនការយល់ដឹង និងសមត្ថភាពរបស់អ្នកកែច្នៃឱ្យកាន់តែល្អប្រសើរឡើង លើការអនុវត្តការធ្វើអនាម័យល្អ និងការអនុវត្តការផលិតល្អ ក្នុងខ្សែច្រវ៉ាក់ផលិតកម្មកែច្នៃជលផល។
- បង្កើនការត្រួតពិនិត្យនិងវិភាគគុណភាព សុវត្ថិភាពលើផល ផលិតផលជលផលតាមបណ្តាទីកន្លែងកែច្នៃនានានិងការនាំចូល។
- បង្កើនសមត្ថភាពផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរឡើង ដើម្បីជួយសម្រួលសកម្មភាពនាំចេញផល ផលិតផលជលផល។
- បន្តការងារសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រទាំងទឹកសាប និងសមុទ្រ។
- បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីជំរុញការងារអភិវឌ្ឍន៍វារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល។

## ៥ ផែនការផ្នែកព្រៃឈើ

**ក. សូចនាករទិសដៅ**

- បរិមាណផលឈើដាំកើនដល់២២៥ពាន់ម៉ែត្រគូប
- អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង១២%
- អត្រាបទល្មើសព្រៃឈើត្រូវបានកាត់បន្ថយ១០%
- ទំហំផ្ទៃដីដាំឈើ រដ្ឋ និងឯកជន កើនដល់១០ពាន់ហ.ត
- សហគមន៍ព្រៃឈើចំនួន ១៦ ត្រូវបានបង្កើនប្រាក់ចំណូល។

**ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់**

- បន្តជំរុញការអនុវត្តផែនការសកម្មភាព និងថវិកាកម្មវិធីទី៤ និងពង្រឹងការប្រមូលចំណូលថវិកាជាតិ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងទំនាក់ទំនងទ្វេភាគី និងពហុភាគីសម្រាប់ការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព្រះរាជអាជ្ញា តុលាការ គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងចូលរួមក្នុងយុទ្ធនាការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ
- បន្តជំរុញការដោះស្រាយទំនាស់ដីធ្លីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងសម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ធ្វើកំណែទម្រង់លើការងារផ្សព្វផ្សាយឲ្យមានភាពទូលំទូលាយ ដោយរៀបចំជាវីដេអូរខ្លីៗបង្ហាញតាមប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គម ព្រមទាំងយកចិត្តទុកដាក់លើការបង្កើតកម្មវិធី App សម្រាប់បង្ហាញ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងវិស័យព្រៃឈើជូនសាធារណជនបានជ្រាប
- បន្តស្វែងរកទីតាំងដីព្រៃទំនេររបស់រដ្ឋដើម្បីបង្កើតជាស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ ចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ និងជំរុញការដាំដុះស្តារព្រៃឈើឡើងវិញ ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ និងរៀបចំពិធីរុក្ខទិវាថ្នាក់ជាតិឆ្នាំ២០២០។
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើ ព្រមទាំងជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូលលើកកម្ពស់ជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ជំរុញការបកស្រាយ និងផលិតផែនទីគម្របព្រៃឈើ ឆ្នាំ២០២០
- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងសិក្សាស្រាវជ្រាវស្ថានភាពសត្វព្រៃ និងហានិភ័យនៃជំងឺឆ្លងពីសត្វព្រៃមកមនុស្ស ព្រមទាំងបន្តចុះផ្សព្វផ្សាយនិងជំរុញការចុះបញ្ជីថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ។
- ពង្រឹងការអនុវត្តច្បាប់ ការត្រួតពិនិត្យ រោងសន្និធិ ការផ្តល់នូវ PC ជាពិសេសការប្រើប្រាស់ត្រាដែលផ្នែករដ្ឋបាលព្រៃឈើទទួលបាន ត្រូវអនុវត្តឲ្យស្របតាមខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋាន ។

## VII- សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលមួយឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ក្រសួងអាចវាយតម្លៃជារួមថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិខ្លះៗក៏ដោយ តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើ បានធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលកន្លងមក។

ការជំរុញកំណើនវិស័យកសិកម្មនៅតែជាគោលដៅចម្បង ដើម្បីធានាសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការនាំចេញ។ គោលដៅនេះ អាចសម្រេចបានដោយសារគោលនយោបាយវិត្ការកម្មរបស់រាជរដ្ឋាភិបាល ក្នុងការវិយោគបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យកសិកម្ម ការស្រាវជ្រាវ ការប្រើប្រាស់ពូជថ្មីៗ ការផ្សព្វផ្សាយបច្ចេកទេសដើម្បីដើរតាមឲ្យទាន់ក្នុងបរិបទនៃសាកលភាវូបនីយកម្ម រួមទាំងការចូលរួមកាន់តែសកម្មជាងមុនពីសំណាក់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការវិនិយោគលើវិស័យកសិកម្ម ពិតមែនតែយើងនៅជួបប្រទះបញ្ហាខ្លះៗនៃការប្រែប្រួលអាកាសធាតុក៏ដោយ។ ម៉្យាងវិញទៀត ផលិតកម្មដំណាំកសិ-ឧស្សាហកម្មត្រូវបានវាយតម្លៃថា

នឹងបន្តកំណើនខ្ពស់ ដោយផ្អែកលើការកើនឡើងនៃតម្រូវការទីផ្សារអន្តរជាតិ ព្រមទាំងការកើនឡើងនៃការវិនិយោគលើផ្នែកកសិ-ឧស្សាហកម្មនេះជាបណ្ដើរៗជាដើម។ ជាមួយគ្នានេះ អនុវិស័យកសិកម្មផ្សេងទៀត ពិសេសវារីវប្បកម្ម និងការចិញ្ចឹមសត្វត្រូវបានវាយតម្លៃថាបានបន្តកំណើនល្អប្រសើរគួរជាទីពេញចិត្ត។ ក្នុងបរិការណ៍នេះ ក្រសួងនឹងបន្តផ្ដោតការផ្ដល់អាទិភាពខ្ពស់ចំពោះការរៀបចំកសាងផែនការមេអភិវឌ្ឍន៍វិស័យកសិកម្ម និងការអនុវត្តផែនការរយៈពេលមធ្យមនិងវែង ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម ដែលទៀមទារឲ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ទាំងវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដោយត្រូវធ្វើ សមាហរណកម្មឲ្យកៀកទៅនឹងផលិតករ សហគមន៍កសិកម្មនៅមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលបាននិងកំពុងជួបប្រទះ។ ដោយឡែក ប្រជាកសិករទទួលបាននូវការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល តាមរយៈការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទ និងការលើកកម្ពស់ផលិតភាពកសិកម្ម ក៏ដូចជាតាមរយៈអន្តរាគមន៍ផ្ទាល់របស់រដ្ឋនៅពេលកសិផល ជាពិសេសស្រូវ-អង្ករ ប្រឈមនឹងការធ្លាក់ចុះថ្លៃនៅលើទីផ្សារអន្តរជាតិ ឬទ្រទ្រង់ថ្លៃកុំឱ្យធ្លាក់ចុះហួសពីថ្លៃទីផ្សារខ្លាំងពេកដោយមិនសមហេតុផលជាដើម។

ក្រសួងកត់សម្គាល់ឃើញថា មានក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិលបាននិងកំពុងផ្ដល់សេវាកម្មដើម្បីបង្កើនចំណេះដឹង និងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាមនិងថ្លៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើន ទៅតាមអនុវិស័យនីមួយៗ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការអនុវត្តច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផល ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងកំពុងចូលរួមរៀបចំធ្វើវិសោធនកម្មច្បាប់ទាំងពីរនេះជាមួយក្រសួងមហាផ្ទៃ ហើយរហូតមកដល់បច្ចុប្បន្ននេះ កំពុងដំណើរការទៅមុខប្រកបដោយការទទួលខុសត្រូវខ្ពស់។ ក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងបានពង្រឹងកិច្ចសហការជាមួយគណៈកម្មការឯកភាពរាជធានីខេត្តល្អប្រសើរ។ លើសពីនេះទៀត ការបន្តចូលរួមសហការជាមួយគណៈកម្មការជាតិដែលបានបង្កើតឡើងក៏ជាការងារសំខាន់មួយទៀត ដើម្បីរួមគ្នាទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងបទល្មើសនេសាទឱ្យបានជោគជ័យ។ ចំពោះការងារកែទម្រង់ផ្នែកគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំអនុវត្តនូវចំណុចគន្លឹះមួយចំនួន ដើម្បីបន្តនិរន្តរភាពលើការគ្រប់គ្រង និងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចឲ្យទទួលបានប្រសិទ្ធភាព។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹង និងយកចិត្តទុកដាក់ខ្ពស់ រួមទាំងការអភិវឌ្ឍធនធានមនុស្ស ការស្ដារហេដ្ឋារចនាសម្ពន្ធ័គាំទ្រចាំបាច់នានា ដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលងបានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃការកែទម្រង់រដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងការបញ្ជ្រាបយេនឌ័រនិងកុមារ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្ដាល រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

លើសពីនេះទៅទៀត សេវាគាំទ្រផ្សេងៗក៏បានសម្រេចលទ្ធផលការងារតាមផ្នែកនីមួយៗល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ទន្ទឹមនឹងនេះ អង្គភាពជំនាញនីមួយៗដែលជាសេនាធិការរបស់ក្រសួង នឹងបន្តអនុវត្តតាមទិសដៅគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះសម្រាប់ឆ្នាំ២០២០-២០២១ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ដើម្បីចូលរួមឲ្យសម្រេចបានគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា លើការលើកស្ទួយវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ក្រសួងនឹងបន្តជំរុញការធ្វើទំនើបកម្មកសិកម្ម ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម ការបង្កើនឧត្តមភាពប្រកួតប្រជែងឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅចូលរួមលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក៏ដូចជាក្នុងបរិបទនៃសាកលភាវូបនីយកម្ម ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិតដ៏ត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ថ្ងៃ ចន្ទ ១ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០១៩

ឧបសម្ព័ន្ធទី ១

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្ដាល | | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | សរុប | បង្កើនរដូវ | | | | | |
| 01 | បន្ទាយមានជ័យ | 251,300 | 249,449 | | - | 249,449 | 100.00 | 77 | 89,437 | - | 124,739 | - | 27,376 | - | 7,897 | 249,449 | 99.26 |
| 02 | បាត់ដំបង | 320,000 | 366,395 | 647 | 0.18 | 365,748 | 99.82 | 69 | 224,389 | 67,534 | 92,486 | - | 43,945 | 348 | 5,189 | 366,357 | 114.49 |
| 03 | កំពង់ចាម | 86,540 | 93,792 | 5,643 | 6.02 | 88,149 | 93.98 | 533 | 40,250 | 9,388 | 29,771 | - | 22,721 | - | 1,050 | 93,792 | 108.38 |
| 04 | កំពង់ឆ្នាំង | 121,800 | 127,655 | 66 | 0.05 | 127,589 | 99.95 | 1,570 | 11,448 | - | 72,421 | - | 43,562 | - | 224 | 127,655 | 104.81 |
| 05 | កំពង់ស្ពឺ | 113,600 | 114,996 | 9,929 | 8.63 | 105,067 | 91.37 | 5,204 | 6,623 | 582 | 62,374 | - | 45,945 | 54 | - | 114,996 | 101.23 |
| 06 | កំពង់ធំ | 213,300 | 225,278 | 5,149 | 2.29 | 220,129 | 97.71 | 1,076 | 49,325 | 23,294 | 103,264 | - | 65,306 | 585 | 6,410 | 224,890 | 105.43 |
| 07 | កំពត | 132,000 | 152,066 | 2,917 | 1.92 | 149,149 | 98.08 | 3,748 | 23,365 | 6,444 | 71,803 | 3,541 | 45,031 | - | - | 140,199 | 106.21 |
| 08 | កណ្ដាល | 34,000 | 40,136 | 705 | 1.76 | 39,431 | 98.24 | 68 | 14,044 | 300 | 10,785 | - | 7,790 | - | - | 32,619 | 95.94 |
| 09 | កោះកុង | 10,420 | 9,242 | 1,314 | 14.22 | 7,928 | 85.78 | 586 | 2,002 | - | 6,723 | - | 517 | 593 | - | 9,835 | 94.39 |
| 10 | ក្រចេះ | 33,000 | 33,585 | 1,084 | 3.23 | 32,501 | 96.77 | 1,130 | 15,299 | 936 | 17,490 | - | 622 | 160 | - | 33,571 | 101.73 |
| 11 | មណ្ឌលគិរី | 23,000 | 22,530 | | - | 22,530 | 100.00 | 1,772 | 6,701 | - | 12,595 | - | 1,922 | 1,640 | - | 22,858 | 99.38 |
| 12 | ភ្នំពេញ | 9,042 | 7,888 | 177 | 2.24 | 7,711 | 97.76 | 78 | 3,727 | - | 3,411 | - | 746 | - | - | 7,884 | 87.19 |
| 13 | ព្រះវិហារ | 89,370 | 90,007 | 274 | 0.30 | 89,733 | 99.70 | 2,381 | 19,336 | - | 46,028 | - | 24,744 | 3,205 | - | 93,313 | 104.41 |
| 14 | ព្រៃវែង | 250,000 | 268,032 | | - | 268,032 | 100.00 | - | 102,842 | 29,274 | 124,153 | - | 43,549 | - | - | 270,544 | 108.22 |
| 15 | ពោធិសាត់ | 115,000 | 128,193 | 335 | 0.26 | 127,858 | 99.74 | 164 | 68,303 | 207 | 35,328 | - | 19,227 | 794 | 3,161 | 126,813 | 110.27 |
| 16 | រតនគិរី | 24,855 | 16,315 | 122 | 0.75 | 16,193 | 99.25 | 1,374 | 2,221 | - | 11,942 | - | 2,152 | 10,412 | - | 26,727 | 107.53 |
| 17 | សៀមរាប | 186,565 | 186,720 | 2,095 | 1.12 | 184,625 | 98.88 | 1,010 | 38,940 | - | 98,830 | - | 39,800 | 1,925 | 7,030 | 186,525 | 99.98 |
| 18 | ព្រះសីហនុ | 14,000 | 10,638 | | - | 10,638 | 100.00 | 15 | 200 | - | 8,476 | - | 1,962 | - | - | 10,638 | 75.99 |
| 19 | ស្ទឹងត្រែង | 27,800 | 24,982 | 1,872 | 7.49 | 23,110 | 92.51 | 2,559 | 10,481 | - | 13,308 | - | 1,183 | 2,452 | - | 27,424 | 98.65 |
| 20 | ស្វាយរៀង | 167,500 | 169,820 | | - | 169,820 | 100.00 | - | 53,107 | 12,608 | 110,665 | - | 6,048 | - | - | 169,820 | 101.39 |
| 21 | តាកែវ | 180,000 | 287,502 | 450 | 0.16 | 287,052 | 99.84 | 30 | 93,482 | 61,655 | 109,227 | - | 6,664 | - | - | 209,373 | 116.32 |
| 22 | ឧត្តរមានជ័យ | 95,000 | 100,498 | | - | 100,498 | 100.00 | 9 | 2,450 | - | 87,277 | - | 4,392 | 1,665 | - | 95,784 | 100.83 |
| 23 | កែប | 3,520 | 3,632 | | - | 3,632 | 100.00 | 72 | 1,019 | 562 | 1,677 | - | 936 | - | - | 3,632 | 103.18 |
| 24 | ប៉ៃលិន | 6,100 | 8,100 | | - | 8,100 | 100.00 | - | 300 | - | 6,300 | - | 1,500 | - | - | 8,100 | 132.79 |
| 25 | ត្បូងឃ្មុំ | 78,440 | 78,540 | | - | 78,540 | 100.00 | 190 | 11,390 | 700 | 34,600 | - | 32,550 | - | - | 78,540 | 100.13 |
| សរុប | | **2,586,152** | **2,815,991** | **32,779** | **1.16** | **2,783,212** | **98.84** | **23,715** | **890,681** | **213,484** | **1,295,673** | | **490,190** | **23,833** | **30,961** | **2,731,338** | **105.61** |
| តួលេខឆ្នាំមុន | | **2,513,895** | **3,006,539** | **107,114** | **3.56** | **2,899,425** | **96.44** | **36,973** | **866,259** | **275,575** | **1,277,503** | | **538,527** | **25,520** | **31,637** | **2,739,446** | **108.97** |
| ប្រៀបធៀប | | **72,257** | **-190,548** | **-74,335** | **-2.40** | **-116,213** | **2.40** | **-13,258** | **24,422** | **-62,091** | **18,170** | | **-48,337** | **-1,687** | **-676** | **-8,108** | **-0.30** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ២០១៩

ឧបសម្ព័ន្ធទី ២

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រភេទផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជយ័ | 249,449 | 67,681 | - | 25,635 | **93,316** | 21,508 | - | 5,505 | **27,013** | 2,398 | 24,615 |
| 02 | បាត់ដំបង | 366,357 | 104,718 | - | 2,296 | **107,014** | 28,960 | - | 2,296 | **31,256** | 23,532 | 7,724 |
| 03 | កំពង់ចាម | 93,792 | - | - | 5,209 | **5,209** | - | - | 1,054 | **1,054** | 1,054 | - |
| 04 | កំពង់ឆ្នាំង | 127,655 | 266 | | | **266** | | | | **-** | | - |
| 05 | កំពង់ស្ពឺ | 114,996 | 3,985 | | | **3,985** | 3,167 | | | **3,167** | | 3,167 |
| 06 | កំពង់ធំ | 224,890 | 15,957 | - | 6,703 | **22,660** | 1,155 | - | 2,958 | **4,113** | 950 | 3,163 |
| 07 | កំពត | 140,199 | | | | **-** | | | | **-** | | - |
| 08 | កណ្តាល | 32,619 | 2,246 | - | 1,200 | **3,446** | 768 | - | - | **768** | | 768 |
| 09 | កោះកុង | 9,835 | | 10 | - | **10** | | | - | **-** | - | - |
| 10 | ក្រចេះ | 33,571 | | | 5,947 | **5,947** | | | 4,456 | **4,456** | 3,019 | 1,437 |
| 11 | មណ្ឌលគិរី | 22,858 | 223 | | | **223** | | | | **-** | | - |
| 12 | ភ្នំពេញ | 7,884 | 525 | | | **525** | | | | **-** | | - |
| 13 | ព្រះវិហារ | 93,313 | 4,610 | - | 4,717 | **9,327** | 423 | - | 2,227 | **2,650** | 423 | 2,227 |
| 14 | ព្រៃវែង | 270,544 | 16,211 | - | 11,277 | **27,488** | 375 | - | 1,356 | **1,731** | 1,731 | - |
| 15 | ពោធិសាត់ | 126,813 | 62,381 | | | **62,381** | 8,527 | | - | **8,527** | 312 | 8,215 |
| 16 | រតនគិរី | 26,727 | | | 2,639 | **2,639** | | | 550 | **550** | | 550 |
| 17 | សៀមរាប | 186,525 | 36,410 | 30 | 3,980 | **40,420** | 4,657 | - | 547 | **5,204** | 1,300 | 3,904 |
| 18 | ព្រះសីហនុ | 10,638 | | 6 | 1,886 | **1,892** | | 6 | 34 | **40** | | 40 |
| 19 | ស្ទឹងត្រែង | 27,424 | | | 5,808 | **5,808** | | | 2,617 | **2,617** | | 2,617 |
| 20 | ស្វាយរៀង | 169,820 | 2,888 | | 510 | **3,398** | 823 | | 32 | **855** | 612 | 243 |
| 21 | តាកែវ | 209,373 | 185 | | | **185** | | | | **-** | | - |
| 22 | ឧត្តរមានជ័យ | 95,784 | | | | **-** | | | | **-** | | - |
| 23 | កែប | 3,632 | | | 7 | **7** | | | | **-** | | - |
| 24 | ប៉ៃលិន | 8,100 | | | | **-** | | | | **-** | | - |
| 25 | ត្បូងឃ្មុំ | 78,540 | 6,894 | - | 2,596 | **9,490** | 1,111 | - | 1,922 | **3,033** | 2,011 | 1,022 |
| សរុប | | **2,731,338** | **325,180** | **46** | **80,410** | **405,636** | **71,474** | **6** | **25,554** | **97,034** | **37,342** | **59,692** |
| តួលេខឆ្នាំមុន | | **2,739,446** | **222,487** | **538** | **110,001** | **333,026** | **58,490** | **1** | **65,959** | **124,450** | **39,318** | **85,132** |
| ប្រៀបធៀប | | **-8,108** | **102,693** | **-492** | **-29,591** | **72,610** | **12,984** | **5** | **-40,405** | **-27,416** | **-1,976** | **-25,440** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០១៩

ឧបសម្ព័ន្ធទី ៣ក

| ល.រ | រាជធានី-ខេត្ត | ស្រូវស្រាល | | | | ស្រូវកណ្តាល | | | | ស្រូវធ្ងន់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល |
| | | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) |
| 01 | បន្ទាយមានជយ័ | 89,437 | 77,789 | 4.278 | 332,780 | 124,739 | 113,636 | 2.480 | 281,817 | 27,376 | 26,232 | 2.156 | 56,556 |
| 02 | បាត់ដំបង | 224,389 | 217,007 | 3.658 | 793,812 | 92,486 | 92,144 | 2.571 | 236,902 | 43,945 | 43,945 | 2.767 | 121,596 |
| 03 | កំពង់ចាម | 40,250 | 40,250 | 3.441 | 138,500 | 29,771 | 29,771 | 3.415 | 101,668 | 22,721 | 22,721 | 3.412 | 77,524 |
| 04 | កំពង់ឆ្នាំង | 11,448 | 11,448 | 3.440 | 39,381 | 72,421 | 72,421 | 3.487 | 252,532 | 43,562 | 43,562 | 3.540 | 154,209 |
| 05 | កំពង់ស្ពឺ | 6,623 | 6,623 | 3.330 | 22,055 | 62,374 | 60,806 | 3.030 | 184,242 | 45,945 | 44,346 | 3.000 | 133,038 |
| 06 | កំពង់ធំ | 49,325 | 48,749 | 2.968 | 144,687 | 103,264 | 102,175 | 2.536 | 259,116 | 65,306 | 64,109 | 2.722 | 174,505 |
| 07 | កំពត | 23,365 | 23,365 | 3.328 | 77,759 | 71,803 | 71,803 | 3.225 | 231,565 | 45,031 | 45,031 | 3.144 | 141,577 |
| 08 | កណ្តាល | 14,044 | 14,044 | 4.036 | 56,682 | 10,785 | 10,332 | 2.757 | 28,485 | 7,790 | 7,475 | 2.509 | 18,755 |
| 09 | កោះកុង | 2,002 | 2,002 | 2.580 | 5,165 | 6,723 | 6,723 | 2.720 | 18,287 | 517 | 517 | 2.880 | 1,489 |
| 10 | ក្រចេះ | 15,299 | 14,232 | 2.875 | 40,917 | 17,490 | 17,120 | 2.704 | 46,292 | 622 | 622 | 2.339 | 1,455 |
| 11 | មណ្ឌលគិរី | 6,701 | 6,701 | 3.305 | 22,147 | 12,595 | 12,595 | 3.025 | 38,100 | 1,922 | 1,922 | 2.664 | 5,120 |
| 12 | ភ្នំពេញ | 3,727 | 3,727 | 2.630 | 9,802 | 3,411 | 3,411 | 2.740 | 9,346 | 746 | 746 | 2.861 | 2,134 |
| 13 | ព្រះវិហារ | 19,336 | 19,336 | 2.950 | 57,041 | 46,028 | 45,137 | 2.880 | 129,995 | 24,744 | 23,408 | 2.989 | 69,967 |
| 14 | ព្រៃវែង | 102,842 | 102,842 | 3.975 | 408,797 | 124,153 | 124,153 | 2.783 | 345,518 | 43,549 | 43,549 | 2.871 | 125,029 |
| 15 | ពោធិសាត់ | 68,303 | 60,093 | 4.148 | 249,266 | 35,328 | 35,328 | 3.148 | 111,213 | 19,227 | 19,227 | 3.158 | 60,719 |
| 16 | រតនគិរី | 2,221 | 2,221 | 2.522 | 5,601 | 11,942 | 11,392 | 2.668 | 30,394 | 2,152 | 2,152 | 2.651 | 5,705 |
| 17 | សៀមរាប | 38,940 | 36,278 | 2.526 | 91,638 | 98,830 | 97,980 | 2.609 | 255,630 | 39,800 | 39,408 | 2.681 | 105,653 |
| 18 | ព្រះសីហនុ | 200 | 200 | 2.960 | 592 | 8,476 | 8,436 | 3.060 | 25,814 | 1,962 | 1,962 | 4.000 | 7,848 |
| 19 | ស្ទឹងត្រែង | 10,481 | 9,087 | 2.500 | 22,718 | 13,308 | 12,085 | 2.450 | 29,608 | 1,183 | 1,183 | 3.000 | 3,549 |
| 20 | ស្វាយរៀង | 53,107 | 53,107 | 3.620 | 192,247 | 110,665 | 110,422 | 2.466 | 272,301 | 6,048 | 6,048 | 2.570 | 15,543 |
| 21 | តាកែវ | 93,482 | 93,482 | 3.543 | 331,209 | 109,227 | 109,227 | 3.272 | 357,400 | 6,664 | 6,664 | 3.431 | 22,864 |
| 22 | ឧត្តរមានជ័យ | 2,450 | 2,450 | 1.730 | 4,239 | 87,277 | 87,277 | 2.743 | 239,383 | 4,392 | 4,392 | 3.450 | 15,152 |
| 23 | កែប | 1,019 | 1,019 | 3.471 | 3,537 | 1,677 | 1,677 | 3.346 | 5,611 | 936 | 936 | 3.361 | 3,146 |
| 24 | ប៉ៃលិន | 300 | 300 | 2.880 | 864 | 6,300 | 6,300 | 3.200 | 20,160 | 1,500 | 1,500 | 3.250 | 4,875 |
| 25 | ត្បូងឃ្មុំ | 11,390 | 11,052 | 3.545 | 39,179 | 34,600 | 34,495 | 3.448 | 118,938 | 32,550 | 31,971 | 3.320 | 106,144 |
| សរុប | | **890,681** | **857,404** | **3.605** | **3,090,615** | **1,295,673** | **1,276,846** | **2.843** | **3,630,317** | **490,190** | **483,628** | **2.965** | **1,434,152** |
| តួលេខឆ្នាំមុន | | **866,259** | **842,720** | **3.640** | **3,067,382** | **1,277,503** | **1,235,191** | **2.848** | **3,517,707** | **538,527** | **522,628** | **2.891** | **1,510,924** |
| ប្រៀបធៀប | | **24,422** | **14,684** | **-0.035** | **23,233** | **18,170** | **41,655** | **-0.005** | **112,610** | **-48,337** | **-39,000** | **0.074** | **-76,772** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០១៩

ឧបសម្ព័ន្ធទី ៣ខ

| ល.រ | រាជធានី-ខេត្ត | ស្រូវចំការ | | | | ស្រូវឡើងទឹក | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) |
| 01 | បន្ទាយមានជយ័ | - | | - | - | 7,897 | 7,177 | 2.094 | 15,032 | 249,449 | 224,834 | 3.052 | 686,185 |
| 02 | បាត់ដំបង | 348 | 348 | 1.836 | 639 | 5,189 | 5,189 | 2.431 | 12,614 | 366,357 | 358,633 | 3.250 | 1,165,563 |
| 03 | កំពង់ចាម | - | | - | - | 1,050 | 1,050 | 2.820 | 2,961 | 93,792 | 93,792 | 3.419 | 320,653 |
| 04 | កំពង់ឆ្នាំង | - | | - | - | 224 | 224 | 2.402 | 538 | 127,655 | 127,655 | 3.499 | 446,660 |
| 05 | កំពង់ស្ពឺ | 54 | 54 | 1.852 | 100 | - | | - | - | 114,996 | 111,829 | 3.035 | 339,435 |
| 06 | កំពង់ធំ | 585 | 585 | 1.754 | 1,026 | 6,410 | 6,109 | 1.636 | 9,995 | 224,890 | 221,727 | 2.658 | 589,329 |
| 07 | កំពត | - | | - | - | - | | - | - | 140,199 | 140,199 | 3.216 | 450,901 |
| 08 | កណ្តាល | - | - | - | - | - | | - | - | 32,619 | 31,851 | 3.263 | 103,922 |
| 09 | កោះកុង | 593 | 593 | 2.730 | 1,619 | - | | - | - | 9,835 | 9,835 | 2.701 | 26,560 |
| 10 | ក្រចេះ | 160 | 160 | 2.163 | 346 | - | | - | - | 33,571 | 32,134 | 2.770 | 89,010 |
| 11 | មណ្ឌលគិរី | 1,640 | 1,640 | 0.995 | 1,632 | - | | - | - | 22,858 | 22,858 | 2.931 | 66,999 |
| 12 | ភ្នំពេញ | - | | - | - | - | | - | - | 7,884 | 7,884 | 2.699 | 21,282 |
| 13 | ព្រះវិហារ | 3,205 | 3,205 | 2.771 | 8,881 | - | | - | - | 93,313 | 91,086 | 2.919 | 265,884 |
| 14 | ព្រៃវែង | - | | - | - | - | | - | - | 270,544 | 270,544 | 3.250 | 879,344 |
| 15 | ពោធិសាត់ | 794 | 794 | 1.741 | 1,382 | 3,161 | 3,156 | 1.726 | 5,447 | 126,813 | 118,598 | 3.609 | 428,027 |
| 16 | រតនគិរី | 10,412 | 10,412 | 1.825 | 19,002 | - | | - | - | 26,727 | 26,177 | 2.319 | 60,702 |
| 17 | សៀមរាប | 1,925 | 1,925 | 2.432 | 4,682 | 7,030 | 7,030 | 2.706 | 19,023 | 186,525 | 182,621 | 2.610 | 476,626 |
| 18 | ព្រះសីហនុ | - | | - | - | - | | - | - | 10,638 | 10,598 | 3.232 | 34,254 |
| 19 | ស្ទឹងត្រែង | 2,452 | 2,452 | 2.500 | 6,130 | - | | - | - | 27,424 | 24,807 | 2.499 | 62,005 |
| 20 | ស្វាយរៀង | - | | - | - | - | | - | - | 169,820 | 169,577 | 2.831 | 480,091 |
| 21 | តាកែវ | - | | - | - | - | | - | - | 209,373 | 209,373 | 3.398 | 711,473 |
| 22 | ឧត្តរមានជ័យ | 1,665 | 1,665 | 2.010 | 3,347 | - | | - | - | 95,784 | 95,784 | 2.737 | 262,121 |
| 23 | កែប | - | | - | - | - | | - | - | 3,632 | 3,632 | 3.385 | 12,294 |
| 24 | ប៉ៃលិន | - | | - | - | - | | - | - | 8,100 | 8,100 | 3.197 | 25,899 |
| 25 | ត្បូងឃ្មុំ | - | | - | - | - | | - | - | 78,540 | 77,518 | 3.409 | 264,261 |
| សរុប | | **23,833** | **23,833** | **2.047** | **48,786** | **30,961** | **29,935** | **2.192** | **65,610** | **2,731,338** | **2,671,646** | **3.095** | **8,269,480** |
| តួលេខឆ្នាំមុន | | **25,520** | **24,696** | **2.082** | **51,409** | **31,637** | **29,079** | **2.251** | **65,471** | **2,739,446** | **2,654,314** | **3.094** | **8,212,893** |
| ប្រៀបធៀប | | **-1,687** | **-863** | **-0.035** | **-2,623** | **-676** | **856** | **-0.060** | **139** | **-8,108** | **17,332** | **0.001** | **56,587** |

# ផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

ឧបសម្ព័ន្ធទី ៤

| ល.រ | ឈ្មោះស្រុក | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | |
| | | | | ហ.ត | % | ហ.ត | % | | | | | |
| 01 | បន្ទាយមានជយ័ | 22,000 | 55,067 | | - | 55,067 | 100.00 | - | - | 55,067 | 55,067 | 250.30 |
| 02 | បាត់ដំបង | 18,675 | 17,244 | | - | 17,244 | 100.00 | - | - | 17,244 | 17,244 | 92.34 |
| 03 | កំពង់ចាម | 42,000 | 42,697 | 3,768 | 8.82 | 38,929 | 91.18 | 25 | 244 | 42,462 | 42,706 | 101.68 |
| 04 | កំពង់ឆ្នាំង | 32,000 | 41,712 | | - | 41,712 | 100.00 | - | - | 41,712 | 41,712 | 130.35 |
| 05 | កំពង់ស្ពឺ | 750 | 450 | 21 | 4.67 | 429 | 95.33 | 1 | 7 | 443 | 450 | 60.00 |
| 06 | កំពង់ធំ | 40,000 | 65,455 | | - | 65,455 | 100.00 | - | - | 65,455 | 65,455 | 163.64 |
| 07 | កំពត | 8,220 | 8,515 | | - | 8,515 | 100.00 | - | - | 8,515 | 8,515 | 103.59 |
| 08 | កណ្តាល | 57,600 | 57,600 | 22 | 0.04 | 57,578 | 99.96 | - | - | 57,600 | 57,600 | 100.00 |
| 09 | កោះកុង | - | - | | | | | | | | - | - |
| 10 | ក្រចេះ | 14,000 | 14,155 | 430 | 3.04 | 13,725 | 96.96 | 30 | 50 | 14,093 | 14,143 | 101.02 |
| 11 | មណ្ឌលគិរី | 100 | 137 | | - | 137 | 107.00 | | | 130 | 130 | 130.00 |
| 12 | ភ្នំពេញ | 945 | 450 | 5 | 1.11 | 445 | 98.89 | 3 | 20 | 430 | 450 | 47.62 |
| 13 | ព្រះវិហារ | 130 | 12 | | - | 12 | 100.00 | | | 12 | 12 | 9.23 |
| 14 | ព្រៃវែង | 75,000 | 111,040 | | - | 111,040 | 100.00 | | | 111,040 | 111,040 | 148.05 |
| 15 | ពោធិសាត់ | 9,500 | 28,356 | | - | 28,356 | 100.00 | | | 26,912 | 26,912 | 283.28 |
| 16 | រតនគិរី | - | - | | | | | | | | - | - |
| 17 | សៀមរាប | 26,455 | 22,585 | | - | 22,585 | 100.00 | - | - | 22,585 | 22,585 | 85.37 |
| 18 | ព្រះសីហនុ | - | - | | | | | | | | - | - |
| 19 | ស្ទឹងត្រែង | - | - | | | | | | | | - | - |
| 20 | ស្វាយរៀង | 20,500 | 20,102 | | - | 20,102 | 100.00 | | | 20,102 | 20,102 | 98.06 |
| 21 | តាកែវ | 80,000 | 104,845 | | - | 104,845 | 100.00 | | | 101,511 | 101,511 | 126.89 |
| 22 | ឧត្តរមានជ័យ | 139 | 155 | | - | 155 | 100.00 | | | 139 | 139 | 100.00 |
| 23 | កែប | 20 | 20 | | - | 20 | 100.00 | | | 20 | 20 | 100.00 |
| 24 | ប៉ៃលិន | 665 | 795 | | - | 795 | 100.00 | | | 795 | 795 | 119.55 |
| 25 | ត្បូងឃ្មុំ | 10,900 | 10,920 | | - | 10,920 | 100.00 | 15 | 135 | 10,785 | 10,920 | 100.18 |
| **សរុប** | | **459,599** | **602,312** | **4,246** | **0.70** | **598,066** | **99.30** | **74** | **456** | **597,052** | **597,508** | **130.01** |
| **តួលេខឆ្នាំមុន** | | **447,500** | **632,056** | **7,033** | **1.11** | **625,023** | **98.89** | **172** | **6,978** | **589,505** | **596,483** | **133.29** |
| **ប្រៀបធៀប** | | **12,099** | **-29,744** | **-2,787** | **-0.41** | **-26,957** | **0.41** | **-98** | **-6,522** | **7,547** | **1,025** | **-3.29** |

# បរិមាណផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ២០១៩-២០២០

ឧបសម្ព័ន្ធទី ៥

| ល.រ | រាជធានី-ខេត្ត | រដូវវស្សាឆ្នាំ២០១៩ | | | | រដូវប្រាំងឆ្នាំ២០១៩-២០២០ | | | | សរុបប្រចាំឆ្នាំ២០១៩-២០២០ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជ័យ | 249,449 | 224,834 | 3.052 | 686,185 | 55,067 | 55,067 | 4.405 | 242,570 | 304,516 | 279,901 | 3.318 | 928,755 |
| 02 | បាត់ដំបង | 366,357 | 358,633 | 3.250 | 1,165,563 | 17,244 | 17,244 | 4.130 | 71,218 | 383,601 | 375,877 | 3.290 | 1,236,781 |
| 03 | កំពង់ចាម | 93,792 | 93,792 | 3.419 | 320,653 | 42,706 | 42,325 | 4.150 | 175,654 | 136,498 | 136,117 | 3.646 | 496,307 |
| 04 | កំពង់ឆ្នាំង | 127,655 | 127,655 | 3.499 | 446,660 | 41,712 | 41,652 | 4.650 | 193,682 | 169,367 | 169,307 | 3.782 | 640,342 |
| 05 | កំពង់ស្ពឺ | 114,996 | 111,829 | 3.035 | 339,435 | 450 | 450 | 3.351 | 1,508 | 115,446 | 112,279 | 3.037 | 340,943 |
| 06 | កំពង់ធំ | 224,890 | 221,727 | 2.658 | 589,329 | 65,455 | 65,235 | 4.296 | 280,255 | 290,345 | 286,962 | 3.030 | 869,584 |
| 07 | កំពត | 140,199 | 140,199 | 3.216 | 450,901 | 8,515 | 8,515 | 4.100 | 34,912 | 148,714 | 148,714 | 3.267 | 485,813 |
| 08 | កណ្ដាល | 32,619 | 31,851 | 3.263 | 103,922 | 57,600 | 57,600 | 4.421 | 254,650 | 90,219 | 89,451 | 4.009 | 358,572 |
| 09 | កោះកុង | 9,835 | 9,835 | 2.701 | 26,560 | - | | - | - | 9,835 | 9,835 | 2.701 | 26,560 |
| 10 | ក្រចេះ | 33,571 | 32,134 | 2.770 | 89,010 | 14,143 | 14,143 | 4.393 | 62,130 | 47,714 | 46,277 | 3.266 | 151,140 |
| 11 | មណ្ឌលគិរី | 22,858 | 22,858 | 2.931 | 66,999 | 130 | 130 | 4.246 | 552 | 22,988 | 22,988 | 2.939 | 67,551 |
| 12 | ភ្នំពេញ | 7,884 | 7,884 | 2.699 | 21,282 | 450 | 450 | 3.400 | 1,530 | 8,334 | 8,334 | 2.737 | 22,812 |
| 13 | ព្រះវិហារ | 93,313 | 91,086 | 2.919 | 265,884 | 12 | 12 | 3.000 | 36 | 93,325 | 91,098 | 2.919 | 265,920 |
| 14 | ព្រៃវែង | 270,544 | 270,544 | 3.250 | 879,344 | 111,040 | 111,040 | 4.400 | 488,576 | 381,584 | 381,584 | 3.585 | 1,367,920 |
| 15 | ពោធិសាត់ | 126,813 | 118,598 | 3.609 | 428,027 | 26,912 | 22,376 | 4.446 | 99,484 | 153,725 | 140,974 | 3.742 | 527,511 |
| 16 | រតនគិរី | 26,727 | 26,177 | 2.319 | 60,702 | - | | - | - | 26,727 | 26,177 | 2.319 | 60,702 |
| 17 | សៀមរាប | 186,525 | 182,621 | 2.610 | 476,626 | 22,585 | 22,585 | 3.530 | 79,725 | 209,110 | 205,206 | 2.711 | 556,351 |
| 18 | ព្រះសីហនុ | 10,638 | 10,598 | 3.232 | 34,254 | - | | - | - | 10,638 | 10,598 | 3.232 | 34,254 |
| 19 | ស្ទឹងត្រែង | 27,424 | 24,807 | 2.499 | 62,005 | - | | - | - | 27,424 | 24,807 | 2.499 | 62,005 |
| 20 | ស្វាយរៀង | 169,820 | 169,577 | 2.831 | 480,091 | 20,102 | 20,102 | 4.300 | 86,439 | 189,922 | 189,679 | 2.987 | 566,530 |
| 21 | តាកែវ | 209,373 | 209,373 | 3.398 | 711,473 | 101,511 | 101,511 | 4.898 | 497,201 | 310,884 | 310,884 | 3.888 | 1,208,674 |
| 22 | ឧត្តរមានជ័យ | 95,784 | 95,784 | 2.737 | 262,121 | 139 | 139 | 3.504 | 487 | 95,923 | 95,923 | 2.738 | 262,608 |
| 23 | កែប | 3,632 | 3,632 | 3.385 | 12,294 | 20 | 20 | 3.650 | 73 | 3,652 | 3,652 | 3.386 | 12,367 |
